## វិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី

# គម្រោង និងអត្ថាធិប្បាយ
# ពន្យល់

## ថ្នាក់ទី ១០.១១.១២

## ភាគ ៣

## រួមមាន ៖

- ប្រធានពន្យល់
- ប្រធានពិភាក្សា
- ប្រធានប្រៀបធៀប

## តែងសេចក្ដីតាមបែបអធិប្បាយ



និពន្ធនិងរៀបរៀងដោយ អ្នកគ្រូ វណ្ណា ឆារ៉ា

# អារម្ភកថា

ការសិក្សាស្រាវជ្រាវ គឺមានសារៈសំខាន់ណាស់នៅក្នុងពេលបច្ចុប្បន្ននេះ មិនថាបុគ្គលិកក្នុងស្ថាប័ននានា មនុស្សក្នុងសង្គមទូទៅ ពិសេសអ្នកកំពុងសិក្សា ស្វែងរកចំណេះដឹង ត្រូវការជាចំបាច់នូវការអាន ការស្តាប់ ការកត់ត្រា និងការសាកសួរ ឬស្រាវជ្រាវបន្ថែមនូវរាល់ចម្ងល់ដែលខ្លួនមាន។ ដើម្បីឱ្យការសិក្សារបស់ខ្លួនពេញលក្ខណៈ ឬសិក្សាដោយមិនខាតបង់នូវពេលវេលា សិក្សាដើម្បីទទួលបាននូវផ្លែផ្កានាពេលខាងមុខ។

តាមរយៈស្នាដៃនិពន្ធ និងស្រាវជ្រាវនេះ គឺបានធ្វើឱ្យអ្នកអាន អ្នកសិក្សា និងបានយល់កាន់តែច្បាស់អំពីវិធីសាស្ត្រនៃការសរសេរសំណេរ ហើយធ្វើឱ្យអ្នកអាន អ្នកសិក្សា អាចសរសេរយ៉ាងណាឱ្យបានល្អ សរសេរយ៉ាងណាឱ្យត្រូវប្រធាន កុំបកស្រាយចាកប្រធានសរសេរតាមបរិបទនៃប្រធានសំណេរ ពិសេសធ្វើឱ្យអ្នកអាន អ្នកសិក្សាស្គាល់ពីលក្ខណៈនីមួយៗរបស់ប្រធានសំណេរ និងចេះពីការធ្វើគ្រោងឆ្អឹងសំណេរ។

តែទោះជាយ៉ាងណាក៏ស្នាដៃនេះគ្រាន់តែជាកិច្ចការស្រាវជ្រាវប៉ុណ្ណោះមិនទាន់មានលក្ខណៈល្អឥតខ្ចោះឡើយ តែអាចឱ្យអ្នកអាន អ្នកសិក្សាយកទៅធ្វើជាគំរូ ឬសិក្សាត្រួសៗបានយ៉ាងងាយស្រួល ហើយវាអាចជួយអ្នកសិក្សាឱ្យមានចំណេះដឹង បន្ថែមលើចំណេះដឹងដែលមានស្រាប់។ លើសពីនេះ ខ្លឹមសារនៃការស្រាវជ្រាវរបស់អ្នកគ្រូនៅមានកម្រិតពុំទាន់មានលក្ខណៈវិទ្យាសាស្ត្រ ជាសកលហើយក៏មិនទាន់ស៊ីជម្រៅលើ

ការស្រាវជ្រាវនៅឡើយ ដែលបណ្ដាលឱ្យមានចំណុចខ្វះចន្លោះឆកល្វែងទាំងឡាយ និងកើតឡើងដោយអចេតនាជាក់ជាពុំខាន។ អាស្រ័យដូចបានជម្រាបខាងលើ សូមលោកគ្រូ អ្នកគ្រូ និងមិត្តអ្នកសិក្សាស្រាវជ្រាវ និងកូនសិស្សជាទីរាប់អានមេត្តាជួយបំពេញបន្ថែមព្រមទាំង មេត្តាអធ្យាស្រ័យរាល់ចំណុចខ្វះខាតទាំងនេះ។

សូមឱ្យព្រលឹងអក្សរសាស្ត្រខ្មែរស្ថិតនៅគង់វង្សរីកចម្រើនក្នុងដួងចិត្តកុលបុត្រកុលធីតាខ្មែរគ្រប់ជំនាន់តទៅ។ ស្នាដៃមួយនេះកើតឡើងជារូបរាងបាន ដោយសារតែសេចក្ដីស្រឡាញ់ ដែលមានចំពោះកូនសិស្សគ្រប់គ្នា!!!

# មាតិកា

អារម្ភកថា
សេចក្តីថ្លែងអំណរគុណ ...............................................................................
ប្រធានទី១ ............................................................................................ ១
ប្រធានទី២ ..........................................................................................១០
ប្រធានទី៣ ..........................................................................................២២
ប្រធានទី៤ ........................................................................................ ៣៣
ប្រធានទី៥ ..........................................................................................៤៤
ប្រធានទី៦ ..........................................................................................៥៥
ប្រធានទី៧ ..........................................................................................៦៤
ប្រធានទី៨ ..........................................................................................៧៤
ប្រធានទី៩ ..........................................................................................៨៥
ប្រធានទី១០ ....................................................................................... ៩៦
ប្រធានទី១១ ..................................................................................... ១០៥
ប្រធានទី១២ ..................................................................................... ១១៤

ប្រធានទី១៣ ........................................................................................ ១២៥
ប្រធានទី១៤ ........................................................................................ ១៤២
ប្រធានទី១៥ ........................................................................................ ១៥៣
ប្រធានទី១៦ ........................................................................................ ១៦៤
ប្រធានទី១៧ ........................................................................................ ១៧៣
ប្រធានទី១៨ ........................................................................................ ១៧៨
ឯកសារយោង ........................................................................................

## សេចក្តីថ្លែងអំណរគុណ

ជាដំបូងខ្ញុំ សូមសម្តែងនូវកត្តញ្ញូតាធម៌ដឹងគុណយ៉ាង ជ្រាលជ្រៅចំពោះលោកអ្នកមានគុណទាំងពីរដែលបានបូជានូវសាច់ស្រស់ឈាមស្រស់ ក្នុងការតស៊ូបំពេញការងារក្នុងការចិញ្ចឹមបីបាច់ ថែរក្សាកូន ទំនុកបម្រុងគ្រប់បែបយ៉ាងទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ដោយគ្មានទាមទារ នូវអ្វី គឺសូមឱ្យតែកូនបានសេចក្តីសុខសុភមង្គល។ ស្នាដៃនេះត្រូវបានចេញពីស្មារតីឆន្ទៈដ៏មុតមាំរបស់អ្នកគ្រូ ឯកទេសអក្សរសាស្ត្រខ្មែរ។ អរគុណចំពោះ

- ពុកម៉ែ ដែលផ្តល់កំណើត ផ្តល់សំភារៈ ផ្តល់កម្លាំងចិត្ត ផ្តល់សេចក្តីស្រឡាញ់ ផ្តល់...គ្រប់យ៉ាង
- បងប្អូន ដែលផ្តល់ជាគំនិត យោបល់ លុយកាក់ ជំរុញទឹកចិត្ត...
- លោកគ្រូ អ្នកគ្រូ ដែលផ្តល់នូវចំណេះដឹង ការអប់រំទូន្មាន ផ្តល់ចំណង់មិត្តភាព...
- មិត្តភ័ក្ត ដែលផ្តល់នូវមិត្តភាពដ៏ល្អ បទពិសោធជីវិត...
- កូនសិស្សជាទីស្រឡាញ់ ដែលផ្តល់នូវស្នាមញញឹម ការរាប់អានដ៏ស្មោះត្រង់ ការយកចិត្តទុកដាក់...
- ខ្លួនឯងដែលមានជំហរដ៏រឹងមាំក្នុងឆន្ទៈជាគ្រូបង្រៀន...

ជាចុងក្រោយខ្ញុំសូមគោរពជូនពរ ដល់អ្នកដែលកំពុងតែអាននូវស្នាដៃនេះ ទាំងអស់ឱ្យជួបប្រទះតែសេចក្តីសុខចម្រើន និងទទួលបានជោគជ័យគ្រប់ភារកិច្ច គ្រប់ពេលវេលា ជាពិសេសឱ្យការសិក្សាកាន់តែមានភាពរីកចម្រើនឡើងៗ។

## ប្រធានទី១

មានទស្សនៈជាច្រើនបានលើកឡើងថា៖ "សីលធម៌ជាកត្តាកំណត់សេចក្តីថ្លៃថ្នូររបស់មនុស្ស"។ ចូរពន្យល់ឱ្យបានក្បោះក្បាយ ព្រមទាំងលើកឧទាហរណ៍មកបញ្ជាក់ផង។

### គម្រោងតែង

#### I. សេចក្តីផ្តើម

– លំនាំបញ្ហា៖ មនុស្សគ្រប់រូបតែងតែប្រាថ្នាចង់ឱ្យជីវិតរបស់ខ្លួនរស់នៅ ប្រកបដោយកិត្តិយស កេរ្តិ៍ឈ្មោះ សេចក្តីថ្លៃថ្នូរ និងការគោរពស្រឡាញ់ពីសំណាក់អ្នកជុំវិញខ្លួន។ ទាល់តែមានការតស៊ូ រួមផ្សំជាមួយនឹងសីលធម៌ល្អផង ទើបជីវិតថ្លៃថ្នូរបាន។

– ចំណូលបញ្ហា៖ ហេតុនេះហើយ ទើបមានទស្សនៈលើកឡើងថា «សីលធម៌ជាកត្តាកំណត់សេចក្តីថ្លៃថ្នូររបស់មនុស្ស»

– ចំណោទបញ្ហា៖ តើទស្សនៈរបស់ប្រធានដែលបានលើកឡើងខាងលើមានអត្ថន័យដូចម្តេចដែរ?

#### II. តួសេចក្តី

– ឃ្លាភ្ជាប់សេចក្តី៖ មុននឹងធ្វើការបកស្រាយនូវទស្សនៈខាងលើឱ្យបានក្បោះក្បាយ យើងគប្បីពន្យល់ន័យនៃពាក្យគន្លឹះមួយចំនួនជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ «សីលធម៌» សេចក្តីល្អ ការប្រព្រឹត្តអំពើល្អ ការចេះគោរពឱ្យតម្លៃចំពោះអ្នកដទៃ។ «សេចក្តីថ្លៃថ្នូរ» ភាពប្រសើរខ្ពង់ខ្ពស់ ប្រកបដោយកិត្តិយសព្រមទាំងទទួលបានការគោរពស្រឡាញ់ពីអ្នកដទៃ។
- ពន្យល់ន័យប្រធាន៖ រាល់ការប្រព្រឹត្តអំពើល្អ និងចេះគោរពឱ្យតម្លៃចំពោះអ្នកដទៃគឺជាកត្តាដ៏សំខាន់ដែលអាចធ្វើឱ្យជីវិតរស់នៅរបស់មនុស្ស ប្រកបដោយកេរ្តិ៍ឈ្មោះ កិត្តិយស និងទទួលបានការគោរពស្រឡាញ់ពីអ្នកដទៃ។
- បកស្រាយ៖ សីលធម៌ជាកត្តាកំណត់សេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រោះថា៖
    - ❖ គំនិតសំខាន់
        - ការរស់នៅរបស់មនុស្សប្រចាំថ្ងៃ ទាមទារឱ្យមានសីលធម៌ចំពោះគ្នាជាចាំបាច់ ទោះបីជាមានទ្រព្យសម្បត្តិស្តុកស្តម្ភ រៀនបានខ្ពង់ខ្ពស់ប៉ុនណាក៏ដោយ បើគ្មានសីលធម៌ ក៏គ្មានតម្លៃដែរ។
        - សីលធម៌ចំពោះខ្លួនឯង
        - សីលធម៌ចំពោះការងារ
        - សីលធម៌ចំពោះ គ្រួសារ
        - សីលធម៌ចំពោះសង្គម
        - សីលធម៌ចំពោះអន្តរជាតិ

បើមនុស្សមានសីលធម៌ទាំងនោះហើយ គេនឹងទទួលបាន៖

- កិត្តិយស មានគេរាប់រកស្រឡាញ់ច្រើន
- មានសេចក្តីថ្លៃថ្នូរ មានគេគោរព និងឱ្យតម្លៃ
- ទទួលបានការសាទរគ្រប់ទីកន្លែង...

ឧទាហរណ៍ក្នុងសង្គម៖

- គ្រូបង្រៀនមិនត្រឹមតែមានចំណេះដឹងទេ ត្រូវមានសីលធម៌ផង ទើប ជីវិតមានតម្លៃ មានកិត្តិយស កេរ្តិ៍ឈ្មោះ។
- សម្តេចសង្ឃរាជជួនណាត ជាបុគ្គលដ៏ឆ្នើម មានចំណេះដឹងជ្រៅជ្រះ និងប្រកបដោយសីលធម៌ល្អ ទើបធ្វើឱ្យទ្រង់មានតម្លៃយ៉ាងវិសេសវិសាល។
- ក្នុងប្រវត្តិសាស្ត្រ

✓ ព្រះនាងឥន្ទ្រទេវី មិនត្រឹមតែមានរូបសម្បត្តិស្រស់ស្អាត និងចំណេះដឹងខ្ពង់ខ្ពស់ប៉ុណ្ណោះទេតែទ្រង់ប្រព្រឹត្តតែអំពើល្អ ប្រកាន់ខ្ជាប់នូវសីលធម៌ល្អប្រសើរទៀតផង ទាំងចំពោះគ្រួសារ ព្រះញាតិវង្ស និងរាជបរិពារ។

- ក្នុងអក្សរសិល្ប៍

✓ រឿងកុលាបប៉ៃលិន ៖ ចៅចិត្រជាតួអង្គមានទាំងទ្រព្យសម្បត្តិ មានទាំងទឹកចិត្តប្រសើរ ទើបធ្វើឱ្យកម្មករ និងមនុស្សទូទៅគោរពស្រឡាញ់គ្រប់ៗគ្នា។

✓ រឿងផ្កាស្រពោន ៖ តួអង្គប៊ុនធឿនទោះបីយាយនួន បំបែកនាងវិធាវីចេញពីខ្លួនយ៉ាងណាក្តី ក៏នៅតែរក្សាជំហរដដែលមិន

ប្រកាន់ខឹង ឬគិតធ្វើអាក្រក់វិញឡើយ មិនតែប៉ុណ្ណោះមានតែជំរុញឱ្យវិធាវីព្រមតាមម្ដាយរៀបការជាមួយណៃស៊ីតទៅវិញ។

✓ រឿងមាលាដួងចិត្ត ៖ ទីឃាវុធជាបុគ្គលស្មោះត្រង់ចំពោះការងារមានឧត្តមគតិមិនគិតផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ ចុងក្រោយទីឃាវុធបានទទួលការគោរពស្រឡាញ់ពីមនុស្សទូទៅ។

- សរុបសេចក្ដី៖ សីលធម៌គឺពិតជាកត្តាកំណត់សេចក្ដីថ្លៃថ្នូររបស់មនុស្សពិតប្រាកដមែន បើគ្មានសីលធម៌ទោះបីជាបុគ្គលនោះ មានទ្រព្យសម្បត្តិ រៀនសូត្រ...។

## III. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន៖ ឆ្លងតាមរយៈការបកស្រាយខាងលើរួចមកយើងឃើញថាប្រធានពិតជាមានអត្ថន័យល្អ ព្រោះបានអប់រំដល់មនុស្សគ្រប់រូបឱ្យប្រកាន់ខ្ជាប់នូវសីលធម៌ល្អក្នុងការរស់នៅ ដើម្បីធ្វើឱ្យជីវិតប្រកបដោយសេចក្ដីថ្លៃថ្នូរ។
- មតិផ្ទាល់ខ្លួន៖ ដូចនេះក្នុងនាមយើងជាមនុស្សប្រកបដោយវិចារណញ្ញាណយើងត្រូវតែមានសីលធម៌ល្អចំពោះគ្នា ទើបជីវិតយើងប្រសើរឡើង។

## សេចក្ដីអធិប្បាយ

មនុស្សគ្រប់រូបតែងតែប្រាថ្នាចង់ឱ្យជីវិតរបស់ខ្លួនរស់នៅប្រកបដោយកិត្តិយស កេរ្តិ៍ឈ្មោះ សេចក្ដីថ្លៃថ្នូរ និងគោរពស្រឡាញ់ពីសំណាក់អ្នកនៅជុំវិញខ្លួនជានិច្ច។ ទន្ទឹមនឹងនេះមិនមែនមានន័យថា មនុស្សគ្រប់រូបសុទ្ធតែទទួលបានរបស់ទាំងនោះឡើយគឺទាល់តែមានការតស៊ូ

ព្យាយាមប្រឹងប្រែង គួបផ្សំជាមួយនឹងមានសីលធម៌ល្អផងដែរ ទើបអាច ធ្វើឱ្យជីវិតប្រកបដោយសេចក្តីថ្លៃថ្នូរបាន។ អាស្រ័យហេតុនេះហើយទើបមានទស្សនៈជាច្រើនបានលើកឡើងថា "សីលធម៌ជាកត្តាកំណត់ សេចក្តីថ្លៃថ្នូររបស់មនុស្ស"។

តើទស្សនៈដែលបានលើកឡើងមកខាងលើមានអត្ថន័យដូចម្តេចដែរ?

មុននឹងធ្វើការបកស្រាយនូវទស្សនៈរបស់ប្រធានឱ្យបានក្បោះក្បាយ និងកាន់តែច្បាស់នោះ យើងគប្បីយល់នូវន័យនៃពាក្យគន្លឹះមួយចំនួនជាមុនសិន។ ចំពោះពាក្យថា "សីលធម៌" គឺមានន័យថាជាសេចក្តីល្អ ការចេះគោរពឱ្យតម្លៃចំពោះអ្នកដទៃ ការប្រព្រឹត្តតែអំពើល្អជាដើម។ ចំណែកពាក្យថា "សេចក្តីថ្លៃថ្នូរ" គឺសំដៅទៅលើភាពល្អប្រសើរខ្ពង់ខ្ពស់ប្រកបដោយកិត្តិយស ព្រមទាំងទទួលបានការគោរពស្រឡាញ់ពីអ្នកដទៃ។ យ៉ាងណាមិញចំពោះទស្សនៈរបស់ប្រធានខាងលើគឺមានន័យថា រាល់ការប្រព្រឹត្តអំពើល្អ និងចេះគោរពឱ្យតម្លៃចំពោះអ្នកដទៃ គឺជាកត្តាដ៏សំខាន់ដែលអាចធ្វើឱ្យជីវិតរស់នៅរបស់មនុស្សប្រកដោយកិត្តិយស កេរ្តិ៍ឈ្មោះព្រមទាំងទទួលបានការគោរពស្រឡាញ់ពីសំណាក់អ្នកដទៃវិញផងដែរ។

ជាការពិតណាស់ ការរស់នៅរបស់មនុស្សប្រចាំថ្ងៃ គឺពិតជាទាមទារឱ្យមានសីលធម៌ ចំពោះគ្នាចាំបាច់បំផុត ដោយហេតុថា មនុស្សគឺជាសត្វថ្នាក់ខ្ពស់ដែលប្រកបដោយវិចារណញ្ញាណ ហើយអាចសម្រេចការងារផ្សេងៗបានដោយជោគជ័យ។ ជាក់ស្តែងបុគ្គលដែលប្រព្រឹត្តតែ

អំពើល្អ ចេះជួយសង្គ្រោះប្រោសប្រណី អាណិតស្រឡាញ់ ឱ្យតម្លៃចំពោះអ្នកដទៃ នោះគេក៏ទទួលបាននូវការតបស្នងដោយល្អត្រឡប់មកវិញដែរ។ ម្យ៉ាងទៀតទោះបីជាបុគ្គលណាម្នាក់មានទ្រព្យសម្បត្តិស្តុកស្តម្ភ រៀនសូត្របានខ្ពង់ខ្ពស់យ៉ាងណាក្តី តែបុគ្គលនោះពុំមានសីលធម៌នៅក្នុងខ្លួន ក៏មិនអាចមានកិត្តិយស និងសេចក្តីថ្លៃថ្នូរបានឡើយ។ មិនថានៅកន្លែងការងារនោះទេ នៅពេលដែលយើងគោរពឱ្យតម្លៃច្បាប់ការងារ មានសីលធម៌ល្អក្នុងការប្រាស្រ័យទាក់ទងគ្នា នោះគេនឹងទទួលបានការសាទរ ដៃគូសហការ និងការយសសក្តិទៅលើតួនាទីរបស់គេ។ មួយវិញទៀតការសាមគ្គីគ្នា មិនបង្កទំនាស់ដល់អ្នកដទៃ ចេះគោរពសិទ្ធិគ្នាទៅវិញទៅមក មិនប្រព្រឹត្តអំពើអយុត្តិធម៌ ស្រឡាញ់មនុស្សនៅជុំវិញខ្លួន នោះបុគ្គលនោះនឹងទទួលបានកិត្តិយស និងការឱ្យតម្លៃនៃមនុស្សដែលរស់នៅក្នុងសង្គម។ បន្ថែមពីនេះនៅក្នុងគ្រួសារក៏មិនខុសគ្នាទៅនឹងសង្គមដែរ បើបុគ្គលដែលស្គាល់ខ្លួនឯងច្បាស់ ស្គាល់ពីតួនាទីខ្លួនឯងក្នុងគ្រួសារ ជាឪពុកម្តាយត្រូវមានឥរិយាបថបែបណាចំពោះកូនចៅ ជាកូនត្រូវបំពេញតួនាទីរបស់ខ្លួនឱ្យល្អ ច្បាស់ណាស់ដែលពួកគេនឹងទទួលបាននូវសេចក្តីសុខ ជាគ្រួសារគំរូដល់ជនទូទៅ។ ពិសេសជាងនេះទៅទៀតនៅពេលយើងផ្តល់ក្តីស្រឡាញ់ទៅកាន់មនុស្សជុំវិញខ្លួន មិនថាក្នុងប្រទេស ឬក្រៅប្រទេស មានភាពស្មោះត្រង់ មិនភូតកុហក រក្សារាប់រកគ្នា នឹងធ្វើឱ្យពួកគេស្គាល់មានញាតិច្រើន រីករាយក្នុងជីវិតជារៀងរហូត។ តួយ៉ាងគ្រូបង្រៀនគឺជាបុគ្គលដែលប្រកបដោយសីលធម៌ល្អ ហើយបានអប់រំទូន្មានប្រៀនប្រដៅសិស្សានុសិស្សឱ្យប្រព្រឹត្ត និងមានសីលធម៌ល្អផងដែរ។ ទោះបីជាគ្រូ

បង្រៀន មិនមានទ្រព្យសម្បត្តិច្រើនហូរហៀរក៏ដោយ តែគ្រូបង្រៀនគឺបានទទួលនូវការគោរពស្រឡាញ់ និងឱ្យតម្លៃយ៉ាងប្រសើរពីសំណាក់សិស្សានុសិស្ស និងសហគមន៍ទាំងមូលទៀតផង។ លើសពីនេះទៀតមនុស្សគ្រប់រូបទាំងសិស្សានុសិស្ស កសិករ កម្មករអាជីវករ គឺត្រូវតែមានសីលធម៌ ចេះគោរពគ្នា ទើបធ្វើឱ្យជីវិតមានតម្លៃ។ ម្យ៉ាងទៀតបើយើងសង្កេតមើលទៅសម្ដេចព្រះសង្ឃជួនណាតទ្រង់គឺជាបុគ្គលមួយរូបដែលមានចំណេះដឹងខ្ពង់ខ្ពស់ ជាបុគ្គល)ឆ្នើមប្រកបដោយសីលធម៌ល្អ ទើបធ្វើទ្រង់មានតម្លៃវិសេសវិសាលបំផុត។ បើយើងក្រឡេកមើលទៅក្នុងប្រវត្តិសាស្ត្រខ្មែរយើង នាសម័យមហានគរឯណោះវិញ យើងឃើញថាព្រះនាងឥន្ទ្រទេវី គឺក្សត្រីមួយអង្គមិនត្រឹមតែមានរូបសម្បត្តិស្រស់ស្អាតមានទាំងចំណេះដឹងខ្ពង់ខ្ពស់ប៉ុណ្ណោះទេ តែទ្រង់មានសីលធម៌យ៉ាងល្អប្រសើរទៀតផង ចំពោះព្រះញាតិវង្សនិងរាជបរិពារគ្រប់គ្នា ហេតុនេះហើយទើបធ្វើឱ្យទ្រង់មានតម្លៃជាអមត។ ដោយសារសីលធម៌ជាកត្តាកត្តាកំណត់សេចក្ដីថ្លៃថ្នូររបស់មនុស្សបែបនេះហើយ ទើបធ្វើឱ្យអ្នកនិពន្ធតាក់តែងជាអក្សរសិល្ប៍ឡើង។ ជាក់ស្ដែងថៅចិត្រនៅក្នុងរឿងកុលាបប៉ៃលិនដែលជាវណ្ណកម្មរបស់លោកញ៉ុកថែមគឺជាតួអង្គមួយរូបដែលប្រកបដោយសីលធម៌ល្អប្រសើរ។ ទោះបីខ្លួនជាកម្មករជីកត្បូងត្រូវធ្វើការលំបាកប៉ុនណាក៏ដោយក៏ថៅចិត្រមិនភ្លេចនូវសីលធម៌ ការគោរពប្រតិបត្តិចំពោះថៅហ្វាយនាយរបស់ខ្លួនឡើយ។ ថៅចិត្រជាមនុស្សស្មោះត្រង់ចំពោះការងារ និងចំពោះថៅហ្វាយនិងចេះគោរពស្រឡាញ់អ្នកនៅជុំវិញខ្លួន ទើបធ្វើឱ្យថៅចិត្របានទទួលនូវលទ្ធផលល្អប្រសើរសមនឹងទង្វើ

របស់ខ្លួនបានប្រព្រឹត្ត។ដោយឡែកលោកហ្លួងរតនសម្បត្តិទោះបីជាលោកមានទ្រព្យសម្បត្តិច្រើនហូរហៀរយ៉ាងណាក៏ដោយ ក៏លោនៅតែរក្សាជំហរជាមនុស្សល្អ ចេះគោរពឱ្យតម្លៃចំពោះ កម្មករទូទៅ ដោយគ្មានការរើសអើងឡើយ។ ហេតុនេះហើយទើបធ្វើឱ្យកម្មករ និងមនុស្សទូទៅគោរពស្រឡាញ់លោកយ៉ាងខ្លាំង។ រឿងផ្កាស្រពោនឯណោះវិញ ក៏បានបង្ហាញពី សីលធម៌ដែលជាប្រភពនាំឱ្យមានសេចក្ដីថ្លៃថ្នូរផងដែរ។ តួយ៉ាង តួរអង្គប៊ុនធឿន គឺជាតួរអង្គមួយរូបដែលប្រកបដោយសីលធម៌ល្អប្រសើរ ទោះបីជាយាយនួន បំបែកនាងវិធាវីចេញពីខ្លួនយ៉ាងណាក្ដី ក៏នៅតែរក្សាជំហរនៅដដែល ប៊ុនធឿន មានតែជួយជម្រុញឱ្យនាងវិធាវីព្រមតាមម្ដាយរៀបការជាមួយនឹងណៃស៊ិតដែលជាអ្នកមានទ្រព្យសម្បត្តិទៀតផង។ លើសពីនេះទៅទៀត ឧត្ដមគតិមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ សុទ្ធចិត្តបាត់បង់ការងារក៏ព្រមឱ្យមនុស្សអាក្រក់ គាបសង្កត់កេងចំណេញលើមនុស្សទន់ខ្សោយឡើយ។ ចុងក្រោយទីឃាវុធបានទទួលការគោរពស្រឡាញ់យ៉ាងច្រើនពីសំណាក់មនុស្សទូទៅ អាស្រ័យដោយការប្រព្រឹត្តអំពើល្អ និងមានសីលធម៌បែបនេះហើយ។

សរុបសេចក្ដីមក សីលធម៌គឺពិតជាកត្តាដ៏សំខាន់ក្នុងការកំណត់សេចក្ដីថ្លៃថ្នូររបស់មនុស្សពិតប្រាកដមែន បើគ្មានសីលធម៌ ទោះបីជាបុគ្គលនោះ មានទ្រព្យសម្បត្តិរៀនសូត្របានខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ ក៏មិនមានតម្លៃគ្រប់គ្រាន់សម្រាប់ធ្វើឱ្យអ្នកដទៃគោរពស្រឡាញ់បានឡើយ

ឆ្លងតាមការបកស្រាយខាងលើរួចមក យើងឃើញថាទស្សនៈរបស់ប្រធានពិតជាមានអត្ថន័យល្អ ព្រោះបានអប់រំមនុស្សគ្រប់រូប

ឱ្យប្រកាន់ខ្ជាប់នូវសីលធម៌ ប្រព្រឹត្តតែអំពើល្អ ក្នុងការរស់នៅដើម្បីធ្វើឱ្យជីវិតប្រកបដោយកិត្តិយស និងសេចក្ដីថ្លៃថ្នូរ។ ដូចនេះក្នុងនាមយើងជាមនុស្សប្រកបដោយវិចារណញ្ញាណយើងត្រូវតែមានសីលធម៌ល្អចំពោះគ្នា ទើបធ្វើឱ្យជីវិតយើងប្រសើរឡើងបាន។

# ប្រធានទី២

មានមតិជាច្រើនបានលើកឡើងថា៖ «អក្សរសិល្ប៍បែបពុទ្ធនិយម គឺអប់រំមនុស្សឱ្យដោះស្រាយបញ្ហាដោយសន្តិភាព»។ ចូរពន្យល់ឱ្យបានក្បោះក្បាយ។

## គម្រោងតែង

### I. សេចក្តីផ្តើម

- លំនាំបញ្ហា៖ អក្សរសិល្ប៍មានមុខងារសំខាន់ក្នុងការផ្តល់ចំណេះដឹងដល់អ្នកអាន អ្នកសិក្សាឱ្យចេះស្វែងយល់ពីជីវភាពការរស់នៅ សកម្មភាពមនុស្សក្នុងសង្គមឬក្នុងសម័យកាលណាមួយ ហើយបញ្ហាទាំងនោះត្រូវស្របទៅតាមក្រឹតក្រមចាំបាច់ដែលមានក្នុងសង្គមពិត។
- ចំណូលបញ្ហា៖ បែបនេះហើយទើបមានទស្សនៈមួយបានលើកឡើងថា "អក្សរសិល្ប៍បែបពុទ្ធនិយម គឺអប់រំមនុស្សឱ្យដោះស្រាយបញ្ហាដោយសន្តិភាព"
- ចំណោទបញ្ហា៖ តើមតិដែលបានលើកឡើងខាងលើមានអត្ថន័យយ៉ាងដូចម្តេច?

### II. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាជំនួយដល់ការបកស្រាយមតិខាងលើ
- ពន្យល់ពាក្យគន្លឹះ៖

+ អក្សរសិល្ប៍បែបពុទ្ធនិយម : គឺជាអត្ថបទអក្សរសិល្ប៍ទាំងឡាយណាដែលនិយាយទាក់ទងនឹងលទ្ធិព្រះពុទ្ធសាសនា។
+ អប់រំ : បង្រៀន ប្រៀនប្រដៅ ទូន្មាន។
+ សន្តិភាព : សេចក្តីស្ងប់ សេចក្តីសាន្តត្រាណ សេចក្តីសុខដុមរមនា។

- ពន្យល់ន័យប្រធានៈ អក្សរសិល្ប៍បែបពុទ្ធនិយម គឺជាស្នាដៃរឿងទាំងឡាយដែលទូន្មានមនុស្សឱ្យចេះដោះស្រាយបញ្ហាដោយសេចក្តីស្ងប់។
- បកស្រាយន័យប្រធានៈ អក្សរសិល្ប៍បែបពុទ្ធនិយម បានជួយអប់រំមនុស្សឱ្យស្រឡាញ់ សន្តិភាព សេចក្តីសុខស្ងប់ សេចក្តីសន្តោសប្រោសប្រណី ស្រឡាញ់រាប់អានគ្នាទៅវិញទៅមកដែលឆ្លុះបញ្ចាំងតាមរឿងទសជាតក បញ្ញាជាតក និងគាថា ជាដើមដើម្បីជួយអប់រំមនុស្សដូចជាៈ

+ អប់រំឱ្យជឿលើទស្សនៈកម្ម-ផលៈ ជឿលើថាអំពើអ្វីដែលយើងបានធ្វើនោះយើងនឹងទទួលផលនោះវិញជាមិនខានមានន័យថាបើយើងធ្វើល្អយើងនឹងទទួលផលល្អ ហើយបើយើងធ្វើអាក្រក់យើងនឹងទទួលផលអាក្រក់នោះឯង។
    - ជាក់ស្តែងក្នុងរឿងវេស្សន្តរ តួអង្គព្រះវេស្សន្តរ តាជូជក។

+ អប់រំកាយ វាចា និងចិត្តៈ ការអប់រំកាយ វាចា និងចិត្តនេះ ទាល់តែមានសីលជាមូលដ្ឋានសិន។

- តួយ៉ាងក្នុងរឿងភូរិទត្តជាតកបង្ហាញអំពីរឿងរ៉ាវផ្សេងៗរបស់តួអង្គព្រះពោធិសត្វ ទាក់ទងជុំវិញការបំពេញសីលបារមីរបស់ព្រះអង្គ នៅជាតិទីប្រាំមួយ។ ការបំពេញបារមីនោះបានអប់រំដូចជា

– អប់រំមនុស្សយើងកុំឲ្យប្រកាន់បក្សពួក រើសអើងប្រកាន់វណ្ណៈ

– អប់រំមនុស្សឱ្យចេះស្រឡាញ់គ្នា ចេះជួយសង្គ្រោះ

– អប់រំមនុស្សឱ្យចេះធ្វើទាន រក្សាសីលបារមី

– អប់រំមនុស្សឱ្យចេះអំណត់ព្យាយាម អត់ធ្មត់ខន្តី មិនក្រោធខឹង

– អប់រំមនុស្សឱ្យប្រើវិធីដោះស្រាយសមស្រប

– អប់រំមនុស្សកុំឱ្យប្រើអំពើហឹង្សា

– អប់រំមនុស្សកុំឱ្យដើរបៀតបៀនសេចក្ដីសុខអ្នកដទៃ

– អប់រំកុំឱ្យមនុស្សភ្លេចគុណអ្នកដទៃ

– បណ្ដុះស្មារតីមនុស្សឱ្យចេះសេពគប់មិត្ត

– អប់រំមាតាបិតាត្រូវមានព្រហ្មវិហារធម៌

– អប់រំមនុស្សឱ្យជឿលើកម្មផល

– អប់រំមនុស្សឱ្យធ្វើអំពើល្អទាំងកាយនិងវាចា។

+ អប់រំឱ្យស្រឡាញ់សន្តិភាព៖ អប់រំមនុស្សឱ្យជៀសវាងនូវការប្រព្រឹត្តអំពើមិនល្អសព្វបែបយ៉ាង ដែលជាមាគ៌ាដឹកនាំមនុស្សឆ្ពោះទៅរកសុភមង្គល។ រាល់ដំណោះស្រាយបញ្ហាក្នុងអក្សរសិល្ប៍ពុទ្ធនិយមដោះស្រាយដោយសន្តិភាព និងវៀរចាកបាប ហើយធ្វើឱ្យមនុស្សស្រឡាញ់សន្តិភាព។

- ជាក់ស្តែងក្នុងរឿងក្រុងសុភមិត្រ គឺ តួអង្គក្រុងសុភមិត្រដើម្បីជៀសវាងការធ្វើសង្គ្រាមច្បាំងនិងបង្ហូរឈាមប្រជាពលរដ្ឋព្រះអង្គបានចាកចេញពីនគរជាមួយមហេសីនិងបុត្រដើម្បីឱ្យសង្គមនិងប្រជាពលរដ្ឋរស់នៅបានសន្តិភាព។

+ អប់រំមនុស្សឱ្យចេះសន្តោសប្រោសប្រណី និងធ្វើទាន៖ តាមរយៈរឿងពុទ្ធនិយមសុទ្ធសាធ (ទសជាតក) និងពុទ្ធនិយមក្លាយ (បញ្ញាជាតក) បានបណ្តុះទឹកចិត្តមនុស្សឱ្យមានព្រហ្មវិហារធម៌ គឺមេត្តា ករុណា មុទិតា និងឧបេក្ខា ចំណោះគ្នានិងគ្នា ចេះចែករំលែកសេចក្តីសុខ មតិយោបល់ និងទ្រព្យសម្បត្តិដល់ជនក្រីក្រ ដើម្បីបានរស់ស្រួលក្នុងសង្គម។

- នៅក្នុងសង្គម យើងអាចសង្កេតឃើញថា ប្រជាពលរដ្ឋខ្មែរនៅតាមភូមិ ស្រុក ចេះជួយសង្គ្រោះគ្នាទៅវិញទៅមក នៅពេលនរណាម្នាក់ ឬក្រុមគ្រួសារ

ណាមួយជួបប្រទះនូវការងារដ៏លំបាកលំបិនណាមួយ ដូចជាការសង់ផ្ទះ ពិធីបុណ្យសព ជាដើម។

- ដូចជារឿងព្រះតេមិយ រឿងសុវណ្ណសាម រឿងព្រះវេស្សន្តរ... បានឆ្លុះបញ្ចាំងពីការធ្វើទាន មានទឹកចិត្តមេត្តា ករុណា មុទិតា និងឧបេក្ខា។

+ អប់រំមនុស្សមិនឱ្យមានគំនិតលោភលន់៖ សំដៅយកតណ្ហាដែលជារងើកភ្លើងទូទ្រង់នូវចំណង់ឱ្យចង់មាន ចង់បានហួសហេតុពេក និងជាប្រភពនាំឱ្យវិនាសដល់ទ្រព្យសម្បត្តិ សុភមង្គល និងអាយុជីវិតផ្ទាល់ខ្លួន ឬក្រុមគ្រួសារទៀតផង។

- តាមរយៈរឿងតេមិយ តួអង្គព្រះពោធិសត្វ សុទ្ធតែបានពិចារណាយ៉ាងល្អិតល្អន់ គឺមិនលោភលន់នឹងអំណាចទ្រព្យសម្បត្តិបន្តិចសោះឡើយ។

+ អប់រំឱ្យអត់ធ្មត់ និងព្យាយាម៖ សំដៅទទួលបាននូវចំណេះដឹង ចេះប្រឹងប្រែងអត់ទ្រាំ តស៊ូព្យាយាមគ្រប់ការងារលំបាកទាំងអស់ ដើម្បីដណ្ដើមយកជ័យជម្នះលើខ្លួនឯង ក៏ដូចជាអ្នកដទៃ។

- ក្នុងរឿងមហាជនក ព្រះបាទជនកតស៊ូព្យាយាមហែលទឹកសមុទ្រដ៏ធំធេង រហូតដល់ទេពធីតារក្សាមហាសមុទ្រ ឈ្មោះនាងមណីមេខលា ជួយស្រោចស្រង់រួចពីស្លាប់។ នៅទីបំផុតព្រះបាទជនក បាន

ឡើងគ្រងរាជ្យសម្បត្តិ នគរមិថិលា ដោយសារតែការតស៊ូព្យាយាមរបស់ព្រះអង្គ។

+ អប់រំឱ្យចេះត្រិះរិះពិចារណាពីហេតុនិងផលៈ សម្រាប់អប់រំជាច្រើនក្នុងដំណើររឿង ឱ្យមនុស្សចេះគោរពគ្នា ចេះពិចារណារកហេតុនិងផល។

- គួយ៉ាងក្នុងរឿងសុវណ្ណសាម គឺ សុវណ្ណសាមត្រូវយក្សបាញ់ តែសុវណ្ណមិនខឹង បែរជាសួររកមូលហេតុដែលយក្សបាញ់ខ្លួន? យក្សប្រាប់ថាៈ ម្រឹគមកចំមុខព្រួញរបស់ខ្ញុំហើយ ផ្អើលបោលអស់ទៅព្រោះហេតុនោះទើបបានជាខ្ញុំខឹង ខ្ញុំបាញ់ទៅ។

– សរុបមតិៈ សរុបសេចក្តីមកអក្សរសិល្ប៍បែបពុទ្ធនិយម បានបង្ហាញនូវចំណុចសំខាន់យ៉ាងច្រើន សម្រាប់អប់រំមនុស្សគ្រប់រូបឱ្យរស់នៅប្រកបដោយ ព្រហ្មវិហារធម៌ ចេះអាណិតស្រឡាញ់ រាប់អាន និងការខិតខំប្រឹងប្រែង មិនលួចឆក់ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ គឺរស់នៅដោយសន្តិភាព។

## III. សេចក្តីបញ្ចប់

– វាយតម្លៃប្រធានៈ មានអត្ថន័យល្អ ជ្រាលជ្រៅដោយបានបង្ហាញពីតម្លៃរបស់អក្សរសិល្ប៍បែបពុទ្ធនិយម និងផ្តល់ជាគំនិតអប់រំដាស់តឿនមនុស្សអ្នកសិក្សាឱ្យយល់ឱ្យប្រកាន់ការដោះស្រាយបញ្ហានានាដោយសន្តិវិធីជានិច្ចដើម្បីយើងរស់នៅបានសុខសាន្តត្រាណ និង សង្គមរីកចម្រើន។

– មតិផ្ទាល់ខ្លួន៖ ដូច្នេះយើងទាំងអស់គ្នា ត្រូវតែខំប្រឹងប្រែងរៀនសូត្រឱ្យបានខ្ពង់ខ្ពស់ និង ត្រូវប្រកាន់ជានិច្ចនូវវប្បធម៌សន្តិភាពក្នុងការដោះស្រាយបញ្ហានានាមិនថាតូចក្ដី ឬធំក្ដី ដើម្បីឱ្យខ្លួនយើងមានសេចក្ដីសុខ និងប្រទេសជាតិយើងមានសុខសន្តិភាព និងការអភិវឌ្ឍន៍ជានិរន្តរភាព។

## សេចក្ដីអធិប្បាយ

អក្សរសិល្ប៍មាននុខងារសំខាន់ក្នុងការផ្ដល់ចំណេះដឹងដល់អ្នកអាន អ្នកសិក្សាឱ្យចេះស្វែងយល់ពីជីវភាព សកម្មភាពមនុស្សក្នុងសង្គមឬក្នុងសម័យកាលណាមួយ ហើយបញ្ហាទាំងនោះត្រូវដោះស្រាយស្របទៅតាមក្រឹតក្រមចាំបាច់ដែលមានក្នុងជីវភាពពិត។ អាស្រ័យហេតុនេះហើយ ទើបមានទស្សនៈមួយបានលើកឡើងថា "អក្សរសិល្ប៍បែបពុទ្ធនិយម គឺអប់រំមនុស្សឱ្យដោះស្រាយបញ្ហាដោយសន្តិភាព"។

តើទស្សនៈដែលបានលើកឡើងខាងលើនេះមានអត្ថន័យយ៉ាងដូចម្ដេច?

ដើម្បីជាជំនួយដល់ការបកស្រាយមតិខាងលើ យើងគួរគប្បីត្រូវយល់ពីពាក្យគន្លឹះ "អក្សរសិល្ប៍បែបពុទ្ធនិយម" "អប់រំ" និង "សន្តិភាព" ជាមុនសិន។ ពាក្យ "អក្សរសិល្ប៍បែបពុទ្ធនិយម"គឺជាអត្ថបទអក្សរសិល្ប៍ទាំងឡាយណាដែលនិយាយទាក់ទងនឹងលទ្ធិព្រះពុទ្ធសាសនា។ ឯពាក្យ "អប់រំ" មានន័យថាការបង្រៀន ប្រៀនប្រដៅ ទូន្មាន។ រីឯពាក្យ "សន្តិភាព" មានន័យថា សេចក្ដីស្ងប់ សេចក្ដីសាន្តត្រាណ សេចក្ដីសុខដុមរមនា។ ដូច្នេះន័យប្រធានខាងលើមានន័យថាអក្សរសិល្ប៍បែបពុទ្ធនិយម គឺជា

ស្នាដៃរឿងទាំងឡាយដែលទូន្មានមនុស្សឱ្យចេះដោះស្រាយបញ្ហាដោយសេចក្ដីស្ងប់។

ជាការពិតណាស់អក្សរសិល្ប៍បែបពុទ្ធនិយមបានជួយអប់រំមនុស្សឱ្យស្រឡាញ់សន្តិភាព សេចក្ដីសុខស្ងប់ សេចក្ដីសន្ដោសប្រោសប្រណី ស្រឡាញ់រាប់អានគ្នាទៅវិញទៅមកដែលឆ្លុះបញ្ចាំងតាមរឿងទសជាតក បញ្ញាសជាតក និងគាថា ជាដើមដើម្បីជួយអប់រំមនុស្ស។ ការអប់រំមានដូចជាអប់រំឱ្យជឿលើទស្សនៈកម្ម-ផលមានន័យថាជឿថាអំពើអ្វីដែលយើងបានធ្វើនោះយើងនឹងទទួលផលនោះវិញជាមិនខានមានន័យថាបើយើងធ្វើល្អយើងនឹងទទួលផលល្អ ហើយបើយើងធ្វើអាក្រក់យើងនឹងទទួលផលអាក្រក់នោះឯង។ ជាក់ស្ដែងក្នុងរឿងវេស្សន្តរ តួអង្គព្រះវេស្សន្តរដែលខិតខំបរិច្ចាគទានដល់មនុស្សសត្វទាំងឡាយ ដើម្បីប្រាថ្នាត្រាស់ជាព្រះពោធិសត្វ តែព្រះអង្គចុងក្រោយបានទៅកើតនាឋានតុសិតទេវលោក។ រីឯតាជូជកដោយសារអំពើរបស់គាត់មិនល្អ និងមានសេចក្ដីប្រោសប្រណីដល់សព្វសត្វមានជីវិត និងល្មោភនឹងភាពមានបានហួសហេតុក៏បានស្លាប់ដោយបរិភោគអាហារច្រើនហួសប្រមាណ។ ស្របគ្នានោះអក្សរសិល្ប៍បែបពុទ្ធនិយមបានអប់រំកាយ វាចា និងចិត្ត គឺការអប់រំកាយ វាចា និងចិត្តនេះ ទាល់តែមានសីលជាមូលដ្ឋានសិន។ តួយ៉ាងក្នុងរឿងភូរិទត្តជាតកបង្ហាញអំពីរឿងរ៉ាវផ្សេងៗរបស់តួអង្គព្រះពោធិសត្វទាក់ទងជុំវិញការបំពេញសីលបារមីរបស់ព្រះអង្គ ព្រោះព្រះអង្គហ៊ានលះបង់កម្លាំងកាយ ហ៊ានប្ដូរជីវិតដើម្បីប្ដូរយកសីលបារមីនៅជាតិទីប្រាំមួយ។ ការបំពេញបារមីបានអប់រំដូចជា អប់រំមនុស្សយើងកុំឱ្យប្រកាន់

បក្សពួក រើសអើងប្រកាន់ វណ្ណៈ អប់រំមនុស្សឱ្យចេះស្រឡាញ់គ្នា ចេះជួយសង្គ្រោះ អប់រំមនុស្សឱ្យចេះធ្វើទាន រក្សាសីលបារមី អប់រំមនុស្សឱ្យចេះអំណត់ព្យាយាម អត់ធ្មត់ ខន្តី មិនក្រោធខឹង អប់រំមនុស្សឱ្យប្រើវិធីដោះស្រាយសមស្រប អប់រំមនុស្សកុំឱ្យប្រើអំពើហឹង្សា អប់រំមនុស្សកុំឱ្យដើរបៀតបៀនសេចក្ដីសុខអ្នកដទៃ អប់រំកុំឱ្យមនុស្សភ្លេចគុណអ្នកដទៃ បណ្ដុះស្មារតីមនុស្សឱ្យចេះសេពគប់មិត្ត អប់រំមាតាបិតាត្រូវមានព្រហ្មវិហារធម៌ អប់រំមនុស្សឱ្យជឿលើកម្មផល និងអប់រំមនុស្សឱ្យធ្វើអំពើល្អទាំងកាយនិងវាចា។ លើសពីនោះអក្សរសិល្ប៍បែបពុទ្ធនិយមបានអប់រំឱ្យស្រឡាញ់សន្តិភាព អប់រំមនុស្សឱ្យជៀសវាងនូវការប្រព្រឹត្តអំពើល្អ ដែលជាមាគ៌ាដឹកនាំមនុស្សឆ្ពោះទៅរកសុភមង្គល។ រាល់ដំណោះស្រាយបញ្ហាក្នុងអក្សរសិល្ប៍ពុទ្ធនិយមដោះស្រាយដោយសន្តិភាព និងវៀរចាកបាបហើយធ្វើឱ្យមនុស្សស្រឡាញ់សន្តិភាព។ ជាក់ស្ដែងក្នុងរឿងក្រុងសុភមិត្រ គឺ តួអង្គក្រុងសុភមិត្រដែលជាស្ដេចដើម្បីជៀសវាងការធ្វើសង្គ្រាមច្បាំង និងបង្ហូរឈាមប្រជាពលរដ្ឋ និងសត្វមានជីវិត ព្រះអង្គបានចាកចេញពីនគរជាមួយមហេសីនិងបុត្រដើម្បីឱ្យសង្គមនិងប្រជាពលរដ្ឋរស់នៅបាន សន្តិភាព។ មិនតែប៉ុណ្ណោះ អក្សរសិល្ប៍បែបពុទ្ធនិយមបានអប់រំមនុស្សឱ្យចេះសន្ដោសប្រោសប្រណី និងធ្វើទាន តាមរយៈរឿងពុទ្ធនិយមសុទ្ធសាធ (ទសជាតក) និងពុទ្ធនិយមក្លាយ (បញ្ញាជាតក) បានបណ្ដុះទឹកចិត្តមនុស្សឱ្យមានព្រហ្មវិហារធម៌ គឺមេត្តា ករុណា មុទិតា និងឧបេក្ខា ចំពោះគ្នានិងគ្នា ចេះចែករំលែកសេចក្ដីសុខ មតិយោបល់ និងទ្រព្យសម្បត្តិដល់ជនក្រីក្រ ដើម្បីបានរស់ស្រួលក្នុងសង្គម។ រីឯនៅក្នុងសង្គម យើងអាច

សង្កេតឃើញថា ប្រជាពលរដ្ឋខ្មែរនៅតាមភូមិ ស្រុក ចេះជួយសង្គ្រោះគ្នាទៅវិញទៅមក នៅពេលនរណាម្នាក់ ឬក្រុមគ្រួសារណាមួយជួបប្រទះនូវការងារដ៏លំបាកលំបិនណាមួយ ដូចជាការសង់ផ្ទះ ពិធីបុណ្យសព ជាដើម។ ចំណែកឯនៅក្នុងអក្សរសិល្ប៍មានដូចជារឿងព្រះតេមិយ រឿងសុវណ្ណសាម រឿងព្រះវេស្សន្តរជាដើម បានឆ្លុះបញ្ចាំងពីការធ្វើទាន មានទឹកចិត្តមេត្តា ករុណា មុទិតា និងឧបេក្ខា។ ជាពិសេសអក្សរសិល្ប៍បែបពុទ្ធនិយមបានអប់រំមនុស្សមិនឱ្យមានគំនិតលោភលន់ សំដៅយកតណ្ហាដែលជារងើកភ្លើងទ្រទ្រង់នូវចំណង់ឱ្យចង់មាន ចង់បានហួសហេតុពេក និងជាប្រភពនាំឱ្យវិនាសដល់ទ្រព្យសម្បត្តិ សុភមង្គល និងអាយុជីវិតផ្ទាល់ខ្លួន ឬក្រុមគ្រួសារទៀតផង។ តាមរយៈរឿងតេមិយ តួអង្គព្រះពោធិសត្វសុទ្ធតែបានពិចារណាយ៉ាងល្អិតល្អន់ គឺមិនលោភលន់នឹងអំណាចទ្រព្យសម្បត្តិបន្តិចសោះព្រោះយល់ថាវាជាហេតុនៃទុក្ខ។ ជាពិសេសជាងនេះ អក្សរសិល្ប៍បែបពុទ្ធនិយមបានអប់រំឱ្យអត់ធ្មត់ និងព្យាយាម សំដៅទទួលបាននូវចំណេះដឹងចេះប្រឹងប្រែងអត់ទ្រាំ តស៊ូព្យាយាមគ្រប់ការងារលំបាកទាំងអស់ ដើម្បីដណ្តើមយកជ័យជម្នះលើខ្លួនឯងក៏ដូចជាអ្នកដទៃ។ ជាក់ស្តែងក្នុងរឿងមហាជនក ព្រះបាទជនកតស៊ូព្យាយាមហែលទឹកសមុទ្រដ៏ធំធេង រហូតដល់ទេពធីតារក្សាមហាសមុទ្រឈ្មោះ នាងមណីមេខលា ជួយស្រោចស្រង់រួចពីស្លាប់។ នៅទីបំផុតព្រះបាទជនក បានឡើងគ្រងរាជ្យសម្បត្តិ នគរមិថិលា ដោយសារតែការតស៊ូព្យាយាមរបស់ព្រះអង្គ។ ទន្ទឹមគ្នានោះដែរ អក្សរសិល្ប៍បែបពុទ្ធនិយមបានអប់រំឱ្យចេះត្រិះរិះពិចារណាពីហេតុនិងផល សម្រាប់អប់រំជា

ច្រើនក្នុងដំណើររឿង ឱ្យមនុស្សចេះគោរពគ្នា ចេះពិចារណារកហេតុនិងផល។ គួយ៉ាងក្នុងរឿងសុវណ្ណសាម គឺ សុវណ្ណសាមត្រូវយក្សបាញ់ តែសុវណ្ណមិនខឹង បែរជាសួររកមូលហេតុដែលយក្សបាញ់ខ្លួន? យក្សប្រាប់ថា: ម្រឹគមកចំមុខព្រួញរបស់ខ្ញុំហើយ ផ្អើលបោលអស់ទៅព្រោះហេតុនោះទើបបានជាខ្ញុំខឹង ខ្ញុំបាញ់ទៅ។ ដោយសារក្តីអាណិតនិងភាពទន់ភ្លន់របស់សុវណ្ណសាម ទើបយក្សបានយកសុវណ្ណមសាមយកទៅចិញ្ចឹមនិងសន្យាជួយរកឪពុកម្តាយឱ្យសុវណ្ណសាម ហើយចុងក្រោយសុវណ្ណសាមបានជួបក្រុមគ្រួសារ។

សរុបសេចក្តីមកអក្សរសិល្ប៍បែបពុទ្ធនិយម បានបង្ហាញនូវចំណុចសំខាន់យ៉ាងច្រើន សម្រាប់អប់រំមនុស្សឱ្យដោះស្រាយបញ្ហានានាដោយសន្តិវិធី និង អប់រំឱ្យរស់នៅប្រកបដោយ ព្រហ្មវិហារធម៌ ចេះអាណិត ស្រឡាញ់ រាប់អាន និងការខិតខំប្រឹងប្រែង មិនលួចឆក់ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ គឺរស់នៅដោយសន្តិភាព។

ឆ្លងតាមរយៈការពន្យល់បកស្រាយទស្សនៈដែលបានលើកខាងលើនេះ យើងអាចវាយតម្លៃបានថាប្រធាននេះមានអត្ថន័យល្អ ជ្រាលជ្រៅដោយបានបង្ហាញពីតម្លៃរបស់អក្សរសិល្ប៍បែបពុទ្ធនិយម និងផ្តល់ជាគំនិតអប់រំ ដាស់តឿនមនុស្ស អ្នកសិក្សាឱ្យយល់ ឱ្យប្រកាន់ការដោះស្រាយបញ្ហានានាដោយសន្តិវិធីជានិច្ចដើម្បីរស់នៅបានសុខសាន្តត្រាណ និងសង្គមរីកចម្រើន។ ដូច្នេះយើងទាំងអស់គ្នា ត្រូវតែខំប្រឹងប្រែងរៀនសូត្រឱ្យបានខ្ពង់ខ្ពស់និង ត្រូវប្រកាន់ជានិច្ចនូវវប្បធម៌សន្តិភាពក្នុងការដោះស្រាយបញ្ហានានាមិនថាតូចក្តី ឬធំក្តី ដើម្បីឱ្យខ្លួនយើងមាន

សេចក្តីសុខ ប្រទេសជាតិយើងមានសុខសន្តិភាពនិងការអភិវឌ្ឍជានិរន្តរភាព។

# ប្រធានទី៣

មានទស្សនៈមួយចំនួនបានលើកឡើងថា៖ "រឿងព្រេងប្រជាប្រិយខ្មែរជារឿងបានផ្ដល់នូវ ការកម្សាន្ត និងបានផ្ដល់នូវតម្លៃអប់រំ"។ ចូរបកស្រាយទស្សនៈរបស់ប្រធានឱ្យបានក្បោះក្បាយ ដោយលើកយកឧទាហរណ៍មកបញ្ជាក់។

## គម្រោងតែង

### ១.ផ្ដើមសេចក្ដី

- លំនាំបញ្ហា៖ បុព្វបុរសខ្មែរយើង ជាមនុស្សដែលមានបទពិសោធក្នុងការរស់នៅ រាល់បទពិសោធទាំងនោះ លោកបានបង្កើតជាស្នាដៃជាច្រើន ដើម្បីឱ្យមនុស្សជំនាន់ក្រោយបានអានកែ កម្សាន្ត និងផ្ដល់ការអប់រំទូន្មានមានប្រៀនប្រដៅឱ្យដើរក្នុងផ្លូវល្អ ហើយស្នាដៃទាំងនោះមានដូចជាកំណាព្យ សុភាសិត អត្ថបទល្ខោនរួមទាំងរឿងព្រេងប្រជាប្រិយជាដើម។
- ចំណូលបញ្ហា៖ ហេតុនេះហើយទើបមានទស្សនៈមួយចំនួនបានលើកឡើងថា"រឿងព្រេងប្រជាប្រិយខ្មែរ បានផ្ដល់នូវការកម្សាន្ត និងបានផ្ដល់នូវតម្លៃអប់រំ"
- ចំណោទបញ្ហា៖ តើទស្សនៈខាងលើនេះមានអត្ថន័យបែបណាខ្លះ?

### ២.តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី៖ ដើម្បីជាជំនួយដល់ការបកស្រាយ...។
- ពន្យល់ពាក្យគន្លឹះ៖

+រឿងប្រជាប្រិយ: គឺជាស្នាដៃអក្សរសិល្ប៍ប្រជាប្រិយដែលមានអត្ថិភាពរហូតមកដល់បច្ចុប្បន្ន ដោយការនិទានផ្សព្វផ្សាយពីមាត់មួយទៅមាត់ ពីតំបន់មួយទៅ តំបន់មួយគ្មានអ្នកនិពន្ធ ច្បាស់លាស់ ហើយត្រូវបានប្រជាជនរាប់អានចូលចិត្តដោយសារសាច់រឿងសាមញ្ញ ការប្រើប្រាស់ពាក្យពេចន៍ងាយយល់។

+ការកំសាន្ត: ការរំសាយទុក្ខកង្វល់ ការលំហែ សប្បាយរីករាយ ការបន្ធូរអារម្មណ៍ ។

+តម្លៃអប់រំ: គឺជាអ្វីៗនៃការហាត់ចិត្ត ជួសជុលចំពោះកិរិយាមារយាទការទូន្មានប្រៀនប្រដៅឱ្យដើរក្នុងផ្លូវត្រឹមត្រូវ។

- ពន្យល់ប្រធាន៖ ដូចនេះប្រធានខាងលើបង្ហាញថា គ្រប់អត្ថបទក្នុងការតាក់តែងរឿងប្រជាប្រិយខ្មែរសុទ្ធតែសរសេរឡើងដើម្បីការកំសាន្ត និងផ្តល់តម្លៃអប់រំដល់អ្នកអានគ្រប់ៗគ្នាដើម្បីរំសាយទុក្ខកង្វល់ ការបន្ធូរអារម្មណ៍ ហើយក៏ទទួលបានចំណេះដឹង នូវការ ហ្វឹកហាត់ចិត្តជួសជុលចំពោះកិរិយាមារយាទ ការទូន្មានប្រៀនប្រដៅឱ្យដើរក្នុងផ្លូវត្រឹមត្រូវ។
- បកស្រាយប្រធាន៖ រឿងព្រេងប្រជាប្រិយបានផ្តល់នូវ
    - ការកំសាន្ត៖ បែបសំណើច កំហឹង កំសត់ សប្បាយរីករាយ កំប្លុកកំប្លែង...
    - តម្លៃអប់រំ:
        - ដឹងពីជីវភាពរស់នៅរបស់ប្រជាជនខ្មែរ

- ឱ្យចេះប្រកាន់ភាពកតញ្ញូចំពោះអ្នកមានគុណ
- ឱ្យស្គាល់ពីផ្នត់គំនិតរបស់ប្រជាជនខ្មែរ(ទំនៀម ទម្លាប់ ប្រពៃណី ជំនឿ)
- ស្គាល់ពីទីតាំងភូមិសាស្ត្រ ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា
- ឱ្យចេះរួបរួមសាមគ្គីគ្នា រួបរួមកម្លាំងគ្នា ឯកភាពគ្នាជាដើម

**ការកំសាន្តៈបែបសំណើច កំហឹង កំសត់ សប្បាយរីករាយ កំប្លុកកំប្លែង...**

+ឧទាហរណ៍: រឿងគង់ហ៊ាន(សម្លាប់ខ្លា ញ៉រដៃជើង រាករអាចម៍ រាកនោម រត់ពួនក្នុងរូងឈើ ទៅច្បាំងសង្គ្រាម រាកនោមលើក្បាលដំរី សម្លាប់ក្រពើ)

+ ឧទាហរណ៍: រឿងធនញ្ជ័យ ( ផ្ចាញ់សេដ្ឋីដោយរើសរអាចម៍សេះដាក់ក្នុងថង់យាម ពិន័យអ្នកដែលមានគោឈ្មោល ចាំចម្ការ នៅពេលភ្លើងឆេះផ្ទះសេដ្ឋី ធនញ្ជ័យយកសំបុកមាន់ សំបកប៉ោត គួរកំប្រោរជាមុខលើគូថរបស់ខ្លួនបែរឱ្យស្ដេចមើល ដៀលស្ដេចស្រុកចិន "មើលមុខស្ដេចស្រុកចិន ដូចមុខឆ្កែ មើលមុខស្ដេចខ្មែរដូចខែពេញបូណ៌មី" )

+ ឧទាហរណ៍: រឿងភ្នំប្រុស ភ្នំស្រី (ប្រពៃណីស្រីចូលដណ្ដឹងប្រុស ដើម្បីកែប្រែប្រពៃណីនេះ ស្រីៗ បបួលប្រុសៗលើកដីពូនជា...ប្រុសដណ្ដឹងស្រីរហូតដល់សព្វថ្ងៃ)។

+ ឧទាហរណ៍: រឿងចចក និងកំពឹស( បបួលសត្វធំៗ បាចទឹក... ផុតពី

គ្រោះថ្នាក់)។

+ ឧទាហរណ៍: រឿងសង្គ្រាមរវាងគីង្គក់ នឹងតាព្រហ្ម (កាលដែលគង្គក់ធ្វើជាមេប្រកាសដល់សព្វសត្វ ទាំងរស់នៅលើដី ទាំងរស់នៅក្នុងទឹក ...ភ្លៀងក៏ធ្លាក់មក ) ។

**បង្ហាញតម្លៃអប់រំ**:

+តម្លៃអប់រំក្នុងរឿងគង់ហ៊ាន(អប់រំឱ្យចេះរួបរួមកម្លាំងគ្នានៅពេលជួបឧបសគ្គដូចពាក្យថា "សំណាបយោងដីស្រីយោងប្រុស កុំមានការអួតក្អេងក្អាងហួសពីសមត្ថភាព របស់ខ្លួន និងហួសពីអ្វីដែលជាការពិត ត្រូវគិតពិចារណាមុននិង ជឿ លើការប្រព្រឹត្តរបស់នរណាម្នាក់)

+ តម្លៃអប់រំ រឿងធនញ្ជ័យ(ស្រឡាញ់ចំណេះវិជ្ជា និងយុត្តិធម៌ស្អប់ខ្ពើមអំពើជិះជាន់ ស្រឡាញ់ប្រជាជន មានស្មារតីអង់អាចក្លាហាន តស៊ូព្យាយាមដើម្បីយុត្តិធម៌និង សិទ្ធិសេរីភាពរបស់ប្រជាជន កុំមើលងាយមនុស្សព្រោះ"ចេះឯងឱ្យក្រែងចេះគេ " កុំជឿលើអបិយជំនឿ មានការទស្សន៍ទាយរបស់ហោរាជាដើម និងមានស្មារតីប្រុងប្រយ័ត្នជាប់ខ្លួនជានិច្ច)

+ តម្លៃអប់រំ ក្នុងរឿងភ្នំប្រុស ភ្នំស្រី (អប់រំឱ្យចេះដោះស្រាយបញ្ហា ចេះរួបរួមសាមគ្គីស្រុះស្រួលគ្នា ឱ្យតម្លៃលើស្ត្រី ឱ្យដឹងពីប្រវត្តិសាស្ត្រភូមិសាស្ត្រ ប្រពៃណីស្ត្រីដណ្ដឹងប្រុស ប្រុសដណ្ដឹងស្រី ដឹងពីរបបមាតាធិបតេយ្យ (យកមេជាធំ) និងចេះទទួលស្គាល់ការពិត កុំមើលស្រាលអ្នកដែល

មានកម្លាំងខ្សោយជាងខ្លួន ចេះរើបម្រាស់ពីបញ្ហាផ្សេងៗ និងគោរពពាក្យសច្ចៈ)

+ តម្លៃអប់រំក្នុងរឿងចចក និងកំពឹស( ចេះជួយគ្នាក្នុងគ្រាមានអាសន្ន ចេះដោះស្រាយបញ្ហានៅពេលជួបឧបសគ្គ ធ្វើអ្វីត្រូវគិតពិចារណាដូចពាក្យចាស់ថា"ចំណេះជិះកងង"

+ តម្លៃអប់រំក្នុងរឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម(ចេះរួបរួមសាមគ្គីគ្នា ចេះតស៊ូរើបម្រាស់ពីអំពើជិះជាន់អយុត្តិធម៌ ចេះរៀបចំផែនការបានច្បាស់លាស់ គោរពពាក្យសច្ចៈ ហ៊ានពលីជីវិតដើម្បីផលប្រយោជន៍រួម ចេះជ្រើសរើសមេដឹកនាំល្អ)

- សរុបមតិ៖ សរុបសេចក្តីមក រឿងព្រេងប្រជាប្រិយខ្មែរពិតជាបានផ្តល់នូវការកម្សាន្ត និងផ្តល់តម្លៃអប់រំ ព្រោះនៅក្នុងរឿងនីមួយៗបានផ្តល់នូវភាពសប្បាយរីករាយ និងតម្លៃអប់រំយ៉ាងច្រើនដល់អ្នកអាន អ្នកស្តាប់ អ្នកសិក្សាឱ្យបានយល់ជ្រួតជ្រាប។

## ៣. សេចក្តីបញ្ចប់

+ វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយនូវខ្លឹមសារខាងលើរួចមកយើងអាចវាយតម្លៃប្រធានពិតជា មានអត្ថន័យយ៉ាងជ្រាលជ្រៅបង្ហាញដល់មនុស្សទូទៅពីអត្ថប្រយោជន៍ នៃរឿងប្រជាប្រិយខ្មែរដែលមានទាំងការកម្សាន្ត និងផ្តល់តម្លៃអប់រំល្អៗដល់មនុស្សជំនាន់ក្រោយឱ្យយកជាគំរូនូវចំនុចល្អៗទាំងនោះ។

+មតិផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាកូនខ្មែរ ត្រូវចូលចិត្តអាន ស្តាប់ ស្វែងយល់និងដឹងអំពី អត្ថប្រយោជន៍នៃការអានស្តាប់រឿងប្រជាប្រិយខ្មែរ ហើយទាញយកនូវតម្លៃអប់រំទាំងនោះទុកធ្វើជាគតិ និងបទពិសោធន៍សម្រាប់ជីវិតជាពិសេសត្រូវលើកស្ទួយការពារ ថែរក្សាអក្សរសាស្ត្រខ្មែរឱ្យបានគង់វង្ស។

## សេចក្តីអធិប្បាយ

បុព្វបុរសខ្មែរយើង គឺជាមនុស្សដែលពោរពេញទៅដោយចំណេះដឹងជ្រៅជ្រះប្រកបដោយភាពប៉ិនប្រសប់ និងគំនិតច្នៃប្រឌិតខ្ពស់។ ពួកគាត់ស្ទើរតែគ្រប់ជំនាន់បានខិតខំខំណាយពេលពេញមួយជីវិត ហ៊ានបូជាមិនស្តាយស្រណោះនូវកម្លាំងកាយចិត្ត អាយុជីវិត ក្នុងគោលបំណងបង្កើត ឬចងក្រងគ្រប់អ្វីអ្វីទាំងអស់មានទាំងអក្សរ សិល្បៈ ទស្សនសុភាសិត សម្រាប់ជាកេរដំណែលដល់ កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយអនុវត្ត ឬធ្វើការពិចារណា។ អាស្រ័យហេតុនេះហើយទើបមានទស្សនៈមួយចំនួនបានលើកឡើងថា "រឿងព្រេងប្រជាប្រិយខ្មែរបានផ្តល់នូវការកម្សាន្ត និងផ្តល់នូវតម្លៃអប់រំ"។

តើទស្សនៈខាងលើនេះមានអត្ថន័យបែបណាខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយទស្សនៈរបស់ប្រធានខាងលើ យើងគួរគប្បីសិក្សាពាក្យគន្លឹះ "រឿងប្រជាប្រិយ" "ការកម្សាន្ត" និង"តម្លៃអប់រំ" ជាមុនសិន។ ពាក្យថា "រឿងព្រេងប្រជាប្រិយ" គឺជាស្នាដៃអក្សរសិល្ប៍ប្រជាប្រិយដែលមានអត្ថិភាពរហូតមកដល់បច្ចុប្បន្ន ដោយសារ

ការនិទានផ្សព្វផ្សាយពីមាត់មួយទៅមាត់មួយ គ្មានអ្នកនិពន្ធច្បាស់លាស់ ហើយត្រូវបានប្រជាជនរាប់អានចូលចិត្ត ដោយសារសាច់រឿងសាមញ្ញ ការប្រើប្រាស់ពាក្យពេចន៍ងាយយល់។ រីឯ"ការ កម្សាន្ត" មានន័យថា ការរំសាយទុក្ខកង្វល់ ការលំហែ សប្បាយរីករាយ ការបន្ធូរអារម្មណ៍ ។ ចំណែកពាក្យថា "តម្លៃអប់រំ" គឺសំដៅលើអ្វីៗនៃការហាត់ចិត្ត ជួសជុលចំពោះកិរិយាមារយាទ ការទូន្មានប្រៀនប្រដៅឱ្យដើរក្នុងផ្លូវល្អត្រឹមត្រូវ។ ដូចនេះទស្សនៈរបស់ប្រធានខាងលើគ្រប់អត្ថបទក្នុងការតាក់តែងរឿងប្រជាប្រិយខ្មែរ សុទ្ធតែសរសេរឡើងដើម្បីការកម្សាន្តនិងបានផ្តល់តម្លៃអប់រំដល់អ្នកអានគ្រប់ៗគ្នា។

រឿងព្រេងប្រជាប្រិយខ្មែរបានផ្តល់នូវការកម្សាន្តនិងបានផ្តល់តម្លៃអប់រំជាច្រើនតាមរយៈរឿងទាំងនោះ ដែលការកំសាន្តមានដូចជា កំហឹង កម្សត់ មនោសញ្ចេតនា កំប្លុកកំប្លែងជាដើម។ ក្នុងអក្សរសិល្ប៍ក៏បានកុំឱ្យមានការអួតក្អាងក្អាងហួសពីសមត្ថភាពរបស់ខ្លួន និងអប់រំឱ្យចេះដោះស្រាយបញ្ហាដោយប្រើប្រាជ្ញា។ ហើយតម្លៃអប់រំទៀតសោត ក៏ដឹងពីជីវភាពរស់នៅរបស់ប្រជាជន ឱ្យចេះប្រកាន់ភាពកតញ្ញូចំពោះអ្នកមានគុណ ឱ្យស្គាល់ពីផ្នត់គំនិតសំខាន់ៗរបស់ខ្មែរ ទំនៀមទម្លាប់ប្រពៃណី ជំនឿ ឱ្យចេះរួបរួម សាមគ្គីគ្នា រួបរួមកម្លាំងគ្នា ឯកភាពគ្នាជាដើម ដែលស្តែងឡើងតាមរឿង គង់ហ៊ាន នៅពេលអ្នកហ៊ាននិងប្រពន្ធធ្វើដំណើរចូលព្រៃ ដែលមានខ្លាតែងតែចាប់មនុស្ស គោ ក្របីស៊ីជារឿយៗ ពេលទៅដល់កន្លែងនោះ ខ្លាក៏ចេញមកស្រែកព្រុសន្ទ្រៅពីចម្ងាយ ធ្វើឱ្យអ្នកហ៊ានភ័យរត់ញ័រដៃ ជើងពួនបាត់ក្នុងរូងឈើ រាកនោម ឯប្រពន្ធទាំងពីរព្រួតគ្នា

សម្លាប់ខ្លា។ អ្នកហ៊ានចេញមកអួតក្អេងក្អាង ផ្អើលអស់អ្នកស្រុក រហូតគេដាក់ឈ្មោះឱ្យអ្នកហ៊ានថា គង់ហ៊ាន។ មិនយូរប៉ុន្មាន ដំណឹងនេះបានជ្រាបដល់ស្ដេច ទ្រង់ក៏បញ្ជាឱ្យនាំគង់ហ៊ានធ្វើជាសេនាសម្រាប់ច្បាំងសង្គ្រាម។ លុះយូរបន្តិចសង្គ្រាមបានកើតឡើង នៅពេលច្បាំងជាមួយសត្រូវធ្វើឱ្យគង់ហ៊ានភ័យរាករអាចម៍ រាកនោមលើក្បាលដំរី ជាហេតុធ្វើឱ្យ ដំរីខំបោលចូលជិតសត្រូវរត់ខ្ចាត់ខ្ចាយ គង់ហ៊ានក៏មានអំនួតទៀត។ លុះក្រោយមកទៀត គង់ហ៊ានត្រូវមានភារកិច្ចចាប់ក្រពើ ពេលនោះគង់ហ៊ានដឹងច្បាស់ណាស់ថា ខ្លួនច្បាស់ស្លាប់ជាក់ជា មិនខាន តែសំណាងល្អ គង់ហ៊ានក៏សម្លាប់ក្រពើបានទៀត ។មិនត្រឹមតែប៉ុណ្ណោះរឿងគង់ហ៊ាន ក៏បានបង្កប់នូវតម្លៃអប់រំដូចជា អប់រំឱ្យចេះរួបរួមកម្លាំងគ្នានៅពេលជួបឧបសគ្គ ក្នុងនាមជាប្រពន្ធត្រូវចេះជួយប្ដី ដូចពាក្យចាស់បានពោលថា "សំណាបយោងដី ស្រីយោងប្រុស" ។ ជាងនេះទៅទៀត កុំឱ្យមានការអួតក្អេងក្អាងហួសពីសមត្ថភាពរបស់ខ្លួន លើសអ្វីដែលជាការពិត មុននឹងជឿលើការប្រព្រឹត្តរបស់បុគ្គលណាម្នាក់ជាដើម។ ចំណែករឿង ធនញ្ជ័យបានផ្ដល់ការកំសាន្តដែលមានលក្ខណៈបែបកំសត់ កំហឹង កំប្លុកកំប្លែង ត្រង់កាលដែលធនញ្ជ័យនៅតូច ប្រពន្ធសេដ្ឋីប្រើឱ្យរើសត្រល់ ប្ដូរជាការឱ្យអំបុក ធនញ្ជ័យបានចាញ់ល្បិចសេដ្ឋី។ បន្ទាប់មក ធនញ្ជ័យក៏ប្រើល្បិចដើម្បីផ្ចាញ់សេដ្ឋី ទាំងដែលការរើសអាចម៍សេះដាក់ក្នុងថង់យាម ទាំងការផាកពិន័យអ្នកមានគោឈ្មោល ការចាំចម្ការ ជាពិសេសនៅពេលភ្លើងឆេះផ្ទះ សេដ្ឋីបានប្រាប់ធនញ្ជ័យយករបស់របរណាដែលស្រាលៗ ធនញ្ជ័យបែរជាយកសំបុកមាន់ សំបកប៉ោតទៅវិញ។ អស់ពីសេដ្ឋី ធនញ្ជ័យ

ក៏ប្រើល្បិចផ្ចាញ់ស្ដេចស្រុកខ្មែរ ស្ដេចស្អប់មិនចង់ឃើញមុខធនញ្ជ័យ។ ធនញ្ជ័យក៏យកកំប្រោរគូរជារាងមុខលើគូថរបស់ខ្លួន បែរទៅឱ្យស្ដេចមើល។ ម្យ៉ាងទៀតនៅពេលដែលស្ដេចបញ្ជាធនញ្ជ័យ ទៅនៅទន្លេ ធនញ្ជ័យក៏យករអង្កាមទៅបាចត្រង់កន្លែងដែលខ្លួនបានព័ទ្ធធ្វើជាកម្មសិទ្ធិ បើនរណាហ៊ានឆ្លងកាត់ត្រូវពិន័យជាប្រាក់សាមសិបតម្លឹង តែស្ដេចឱ្យយកតែមួយបាត្រ ឯធនញ្ជ័យបែរជាយកមួយបាត្រលោកទៅវិញ។ ប្រាជ្ញាធនញ្ជ័យបានល្បីដល់ស្ដេចស្រុកចិន តែត្រូវបានធនញ្ជ័យដៀលថា "មើលមុខស្ដេចស្រុកចិន ដូចមុខឆ្កែ មុខស្ដេចស្រុកខ្មែរដូចខែពេញបូរណ៍មី"។ ជាងនេះទៅទៀត រឿងធនញ្ជ័យបានបង្កប់អត្ថន័យអប់រំជាច្រើនដូចជា ស្រឡាញ់ចំណេះវិជ្ជា និងយុត្តិធម៌ ស្អប់ខ្ពើមអំពើជិះជាន់ ស្រឡាញ់ ប្រជាជន និងមាតុភូមិ មានស្មារតីអង់អាចក្លាហាន ព្យាយាម តស៊ូ ដើម្បីយុត្តិធម៌ និងសិទ្ធិសេរីភាពរបស់ប្រជាជន កុំមើលងាយមនុស្សព្រោះ "ចេះឯងឱ្យក្រែងចេះគេ" កុំជឿលើអបិយជំនឿ មានការទស្សន៍ទាយរបស់ហោរាជាដើម និងមានស្មារតីប្រុងប្រយ័ត្នជាប់ខ្លួនជានិច្ច។ ចំណែករឿងភ្នំប្រុស ភ្នំស្រី ក៏បាននិយាយរៀបរាប់ពីដំណើររឿងនៃប្រពៃណីស្រីចូលស្តីដណ្តឹងប្រុស ដើម្បីកែប្រែប្រពៃណីនេះ ស្រីៗបានបបួលប្រុសៗលើកដីពូនជាភ្នំ ដោយដាក់ខសន្យាថាបើខាងណាចាញ់ត្រូវទៅចូលស្ដីដណ្ដឹងធ្វើជាប្ដី ឬប្រពន្ធ។ ខាងស្រីៗបានរៀបល្បិចបង្ហូតគោមធ្វើជាផ្កាយព្រឹក ខាងប្រុសៗស្មានថាផ្កាយព្រឹករះមែនក៏នាំគ្នាឈប់ សម្រាក។ ពេលផ្កាយព្រឹកមែនទែនរះ ពួកប្រុសៗគឺចាញ់ល្បិចស្រីៗបាត់ទៅហើយ។ ចាប់តាំងថ្ងៃនោះមក ប្រុសៗត្រូវទៅដណ្ដឹងស្រីៗធ្វើជាប្រពន្ធរហូតដល់សព្វថ្ងៃ។ ជាង

នេះទៅទៀត តម្លៃអប់រំរឿងនេះ គឺអប់រំឱ្យចេះដោះស្រាយបញ្ហាដោយប្រើប្រាជ្ញា ចេះរួបរួមសាមគ្គីគ្នា ស្រុះស្រួលគ្នា ឱ្យតម្លៃលើស្ត្រី ឱ្យដឹងពីប្រវត្តិប្រពៃណីស្រីដណ្ដឹងប្រុស ប្រុសដណ្ដឹងស្រី ដឹងពីរបបមាតាធិបតេយ្យយកមេជាធំ និងចេះទទួលស្គាល់ការពិត ជាពិសេសអប់រំកុំមើលស្រាលចំពោះអ្នកដែលមានកម្លាំងខ្សោយជាងខ្លួន ចេះរើបម្រាស់ពីបញ្ហាផ្សេងៗនិងគោរពពាក្យសច្ចៈ។ តួយ៉ាងរឿងចចក និងកំពឹស ដែលចចកជាសត្វសាហាវបានបបួលគ្រប់សត្វធំៗមកបាចទឹកដើម្បីចាប់ត្រី កំពឹសស៊ីជាអាហារ បានត្រូវចាញ់ឧបាយកល និងប្រាជ្ញាដ៏ឈ្លាសវៃរបស់ទន្សាយ។ ក្នុងនោះដែរ ដើម្បីគេចផុតពីគ្រោះថ្នាក់ត្រីក្រាញ់បានធ្វើពលិកម្ម ទៅជួបសុភាទន្សាយដើម្បីជួយពួកខ្លួន។ចំពោះតម្លៃអប់រំវិញគឺត្រូវចេះជួយគ្នាក្នុងគ្រាមានពេលជួបឧបសគ្គ ចេះសាមគ្គីគ្នាដើម្បីរំដោះខ្លួនឱ្យផុតពីគ្រោះថ្នាក់ ធ្វើអ្វីត្រូវគិតពិចារណាដូចពាក្យចាស់ថា"ចំណេះជិះកឯង"។ មិនត្រឹមតែប៉ុណ្ណោះ រឿងសង្គ្រាមរវាងគីង្គក់ និង តាព្រហ្ម កាលដែលគីង្គក់ធ្វើជាមេ រួមទាំងហ៊ីងប្រកាសធ្វើសង្គ្រាមជាមួយតាព្រហ្ម ដើម្បីយកទឹកភ្លៀងសព្វសត្វ និងរុក្ខជាតិបានចូលរួមយ៉ាងសកម្ម ក្នុងការវាយប្រហារបានតាព្រហ្ម ដោយសារការរួបរួមកម្លាំង និងមានការសាមគ្គី និងឯកភាពគ្នាដូចនេះ បានធ្វើឱ្យតាព្រហ្មសុំចុះចាញ់ និងព្រមសន្យាបង្អុរទឹកភ្លៀងតាមលក្ខខណ្ឌដែល គីង្គក់ និង ហ៊ីងដាក់ឱ្យ។ ចាប់ពីថ្ងៃនោះមក នៅពេលដែលគីង្គក់ និងហ៊ីងសង្កៀតធ្មេញ ពុ ក្រតៗ អែបៗ អោបៗ ហ៊ីងហាងៗ ភ្លៀងក៏ធ្លាក់មក។ ក្នុងនោះផងដែរ តម្លៃអប់រំក៏ផ្ដល់ដល់អ្នកអានជាច្រើនដូចជាចេះរួបរួមសាមគ្គីគ្នា ចេះរៀបចំផែនការបានច្បាស់លាស់ហ៊ានពលីជីវិត

ដើម្បីផលប្រយោជន៍រួមចេះតស៊ូរើបំរាស់ពីការជិះជាន់អយុត្តិធម៌ គោរពពាក្យសច្ចៈចេះជ្រើសរើសមេដឹកនាំល្អ ។

សរុបសេក្តីមក រឿងព្រេងប្រជាប្រិយខ្មែរសុទ្ធតែបានផ្តល់នូវការកម្សាន្តនិង បានបង្កប់នូវតម្លៃអប់រំដល់អ្នកអានគ្រប់រូប ដូចជាមានការកំសាន្តបែបកម្សត់ កំហឹង សប្បាយរីករាយ កំប្លុកកំប្លែងជាដើម ហើយតម្លៃអប់រំទៀតសោត មានដូចជាការដោះស្រាយបញ្ហាដោយសន្តិវិធី ស្រឡាញ់ចំណេះវិជ្ជា មានការរើបម្រះពីការជិះជាន់ មានស្មារតីប្រឆាំងតបត ដឹងគុណចំពោះអ្នកមានគុណ ស្គាល់ពីទីតាំងភូមិសាស្ត្រ ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ឱ្យចេះរួបរួមសាមគ្គីគ្នា និងជាពិសេសដឹងពីជីវភាពរស់នៅរបស់ប្រជាជនខ្មែរ។

ឆ្លងតាមការបកស្រាយខាងលើរួចមក យើងឃើញថារឿងព្រេងប្រជាប្រិយខ្មែរពិតមានអត្ថន័យយ៉ាងជ្រាលជ្រៅបង្ហាញដល់មនុស្សទូទៅពីអត្ថប្រយោជន៍នៃរឿងប្រជាប្រិយខ្មែរដែលមានទាំងការកម្សាន្ត និងផ្តល់ទាំងតម្លៃអប់រំល្អៗដល់មនុស្សជំនាន់ក្រោយឱ្យយកជាគំរូនូវចំណុចល្អទាំងនោះ។ ដូចនេះក្នុងនាមជាកូនខ្មែរយើងត្រូវខិតខំប្រឹងប្រែងរៀនសូត្រ ដើម្បីជាជំនួយក្នុងការពង្រឹងចំណេះដឹងឱ្យបានល្អប្រសើរខ្ពង់ខ្ពស់ក្នុងការអភិវឌ្ឍប្រទេសយើងឱ្យបានរីកចម្រើនពិសេស កសាងអក្សរជាតិឱ្យបានគង់វង្ស។

## ប្រធានទី៤

មានទស្សនៈជាច្រើនបានលើកឡើងថា៖ “គ្មានជីវិតណាដែលមានសុភមង្គលហើយគ្មានទុក្ខនោះទេ”។ ចូរពន្យល់ព្រមទាំងលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍បញ្ជាក់។

### គម្រោងតែង

### ១. សេចក្តីផ្តើម

- *លំនាំបញ្ហា៖ មនុស្សគ្រប់រូបសុទ្ធតែកើតមកដោយខ្លួនទទេ គ្មានអ្វីជាប់មកជាមួយនោះឡើយ បើចង់សុខស្រួលនោះ ត្រូវតែខិតខំព្យាយាមគ្រប់បែបយ៉ាងទើបបានសម្រេច និងមានសេចក្តីសុខ។*
- *ចំណូលបញ្ហា៖ អាស្រ័យហេតុនេះហើយទើបមានទស្សនៈជាច្រើនបានលើកឡើងថា៖ “គ្មានជីវិតណាដែលមានសុភមង្គលហើយគ្មានទុក្ខនោះទេ”។*
- *ចំណោទបញ្ហា៖ តើទស្សនៈខាងលើនេះមានអត្ថន័យយ៉ាងដូចម្តេច?*

### ២. តួសេចក្តី

- *ឃ្លាភ្ជាប់សេចក្តី៖ មុននឹងឈានដល់ការបកស្រាយនូវទស្សនៈខាងលើ ឱ្យបានក្បោះក្បាយ យើងគួរគប្បីយល់អត្ថន័យរបស់ពាក្យមួយចំនួនជាមុនសិន។*
- *ពន្យល់ពាក្យគន្លឹះ*

+ សុភមង្គល: សេចក្ដីសុខស្រួល សុខសប្បាយទាំងផ្លូវកាយ និងផ្លូវចិត្ត...។
+ ទុក្ខ : សេចក្ដីលំបាក ទីទ័លក្រ អត្តខាត់ជាដើម...។

- ពន្យល់ន័យប្រធាន៖ ប្រធានខាងលើចង់បង្ហាញឱ្យឃើញថា គ្មានជីវិតនរណាម្នាក់ដែលទទួលបានសេចក្ដីសុខស្រួលសេចក្ដីសុខសប្បាយទាំងផ្លូវកាយ និងចិត្តដោយមិនបានឆ្លងកាត់ នូវការលំបាក ទីទ័លក្រ ឬអត្តខាត់នោះឡើយ។
- បកស្រាយប្រធាន៖ ការរស់នៅរបស់មនុស្សប្រកបដោយសេចក្ដីសុខ សប្បាយនោះ ពួកគេតែងឆ្លងកាត់ហេតុការណ៍ជាច្រើន មិនថាល្អឬអាក្រក់ទេ...

  + សិស្សនិស្សិត : មុននឹងទទួលបាននូវ៖
    - បណ្ណសរសើរ
    - ពានរង្វាន់
    - អាហារូបករណ៍
    - សញ្ញាបត្រ ...

គេត្រូវ៖

- លះបង់ពេលវេលា ឧ. ត្រឹមវិទ្យាល័យរយៈពេល ១៣ឆ្នាំ
- ថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ ឧ. រៀននៅសាកល

- ឃ្លាតឆ្ងាយឪពុកម្ដាយ ញាតិមិត្ត ឧ. មករស់នៅម្នាក់ឯង
- លះបង់កំលាំងកាយកំលាំងចិត្ត... ឧ. មិនបានដេកពួន

\+ គ្រួសារ : រាល់គ្រួសារនីមួយៗទម្រាំតែះ

- មានជម្រកជ្រកកោនត្រឹមត្រូវ
- មានហូបមានចុកគ្រប់គ្រាន់
- បានរស់នៅជួបជុំគ្នា
- មានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់

គេត្រូវះ

- ឆ្លងកាត់ភាពអត់ធ្មត់សង្កត់ចិត្ត
- ការខិតខំប្រឹងប្រែងធ្វើការដោយមិនទំនេរដៃ
- សន្សំសំចៃ
- លះបង់ភាពហ៊ឺហារឡូយឆាយផ្សេងៗជាដើម...។

\+ ក្នុងការងារៈ ទម្រាំបានតួនាទីខ្ពស់ តំណែងសមរម្យះ

- ជាប្រធានផ្នែកអ្វីមួយ
- ជាជំនួយការ
- ជាអ្នកគ្រប់គ្រងក្រុមហ៊ុន
- ជាលេខា...

គេត្រូវះ

- ឆ្លងកាត់ការងារតូចតាច

- មានចិត្តអំណត់
- មានគំនិតច្នៃប្រឌិត
- ខិតខំបង្ហាញសមត្ថភាពរបស់ខ្លួន
- ......................................។

ឧទាហរណ៍ក្នុងអក្សរសិល្ប៍៖

- រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់: មុននឹងសម មានហូបមានចុកគ្រប់គ្រាន់ មានផ្ទះសំបែងរស់នៅពេញមុខពេញមាត់ រហូតដល់បានក្លាយទៅជាកសិករគំរូ សមត្រូវឆ្លងកាត់រឿងជាច្រើនដូចជា
  - រត់គេចពីសង្គ្រាម
  - តស៊ូចំពោះជីវិតរស់នៅ
  - តស៊ូជាមួយនាយទុន ឧ. ម្ចាស់ស៊ីក្លូន ថៅកែហុក
  - តស៊ូជាមួយអ្នកនយោបាយ
  - តស៊ូជាមួយសីលធម៌សង្គម (ត្រូវគេចាប់ដាក់គុក)។
- រឿងកុលាបប៉ៃលិន: មុននឹងចៅចិត្រ មានការងារធ្វើត្រឹមត្រូវ មានទីពឹងពាក់អាស្រ័យ ទទួលបានការសណ្ដោសប្រណីពីលោកហ្លួងរតនៈសម្បត្តិ និងការស្រឡាញ់ពីនាង ឃុន នារី ចៅចិត្រត្រូវឆ្លងកាត់រឿងជាច្រើនដូចជា៖

- ការធ្វើដំណើរផ្សងព្រេងម្នាក់ឯង
- ទទួលការមើលងាយ និងធ្វើបាបពីនាង ឃុន នារី
- ទទួលការប្រមាថពីបាឡាត់ស្រុក
- តស៊ូប្តូរជីវិតជាមួយចោរ
- ខិតខំធ្វើការរស់ពីកំលាំងកាយចិត្ត
- រក្សាភាពកត្តញ្ញូ និងភាពស្មោះត្រង់ជាដើម។

➢ រឿងព្រះវេស្សន្តរ៖ មុននឹងព្រះវេស្សន្តរបានសម្រេចផ្លូវនិពាន្ធ មានការការសាទរពីសំណាក់ពីប្រជានុរាស្ត្រ ទទួលបានការជួយជ្រោមជ្រែងពីព្រះឥន្ទ្រ ព្រះវេស្សន្តរត្រូវឆ្លងកាត់រឿងជាច្រើនដូចជា៖

✓ ការបះបោរពីប្រជារាស្ត្ររបស់ព្រះអង្គ
✓ ព្រះអង្គត្រូវយាងទៅគង់ក្នុងព្រៃ
✓ ព្រះអង្គឆ្លងកាត់នៃការយាងដោយបាទា
✓ ព្រះអង្គជាក្សត្រត្រូវបួសរៀនដោយចិត្តអំណត់
✓ ការធ្វើទានដោយទឹកមុខ ទឹកចិត្តជ្រះថ្លា...

- សរុបមតិ: សរុបមកគ្រប់ជីវិតរស់នៅ គ្រប់ស្រទាប់វណ្ណៈចំបាច់ត្រូវតែតស៊ូក្រាញនឿល ជំនះឧបសគ្គចំពោះមុខដរាបណា

មិនទាន់បានសម្រេច មិនរាថយនោះទើប ទទួលបានសុខសាន្ត ក្នុងជីវិត។

## ៣. សេចក្តីបញ្ចប់

- វាយតម្លៃប្រធានៈ ឆ្លងតាមការបកស្រាយ និងលើកឧទាហរណ៍ យ៉ាងក្បោះក្បាយខាងលើរួចមកយើងអាចសន្និដ្ឋានបានថា ប្រធានខាងលើពិតមានអត្ថន័យ និងមានបំណងអប់រំឱ្យយើង ខិតខំប្រឹងប្រែងធ្វើការ មិនធ្វេសប្រហែស នឹងកុំឱ្យយើងពឹង ផ្អែកលើព្រេងវាសនា។
- ទស្សនៈផ្ទាល់ខ្លួនៈ ដូច្នេះក្នុងនាមយើងជាអ្នកសិក្សារៀនសូត្រ មួយរូប គួរគប្បីប្រឹងប្រែងស្វ័យសិក្សាស្រាវជ្រាវ ឱ្យបានមុតមាំ ទើបទទួលបានជោគជ័យក្នុងការសិក្សា នឹងក្លាយទៅជាធនធាន មួយរូបដែលជួយដឹកនាំគ្រួសារ និងប្រទេសជាតិឱ្យជួបតែសុភម ង្គល។

## សេចក្តីអត្ថាធិប្បាយ

មនុស្សគ្រប់ៗរូបសុទ្ធតែកើតមកដោយខ្លួនទទេ គ្មានមាសប្រាក់ ទ្រព្យធន ឬក៏របស់អ្វីជាប់មកជាមួយនោះឡើយ។ បើចង់បានសេចក្តី ស្រួលនោះ ត្រូវតែខិតខំប្រឹងប្រែងពុះពារព្យាយាមគ្រប់បែបយ៉ាង ទើប បានសម្រេច និងមានសេចក្តីសុខ។ អាស្រ័យហេតុនេះហើយទើបមានទ ស្សនៈជាច្រើនបានលើកឡើងថា៖ «គ្មានជីវិតណាដែលមានសុភមង្គល ហើយគ្មានទុក្ខនោះទេ»។

តើទស្សនៈនេះមានអត្ថន័យយ៉ាងដូចម្តេច?

មុននឹងឈានទៅដល់ការបកស្រាយនូវមតិខាងលើឱ្យបានក្បោះក្បាយ យើងគប្បីយល់អត្ថន័យរបស់ពាក្យមួយចំនួនជាមុនសិន។ ពាក្យ «សុភមង្គល» សំដៅដល់សេចក្ដីសុខស្រួល សុខសប្បាយទាំងផ្លូវកាយ និងផ្លូវចិត្ត។ រីឯពាក្យ «ទុក្ខ» មានន័យថាសេចក្ដីលំបាក ភាពទីទ័លក្រ តោកយ៉ាក អត្តខាត់ជាដើម។ តាមអត្ថន័យរបស់ពាក្យគន្លឹះទាំងពីរប្រធានខាងលើចង់បង្ហាញឱ្យឃើញថា គ្មានជីវិតនរណាមួយដែលបានទទួលសេចក្ដីសុខស្រួល សេចក្ដីសុខសប្បាយទាំងផ្លូវកាយ និងផ្លូវចិត្ត ដោយមិនបានឆ្លងកាត់នូវការលំបាក ភាពទីទ័លក្រ តោកយ៉ាក ឬអត្តខាត់ឡើយ។

ពិតណាស់មនុស្សម្នាក់ៗរមែងឆ្លងកាត់សេចក្ដីទុក្ខមុននឹងសម្រេចបាននូវអ្វីដែលពួកគេប្រាថ្នា។ បើយើងមើលទៅលើការសិក្សាវិញ សិស្សនិស្សិតម្នាក់ៗមុន នឹងបានបណ្ណសរសើរ បានរង្វាន់ បានអាហារូបករណ៍ បានសញ្ញាបត្រមួយៗ ពួកគេត្រូវលះបង់ពេលវេលារាប់ឆ្នាំទៅតាមកម្រិតថ្នាក់ បើគិតត្រឹមវិទ្យាល័យគឺ គេចាយពេលវេលាអស់ដប់បីឆ្នាំ តែបើដល់សាកលវិទ្យាល័យគឺថែមបួន ទៅប្រាំឆ្នាំទៀត ហើយបើលើសពីនោះទៅទៀតគឺរឹតតែយូរទៅទៀត។ បើនិយាយពីថវិកាវិញឃើញថាចំណាយយ៉ាងច្រើនសន្ធឹកសន្ធាប់ ជាពិសេសពេលរៀនដល់ថ្នាក់មហាវិទ្យាល័យនេះតែម្ដង ព្រោះត្រូវការចំណាយទៅលើការបង់សាលា និងទិញឯកសារស្រាវជ្រាវ ផ្សេងៗ។ម្យ៉ាងទៀតត្រូវឃ្លាតឆ្ងាយពីឪពុកម្ដាយ ញាតិមិត្តបងប្អូន មករស់នៅតែម្នាក់ឯងគ្មានអ្នកមើលថែ ត្រូវពុះពារប្រឈមមុខ និងឧបសគ្គដោយខ្លួនឯងជាដើម។ ច្រើនជាងនេះទៅ

ទៀត ត្រូវខិតខំស្រវាស្រទេញលះបង់កំលាំងកាយចិត្ត មិនបានដេកពួន ទាំងយប់ទាំងថ្ងៃ ទម្រាំទទួលបានជោគជ័យ។ ដូចគ្នានោះដែរ នៅក្នុងគ្រួសារមួយទម្រាំតែមានជម្រកជ្រកកោនត្រឹមត្រូវសមរម្យ មានអាហារហូបចុកគ្រប់គ្រាន់បរិបូណ៌មិនខ្វះមុខខ្វះក្រោយ បានរស់នៅជួបជុំគ្នាប្រពន្ធប្តីកូន មានសម្ភារៈប្រើប្រាស់ផ្សេងៗ នោះត្រូវឆ្លងកាត់នូវភាពអត់ធ្មត់សង្កត់ចិត្តព្រោះថាធម្មតាចានក្នុងរាវរមែងតែងប៉ះទង្គិចគ្នា ដូចនេះប្រសិនបើគូស្វាមីភរិយាមិនចេះអត់ឱនឱ្យគ្នាទេ នោះប្រាកដជាបែកបាក់មិនខានឡើយ។ មិនតែប៉ុណ្ណោះគឺត្រូវតែ ខិតខំប្រឹងប្រែងធ្វើការយ៉ាងសកម្មមិនទំនេរដៃទាំងអស់គ្នា និងចេះសន្សំសំចៃឱ្យដល់កម្រិតមិនខ្ជះខ្ជាយផ្តេសផ្តាស ហ៊ានលះបង់ការសប្បាយហ៊ឺហារផ្សេងៗ ជាដើម។ មួយវិញទៀតក្នុងការងារៈ ទម្រាំបានតួនាទីខ្ពស់ តំណែងសមរម្យក្លាយជាប្រធានផ្នែកអ្វីមួយ ជំនួយការ ជាអ្នកគ្រប់គ្រងក្រុមហ៊ុន ជាលេខាមានតួនាទី មានមុខមាត់បានប្រាក់ខែខ្ពស់នោះត្រូវការដុសខាត់ធ្វើការឱ្យមានបទពិសោធន៍ មិនថាការងារការងារតូចតាចនោះទេ។ តម្រូវឱ្យមានចិត្តអំណត់ មានគំនិតច្នៃប្រឌិត ខិតខំបង្ហាញសមត្ថភាពរបស់ខ្លួនយ៉ាងស្ទាត់ជំនាញ ដើម្បីសម្រេចគោលដៅ។ ម្យ៉ាងទៀតបើយើងក្រឡេកមកអក្សរសិល្ប៍វិញតាមរយៈ រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ដែលជាស្នាដៃឯករបស់លោក សួន សុរិន្ទ ឃើញថាមុន នឹងសមមានហូបមានចុកគ្រប់គ្រាន់ មានផ្ទះសំបែងរស់នៅពេញមុខពេញមាត់ រហូតដល់បានក្លាយទៅជាកសិករគំរូ សមត្រូវឆ្លងកាត់រឿងរ៉ាវជូរចត់ជាច្រើន រហូតដល់ឃ្លាតឆ្ងាយពីស្រុកកំណើតដោយសារតែការរត់គេចពីសង្គ្រាម មករសាត់

អវណ្ដែងនៅភ្នំពេញតែម្នាក់ឯង ព្រមទាំងតស៊ូជាមួយនឹងឆាកជីវិតរស់នៅដោយគ្មានទ្រព្យសម្បត្តិអ្វីជាប់នឹងខ្លួនទាល់តែសោះ។ លើសពីនេះទៅទៀតសមបានទទួលការជិះជាន់មើលងាយមើលថោក ពីសំណាក់នាយទុនមួយចំនួនដូចជា ម្ចាស់ស៊ីក្លូ និងថៅកែហុកជាដើម។ មិនតែប៉ុណ្ណោះសមត្រូវប្រឈមមុខជាមួយ និងអ្នកនយោបាយបោកប្រាស់ដែលកេងប្រវ័ញ្ចកំលាំងញើសឈាមកម្មករទាំងសមាគមន៍ នោះគឺ នាយ យ៉េងដែលធ្វើមិនស្គាល់សមព្រមទាំងមើលងាយសមសព្វសារពើ ពេលជាប់ជាដំណាងរាស្ត្រ។ ជាងនេះទៀតសមត្រូវតស៊ូជាមួយ និងសីលធម៌សង្គមដែលឱ្យតម្លៃទៅលើសម្ភារៈលាភសក្ការៈច្រើនជាងភាពត្រឹមត្រូវ ភាពយុត្តិធម៌ គឺនៅពេលដែលនាងសយឈឺពោះសម្រាលកូន តែគ្រូពេទ្យបែរជាមិនជួយដោយសារតែសមគ្មានប្រាក់ ទុកឱ្យនាងស្លាប់យ៉ាងវេទនា។ ហើយសមក៏ត្រូវជាប់គុកម្ដងហើយម្ដងទៀតដោយសារអសីលធម៌សង្គមនេះឯង។ ទទ្ទឹមនឹងនោះក៏មានរឿងមួយទៀត ដែលលើកពីបញ្ហានេះដែរ នោះគឺរឿងកុលាបប៉ៃលិន ដែលជាស្នាដៃរបស់កវីនិពន្ធ ញ៉ុក ថែម បានលាតត្រដាងអំពីជីវិតរបស់ចៅចិត្រជាក្មេងកំព្រា មុននឹងចៅចិត្រមានការងារធ្វើត្រឹមត្រូវ មានទីកន្លែងសម្រាប់ពឹងពាក់អាស្រ័យ និងបានទទួលការសណ្ដោសប្រណីពីលោកហ្លួងរតនៈសម្បត្តិ ឱ្យចូលធ្វើការ និងឱ្យធ្វើជាអ្នកកាន់បញ្ជីទោះបីជាកូនស្រីយល់ថាចៅចិត្រជាមនុស្សយ៉ាងណាក៏ដោយ ហើយម្យ៉ាងទៀត ទម្រាំតែចៅចិត្រយកឈ្នះចិត្ត នាងក្រមុំ ឃុននារី បានរហូតបានក្លាយទៅកូនប្រសារលោក ហ្លួងរស់យ៉ាងសុខុមនោះចៅចិត្រត្រូវឆ្លងកាត់នូវរឿងរ៉ាវជាច្រើនរាប់មិនអស់។ ជាពិសេសពេល

ដែលចៅចិត្រ ត្រូវឃ្លាតចាកពីភូមិកំណើតដំបូងស្របពេលដែលឪពុកទើប នឹងស្លាប់ថ្មីៗ ធ្វើដំណើរផ្សងព្រេងតែម្នាក់ឯង លុះមកដល់ហើយចៅចិត្រ ត្រូវទទួលបាននូវការរើសអើងពីនាង ឃុន នារី ទៀត។ ថែមទាំងត្រូវនាងធ្វើបាបសព្វសារពើ ដូចជាការឱ្យកាន់ឥវ៉ាន់សំពីងសំពងច្រើនជាដើម។ ហើយជាពិសេសគឺបាទឡាត់ស្រុកដែលស្អប់ចៅចិត្រជាទីបំផុត ហើយថែមទាំងប្រមាថចៅចិត្រទៀតផង។ ជាងនេះទៅទៀតចៅចិត្រ តស៊ូប្តូរផ្តាច់ជាមួយ និងក្រុមចោរម្តងហើយម្តងទៀត នាកណ្តាលព្រៃនិងនៅផ្ទះពេលយប់ ដោយសារការពារនាងឃុននារី និងលោកហ្លួង រហូតត្រូវរបួសធ្ងន់ធ្ងរ តែទោះជាយ៉ាងណា ក៏ចៅចិត្រមិនបោះបង់ការព្យាយាមដែរ នៅតែប្រឹងប្រែងបំពេញភារៈកិច្ចខ្លួនឯងរហូត។ មួយវិញទៀតក្នុងរឿង ព្រះវេស្សន្តរ មុននឹងព្រះអង្គសម្រេចត្រាស់ជាព្រះសម្មាសម្ពុទ្ធនៅអនាគតជាតិ ព្រះអង្គឆ្លងកាត់ការធ្វើទាន សន្សំកុសល បួសរៀនភាវនាធម៌គ្រប់ពេលនៃជីវិតរបស់ព្រះអង្គ។ ម្យ៉ាងទៀតព្រះអង្គត្រូវដុសខាត់ចិត្តឱ្យជ្រះថ្លាក្នុងការធ្វើទាន។ ព្រះអង្គបានធ្វើការលះបង់មិនថាជីវិត អង្គកាយរបស់ព្រះអង្គចំពោះព្រាហ្មណ៍ណាដែលចង់បាន។ មិនតែប៉ុណ្ណោះព្រះវេស្សន្តរបានលះបង់គ្រួសារចូលគង់ក្នុងព្រៃស្វែងរកភាពស្ងប់សុខក្នុងភេទជាអ្នកបួស និងបន្តធ្វើទានជានិច្ច។ ពិសេសព្រះអង្គបានធ្វើទានបុត្ររបស់ព្រះអង្គដល់តាជូជកទាំងដែលព្រះអង្គមានព្រះទ័យស្រឡាញ់បុត្រយ៉ាងខ្លាំង។ ចំណុចនេះមិនមែនមនុស្សទាំងអស់អាចធ្វើបានទេ តែព្រះអង្គក៏ព្រោះតែចង់ស្វែងរកសេចក្តីសុខនៃសត្វលោក ទើបព្រះអង្គមានព្រះទ័យអំណត់អត់ធ្មត់ក្នុងការបំពេញរាជកិច្ចមួយនេះ។

សរុបមកគ្រប់ជីវិតរស់នៅ គ្រប់ស្រទាប់វណ្ណៈចាំបាច់ត្រូវតែតស៊ូក្រាញនន់ៀល ជំនះរាល់ឧបសគ្គចំពោះមុខ ដរាបណាមិនទាន់បានសម្រេច មិនរាថយនោះទើប ទទួលបានសុខសាន្តក្នុងជីវិត។

ឆ្លងតាមការបកស្រាយ និងលើកឧទាហរណ៍យ៉ាងស៊ីជម្រៅខាងលើរួចមក យើងអាចសន្និដ្ឋានបានថា ប្រធានខាងលើពិតជាមានអត្ថន័យ និងមានបំណងអប់រំឱ្យយើងខិតខំប្រឹងប្រែងធ្វើការមិនធ្វេសប្រហែស និងកុំឱ្យយើងពឹងផ្អែកលើព្រេងវាសនា។ ដូច្នេះក្នុងនាមយើងជាអ្នកសិក្សាមួយរូប គួរគប្បីប្រឹងប្រែងស្វ័យសិក្សាស្រាវជ្រាវ ឱ្យបានមុតមាំទើបទទួលបានជោគជ័យក្នុងការសិក្សា នឹងក្លាយទៅជាធនធានមនុស្សមួយរូបដែលជួយដឹកនាំគ្រួសារ និងប្រទេសជាតិឱ្យជួបតែសេចក្តីសុខចម្រើន។

## ប្រធានទី៥

មានទស្សនៈមួយបានលើកឡើងថា៖ "ភាពជោគជ័យកើតឡើងពីសេចក្តីព្យាយាម"។ តើទស្សនៈខាងលើនេះមានអត្ថន័យដូចម្តេចខ្លះ? ចូរពន្យល់និងលើកឧទាហរណ៍ក្នុងសង្គម និងស្នាដៃអក្សរសិល្ប៍មកបញ្ជាក់ឱ្យក្បោះក្បាយ។

## គម្រោងតែងសេចក្តី

### I សេចក្តីផ្តើម

-លំនាំបញ្ហា៖ ការរស់នៅរបស់មនុស្សយើងម្នាក់ៗគឺមានលក្ខណៈប្លែកៗ...

-ចំណូលបញ្ហា៖ ស្របតាមទស្សនៈប្រធានខាងលើទើបមានទស្សនៈមួយបានលើកឡើងថា៖ "ភាពជោគជ័យកើតឡើងពីសេចក្តីព្យាយាម"។

-ចំណោទបញ្ហា៖ តើការលើកឡើងរបស់ប្រធានខាងលើនេះមានអត្ថន័យដូចម្តេចខ្លះ?

### II តួសេចក្តី

-ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាជំនួយដល់ការបកស្រាយ............

-ពន្យល់ពាក្យគន្លឹះ៖

- ភាពជោគជ័យគឺសេចក្តីសមប្រកប សុខស្រួល ការមានជ័យជម្នះក្នុងរឿងអ្វីមួយ។
- សេចក្តីព្យាយាមគឺការតស៊ូ ការអត់ធ្មត់ ជំនះការលំបាកក្នុងរឿងអ្វីមួយ។

-ពន្យល់ន័យប្រធាន៖

ការមានសេចក្តីសុខស្រួល សមប្រកប មានជ័យជំនះទៅបានគឺចាំបាច់ត្រូវឆ្លងកាត់នូវសេចក្តីព្យាយាម អត់ធ្មត់ពុះពារគ្រប់ឧបសគ្គទើបបានសម្រេច។

-បកស្រាយប្រធាន៖

ភាពជោគជ័យទាំងឡាយត្រូវបានពើបប្រទះទៅនឹងបញ្ហាលំបាកជាច្រើនដូចជា៖

- ទាំងការរស់នៅ៖ការប្រកបមុខរបរចិញ្ចឹមជីវិតគឺមានភាពលំបាកក្នុងការស្វែងរកប្រាក់ចំណូល ត្រូវមានការប្រកួតប្រជែងការងារដោយទាមទារឲ្យយើងត្រូវមានសេចក្តីអត់ធ្មត់ តស៊ូគ្រប់បញ្ហាដើម្បីឲ្យជីវិតមានក្តីសុខស្រួល សមប្រកប និងមានជ័យជម្នះ។
- ទាំងការសិក្សា៖ មុននឹងបានសញ្ញាបត្រ បណ្ឌសរសើរ ... ខំប្រឹងរៀន។ ក្នុងការសិក្សារៀនសូត្រ ការកំណត់ទិសដៅជីវិត ឆ្លងកាត់ដំណាក់កាលលំបាកជាច្រើនដែលទាមទារឲ្យយើងមានការខិតខំប្រឹងប្រែង តស៊ូ ប្រឹងយកជ័យជម្នះឈានទៅរកការកំណត់ទិសដៅជីវិតឲ្យមានភាពត្រចះត្រចង់ រុងរឿងនាពេលអនាគត។
- ទាំងការកសាងគ្រួសារ៖ ចង់បានគ្រួសារមួយដែលមានសុភមង្គល មានការយោគយល់គ្នា...ព្យាយាមយល់ពីតួ

នាទី ដើម្បីជុសខាត់ខ្លួនឯងឱ្យក្លាយជាមនុស្សម្នាក់ដែល ធ្វើឱ្យគ្រួសាររីករាយ...។

- ទាំងការយកឈ្នះចិត្តខ្លួនឯង៖ ស្គាល់ពីអ្វីដែលខ្លួនឯងមាន អ្វីដែលខ្លួនឯងខ្វះខាត ប្រសិនបើមនុស្សអាចចិត្តខ្លួនឯងឈ្នះ ពិតជាប្រសើរណាស់ ព្រោះចិត្តមនុស្សពិបាកយល់ និង តាមទាន់ណាស់។
- ទាំងការដឹកនាំ...

ឧទាហរណ៍៖

ក្នុងប្រវត្តិសាស្ត្រ៖ ក្រោមការដឹកនាំដោយសម្ដេចសីហនុ

ឧទាហរណ៍ក្នុងសង្គមៈ លោកឧកញ៉ាសុខ គង់បានតស៊ូពីបាតដៃ ទទេជាអ្នកប៉ះកង់...រហូតបានក្លាយជាសេដ្ឋីក្នុងស្រុកខ្មែរ

ឧទាហរណ៍ក្នុងសង្គម លោកឧកញ៉ាម៉ុង ឫទ្ធីបានតស៊ូពីកូនកសិករក្រីក្រម្នាក់ប្រឹងរៀនសូត្រ...បានក្លាយជាបណ្ឌិត អ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ។

ឧទាហរណ៍ក្នុងអក្សរសិល្ប៍

-រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់(សមបានឆ្លងកាត់ភាពលំបាកវេទនាគ្រប់បែបយ៉ាងពុះពារ....រហូតជីវិតទទួលបានភាពល្អប្រសើរជាងមុន)។

-រឿងតេជោយ៉ត(យ៉តជាអ្នកបម្រើស្ដេចតែមានសេចក្ដីក្លាហានព្យាយាម...រហូតបានក្លាយជាមេដឹកនាំល្អម្នាក់)។

-រឿងមាឃើង(ចៅមាណពជាមនុស្សឧស្សាហ៍ព្យាយាម ឈ្មោះត្រង់...បានក្លាយជាមនុស្សមានទ្រព្យសម្បត្តិ ជាមន្ត្រីក្នុងរាជវាំង)។

-រឿងផ្កាស្រពោន(ប៊ុនធឿនជាអ្នកសិក្សាស្រឡាញ់ចំណេះវិជ្ជា ពុះពារការលំបាក....បានប្រឡងជាប់មានការងារល្អធ្វើសម្រាប់ជីវិត)។

-រឿងសូផាត(សូផាតខិតខំរៀនសូត្រ....បានបញ្ចប់ការសិក្សាស្វែងរកការងារល្អ)។

-សរុបសេចក្ដី៖

សរុបសេចក្ដីមកភាពជោគជ័យរបស់មនុស្សម្នាក់ៗក្នុងជីវភាពរស់នៅ ទាំងការសិក្សា ការកំណត់ទិសដៅជីវិត សុទ្ធតែឆ្លងកាត់ការលំបាក ការតស៊ូព្យាយាម ជម្នះពុះពារជាមុនសិនទើបបានសម្រេចនូវភាពជោគជ័យ។

## III សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន៖ មានអត្ថន័យជ្រៅជ្រះពោរពេញទៅដោយការអប់រំ ដាស់តឿនប្រជាជនខ្មែរអ្នកសិក្សាគ្រប់រូបក្នុងការការរស់នៅប្រចាំថ្ងៃនិងការសិក្សាការកំណត់ទិសដៅអនាគតសម្រាប់នាពេលអនាគតចាំបាច់ត្រូវតែមានសេចក្ដីព្យាយាម ពុះពារ គ្រប់ឧបសគ្គ ជម្នះរាល់ការលំបាក កុំឆាប់ចុះចាញ់ ត្រូវតែតស៊ូឲ្យដល់គោលដៅបំណងប្រាថ្នាដែលខ្លួនចង់បាន។

-មតិផ្ទាល់ខ្លួន៖ ដូច្នេះយើងទាំងអស់គ្នា គប្បីត្រូវតែតាំងចិត្តឲ្យបានមុតមាំ ក្នុងការកំណត់ទិសដៅជីវិត និងការរស់នៅប្រចាំថ្ងៃហើយមិនត្រូវឆាប់ចុះចាញ់ពេលជួបនូវឧបសគ្គនោះទេ ត្រូវតែជំនះរាល់ការលំបាក

ព្យាយាម អត់ធ្មត់ ខិតខំប្រឹងប្រែង ក្រេបជញ្ជក់ចំណេះវិជ្ជា ខិតខំធ្វើខ្លួនជាមនុស្សល្អមានប្រយោជន៍ សម្រាប់សង្គម និងគ្រួសារ៕

## សេចក្តីអធិប្បាយ

ការរស់នៅរបស់មនុស្សយើងម្នាក់ៗ គឺមានលក្ខណៈប្លែកៗពីគ្នាតាមដំណើរជីវិតរៀងៗខ្លួន។ជីវិតមនុស្សយើងកើតមកមិនមែនសុទ្ធតែរស់នៅក្នុងភាពសុខស្រួលរហូតនោះទេវាតែងតែជៀសមិនផុតពីការជួបប្រទះនូវបញ្ហា ឬឧបសគ្គ តិចឬច្រើន ទៅតាមស្ថានភាពនៃបុគ្គលនោះ។បើយើងមិនមានសេចក្តីអត់ធ្មត់ ជម្នះរាល់ការលំបាកទាំងអស់នោះទេ យើងប្រាកដជាមិនអាចទទួលបានសេចក្តីសុខ និងជោគជ័យក្នុងជីវិតបានឡើយ។ ហេតុដូច្នេះហើយ ទើបមានទស្សនៈមួយបានលើកឡើងថា៉ភាពជោគជ័យ កើតឡើងពីសេចក្តីព្យាយាម៉។

តើការលើកឡើងរបស់ទស្សនៈនេះមានអត្ថន័យដូចម្តេចខ្លះ?

ដើម្បីជាជំនួយក្នុងការបកស្រាយនូវទស្សនៈខាងលើ យើងត្រូវស្វែងយល់នូវពាក្យគន្លឹះជាមុនសិន។ពាក្យថា៉ភាពជោគជ័យ៉មានន័យថាការទទួលបានជ័យជម្នះ ការសមប្រកប ការមានសេចក្តីសុខស្រួលក្នុងរឿងអ្វីមួយ។ រីឯពាក្យថា៉សេចក្តីព្យាយាម៉មានន័យថាភាពអត់ធ្មត់ ការតស៊ូ ការពុះពារជម្នះគ្រប់ការលំបាកនៅក្នុងរឿងអ្វីមួយ។ដូចនេះអត្ថន័យរបស់ទស្សនៈទាំងមូលបានសេចក្តីថាមុននឹងមានភាពជោគជ័យ សេចក្តីសុខសមប្រកបទៅបាន លុះត្រាតែយើងមានការតស៊ូព្យាយាម អត់ធ្មត់ ពុះពារគ្រប់ឧបសគ្គដែលរារាំងជាមុនសិន។

ដូចដែលយើងបានដឹងហើយថា គ្មានជនណាម្នាក់ដែលកើតមកនៅលើលោកនេះសុទ្ធតែជួបប្រទះតែភាពជោគជ័យ សុខស្រួល សមប្រកប ដោយស្រួលៗនោះឡើយទេ វាតែងតែជួបប្រទះនូវឧបសគ្គ បញ្ហា អ្នកខ្លះជួបតិច អ្នកខ្លះ ជួបច្រើនទៅ។ដូចនៅក្នុងការរស់នៅក្នុងជីវភាពប្រចាំថ្ងៃមានអ្នកខ្លះគាត់កើតមកនៅក្នុងនៅក្នុងគ្រួសារ ដែលមានជីវភាពធូរធារ ខ្ពង់ខ្ពស់ សមប្រកបទៅដោយភាពសុខស្រួល ហើយការលំបាកមានមិនសូវជាច្រើននោះទេ។រីឯចំណែកឯអ្នកខ្លះគាត់កើតមកក្នុងគ្រួសារដែលមានជីវភាពខ្វះខាត ក្រីក្រ លំបាក តោកយ៉ាក វេទនា ខ្វះមុខ ខ្វះក្រោយ ភាពលំបាកគឺមានច្រើនសម្រាប់ជីវិតរាប់មិនអស់។ហើយក្នុងការរស់នៅរបស់មនុស្សយើងម្នាក់ គឺចាំបាច់ត្រូវមានមុខរបរ មានជំនាញវិជ្ជាជីវៈក្នុងជីវិតរៀងៗខ្លួនសម្រាប់រកប្រាក់ចំណូលមកផ្គត់ផ្គង់ចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃ។ ក្នុងនោះការប្រកបមុខរបរចិញ្ចឹមជីវិតមិនមែនអាចរកប្រាក់បានមកដោយងាយស្រួលនោះឡើយ គឺក្នុងមួយថ្ងៃៗយើងត្រូវខិតខំប្រឹងធ្វើយ៉ាងណាឲ្យជីវភាពរបស់ខ្លួនកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ព្រោះក្នុងការប្រកបរបរចិញ្ចឹមជីវិតគឺមានការប្រកួតប្រជែងច្រើន ហើយទាមទារឲ្យយើងបូជាកម្លាំងកាយចិត្ត ហូរញើស ហូរឈាមធ្វើយ៉ាងណាដើម្បីរកប្រាក់មកទ្រទ្រង់ជីវិត និងធ្វើឲ្យសេដ្ឋកិច្ចគ្រួសារមានការរីកចម្រើនប្រសើរឡើង។ហើយក្នុងការធ្វើកិច្ចការទាំងអស់នោះបើយើងមិនមានឆន្ទៈមោះមុត តស៊ូ អត់ធ្មត់ ព្យាយាមគ្រប់ឧបសគ្គ ហើយឆាប់ចុះចាញ់ ដកខ្លួន មិនអាចស៊ូទ្រាំនឹងភាពភាពលំបាកទាំងអស់នោះទេជីវិតរបស់យើងប្រាកដជាមិនមានភាពរីកចម្រើន ស្គាល់

ភាពត្រចះត្រចង់ មានក្តីសុខបានឡើយយើងប្រកដជាជួបតែភាពលំបាកនៅក្នុងជីវិត។ ក៏ដូចជាការសិក្សាដែរ ប្រសិនបើយើងមិនមានការព្យាយាមសិក្សារៀនសូត្រពីកម្រិតមតេយ្យ រហូតដល់សកលវិទ្យាល័យ សួរថាយើងអាចទទួលបានសញ្ញាបត្របុទេ? ចំណុចទាំងនោះតម្រូវឱ្យសិស្សានុសិស្សទាំងអស់ខំប្រឹងរៀនទាំងផ្នែកអក្សរ លេខនព្វន្ត បូក ដក គុណ ចែក ភាសាជាតិ និងអន្តរជាតិ។ ម៉្យាងទៀតតម្រូវឱ្យដុសខាត់ សិក្សាស្រាវជ្រាវបន្ថែម អនុវត្តលំហាត់ ឬកិច្ចការដែលទាក់ទងទៅនឹងការសិក្សារបស់សិស្សបន្ថែមទៀត ទើបគេមានចំណេះដឹងអាចប្រឡងជាប់បាន។ ជាមួយគ្នានោះដែរបើអ្នកសិក្សាម្នាក់ៗមិនបានធ្វើការលុតដំដុសខាត់នូវសមត្ថភាពពីដើមដំបូងនោះទេ ពួកគេប្រាកដជាមានភាពស្តាយក្រោយព្រោះពួកគេគ្មានចំណេះវិជ្ជាគ្រប់គ្រាន់ ហើយគ្មានសមត្ថភាពអាចស្វែងរកការងារ រធ្វើសម្រាប់កសាងអនាគតដោយខ្លួនឯងនោះទេ។ហេតុនេះតម្រូវឲ្យពួកគេគប្បីត្រូវតែខិតខំហ្វឹកហាត់ ឧស្សាហ៍ព្យាយាមតស៊ូលុះត្រាតែដល់គោលដៅដែលយើងចង់បាន នោះជីវិតរបស់យើងប្រកដជាទទួលបាននូវភាពល្អប្រសើររុងរឿងខ្ពង់ខ្ពស់នាពេលអនាគត។ ហើយនៅក្នុងប្រវត្តសាស្ត្របើនិយាយពីការបំពេញកិច្ចការវិញ នៅក្នុងរជ្ជកាលព្រះបាទសម្តេច សីហនុព្រះអង្គទាមទារឯករាជពីបារាំងវិញរហូតទទួលបានជោគជ័យដោយសារព...។ **តួរយ៉ាងលោកសុខ គង់** កាលដើមឡើយលោកគឺជាអ្នកប៉ះកង់កម្សត់កម្រម្នាក់ គាត់មានប្រាក់តែប្រាំដីសម្រាប់រកស៊ីចិញ្ចឹមជីវិតតស៊ូ ពីមួយថ្ងៃទៅមួយថ្ងៃហើយបន្តបើកជាកន្លែងលក់សាំងពីខ្នាតតូចឈានដល់ ខ្នាតធំរហូតបានក្លាយជាអ្នកមានទ្រព្យសម្បត្តិច្រើនម្នាក់

នៅក្នុងស្រុកខ្មែរ។ បើក្រឡេកមើលការសិក្សានៅក្នុងសង្គមខ្មែរយើង ឃើញហើយថា លោកឧកញ៉ាៗ មហាសេដ្ឋី អ្នកដឹកនាំ មួយចំនួនតួរយ៉ាង**លោកឧកញ៉ាម៉ុង ឫទ្ធី** គាត់បានឆ្លងកាត់នូវភាពលំបាក ភាពក្រខ្សត់ ដែលមិនមានទ្រព្យសម្បត្តិច្រើនឡើយគឺគាត់បានខិតខំតស៊ូ ព្យាយាមមិនបោះបង់ចោលការសិក្សានោះទេគាត់បានបន្តការសិក្សាផងប្រឹងធ្វើការងារផងលុះត្រា បានចប់ចុងចប់ដើមហើយបានយកចំណេះវិជ្ជា ដែលគាត់មានទៅប្រើការដើម្បីស្វែងរកការងារធ្វើសម្រាប់ចិញ្ចឹមជីវិត ដែលមានប្រាក់ចំណូលពីមួយថ្ងៃទៅមួយថ្ងៃ ច្រើនឡើងៗ ដោយសារគាត់ជាមនុស្សដែលមាន ចំណេះវិជ្ជាមានប្រាជ្ញាឈ្លាសវៃ អាចធ្វើជាជំនួញ រកស៊ីផងមានបានជាបន្តបន្ទាប់ដែលធ្វើឲ្យ ជីវិតរបស់គាត់បានកែប្រែរីកចម្រើនមានមាសប្រាក់ចាយវាយគ្រប់គ្រាន់មានកេរ្តិ៍ឈ្មោះល្បាញល្បីក្នុងសង្គមព្រោះតែការតស៊ូ ប្រឹងប្រែង ព្យាយាម ប្រឹងប្រែងរបស់គាត់។ រីឯនៅក្នុងស្នាដៃអក្សរសិល្ប៍វិញរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ តួរអង្គសមកើតក្នុងត្រកូលកសិករកម្សត់ម្នាក់ដែលមានជីវិតដ៏សែនកម្សត់វេទនា គ្មានការងារល្អធ្វើជាប់លាប់ គ្មានប្រាក់ចំណូលគ្រប់គ្រាន់ គ្មានជម្រកពិតប្រាកដជាបន្តបន្ទាប់ ប៉ុន្តែគាត់មិនអស់សង្ឃឹមឡើយគឺគាត់ បានពុះពារ ហែលឆ្លងការលំបាករាប់មិនអស់គ្រប់ឧបសគ្គពីមួយថ្ងៃទៅមួយថ្ងៃ ដោយខិតខំស្វះស្វែងរកប្រាក់ រកការងារធ្វើ ដើម្បីបានអាហារចិញ្ចឹមជីវិត មានជម្រកជ្រកកោនដើម្បីមានជីវិតរស់នៅបន្តទៅមុខទៀតព្រោះ គាត់គិតថាជីវិតគឺមានតម្លៃណាស់មិនអាចចុះចាញ់ដោយងាយៗឡើយដោយសមបានបន្តជីវិតជាកម្មករធាក់ស៊ីក្លូផង ជាកម្មកររោងចក្រផង ដោយទ្រាំ

ទ្រនឹងភាពលំបាកអត់ឃ្លាន ជម្នះរាល់ភាពនឿយហត់រហូតត្រាតែបាន ទទួលជីវិតមួយថ្មីគឺ បានក្លាយជាកសិករគំរូម្នាក់ដែលមានមានជីវភាពធូរ ធារប្រសើរជាងមុន។ជាមួយគ្នានោះនៅក្នុងរឿងមាយើង ចៅមាណព កាលដើមឡើយជាមនុស្សក្រីក្រ សាមញ្ញម្នាក់ ប៉ុន្តែគាត់ជាមនុស្សដែល ឧស្សាហ៍និងព្យាយាមក្នុងការងារមិនខ្ជិល ច្រអូសឡើយ ហើយការ ព្យាយាមរបស់គាត់បានធ្វើឲ្យគាត់រីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ គឺផង គាត់ចាប់ផ្តើមមានទ្រព្យសម្បត្តិច្រើនឡើងៗ និងរហូតបានក្លាយជាមន្ត្រី នៅក្នុងរាជវាំងថែមទៀត។ រីឯនៅក្នុងស្នាដៃអក្សរសិល្ប៍វិញរឿងផ្កា ស្រពោន ប៊ុនធឿនជាកូនឈ្មួញជួញដូរម្នាក់បានទៅបន្តការសិក្សានៅទី ក្រុងដែលគ្មានលុយកាក់សម្ភារគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់ក្នុងការសិក្សា ឡើយ។ តែទោះជាយ៉ាងណាក៏ប៊ុនធឿនបានខិតខំជំនះរាល់ឧបសគ្គដែល លំបាក ខិតខំប្រឹងរៀនសូត្រឲ្យបានដល់ទីបញ្ចប់ ហើយទទួលបានចំណេះ វិជ្ជាសម្រាប់កសាងជីវិតនាពេលអនាគត។ ជាមួយគ្នានោះនៅក្នុងរឿង សូផាត សូផាតជាក្មេងដែលត្រូវឪពុកបោះបង់ហើយម្តាយស្លាប់ចោល ទៀត ហើយបានទៅរស់នៅ ឯទីក្រុងរស់នៅជាក្មេងវត្តបានក្រេបយក ចំណេះវិជ្ជា នៅក្នុងវត្តនិងនៅសាលាទំនើបប៉ុន្តែដោយសារតែ សេចក្តី ព្យាយាមរបស់គាត់សូផាតបានទទួលចំណេះវិជ្ជាដែលគាត់ទទួលបាន ដើម្បីកសាងជីវិតរបស់គាត់ និងគ្រួសារបានល្អប្រសើរជាងមុនដោយ សប្បាយរីករាយ។ បន្ថែមលើនោះនៅក្នុងរឿងតេជោយ៉ត តួអង្គយ៉តមុន ដំបូងឡើយ គឺជាអ្នកបម្រើស្តេចម្នាក់ គ្មានអំណាច បុណ្យសក្តិត្រូវបានគេ ប្រើឲ្យធ្វើការងារ តាមតែបញ្ជាប៉ុន្តែយ៉តជាមនុស្សដែលតស៊ូ មានប្រាជ្ញា

ឈ្លាសវៃ ក្លាហាន ព្យាយាមធ្វើការបម្រើស្តេចដោយយកចិត្តទុកដាក់ធ្វើឲ្យគេស្រឡាញ់និងគោរពហើយបានក្លាយជា មេដឹកនាំដ៏ល្អម្នាក់ថែមទៀតផង។ជាមួយគ្នានេះដែរនៅក្នុងការសិក្សារៀនសូត្ររបស់ សិស្សានុសិស្សម្នាក់ៗវិញមុននឹងបានក្លាយទៅជាអ្នកដែលមានចំណេះដឹងម្នាក់ គឺមិនងាយបាននោះឡើយ គឺទាមទារឲ្យយើងខិតខំហ្វឹកហាត់ ប្រឹងប្រែងត្រងត្រាប់ក្រេបយកនូវចំណេះវិជ្ជាដោយយកមានចិត្តទុកដាក់ សិក្សាស្វែងយល់រុករកស្រាវជ្រាវជានិច្ច ជាពិសេសនៅពេលដែលយើងជួបប្រទះជាមួយបញ្ហាត្រូវហ៊ានប្រឈមមុខ តតាំង មិនចុះញម ធ្វើការតស៊ូលត់ដំ ដុសខាត់សមត្ថភាពបន្តិចម្តងៗ ដោយមិនខ្ជិលច្រអូស ត្រូវប្តេជ្ញាថានឹងយកឈ្នះនូវរាល់ការលំបាកទាំងអស់នោះឲ្យបាន។ ពេលនោះក្តីប្រាថ្នានៃអនាគតរបស់យើងប្រាកដជាទទួលបានភាពត្រចះត្រចង់ រុងរឿងព្រោះយើងមានសមត្ថភាពពេញលេញ មានចំណេះវិជ្ជាក្នុងខ្លួន អាចស្វែងរកការងារធ្វើប្រចាំថ្ងៃជីវិតដោយមានមុខរបរច្បាស់លាស់ សម្រាប់ចិញ្ចឹមជីវិតរស់នៅប្រចាំរបស់យើងនាពេលអនាគត។

សរុបសេចក្តីមកជីវិតរបស់មនុស្សយើងម្នាក់ៗគឺមិនមែនសុទ្ធតែមានភាពជោគជ័យសុខស្រួលរហូតនោះទេទាំងក្នុងជីវភាពរស់នៅទាំងក្នុងការសិក្សារៀនសូត្រ ការសម្រេចទិសដៅអនាគតជីវិតក្តីគឺចាំបាច់ឲ្យយើងត្រូវតែមានការតាំងចិត្ត មានឆន្ទះមោះមុត ខិតខំប្រឹងប្រែង ពុះពាររាល់ការលំបាក មានភាពព្យាយាម ឧស្សាហ៍ តស៊ូ ទ្រាំទ្រនឹងភាពលំបាកឲ្យដល់គោលដៅដល់ទីបញ្ចប់នោះក្តីបំណងប្រាថ្នាប្រាកដជាសម្រេចមិនខានឡើយ។

ឆ្លងតាមការបកស្រាយរបស់ទស្សនៈខាងលើគឺពិតជាបង្កប់នូវអត្ថន័យជ្រាលជ្រៅដែលបង្កប់ទៅដោយនូវការដាស់តឿន ក្រើនរំឭកប្រជាជនខ្មែរ អ្នកសិក្សាគ្រប់រូបឲ្យមានស្មារតី ឆន្ទៈ ចេះអត់ធ្មត់ កុំឆាប់ចុះចាញ់នៅពេលជួបប្រទះបញ្ហា ឧបសគ្គ នានាតស៊ូឲ្យដល់ទីបញ្ចប់ទើបអាចសម្រេចនូវក្ដីប្រាថ្នាមានអនាគតល្អប្រសើរសម្រាប់ជីវិត។ដូច្នេះយើងទាំងអស់ត្រូវតែខិតខំកសាងអនាគតរបស់ខ្លួនកុំបណ្ដែតបណ្ដោយឲ្យពេលវេលាកន្លងផុតគ្មានប្រយោជន៍នាំឲ្យមានភាពស្ដាយក្រោយ គឺយើងត្រូវប្ដេជ្ញាចិត្ត តស៊ូ ប្រឹងប្រែង ហ្វឹកហាត់ដុះខាត់សមត្ថភាពរបស់ខ្លួនឲ្យទទួលបានភាពរីកចម្រើនហើយមានសមត្ថភាព ពិតប្រាកដដើម្បីក្លាយជាធនធានមនុស្សដ៏មានប្រយោជន៍សម្រាប់ចូលរួមចំណែក អភិវឌ្ឍប្រទេសជាតិនិង ក្រុមគ្រួសារឲ្យមានការរីកចម្រើនជានិរន្តរ៍៕

# ប្រធានទី៦

ទស្សនៈមួយបានលើកឡើងថា៖ "អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងពីសង្គម"។ តើទស្សនៈខាង លើនេះមានអត្ថន័យយ៉ាងណាខ្លះ? ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍មក បញ្ជាក់។

## គម្រោងតែងសេចក្តី

### I. សេចក្តីផ្តើម

-លំនាំបញ្ហា៖ សរសេរទាក់នឹងសង្គម ឬអក្សរសិល្ប៍ដែលឆ្លុះបញ្ចាំងពីសង្គម និងអក្សរសិល្ប៍។

-ចំណូលបញ្ហា៖ អាស្រ័យហេតុនេះហើយទើបមានទស្សនៈមួយលើកឡើងថា "អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងពីសង្គម"

-ចំណោទបញ្ហា៖ តើទស្សនៈខាង លើនេះមានអត្ថន័យយ៉ាងណាខ្លះ?

### II. តួសេចក្តី

-ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាជំនួយក្នុងការបកស្រាយនូវប្រធានខាងលើ យើងគប្បីយល់ន័យរបស់។

- ពន្យល់ពាក្យគន្លឹះ៖

+ អក្សរសិល្ប៍

-ជាកម្រងអត្ថបទដែលលើកយកបញ្ហានៃមនុស្សក្នុងសង្គមមកចោទ និងដោះស្រាយ ទៅតាមសិល្បវិធី និងទៅ

តាមបរិយាកាសនៃសង្គមនីមួយៗ និងមានការវិវត្តទៅតាមសង្គមកាលនីមួយៗ។

+ សង្គម: ការជួបជុំគ្នា ការប្រជុំគ្នា ការប្រមូលរួបរួមក្រុមមនុស្សជាច្រើន ដែលជាជនជាតិ មានសាច់ឈាម ពណ៌សម្បុរ វប្បធម៌ប្រពៃណី អត្តសញ្ញាណតែមួយ ជារដ្ឋ ឬ ប្រទេសមួយ។

- ពន្យល់ន័យប្រធាន៖ គ្រប់បញ្ហាទាំងឡាយរបស់សង្គមណាមួយ ទោះបីជា បញ្ហាល្អក្តី អាក្រក់ក្តី តែងតែត្រូវបានអ្នកនិពន្ធលើកយកមកបញ្ចូលទៅក្នុងស្នាដៃ អក្សរសិល្ប៍របស់ខ្លួន ដើម្បីឆ្លុះបញ្ចាំងពីការពិតនៃសង្គម។

-បកស្រាយប្រធាន៖ អក្សរសិល្ប៍ តែងផ្សារភ្ជាប់ទៅនឹងតថភាពជាក់ស្តែងនៃសង្គមមនុស្ស កម្មវត្ថុរបស់អក្សរសិល្ប៍គឺសិក្សាពីបញ្ហានៃមនុស្ស ទោះជាអក្សរសិល្ប៍ខ្លះតួអង្គមិនមែនជាមនុស្ស ក៏អ្នកនិពន្ធបង្កប់អត្ថន័យខ្លឹមសារឆ្លុះបញ្ចាំងពីសង្គមមនុស្សដែរ ដូចជា៖

- ឆ្លុះបញ្ចាំងពីរបបនយោបាយ ការដឹកនាំ ការគ្រប់គ្រងប្រទេស រាជានិយម ផ្តាច់ការរបបអាណានិគម បញ្ហាជីវភាពរស់នៅ ឆ្លុះបញ្ចាំងពីបញ្ហានៅក្នុងសង្គមតាមសម័យ កាលនីមួយៗជាដើម។
- ឆ្លុះបញ្ចាំងពីផ្នែកវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់នៃជាតិសាសន៍ក្នុងសម័យកាលណាមួយ។

ឧ. រឿងទុំទាវ (ស្នេហាយុវវ័យ ស្ដេចត្រាញ់ ព្រះមហាក្សត្រជារបបសក្តិភូមិផ្ដាច់ការ)

ឧ. រឿងភូមិតិរច្ឆាន (ការតស៊ូប្រឆាំងនឹងអាណានិគមបារាំង)

ឧ. រឿងរាមកេ្តរ៍(ជំនឿ ផ្នត់គំនត់ និងទំនៀមទម្លាប់ជាច្រើន)

ឧ.អត្ថបទកំណាព្យ "មើលផែនដីខ្មែរ" របស់លោក ជួន ម៉េន (ឆ្លុះបញ្ចាំងបញ្ហាសង្គម នៅសម័យកម្ពុជាប្រជាធិបតេយ្យ)

សរុបសេចក្ដីមកអក្សរសិល្ប៍ទាំងអស់សុទ្ធតែបាន លើកយកបញ្ហារបស់សង្គម តាមសម័យកាលនីមួយៗមកបង្ហាញ ដល់អ្នកសិក្សា អ្នកអានទាំងឡាយឱ្យបានយល់ដឹង តថភាពពិតនៃសង្គមកាលនីមួយៗ។

## III. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន៖ មានអត្ថន័យល្អជ្រាលជ្រៅ ដោយបង្ហាញពីតម្លៃនៃអក្សរ សិល្ប៍ ក៏ដូចជារំឭកដល់អ្នកនិពន្ធទាំងឡាយឱ្យមានការគិតគូរច្បាស់លាស់ មុននឹង សម្រេចនិពន្ធអត្ថបទរបស់ខ្លួនសម្រាប់សាធារណជន។
- មតិផ្ទាល់ខ្លួន៖ ដូច្នេះហើយអក្សរសិល្ប៍ មានតួនាទីសំខាន់ណាស់សម្រាប់ឱ្យយើងសិក្សាអំពីបញ្ហាពិត របស់សង្គមនីមួយៗ ហេតុនេះយើងគួរអំពីអក្សរសិល្ប៍ឱ្យបានច្រើន។

# សេចក្តីអធិប្បាយ

អក្សរសិល្ប៍ជាប្រភពនៃបញ្ហាសង្គម ព្រោះអក្សរសិល្ប៍បានផ្តល់ឱ្យនូវចំណេះដឹងដល់អ្នកសិក្សាអំពីបញ្ហាទាំងឡាយនៃសង្គមដូចជា ប្រវត្តិសាស្ត្រ ប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា តាមសម័យកាលនីមួយៗ ហេតុនេះហើយទើបមាន ទស្សនៈមួយបានលើកឡើងថា "អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងពីសង្គម" ។

តើទស្សនៈខាង លើនេះមានអត្ថន័យយ៉ាងណាខ្លះ?

ដើម្បីជាជំនួយក្នុងការបកស្រាយនូវទស្សនៈខាងលើឱ្យបានស៊ីជម្រៅ និងក្បោះក្បាយ យើងគប្បីយល់នូវអត្ថន័យរបស់គន្លឹះជាមុនសិន។ ពាក្យថា "អក្សរសិល្ប៍" គឺជាកម្រងអត្ថបទដែលលើកយកបញ្ហាមនុស្សក្នុងសង្គមមកចោទ និងដោះស្រាយទៅតាមសិល្បវិធី និងទៅតាមបរិយាកាសនៃសង្គមនីមួយៗ ហើយអក្សរសិល្ប៍មានការវិវត្តទៅតាមសង្គមកាលនីមួយៗ។ ឯពាក្យថា "សង្គម" គឺការជួបជុំគ្នា ការប្រជុំគ្នា ការប្រមូលរួបរួមក្រុមមនុស្សជាច្រើន ដែលជាជនជាតិ មានសាច់ឈាមពណ៌សម្បុរ វប្បធម៌ប្រពៃណី អត្តសញ្ញាណតែមួយ ជារដ្ឋឬប្រទេសមួ-យ។ ដូច្នេះប្រធានខាងលើមានន័យថា គ្រប់បញ្ហាទាំងឡាយរបស់សង្គមណាមួយ ទោះបីជា បញ្ហាល្អក្តី អាក្រក់ក្តី តែងតែត្រូវបានអ្នកនិពន្ធលើកយកមកបញ្ចូលទៅក្នុងស្នាដៃ អក្សរសិល្ប៍របស់ខ្លួន ដើម្បីឆ្លុះបញ្ចាំងពីការពិតនៃសង្គម។

ជាការពិតណាស់ ប្រធានបទរបស់អ្នកនិពន្ធអក្សរសិល្ប៍ទាំងអស់មិនអាចទៅណាឱ្យ ឆ្ងាយ អំពីបញ្ហារបស់មនុស្សដែលកើតមានឡើងនៅ

ក្នុងសង្គមនីមួយៗបានទេ។ អក្សរសិល្ប៍តែងផ្សារភ្ជាប់ទៅនឹងតថភាពជាក់ស្តែងនៃសង្គមមនុស្ស ព្រោះកម្មវត្ថុរបស់អក្សរសិល្ប៍ គឺសិក្សាពីបញ្ហានៃមនុស្ស ទោះជាអក្សរសិល្ប៍ខ្លះតួរអង្គមិនមែនជាមនុស្ស ក៏អ្នកនិពន្ធបង្កប់អត្ថន័យខ្លឹម សារឆ្លុះបញ្ចាំងពីសង្គមមនុស្សដែរ។ តថភាពទាំងឡាយ ដែលអក្សរសិល្ប៍បានឆ្លុះបញ្ចាំងពី បញ្ហាសង្គមមានដូចជាប្រវត្តិសាស្ត្រ ភូមិសាស្ត្រ របបគ្រប់គ្រង ប្រពៃណីទំនៀមទម្លាប់ ជំនឿសាសនា ធម្មជាតិព្រៃព្រឹក្សា រូបសម្រស់ ពណ៌សម្បុរ ការស្លៀកពាក់ជាដើម។ ជាក់ស្តែងនៅ ក្នុងរឿងទុំទាវ របស់ភិក្ខុសោម គឺបានរៀបរាប់យ៉ាងច្រើន អំពីបញ្ហាសង្គមនាសម័យកាល លង្វែក រឿងនេះបានលាតត្រដាងអំពីការតស៊ូរបស់យុវវ័យក្នុងសម័យកាលនោះ រើបម្រះ ប្រឆាំងនឹងទស្សនៈប្រពៃណី "នំមិនធំជាងនាឡិ" ដើម្បីទាមទារសិទ្ធិសេរីភាពក្នុងជ្រើសរើសគូ ស្រករតាមការពេញចិត្តរបស់គេរៀងៗខ្លួន។ ទុំទាវស្រឡាញ់គ្នាប្តូរផ្តាច់ បានស្បថសច្ចានឹងគ្នា ថា "ទាវស្រួលទទួលព្រមចូលចិត្ត ទុំសោតស្នេហ៍ស្និទ្ធថើបភ័ក្ត្រា ទាំងពីរហ៊ានស្បថប្រាកដថា ខ្ទាក់ស្លាប្តូរគ្នារួចទាវឆ្លើយ។ អ្នកថ្លៃប្អូនអើយក្រែងអ្នកបង បានរួមស្នេហ៍ស្នងនៅក្បៀកកើយចេញចាកចោលប្អូនទេដឹងអើយ អ្នកអើយអាសូរចិត្តប្អូនវ៉ា។ ទុំថើបល្បួងលោមថ្លៃនួនល្អង ថាឱ មាសបងដួងជីវ៉ា បងមិនដោះដៃចោលកនិដ្ឋា បងផ្ញើអាត្មារស់ជីពជន្ម"។ នេះគឺជាការស្មោះ ស្ម័គ្រ ហ៊ានលះបង់របស់យុវវ័យនាសម័យកាលនោះ។ ក្នុងរឿងទុំទាវនេះដដែល យើងឃើញ ថា កូនស្រីមិនមានសិទ្ធក្នុងការជ្រើសរើសគូស្រករទេ គឺស្រេចតែលើម្តាយឪពុកជាអ្នកទុកដាក់ ដូចជាសម្តីម្តាយទាវបាននិយាយថា "មិនដែលសោះ

ឡើយទាវអើយនំ ច្រឡើសបើសធំម្តេច ជាងនាឡិ។ និយាយពីរបប គ្រប់គ្រងនាសម័យកាលនោះវិញ ជារបបផ្តាច់ការ គ្រប់គ្រងដោយ ព្រះរាជា និងស្តេចត្រាញ់ ដូចជាឃ្លាមួយបានពោលថា "ឧកញ៉ាអរជូនមួនមាំ ពេក ធម្មតាក្រោមមេឃទាបជាងភ្នំ មានឫទ្ធិអំណាចឥតជំនុំ កាប់ចាក់វាយដំពុំប្រណី"។ និងបញ្ជាក់ពីប្រពៃណី ចូលម្លប់ជាដើម។ ម៉្យាងទៀត នៅក្នុងរឿង រាមកេរ្តិ៍ អ្នកនិពន្ធបានឆ្លុះបញ្ចាំងឱ្យឃើញពីផ្នែកជំនឿ ទំនៀមទម្លាប់ និងផ្នត់គំនិត នៅពេលដែលព្រះនាងសីតាត្រូវបានក្រុងរាពណ៍ចាប់យកទៅទីក្រុងលង្កា ព្រះរាមបានស្វែងរកព្រះនាង។ មិនយូរប៉ុន្មានព្រះរាមបានទទួលដំណឹងពីសត្វកុកមកក្រាបទូលថាក្រុងរាពណ៍ឆក់ព្រះនាងទៅបាត់ហើយ។ ដំណឹងនេះពិតជាធ្វើឱ្យព្រះរាមខ្ញាល់រហូតចង់សម្លាប់កុក ប៉ុន្តែបានព្រះលក្ខណ៍ឃាត់ទើបព្រះរាមមិនសម្លាប់សត្វកុក។ ត្រង់ចំណុចនេះចង់បង្ហាញថា សត្វកុកជាសត្វចង្រៃ ប្រសិនបើវាហោះហើរ ឬស្រែកប្រាប់ពីអ្វី រឿងនោះជាការពិត ទើបដូនតាយើងគិតសត្វនេះអពមង្គលណាស់ ក។នៅជិត ឬចិញ្ចឹមវា។ មិនតែប៉ុណ្ណោះក្នុងផ្ទៃរឿងក៏បានបង្ហាញពីទំនៀមទម្លាប់នៅមុនពេលដល់រដូវធ្វើស្រែចម្ការ តម្រូវឱ្យព្រះរាជាគ្រងពិធីច្រត់ព្រះនង្គ័ល ជាការបើកបង្ហាញឱ្យប្រជារាស្ត្រប្រកបរបរធ្វើស្រែចម្ការ ឬដល់រដូវធ្វើស្រែចម្ការ ដែលនៅក្នុងរឿងព្រះបាទជនកបានធ្វើពិធីច្រត់ព្រះនង្គ័លនៅក្បែរទន្លេ ដើម្បីបង្ហាញ ក៏ដូចជាសម្តោធឱ្យប្រជារាស្ត្រព្រះអង្គប្រតិបត្តិតាមជាដើម។ មួយវិញទៀត នៅក្នុងរឿងភូមិតិរច្ឆាន គឺអ្នកនិពន្ធបានឆ្លុះបញ្ចាំងអំពីបញ្ហា សង្គម នៅពេលដែលបារាំងបានធ្វើជាអាណាព្យាបាលត្រួតត្រាលើខ្មែរ បញ្ហាដែល

ចោទជាបញ្ហា លំបាកដល់ប្រជាជនខ្មែរនាសម័យកាលនោះ គឺការយកពន្ធអាករគ្រប់ប្រភេទ និងច្រើនលើស លប់ពីពួកបារាំង ដែលតម្រូវឱ្យប្រជាជនខ្មែរគ្រប់រូបត្រូវតែបង់ពន្ធឱ្យវា។ ទើបធ្វើឱ្យប្រជាជន ខ្មែរនាសម័យកាលនោះ ក្រោកឡើងតស៊ូប្រឆាំងនឹងពួកបារាំងយ៉ាងខ្លាំងក្លា រហូតដល់សម្លាប់ រេស៊ីដង់បារដេស បារាំងខឹងខ្លាំងក៏ដូរឈ្មោះភូមិក្រាំងលាវ ទៅជាភូមិតិរច្ឆានវិញ។ តួអង្គជួន និង នៅ បានដើរបញ្ចុះបញ្ចូលយុវជនតាមភូមិឱ្យរួមគ្នាសម្លាប់បារាំងជាមួយខ្លួនថា "បងប្អូន ទាំងអស់គ្នា ! ខាងខ្ញុំទាំងពីរនាក់ គឺជួន និងនៅ ស្រុះចិត្តគ្នាជាស្រេចថា សម្លាប់បារាំងកំណាច ឈ្មោះបារដេសនេះឱ្យបាន បើសម្លាប់មិនបានទេ យើងខ្ញុំមិនខ្វីឱ្យគេហៅ ឈ្មោះខ្ញុំថា ជួន អ្នក ជើងឯកព្រៃខ្មែរជាដាច់ខាត!ស្តាប់បានទេបងប្អូន"។ ងាកទៅមើលរឿងកុលាបប៉ៃលិន របស់អ្នក និព្ន ញ៉ុក ថែម ឯណោះវិញ គឺអ្នកនិពន្ធបានឆ្លុះបញ្ចាំងអំពីជីវិតតស៊ូរបស់យុវជន ដើម្បីស្វែងរក ឧត្តមភាពសម្រាប់ជីវិតរបស់ខ្លួន។ តួអង្គចៅ ចិត្ត ជាកូនកំព្រាឪពុកស្លាប់ចោល រស់នៅម្នាក់ឯង ប៉ុន្តែចៅ ចិត្ត មានចិត្តអំណត់តស៊ូមិនរុញរា មិនខ្លាចនឿយហត់ តាំងចិត្តថាជាកូនប្រុសដូចគេ ឯង គេធ្វើអ្វីបាន យើងក៏អាចធ្វើបានដែរ។ ពេលជួបសន្ទនាជាមួយលោកហ្លួងរតនៈសម្បត្តិ ចៅចិត្ត បាននិយាយប្រាប់លោកហ្លួងរតនៈសម្បត្តិថា "មនុស្សដទៃទៀត គេទ្រាំធ្វើបានយ៉ាងណា ឯ ខ្ញុំបាទគង់តែធ្វើបានដូចជាគេដែរ សូមព្រះតេជព្រះគុណកុំព្រួយឱ្យសោះ ! "ចៅ ចិត្ត ពោលរាប់ រង់យ៉ាងម៉ឺងម៉ាត់។ សម្ដីនេះ សបញ្ជាក់យ៉ាងច្បាស់ថា មនុស្សគ្រប់រូបនៅក្នុងសង្គមសុទ្ធតែមាន ឧត្តមគតិ និង ការអំណត់តស៊ូរៀងៗខ្លួន ដើម្បីសេចក្តីថ្លៃថ្នូរ

និងភាពរុងរឿងនៃជីវិតរបស់ពួក គេ។ បើយើងនាំគ្នាក្រឡេកទៅមើល អត្ថបទកំណាព្យដែលមានចំណងជើងថា មើលផែនដីខ្មែរ របស់កវីនិពន្ធ ជួន ម៉េន វិញ យើងនឹងឃើញមានការរៀបរាប់អំពីទុក្ខសោក ខ្លោចផ្សា របស់ ប្រជាជនខ្មែរ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ កាលនោះប្រជាជន ខ្មែរទាំងអស់ គ្រប់ស្រទាប់ វណ្ណៈ ត្រូវបានជម្លៀសពីលំនៅស្ថានស្តុកស្តម្ភ នៅតាមទីក្រុង ឱ្យទៅនៅតាមខ្ទមស្រែ នៅតាម ជនបទដាច់ស្រយ៉ាល ព្រមទាំងបង្ខំឱ្យធ្វើការងារធ្ងន់ និងគ្មានអាហារ បាយទឹក នំចំណីគ្រប់ គ្រាន់សម្រាប់បរិភោគ លើសពីនេះទៅទៀត ពួកគេបានសម្លាប់ប្រជាជន ដោយគ្មានហេតុផល ឬមិនបានរកខុសត្រូវអ្វីឡើយ ជាសង្គមមួយដែល គ្មានមនុស្សធម៌ គុណធម៌ ចំពោះគ្នាឡើយ កូនមិនស្គាល់ឪពុកម្តាយ បាត់បង់វប្បធម៌ប្រពៃណីស្ទើរសូន្យ។ កវី ជួន ម៉េន បានរៀបរាប់ថា "ប្រុស ស្រីប្រែភេទ ស្លាប់គ្មានដឹងហេតុ ខ្លួនខ្លាំងធ្លាក់ខ្សោយ រដូវប្រួលប្រែ ថ្ងៃខែ លែងឱ្យ រស់ ដោយអំណោយ មេឃខ្យល់ប្រទាន។ មនុស្សធម៌បង់បាត់ ខ្លួនមនុស្សចិត្តសត្វ លែងស្គាល់បង ប្អូន។ បង្រៀនឱ្យស្អប់ គប់គុណម៉ែឪ តាំងចិត្តសត្រូវ ព្រះទាំងក្រៅក្នុង។ សម្លាប់ដោយខឹង គ្មាន ប្រាប់ឱ្យដឹង ថា ខ្មៅឬស សុទ្ធខ្មាំងវណ្ណៈ ត្រូវធ្លាក់បាក់ក ជាតិពូជមិនល្អ ទាក់កប្រល័យ។

សរុបសេចក្តីមក យើងឃើញថា អក្សរសិល្ប៍គឺពិតជាបង្កប់នូវ ន័យយ៉ាងទូលំទូលាយ ដោយបានឆ្លុះបញ្ចាំងអំពីភាពពិតជាក់ស្តែងនៃ ព្រឹត្តិការណ៍សង្គមនីមួយៗ ពិតប្រាកដមែន ដូច ដែលបានបកស្រាយ រៀបរាប់រួចមកហើយ។ ព្រោះកវីនិពន្ធទាំងឡាយ ប្រើប្រាស់នូវសិល្បវិធី

របស់ខ្លួនក្នុងនិមិត្តកម្មអក្សរសិល្ប៍ ដោយលើកយកបញ្ហាណាមួយ ដែលមាននៅក្នុងសង្គមមកបញ្ចូលនៅក្នុងស្នាដៃអក្សរសិល្ប៍របស់ខ្លួន ។

ឆ្លងតាមការបកស្រាយខាងលើនេះ ទស្សនៈរបស់ប្រធានដែលលើកឡើង គឺពិតជាមាន អត្ថន័យជ្រាលជ្រៅ បង្កប់នូវគំនិតអប់រំដ៏សម្បូរបែប ក៏ដូចជាផ្ដល់ជាគតិដល់អ្នកនិពន្ធអក្សរ សិល្ប៍ទាំងឡាយឱ្យចេះបញ្ចូលតម្លៃអប់រំដែលឆ្លុះបញ្ចាំងពីសង្គមជាក់ស្ដែង។ ដូច្នេះអ្នកសិក្សាស្នាដៃអក្សរសិល្ប៍ទាំងឡាយ គប្បីស្វែងយល់ឱ្យបានស៊ីជម្រៅ នូវតថភាពសង្គមណាមួយ ដែលអ្នកនិពន្ធចង់បង្ហាញឱ្យឃើញ៕

# ប្រធានទី៧

គេថា៖ «ការសិក្សាអក្សរសិល្ប៍ពុំមានតម្លៃទេ នៅក្នុងសតវត្សរ៍ទី ២១ នេះ ព្រោះសព្វថ្ងៃនេះ គេត្រូវការតែអ្នកបច្ចេកទេសតែប៉ុណ្ណោះ ក្នុងការកសាងជាតិ» ។ តើអ្នកយល់យ៉ាងណាដែរ? ចូរពិភាក្សាដោយលើកពីសង្គម និងរឿងក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែង

### I. សេចក្តីផ្តើម

- លំនាំបញ្ហា៖ មានអ្នកនិពន្ធខ្មែរច្រើនណាស់ ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃរបស់ខ្លួន ក្នុងការចងក្រងអត្ថបទអក្សរសិល្ប៍ ដើម្បីជាចំណងដៃទុកឱ្យកូនខ្មែរសិក្សាស្វែងយល់ និងដកស្រង់យកបទពិសោធល្អជាមេរៀនក្នុងជីវិតរស់នៅ។
- ចំណូលបញ្ហា៖ ការសិក្សាអក្សរសិល្ប៍ពុំមានតម្លៃទេ ក្នុងសតវត្សរ៍ទី២១នេះ ពីព្រោះ សព្វថ្ងៃនេះ គេត្រូវការតែអ្នកបច្ចេកទេសតែប៉ុណ្ណោះ ក្នុងការកសាងជាតិ។
- ចំណោទបញ្ហា៖ តើការកសាងជាតិ គេត្រូវការតែអ្នកបច្ចេកទេសតែប៉ុណ្ណោះ ឬយ៉ាងណា?

### II. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីងាយស្រួលក្នុងការបកស្រាយបញ្ហាប្រធានខាងលើយើង គប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ

  - បច្ចេកទេស៖ សំដៅអ្នកមានវិជ្ជាឯកទេស សម្រាប់អនុវត្តកិច្ចការអ្វីមួយ។

  - ការកសាងជាតិ៖ សម្គាល់លើការរៀបចំស្រុកទេស ឱ្យបានលូតលាស់។
- ពន្យល់ន័យប្រធាន៖ ការសិក្សាអក្សរសិល្ប៍គ្មានតម្លៃទេ ក្នុងសតវត្សរ៍វិទ្យាសាស្រ្ត ទំនើបនេះ ពីព្រោះការកសាងប្រទេសជាតិ គេត្រូវការតែអ្នកបច្ចេកទេស។
- បំណកស្រាយ៖ ដូចដែលបានរៀបរាប់រួចមកហើយ មានមតិពីរខ្វែងគ្នា ហើយសុទ្ធតែមានអំណះអំណាងរៀងៗខ្លួន។

ក. មតិស្រប៖ ការកសាងជាតិ គេត្រូវការអ្នកបច្ចេកទេស ពីព្រោះសមិទ្ធផលទាំងឡាយ ជាស្នាដៃអ្នកបច្ចេកទេស។ បច្ចេកទេសជាផ្នែកមួយងាយស្រួលក្នុងការកងាសអ្វីមួយបានយ៉ាងលឿន។

បច្ចេកវិទ្យា ជាការប្រមូលផ្តុំនូវរូបមន្តដែលយើងចងតែម្តងវាជួយបានរហូត។...

- ឧទាហរណ៍

  - ការកសាងវិស័យសេដ្ឋកិច្ច (ផ្នែកឧស្សាហកម្ម កសិកម្ម គមនាគមន៍ ពាណិជ្ជកម្ម)។

- ការកសាងវិស័យសង្គមកិច្ច (សុខាភិបាលជាដើម)។

- ការកសាងវិស័យនយោបាយ (សន្តិសុខ ការពារជាតិ ការឃោសនា)។

- សរុបមតិស្រប

តើមតិខាងលើត្រឹមត្រូវគ្រប់ជ្រុងជ្រោយហើយឬនៅ?

ខ. មតិផ្ទុយៈ អ្នកបច្ចេកទេសតែឯង មិនគ្រប់គ្រាន់ទេ គេត្រូវការអ្នកអក្សរសិល្ប៍ជួយតម្រង់ផ្លូវទើបអាចរីកចម្រើនទៅបាន ព្រោះការសិក្សាអក្សរសិល្ប៍ផ្តល់នូវសារប្រយោជន៍ច្រើនសម្រាប់ការរស់នៅរបស់មនុស្សៈ

- វាអាចជួយបង្ហាញ ឱ្យឃើញពីគ្រោះថ្នាក់ ឬផ្លូវល្អដើម្បីឆ្ពោះទៅរកសុភមង្គល។
- បណ្តុះគំនិតស្នេហាជាតិ ស្មារតីភ្ញាក់រលឹក មនុស្សធម៌ និងសីលធម៌
- បណ្តុះគំនិតច្នៃប្រឌិតខ្ពស់ និងប្រើប្រាជ្ញាក្នុងការដោះស្រាយបញ្ហា ជាជាងការប្រើកម្លាំងកាយ
- បង្ហាញសេចក្តីត្រូវការពិតៗរបស់សង្គម និងផលវិបាកដែលកើតមានឡើង។

ឧទាហរណ៍:

ឧទាហរណ៍: រឿងកុលាបប៉ៃលិន រឿងចៅកែចិត្តចោរ មហាវេស្សន្តរជាតក រឿងភូមិតិរច្ឆាន។

បណ្តុះគំនិតស្នេហាជាតិ ស្មារតីភ្ញាក់រលឹក មនុស្សធម៌ និងសីលធម៌។

ឧទាហរណ៍: រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់។

- សរុបមតិផ្ទុយ

គ. សំយោគមតិ

- មតិទី១ : មិនត្រឹមត្រូវ ព្រោះបើមានតែអ្នកបច្ចេកទេសសុទ្ធសាធ នាំឱ្យមានគ្រោះថ្នាក់ដល់សង្គមជាតិ។

- មតិទី២ : មិនត្រឹមត្រូវ ព្រោះបើយើងមានតែអ្នកអក្សរសិល្ប៍ក៏មិនរីកចម្រើនដែរ

-ដូចនេះ ដើម្បីរៀបចំស្រុកទេសឱ្យរីកចម្រើន គេត្រូវការអ្នកបច្ចេកទេសផង អ្នកចេះដឹង ផ្នែកអក្សរសិល្ប៍ ចេះដឹងវប្បធម៌ទូទៅផង ព្រោះអ្នកចេះដឹងទាំងនោះ ជាអ្នកបង្កើតទ្រឹស្តី ឯអ្នកបច្ចេកទេសជាអ្នកអនុវត្តកិច្ចការ។

## III. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ មិនត្រឹមត្រូវពេញលេញទេ។
- ទស្សនៈផ្ទាល់ខ្លួន៖ ត្រូវចេះរួមសហការគ្នារវាងខាងផ្នែកបច្ចេកទេស និងខាងផ្នែកខាងអក្សរសិល្ប៍ទើបធ្វើឱ្យសង្គមជាតិចម្រើនរុងរឿង។

# សេចក្តីអត្ថាធិប្បាយ

មានអ្នកនិពន្ធខ្មែរច្រើនណាស់ ដែលពួកគាត់បានខិតខំចំណាយពេលវេលា ដ៏មានតម្លៃរបស់ខ្លួនក្នុងការចងក្រងនូវអត្ថបទអក្សរសិល្ប៍ ដើម្បីជាចំណងដៃទុកឱ្យកូនខ្មែរសិក្សាស្វែងយល់ និងដកស្រង់យកបទពិសោធល្អៗ ជាមេរៀនក្នុងជីវិតរស់នៅ។ ប៉ុន្តែបែរជាមានមតិមួយបានពោលថា៖ ↔ការសិក្សាអក្សរសិល្ប៍ពុំមានតម្លៃទេ ក្នុងសតវត្សរ៍ទី២១នេះ ព្រោះសព្វថ្ងៃនេះគេត្រូវការតែអ្នកបច្ចេកទេសប៉ុណ្ណោះក្នុងការកសាងជាតិ៉។

តើក្នុងការកសាងជាតិគេត្រូវការតែអ្នកបច្ចេកទេសតែប៉ុណ្ណោះឬយ៉ាងណា?

ដើម្បីងាយស្រួលក្នុងការបកស្រាយបញ្ហាប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន។ ពាក្យ ↔អ្នកបច្ចេកទេស៉សំដៅដល់អ្នកដែលមានវិជ្ជាឯកទេសសម្រាប់អនុវត្តកិច្ចការអ្វីមួយ។ រីឯ ↔ការកសាងជាតិ៉សម្គាល់លើការរៀបចំស្រុកទេសឱ្យបាននូវការលូតលាស់។ យោងតាមអត្ថន័យនៃពាក្យខាងលើនេះ មតិរបស់ប្រធានមានន័យថា ការសិក្សាអក្សរសិល្ប៍គ្មានតម្លៃទេ ក្នុងសតវត្សរ៍វិទ្យាសាស្ត្រទំនើប ពីព្រោះការកសាងប្រទេសជាតិ គេត្រូវការតែអ្នកបច្ចេកទេស។ ការពោលអះអាងបែបនេះពិតជាត្រឹមត្រូវប្រាកដមែនហើយ ពីព្រោះថាសមិទ្ធផលទាំងឡាយដែលយើងបានឃើញនៅក្នុងសង្គមនេះ គឺសុទ្ធសឹងតែកើតចេញពីស្នាដៃនៃអ្នកបច្ចេកទេសទាំងអស់។ ភាពជាក់ស្តែងក្នុងការកសាងសេដ្ឋកិច្ចជាតិ ដើម្បីឱ្យឧស្សាហកម្មបោះ

ជំហានទៅមុខបានវិស្វករ និងអ្នកបច្ចេកទេសបានបង្កើតនូវរោងចក្រធំៗ ដើម្បីផលិតទំនិញសព្វសារពើ តាំងពីគ្រឿងស្លៀកពាក់ គ្រឿងឧបភោគ បរិភោគផ្សេងៗសព្វ យ៉ាង។ ទន្ទឹមនឹងនេះ ក៏មានខាងផ្នែកកសិកម្ម គេបង្កើតត្រាក់ទ័រ ឬគោយន្តជំនួសនង្គ័ល ម៉ាស៊ីនបូមទឹកជំនួសស្នាច ម៉ាស៊ីនច្រូតកាត់បោកបែនជំនួសកណ្ដៀវ ក្ដារបោក ព្រមទាំងរថយន្តសម្រាប់ដឹកផលស្រូវជំនួលរទេះគោជាដើម។ ម្យ៉ាងវិញទៀត ខាងផ្នែកគមនាគមន៍ គេបង្កើតយានយន្តគ្រប់ប្រភេទ ដើម្បីធ្វើដំណើរក្នុងប្រទេស ពីប្រទេសមួយទៅកាន់ប្រទេសមួយទៀត ឬពីទ្វីបមួយទៅកាន់ទ្វីបមួយទៀតបានយ៉ាងឆាប់រហ័ស។ ផ្លូវទឹកគេបង្កើតកាណូត កប៉ាល់ នាវាផ្សេងៗជំនួសទូក។ ផ្លូវដែក មានរថភ្លើងទំនើបៗ និងចំណែកផ្លូវអាកាសវិញ ក៏មានយន្តហោះគ្រប់ធុនដឹកអ្នកដំណើរពីតំបន់មួយទៅកាន់តំបន់មួយទៀតដែរ។ ជាពិសេសទៅទៀតនោះ ខាងផ្នែកពាណិជ្ជកម្ម វិស្វករ និងអ្នកបច្ចេកទេស ក៏បានរិះរកឧបករណ៍ទំនើប ដូចជា ម៉ាស៊ីនគិតលេខ កុំព្យូទ័រ ជាដើម ដើម្បីសម្រួលការងារនេះឱ្យបានឆាប់រហ័ស ហើយគ្មានការភាន់ច្រឡំ តទៅទៀត។ ចំពោះការរៀបចំផ្នែកសង្គមកិច្ចវិញក៏ដូចគ្នាដែរ ខាងវិស័យសុខាភិបាល គេត្រូវការអ្នកបច្ចេកទេសសាងសង់មន្ទីរពេទ្យ ផលិតឧបករណ៍ប្រើប្រាស់ទាន់សម័យ ដូចជា ម៉ាស៊ីនថតឆ្លុះ កែវពង្រីក និងឱសថទំនើបៗ ដើម្បីព្យាបាលរោគឱ្យបានឆាប់ជាសះស្បើយ។ ខាងវិស័យអប់រំ គេត្រូវការអ្នកបច្ចេកទេសសាងសង់អគារសិក្សាឱ្យបានច្រើន ផលិតតុកៅអី ក្ដារខៀន និងឧបករណ៍ពិសោធ ដើម្បីឱ្យសិស្សងាយស្រួលក្នុងការសិក្សារៀនសូត្រ។ ចំណែកឯក្នុងការពង្រឹងផ្នែកនយោបាយវិញ ដើម្បីឱ្យ

វិស័យការពារជាតិ ធានាបាននូវសុខសន្តិភាពយ៉ាងរឹងមាំ គេត្រូវការអ្នកបច្ចេកទេសដើម្បីបង្កើតនូវអាវុធយុទ្ធភណ្ឌទំនើបៗដូចជាកាំភ្លើង គ្រាប់មីន យន្តហោះចម្បាំងជាដើម។ ការបង្កើតរបស់ទាំងនេះ គឺសម្រាប់ត្រៀមនូវលក្ខណៈការពារសត្រូវ។ ចំណែកឯវិស័យ ឃោសនា គេត្រូវការអ្នកបច្ចេកទេស ផលិតឧបករណ៍ទំនើបៗដូចជា វិទ្យុ ទូរស័ព្ទ ម៉ាស៊ីនថតរូបភាព ម៉ាស៊ីនថតចម្លង ដើម្បីងាយស្រួលក្នុងការផ្តល់ព័ត៌មានឱ្យបានទាន់ពេលវេលា។ សរុបសេចក្តីមក វិស័យកសាងជាតិគ្រប់ប្រភេទ គេត្រូវការអ្នកបច្ចេកទេស គេពុំត្រូវការអ្នកអក្សរសិល្ប៍មកប្រើទេ រីឯការសិក្សាអក្សរសិល្ប៍ក្នុងសម័យវិទ្យាសាស្ត្រទំនើប ក៏ពុំមានតម្លៃដែរ។

តើមតិខាងលើត្រឹមត្រូវគ្រប់ជ្រុងជ្រោយហើយឬនៅ?

ទន្ទឹមនឹងនេះ ក៏មានមតិមួយចំនួនយល់ឃើញផ្ទុយពីនេះទៅវិញថា ក្នុងការកសាងជាតិ អ្នកបច្ចេកទេសតែឯងពុំគ្រប់គ្រាន់ទេ គេត្រូវការអ្នកអក្សរសិល្ប៍ ឬអ្នកមានចំណេះដឹងវប្បធម៌ទូទៅទូលំទូលាយជួយតម្រង់ទិសដៅ ដើម្បីដើរឆ្ពោះទៅរកការរីកចម្រើន។ ការពោលអះអាងបែបនេះ គឺពិតជាត្រឹមត្រូវហើយ ព្រោះការសិក្សាអក្សរសិល្ប៍បានផ្តល់សារប្រយោជន៍ច្រើនណាស់សម្រាប់ការរស់នៅរបស់មនុស្ស។ វិជ្ជានេះអាចជាប្រទីបជួយបំភ្លឺផ្លូវយើង ឱ្យមើលឃើញពីគ្រោះថ្នាក់ដែលកើតពីការលោភលន់ហួសប្រមាណ និងប្រាប់ពីផ្លូវល្អដែលមនុស្សត្រូវប្រកាន់យកដើម្បីធ្វើឱ្យសង្គមជាតិរីកចម្រើន។ តាមរយៈការសិក្សាអក្សរសិល្ប៍ រឿងកុលាបប៉ៃលិន និងរឿងថៅកែចិត្តចោរ អ្នកនិពន្ធបានលាតត្រដាងឱ្យឃើញថា នៅក្នុងសង្គម បើមានប្រភេទអ្នកបច្ចេកទេសបើកឡានបែប

ពូហំ ប្រភេទចៅកែចិត្តចោរ ប្រភេទមន្ត្រីរាជការបែបលោកបាឡាត់ ប្រទេសជាតិនឹងឈានទៅរកការរំលាយ ព្រោះអ្នកទាំងនេះ ដើម្បីធ្វើឱ្យសម្រេចបំណងរបស់ខ្លួនហ៊ានប្រព្រឹត្តអំពើថោកទាបអមនុស្សធម៌។ ផ្ទុយទៅវិញ បើមានប្រភេទកម្មករបែបចៅចិត្រ ចៅកែ ហ្លួង រតនសម្បត្តិ ប្រទេសជាតិនឹងរីកចម្រើនជឿនលឿន ព្រោះគេប្រកាន់តែអំពើល្អ សុចរិត និងយុត្តិធម៌។ ទន្ទឹមនឹងនេះផងដែរ វិជ្ជាអក្សរសិល្ប៍ក៏បានបង្ហាញឱ្យឃើញពីសេចក្តីពិតរបស់សង្គម និងផលវិបាកដែលកើតមានឡើង។ នៅក្នុងរឿងមហាវេស្សន្តរជាតក អ្នកនិពន្ធបង្ហាញឱ្យឃើញពី↔លទ្ធិប្រជាធិបតេយ្យៈដែលជាប្រពៃណីគ្រប់គ្រងប្រទេសមួយដ៏ល្អ និងជាតម្រូវការពិតៗ របស់សង្គមជាតិនីមួយៗ។ ការគោរពលទ្ធិប្រជា ធិបតេយ្យរបស់ព្រះបាទស្រីសញ្ជ័យ និងព្រះវេស្សន្តរ បានធ្វើឱ្យអ្នកនគរស្រីពិរាស្ត្ររួចផុតពីសង្គ្រាម ហើយរស់នៅយ៉ាងសុខសាន្ត។ ឯនៅក្នុងរឿងភូមិតិរច្ឆានវិញ ក្រោមការជិះជាន់នៃពួកអាណានិគមបារាំង ធ្វើឱ្យប្រជារាស្ត្រខ្មែរបាត់បង់សិទ្ធិសេរីភាព ហើយការរស់នៅលំបាកវេទនា។ មិនតែប៉ុណ្ណោះវិជ្ជាអក្សរសិល្ប៍បានបណ្តុះស្មារតីស្នេហាជាតិ ស្មារតីភ្ញាក់រលឹក មនុស្សធម៌ និងសីលធម៌ថែមទៀតផង។ នៅក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនចាស់ អ្នកនិពន្ធបានបង្ហាញឱ្យឃើញពីគំនិតមនុស្សធម៌ សីលធម៌ និងស្នេហាជាតិរបស់លោករដ្ឋ មន្ត្រីក្មេង ដែលបានជួយសង្គ្រោះសម ឱ្យរួចផុតពីគ្រោះថ្នាក់ និងមានការងារធ្វើថែមទៀត។ សរុបសេចក្តីមក ការសិក្សាអក្សរសិល្ប៍ ពិតជាផ្តល់នូវអត្ថប្រយោជន៍ក្នុងការកសាងជាតិ ដើរឆ្ពោះទៅរក

សេចក្ដីរីកចម្រើនមែន ហើយនៅតែមានតម្លៃជានិច្ចនិរន្តរ៍ ទោះបីស្ថិតក្នុងសតវត្សរ៍ណាក៏ដោយ។

ជារួមដូចដែលបានរៀបរាប់រួចមកហើយ មានមតិពីរខ្វែងគ្នា ហើយសុទ្ធតែមានអំណះអំណាងរៀងៗ ខ្លួន។ តែយើងក៏អាចវិភាគបានថា មតិទី១មិនទាន់ត្រឹមត្រូវទាំងស្រុងទេ ព្រោះថាបើមានតែអ្នកបច្ចេកទេសសុទ្ធសាធនឹងនាំឱ្យមានគ្រោះថ្នាក់យ៉ាងធំដល់សង្គមជាតិទៅវិញ។ នៅពេលខ្លះអ្នកបច្ចេកទេសជាអាវុធ បើកផ្លូវឱ្យអ្នកស្រឡាញ់អំណាច បុណ្យសក្តិ គ្មានសីលធម៌ រំលោភបំពាន ឈ្លានពានលើអ្នកខ្សត់ខ្សោយ។ រីឯមតិទី២ ក៏មិនត្រឹមត្រូវទាំងស្រុងដែរ ព្រោះបើមានតែអ្នកចេះអក្សរសិល្ប៍ កិច្ចការអ្វីៗពុំអាចដើរទៅមុខរួចឡើយ ដោយគ្មានអ្នកធ្វើ។ ក្នុងករណីនេះយើងយល់ថា ដើម្បីរៀបចំស្រុកទេសឱ្យមានការអភិវឌ្ឍ គេត្រូវការអ្នកបច្ចេកទេសផង អ្នកអក្សរសិល្ប៍ ឬអ្នកចេះវប្បធម៌ទូទៅទូលំទូលាយផង ព្រោះអ្នកចេះដឹងចំណេះទូទៅជាអ្នករៀបចំអង្គការទាក់ទង ដើម្បីឱ្យរីកចម្រើនលូតលាស់ រីឯអ្នកបច្ចេកទេសជាអ្នកអនុវត្តកិច្ចការនីមួយៗ។

យោងទៅតាមការពិភាក្សារួចមកហើយនេះ យើងក៏អាចវាយតម្លៃមតិរបស់ប្រធានបានថា មតិនេះពុំទាន់ត្រឹមត្រូវគ្រប់ជ្រុងជ្រោយទេ។ ដើម្បីឱ្យពេញលេញនោះ ការកសាងប្រទេសទាមទារអ្នកអក្សរសិល្ប៍ និងអ្នកបច្ចេកទេសសាមគ្គីគ្នាជាធ្លុងមួយទើបសម្រេចបានជោគជ័យ។ ដូចនេះ មនុស្សដែលរស់នៅក្នុងសង្គមមិនត្រូវប្រកាន់ខ្ជាប់នូវគំនិតអាត្មា

និយមទៀយ។ ពោលគឺត្រូវចេះរួបរួមកម្លាំងគ្នាជាប្រាច់តែមួយ ដើម្បីកសាងសង្គមជាតិរបស់យើងឱ្យឈានទៅរកភាពសម្បូររុងរឿង៕

# ប្រធានទី៨

មានទស្សនមួយពោលថា៖ "ចំណេះ និងចរិយាជាកត្តានាំឱ្យមានសោភ័ណបុគ្គល"។ ចូរពន្យល់ដោយលើកឧទាហរណ៍នៅក្នុងសង្គមប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍មកបញ្ជាក់ឱ្យបានក្បោះក្បាយ។

## គម្រោងតែង

### ១. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ ក្នុងការរស់នៅ មនុស្សម្នាក់ៗរមែងចង់បានសេចក្ដីសុខ និងការគោរពស្រឡាញ់រាប់អានពីអ្នកនៅជុំវិញខ្លួន ហើយបំណងប្រាថ្នានេះវាអាចទទួលជោគជ័យទៅបានវាអាស្រ័យលើទង្វើដែលយើងប្រព្រឹត្តជាប្រចាំ។

- ចំណូលបញ្ហា៖ អាស្រ័យហេតុនេះហើយទើបមានមតិមួយពោលថា "ចំណេះ និងចរិយាជាកត្តានាំឱ្យមានសោភ័ណបុគ្គល" ។

- ចំណោទបញ្ហា៖ តើមតិប្រធានខាងលើមានអត្ថន័យយ៉ាងដូចម្ដេច?

### ២. តួសេចក្ដី

ក. ឃ្លាភ្ជាប់សេចក្ដី

ដើម្បីជាទុនក្នុងការបកស្រាយប្រធានបទខាងលើឱ្យបានក្បោះក្បាយ ជាបឋមយើងគប្បីយល់ន័យនៃពាក្យគន្លឹះជាមុនសិន។

ខ. ពន្យល់ពាក្យ

- "ចំណេះ" សំដៅលើអ្វីៗដែលយើងចេះ ដឹងតាមរយៈការសិក្សារៀនសូត្រ។
- "ចរិយា" មានន័យថា ការប្រព្រឹត្ត ឬកិរិយាមារយាទ។
- "សោភ័ណ" គឺជាលម្អ ភាពប្រសើរថ្លៃថ្លា មានតម្លៃ ។

គ. ពន្យល់ន័យប្រធាន

ដូចនេះប្រធានខាងលើចង់បង្ហាញថា ដើម្បីឲ្យជីវិតរស់នៅប្រកបដោយភាពល្អប្រសើរថ្លៃថ្លាមនុស្សម្នាក់ៗត្រូវតែមានចំណេះវិជ្ជា និងកិរិយាមាយាទល្អ ដែលជាការលម្អសម្រាប់មនុស្សទូទៅគោរព និងឲ្យតម្លៃផងដែរ។

ឃ. បកស្រាយប្រធាន

ជាការពិតណាស់ មនុស្សកើតមកតែងមានបំណងប្រាថ្នាចង់បានតម្លៃ កិត្តិយស និងសេចក្តីថ្លៃថ្នូរ។ រាល់ចំណុចទាំងនេះ អាចទទួលទៅបាន គឺវាអាស្រ័យទៅលើបុគ្គលគ្រប់រូបមានចំណេះដឹង និងចរិយាថ្លៃថ្នូរ និងខ្ពង់ខ្ពស់ ។ ហេតុផលទាំងនេះ ដោយយោងទៅលើ៖

❖ គំនិតសំខាន់

រូបភាពនៃអ្នកមានចំណេះវិជ្ជា៖

- ការដឹងពីអ្វីដែលខ្លួនកំពុងតែជួប
- ចេះធ្វើអ្វីដែលខ្លួនកំពុងតែជួប
- ដំណើរដែលចេះមិនថាធ្វើអ្វីក៏ដោយ
- យល់ដឹងជាក់ច្បាស់
- .........

រីឯចរិយាមារយាទសំដៅ៖

- ការប្រព្រឹត្តរបស់មនុស្ស
- ផ្នែកសណ្ដាប់ធ្នាក់
- ឫកពារ របៀប របប កិរិយា

ប្រសិនបើមនុស្សមានចំណេះវិជ្ជា គួបផ្សំជាមួយចរិយាមារយាទនោះគេនឹង៖

- ចេះគិតពិចារណាបានវែងឆ្ងាយ ស្គាល់ខុសស្គាល់ត្រូវ ...។
- ចរិយាមារយាទល្អជាគុណសម្បត្តិដ៏ប្រពៃ បូករួមនឹងចំណេះដឹងដែលយើងមាន...។
- ចំណេះវិជ្ជា និងចរិយាបានធ្វើឱ្យបុគ្គលមានកិត្តិយសសេចក្ដីថ្លៃថ្នូរ...។
- ជាអ្នកកំណត់តម្លៃរបស់មនុស្ស ធ្វើឱ្យគេគោរពស្រឡាញ់។
- បុគ្គលដែលអស្ចារ្យ ជាបុគ្គលដែលមានទាំងចំណេះ និងចរិយា...។

➢ ឧទាហរណ៍នៅក្នុងសង្គម៖

✓ បុគ្គលដែលមានចំណេះដឹងជ្រៅជ្រះ និងមានក្រមសីលធម៌ល្អរមែងទទួលនូវការគោរពស្រឡាញ់ មានបុខរបរ មានជំនាញច្បាស់លាស់ និងឡើងមុខតំណែង...។

✓ សម្ដេចសង្ឃរាជជួន ណាត ទ្រង់បានចំណាយពេលពេញជីវិតបន្សល់ទុកស្នាដៃដូចជា វចនានុក្រម និពន្ធបទនគររាជ និងបទសរភញ្ញជាដើម ។

✓ ព្រះភិរម្យភាសាអ៊ូ បានបួសរៀនមានចំណេះដឹងរហូតពេលលាចាកសិក្ខាបទហើយចេះច្រៀងសាដៀវប្រែកបដោយកាព្យឃ្លោងល្អ ហើយបានយកចំណេះនេះទៅប្រើក្នុងផ្លូវល្អរហូតគេបានចងក្រងទុកជាស្នាដៃដូចជាសម្រាប់សិក្សារៀនសូត្រ...។

➢ នៅក្នុងប្រវត្តិសាស្ត្រ

✓ ព្រះនាងឥន្ទ្រទេវី មានទាំងវិជ្ជាសម្បត្តិ និងចរិយាសម្បត្តិជាស្ត្រីទីមួយបានលើកតម្កើងតម្លៃអក្សរសាស្ត្រដោយបានសិក្សារៀនសូត្រអក្សរសាស្ត្រជាតិ និងជួយជ្រោមជ្រែងព្រះបាទជ័យវរ្ម័នទី៧ក្នុងការដឹកនាំប្រទេសឲ្យរីកចម្រើនគ្រប់វិស័យ...។

➢ នៅក្នុងអក្សរសិល្ប៍

- រឿងកុលាបប៉ៃលិន

✓ ចៅចិត្រជាយុវជនថ្លៃថ្នូរ ដែលចេះកសាងខ្លួនដោយឈរលើចំណេះដឹងជ្រៅជ្រះ និងមានសីលធម៌ល្អទើបក្លាយជាមនុស្សដែលមានគេស្រឡាញ់រាប់អានគ្រប់គ្នា...។

- រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់

✓ តួអង្គលោករដ្ឋមន្ត្រីវ័យក្មេងជាមនុស្សដែលមានចំណេះដឹងជ្រៅជ្រះ បូករួមនឹងចរិយាថ្លៃថ្នូរធ្វើឱ្យប្រជារាស្ត្រទូទៅគោរពស្រឡាញ់ជាពិសេសសម...។

- រឿងមាលាដួងចិត្ត

✓ ទីឃាវុធ ជាយុវជនដែលមានចំណេះដឹង និងមានឧត្តមគតិស្រឡាញ់ជាតិ...។

ង. សរុបមតិ

សរុបសេចក្ដីមកយើងឃើញទាំងចំណេះដឹងនិងសីលធម៌ ចរិយាមារយាទថ្លៃថ្នូរគឺពិតជាសំខាន់ខ្លាំងណាស់ ដែលមនុស្សគ្រប់រូបចាំបាច់ត្រូវតែមានទាំងពីរសម្រាប់ជាគ្រឿងលម្អក្នុងការរស់នៅប្រកបដោយកិត្តិយស និងមានកេរ្ដិ៍ឈ្មោះប្រសើរថ្លៃថ្លាក្នុងការច្នៃខ្លួនឯងឱ្យក្លាយជាមនុស្ស ដែលមានតម្លៃសម្រាប់គ្រួសារនិងប្រទេសជាតិ ។

## ៣. បញ្ចាប់សេចក្ដី

- វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយរួចមកនេះយើងឃើញថាមតិប្រធានខាងលើពិតជាមានតម្លៃអប់រំសម្រាប់ឲ្យយើងអនុវត្តតាមដោយយកចំណេះ ដែលមានទៅប្រព្រឹត្តខ្លួនជាពលរដ្ឋល្អ និងបម្រើផលប្រយោជន៍ដល់សង្គមប្រកបដោយចរិយាមារយាទថ្លៃថ្នូរ។

- ទស្សនៈផ្ទាល់ខ្លួន៖ ដូចនេះក្នុងនាមយើង ជាអ្នកសិក្សាត្រូវខិតខំប្រឹងប្រែងរៀនសូត្រស្ដាប់តាមដំបូន្មានឪពុកម្ដាយ និងលោកគ្រូអ្នកគ្រូដើម្បីក្លាយខ្លួនទៅជាពលរដ្ឋល្អ និងយកចំណេះទៅកសាងសង្គមឲ្យមានវឌ្ឍនភាពនិងសន្តិភាព។

## សេចក្ដីអធិប្បាយ

ក្នុងការរស់នៅមនុស្សម្នាក់ៗរមែងចង់បាននូវសេចក្ដីសុខ និងការគោរពស្រឡាញ់រាប់អានពីអ្នកនៅជុំវិញខ្លួន ហើយសេចក្ដីប្រាថ្នានេះអាចនឹងទទួលជោគជ័យទៅបានអាស្រ័យលើទង្វើដែលយើងប្រព្រឹត្តជាប្រចាំ។ អាស្រ័យហេតុនេះទើបមានមតិមួយពោលថា "ចំណេះ និងចរិយាជាកត្តានាំឲ្យមានសោភ័ណបុគ្គល"។

តើទស្សនប្រធានខាងលើមានអត្ថន័យយ៉ាងដូចម្ដេច?

ដើម្បីជាទុនក្នុងការបកស្រាយមតិប្រធានខាងលើឲ្យបាន ក្បោះក្បាយ ជាបឋមយើងគប្បីយល់ន័យនៃពាក្យគន្លឹះជាមុនសិន។ ពាក្យ "ចំណេះ" សំដៅលើអ្វីៗ ដែលយើងចេះដឹងតាមរយៈការសិក្សារៀនសូត្រ។ រីឯពាក្យ "ចរិយា" មានន័យថាការប្រព្រឹត្ត ឬកិរិយាមារយាទល្អ។ ចំណែកឯ "សោភ័ណ" គឺជាភាពលម្អ ភាពល្អប្រសើរថ្លៃថ្លា។ ដូចនេះប្រធានខាងលើមានន័យថា ដើម្បីឱ្យជីវិតរស់នៅប្រកបដោយភាពប្រសើរថ្លៃថ្លា មនុស្សម្នាក់ៗត្រូវតែមានចំណេះវិជ្ជា និងកិរិយាមារយាទល្អ ដែលជាគ្រឿងលម្អរបស់ជីវិតសម្រាប់ឱ្យមនុស្សទូទៅគោរពស្រឡាញ់និងឲ្យតម្លៃផងដែរ។

ជាការពិតណាស់ មនុស្សម្នាក់ៗកើតមកតែងតែប្រាថ្នាចង់បានកិត្តិយស កេរ្តិ៍ឈ្មោះ និងសេចក្ដីថ្លៃថ្នូរហើយមានតម្លៃនៅក្នុងសង្គម។ មនុស្សដែលមានចំណេះវិជ្ជាជាមនុស្សការដឹងពីអ្វីដែលខ្លួនកំពុងតែជួប ចេះធ្វើអ្វីដែលខ្លួនកំពុងតែជួប ដំណើរដែលចេះមិនថាធ្វើអ្វីក៏ដោយ យល់ដឹងជាក់ច្បាស់ពីកិច្ចការមិនថាកាលៈទេសៈណាក៏ដោយ។ ប៉ុន្តែរាល់ចំណុចទាំងនេះ អាចកើតឡើងបាន គឺវាអាស្រ័យទៅលើបុគ្គលគ្រប់រូបមានចំណេះដឹងជ្រៅជ្រះ ទូលំទូលាយ និងចរិយាមារយាទថ្លៃថ្នូរ ខ្ពង់ខ្ពស់ផងដែរ។ ពិតមែនហើយចំណេះវិជ្ជា គឺមានសារៈសំខាន់ និងអត្ថប្រយោជន៍ខ្លាំងណាស់សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ព្រោះវាជាទ្រព្យសម្បត្តិដែលមានតម្លៃយ៉ាងគាប់ប្រសើរ ហើយនៅជាប់នឹងខ្លួនយើងជានិច្ចមិនពិបាកក្នុងការទុកដាក់ វេចស្ពាយឬខ្លាចចោរលួច

ឆក់ប្លន់ដូចមាសប្រាក់ឡើយ។ ប្រសិនបើយើងប្រើប្រាស់កាន់តែច្រើន គឺកាន់តែរីកចម្រើនឡើង។ មិនត្រឹមតែប៉ុណ្ណោះអ្នក ដែលមានចំណេះវិជ្ជារមែងមានការចេះគិតគូរត្រិះរិះពិចារណាបានវែងឆ្ងាយ និងបានគ្រប់ជ្រុងជ្រោយល្អិតល្អន់ក្នុងការដោះស្រាយបញ្ហា ឬធ្វើកិច្ចការងារអ្វីមួយ។ ស្រប គ្នានឹងនេះផងដែរ ប្រសិនបើយើងមានតែចំណេះវិជ្ជាតែម្យ៉ាងហើយខ្វះចរិយាមារយាទថ្លៃថ្នូរគុណធម៌ និងសីលធម៌ល្អក្នុងការរស់នៅ ឬការប្រាស្រ័យទាក់ទងល្អជាមួយអ្នកដទៃក៏គេមិនសូវឱ្យតម្លៃផងដែ។ យ៉ាងនេះហើយទើបបានជាគេនិយាយថា ចរិយាមារយាទល្អជាគុណសម្បត្តិមួយដ៏ប្រពៃ ដែលមនុស្សត្រូវតែមានជាចាំបាច់ដូចចំណេះវិជ្ជាដែរ។ ហេតុនេះទាល់តែមានទាំងចំណេះផង និងចរិយាផងទើបជាគ្រឿងលម្អ ដែលធ្វើឱ្យមនុស្សកាន់តែមានតម្លៃយ៉ាងគាប់ប្រសើរក្នុងជីវិត ហើយអ្នកផងទាំងឡាយគោរពនិងកោតសរសើរ។ តួយ៉ាងនៅក្នុងសង្គមយើង បុគ្គលដែលមានចំណេះដឹងជ្រៅជ្រះរមែងមានមុខរបរ និងមានជំនាញច្បាស់លាស់ និងសីលធម៌ល្អរឹតតែធ្វើឱ្យចៅហ្វាយនាយ ឬអ្នកដឹកនាំស្រឡាញ់ពេញចិត្ត គោរពនិងកោតសរសើរ ឬតម្លើងមុខតំណែង និងតួនាទីឱ្យផងដែរ។ យ៉ាងណាមិញសម្តេចសង្ឃរាជជួន ណាត ក៏ជាជនគំរូមួយរូបដែលមានទាំងចំណេះ និងចរិយាប្រពៃដូចគ្នាផងដែរទើបកូនខ្មែរគោរពស្រលាញ់ ព្រោះលោកយកចំណេះវិជ្ជា ដែលមានមកគិតដល់ប្រយោជន៍ជាតិជាធំដោយទ្រង់បានចំណាយពេលវេលាស្ទើរពេញមួយជីវិតស្វាធ្យាយសិក្សារៀនសូត្រសព្វបែបយ៉ាង ទើបក្លាយជាបញ្ញវន្តមួយរូបដែលកូនខ្មែរគ្រប់សម័យកាលគោរព និងកោតសរសើរនូវស្នាដៃរបស់

លោកមានដូចជាវចនានុក្រមខ្មែរភាគ១ភាគ២ ទុកសម្រាប់ជាគោល ចំពោះអ្នកសិក្សាអក្សរសាស្ត្រជាតិ និងបាននិពន្ធបទនគររាជឲ្យកូនខ្មែរ ច្រៀងគោរពទង់ជាតិរាល់ថ្ងៃ ដើម្បីរំឭកដល់គុណព្រះមហាក្សត្រសរសើរ ដល់បុព្វបុរសជំនាន់មុន ដែលបានបន្សល់ទុកនូវប្រាង្គប្រាសាទយ៉ាងល្អ វិចិត្រ និងគោរពដល់សាសនា។ មួយវិញទៀតកវីក្រមង៉ុយលោកក៏ជា បុគ្គលម្នាក់ ដែលមានតម្លៃសោភ័ណដូចគ្នា ព្រោះលោកបានបួសរៀន ធម៌អាចិ និងមានចំណេះជ្រៅជ្រះថែមទាំងចេះច្រៀងសាដៀវទៀតផង រហូតបានធ្វើឱ្យព្រះករុណាព្រះស៊ីសុវត្ថិ ពេញព្រះរាជហឫទ័យប្រទាន ប្រាក់ និងគោរមម្យងារថា "ព្រះភិរម្យភាសាអ៊ូ"។ ហើយត្រូវបាន អ្នកស្រីស៊ូ សានកាពេលេស បានកត់ត្រាសំដីច្រៀងរបស់លោកទុកជាស្នាដៃ ចម្រៀងរួមមាន សេចក្តីរំឭកដាស់តឿន ច្បាប់កេរកាលថ្មី ច្បាប់ល្បើកថ្មី ច្បាប់ទូន្មានជនប្រុសស្រី និងបណ្តាំក្រមង៉ុយទុកទូន្មានកូនខ្មែរជំនាន់ ក្រោយត្រិះរិះពិចារណា។ យ៉ាងណាមិញនៅក្នុងប្រវត្តិសាស្ត្រខ្មែរព្រះនាង ឥន្ទ្រទេវី ទ្រង់គឺជាស្ត្រីម្នាក់ដែលមានទាំងចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិ ព្រោះ ព្រះនាងជាស្ត្រីទី១ដែលបានសិក្សារៀនសូត្រ និងលើកតម្កើងវិស័យ អក្សរសាស្ត្រជាតិ ដោយទ្រង់បានយកចំណេះដឹងដែលមានមកជួយ បង្ហាត់បង្រៀនដល់ស្ត្រីខ្មែរទាំងឡាយ និងរាជបរិពារក៏ដូចជាជួយ ជ្រោមជ្រែងដល់ព្រះស្វាមីក្នុងការគិតគូរដល់សុខទុក្ខរបស់រាស្ត្រ និងដឹកនាំ ធ្វើឲ្យសម័យមហានគរអភិវឌ្ឍន៍គ្រប់វិស័យ មានកិត្តិសព្ទល្បីល្បាញលើ ពិភពលោក។ នេះបញ្ជាក់ថាទ្រង់ គឺជាក្សត្រីដែលមានបញ្ញាឈ្លាសវៃ និង ចរិយាដ៏ប្រពៃសម្រាប់រាស្ត្រខ្មែរគោរពនិងឱ្យតម្លៃ។ ចំណែកឯស្នាដៃ

អក្សរសិល្ប៍រឿងកុលាប៉ៃលិនក៏មានលើកឡើងពី តួអង្គចៅចិត្រដែលអ្នកសិក្សាចាត់ទុកថាជាយុវជនថ្លៃថ្នូរមានទាំងចំណេះដឹង និងសមត្ថភាពបញ្ញាវាងវៃចេះដោះស្រាយបញ្ហាតាមស្ថានភាព និងកាលៈទេសៈ។ ជាពិសេសនៅក្នុងដំណើររឿង ចៅចិត្របានប្រឡងជាប់ប្រកាសនីយបត្រដែលជាសញ្ញាបត្រមួយដ៏មានតម្លៃនៅសម័យនោះទៀតផង និងបន្ទាប់ពីឪពុកស្លាប់ទៅបានមកធ្វើការជាកម្មករជីកត្បូងនៅផ្ទះ លោកហ្លួងរតនសម្បត្តិ និងទទួលបានការស្រឡាញ់រាប់អានពីសំណាក់ពួកកម្មករដូចគ្នានេះក៏ដោយសារតែចៅចិត្រមានចរិយាមារយាទថ្លៃថ្នូរ សុភាពរាបសារដឹងខុសត្រូវស្គាល់ល្អអាក្រក់ មានភាពស្មោះត្រង់ចំពោះចៅហ្វាយនាយ និងចេះជួយយករអាសាអ្នកដទៃដោយមិនចង់បានផលតបស្នង។ ជាក់ស្តែងពេល ដែលលោកហ្លួងរតនសម្បត្តិបានប្រគល់ការងារកាន់កាប់បញ្ជីត្បូងចៅចិត្រមិន ដែលមានគំនិតកេងប្រវ័ញ្ចឡើយ រហូតដល់ពេលមានចោរប្លន់នៅផ្ទះក៏ចៅចិត្រចេញមុខទៅជួយដោយមិនខ្លាចសេចក្តីស្លាប់ ដើម្បីការពារចៅហ្វាយនាយ។ ដោយមើលឃើញពីតម្លៃនៃអំពើល្អនេះហើយ ទើបលោកហ្លួងរតនសម្បត្តិព្រមឱ្យកូនស្រីរៀបការជាមួយចៅចិត្រ។ ហេតុនេះយើងឃើញថា បើទោះជាយើងគ្មានទ្រព្យសម្បត្តិ គ្មានបុណ្យសក្តិប៉ុន្តែបើយើងមានចំណេះវិជ្ជាជ្រៅជ្រះ និងសីលធម៌ល្អ នោះមនុស្សទូទៅនឹងឱ្យតម្លៃដូចគ្នា។ លើសពីនេះទៅទៀតក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់តួអង្គលោករដ្ឋមន្ត្រីវ័យក្មេងជាមនុស្ស ដែលបានសិក្សារៀនសូត្រខ្ពង់ខ្ពស់ជ្រៅជ្រះ ហើយបូករួមទាំងមានសីលធម៌ល្អក្នុងការរស់នៅ ចេះអាណិតអាសូរនិងមានមេត្តាករុណាចំពោះអ្នកនៅជុំវិញ

ខ្លួន។ តួយ៉ាងនៅពេលដែលបើកឡានបុកសមហើយ លោកបានចុះមកមើល ហើយបានជួយសង្គ្រោះសមដោយជួយរកការងារឱ្យសមធ្វើរហូតដល់មានជីវភាពធូរធារ។ ដោយសារទង្វើល្អបែបនេះហើយបានជាប្រជារាស្ត្រ និងសមផ្ទាល់គោរពនិងស្រឡាញ់ចំពោះលោកណាស់។ ជាងនេះទៅទៀតក្នុងស្នាដៃរឿងមាលាដួងចិត្តតួអង្គ ទីឃាវុធជាយុវជនមួយរូបដែលមានចំណេះដឹង និងមានឧត្តមគតិស្នេហាជាតិថែមទៀតផង ព្រោះគេបានប្ដេជ្ញាចិត្តតាំងពីនៅរៀនថានឹងមិនលក់ឧត្តមគតិខ្លួនឡើយ ទោះបីត្រូវថៅកែហុងឈី យកលុយមកសូកប៉ាន់រឿងទិញកំណាត់គ្មានគុណភាពមកកាត់ឯកសណ្ឋានឱ្យប៉ូលិសក៏ដោយ ក៏ទីឃាវុធមិនទទួលយកដែរ គឺគេបាននឹកឃើញដល់មន្ត្រីរាជការតូចតាច ដែលត្រូវលំបាកវេទនាស្លៀកសម្លៀកបំពាក់ឆាប់រហែកមិនល្អ ប្រសិនបើខ្លួនយល់ព្រមធ្វើតាមការស្នើសុំរបស់មនុស្សខិលខូចដូចថៅកែ ហុង ឈី។ នេះសបញ្ជាក់ឱ្យឃើញថា គាត់ជាមនុស្សថ្លៃថ្នូរដែលមានទាំងវិជ្ជា និងគុណធម៌ គិតប្រយោជន៍ជាតិជាធំ សមជាគំរូសម្រាប់យុវជនទូទៅយកតម្រាប់តាម។

សរុបសេចក្ដីមកយើងឃើញថា ទាំងចំណេះដឹង និងសីលធម៌ចរិយាមារយាទថ្លៃថ្នូរ គឺពិតជាសំខាន់ខ្លាំងណាស់ ដែលមនុស្សគ្រប់រូបចាំបាច់ត្រូវតែមានទាំងពីរសម្រាប់ជាគ្រឿងលម្អក្នុងការរស់នៅប្រកបដោយកិត្តិយស កេរ្តិ៍ឈ្មោះប្រសើរថ្លៃថ្លាក្នុងការច្នៃខ្លួនឯងឱ្យក្លាយជាមនុស្សដែលមានតម្លៃសម្រាប់គ្រួសារ និងប្រទេសជាតិ ។

ឆ្លងតាមការបកស្រាយរួចមកនេះយើងឃើញថា មតិប្រធានខាងលើពិតជាមានតម្លៃអប់រំយ៉ាងជ្រាលជ្រៅសម្រាប់ឱ្យយើងយកចំណេះដឹង

ដែលមានទៅប្រតិបត្តិខ្លួនជាពលរដ្ឋល្អ ហើយប្រកបដោយកិរិយាមារយាទថ្លៃថ្នូរនៅក្នុងសង្គម។ ដូចនេះ ក្នុងនាមយើងជាអ្នកសិក្សាត្រូវខិតខំប្រឹងប្រែងរៀនសូត្រស្តាប់តាមដំបូន្មានឪពុកម្តាយ និងលោកគ្រូ អ្នកគ្រូដើម្បីក្លាយខ្លួនទៅជាពលរដ្ឋល្អ ហើយយកចំណេះដឹងដែលមានទៅកសាងសង្គមឱ្យមានវឌ្ឍនភាព និងសន្តិភាព៕

# ប្រធានទី៩

នៅក្នុងកំណាព្យបណ្ដាំក្រមង៉ុយ អ្នកព្រះភិរម្យភាសាអ៊ូ បានពោលទុកថា៖ "កូនកាចបំពេញទុក្ខ ម្ដាយឪពុកមានបារម្ភ កូនស្លូតដឹងគួរសម មេបាថ្កុំថ្កើងកេរ្ដិ៍ឈ្មោះ"។ ចូរអ្នកបកស្រាយនូវកំណាព្យដកស្រង់នេះឱ្យបានក្បោះ

## គម្រោងតែង

### I. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ តាមធម្មជាតិ អ្នកមានស្វាមីភរិយា កាលបើគ្មានកូន ក៏ចង់តែបានកូន រហូតដល់បន់ព្រះសំពះទេវតា អារុក្ខ អារក្ស អ្នកតា វត្ថុសក្ដិសិទ្ធទាំងពួង ក្នុងគោលបំណងចង់បានកូន ដោយហេតុថាកូនជាសម្បត្តិរបស់មនុស្ស សម្រាប់បន្តពូជពង្សវង្សត្រកូល។ កូនខ្លះធំឡើងប្រកបទៅដោយគន្លងធម៌ ឯខ្លះទៀតប្រាសចាកគន្លងធម៌ ។
- ចំនួលបញ្ហា៖ ដោយសង្កេតឃើញដូច្នេះហើយទើបបានជាអ្នកព្រះភិរម្យភាសាអ៊ូ បានពោលទុកនៅក្នុងកំណាព្យបណ្ដាំក្រមង៉ុយរបស់លោកថា "កូនកាចបំពេញទុក្ខ ម្ដាយឪពុកមានបារម្ភ កូនស្លូតដឹងគួរសម មេបាថ្កុំថ្កើងកេរ្ដិ៍ឈ្មោះ"។
- ចំណោទបញ្ហា៖ តើកំណាព្យដកស្រង់ខាងលើមានបង្កប់នូវអត្ថន័យយ៉ាងដូចម្ដេចខ្លះ?

### II. តួសេចក្ដី

ក. ឃ្លាភ្ជាប់សេចក្ដី

ខ. ពន្យល់សំនួនពាក្យគន្លឹះ

- កូនកាច មានន័យថា កូនទាំងឡាយណាដែលមិនស្តាប់ដំបូន្មានឪពុកម្តាយ ជាកូនអកត្តញ្ញូ កូនដែលប្រាសចាកគន្លងធម៌ កូនដែលមិនគោរពមាតាបិតា គ្រូបាធ្យាយនិងខ្ជិលច្រអូសបង្ករឿងឥតឈប់ឈរ។ ក្នុងន័យនេះគេធៀបកូនកាចទៅនឹងពលរដ្ឋដែលមិនគោរពច្បាប់ទម្លាប់របស់រដ្ឋ បង្កផលលំបាកគ្រប់បែបយ៉ាងចំពោះជាតិមាតុភូមិ។
- កូនស្លូត សំដៅដល់ កូនទាំងឡាយណាដែលស្តាប់ដំបូន្មានឪពុកម្តាយ កូនល្អ កូនកត្តញ្ញូ កូនដែលលើកស្ទួយមុខមាត់ឪពុកម្តាយ។ ក្នុងន័យនេះគេធៀបកូនកាចទៅនឹងពលរដ្ឋគោរព និងអនុវត្តតាមច្បាប់ទម្លាប់ល្អរបស់ប្រទេស។

គ. ពន្យល់ន័យ

→ បញ្ហារបស់ប្រធានដែលបានលើកឡើងនេះមានន័យថា កូនគ្មានប្រយោជន៍ មានតែបង្កើតសេចក្តីហិនហោច ខ្លោចផ្សា ក្តៅក្រហាយចំពោះឪពុកម្តាយ ជាដង្កូវមេរោគនៃប្រទេសជាតិ ចំណែកឯកូនមានប្រយោជន៍ ឱ្យសេចក្តីចម្រើន កើតកាលវាលគុម្ព ត្រជាក់ត្រជុំ ចម្រុងចម្រើនដល់ក្រុមគ្រួសារ ញាតិមិត្ត រហូតដល់ប្រទេសជាតិទៀតផង។

ឃ. បំណកស្រាយ

➢ កូនកាចបំពេញទុក្ខ ម្តាយឪពុកមានបារម្ភ

- កូនល្ងង់ គឺជាកូនដែលគ្មានចំណេះវិជ្ជា តាំងពីវិជ្ជា អក្សរ ភាសា លេខនព្វន្ត រហូតដល់ល្ងង់ក្នុងកិច្ចការផ្សេងៗ ដោយម៉ែឪមិន

បានបញ្ជូនទៅសិក្សារអប់រំនូវវិជ្ជានានា ឬដោយកូននោះជាមនុស្សអៀនប្រៀន ខ្ជិលច្រអូស មិនព្រមសិក្សា ក៏ទៅជាកូនល្ងង់ងឹតឥតវិជ្ជា។ សេចក្ដីល្ងង់នៃកូននោះ មិនមានប្រយោជន៍អ្វីចំពោះកូននោះផង ចំពោះម៉ែឪវង្សត្រកូលផង ប្រទេសជាតិផង អាកប្បកិរិយាតាំងពីនិយាយស្ដីអ្វីក៏ឆ្គាំឆ្គងខុសទំនង ធ្វើការងារអ្វីមិនកើត ចូលជំនុំចំណោមមិនចុះ ជាទីពេបជ្រាយមើលងាយនៃជនទាំងឡាយ មិនអាចកសាងខ្លួនឱ្យមាំមួនស្ដុកស្ដម្ភដោយធនធាន មានកេរ្តិ៍ឈ្មោះ យសសក្តិ មិនអាចជាទីពឹងពាក់នៃម៉ែឪ គ្រួសារ ញាតិមិត្ត មិនអាចជួយឃឹតយោងជ្រោងស្ទួយវង្សត្រកូលឱ្យខ្ពង់ខ្ពស់បាន មានតែធ្វើឱ្យទាបទន់អន់ខ្សោយចុះ។

- កូនមិនប្រកបដោយធម៌ កូនគ្មានវិជ្ជា គ្មានបញ្ញា គឺកូនល្ងង់រមែងធ្វើឱ្យម៉ែឪពិបាកមួយផ្នែកហើយ បើកូននោះ មិនប្រកបដោយធម៌ផង ក៏រឹតតែធ្វើឱ្យម៉ែឪក្តៅក្រហាយ តឹងចិត្តផ្អែតទ្រូងថែមទៀត ដោយហេតុថាកូនដែលមិនប្រកបដោយគន្លងធម៌ ជាកូនប្រកបដោយកិរិយាការប្រព្រឹត្តិខុសក្រមក្រឹត្យឥតសុជីវធម៌ សុជីវធម៌ សីលធម៌ ចរិយាធម៌ ជូរជាតិ មារយាទព្រហើនកោងកាច ខិលខូច ឃោរឃៅ ពាលា ប៉ោទ្បេអាវ៉ាសែប្រព្រឹត្តិអាក្រក់ថោកទាប មានល្បួចប្លន់កាប់ចាប់ ជាប់នឹងអំពើអបាយមុខ បង្ហិនបំផ្លាញទ្រព្យសម្បត្តិ មនុស្សទាំងឡាយស្អប់ខ្ពើមឆ្អើមខ្ពាញ់ ស្អុយខូចកេរ្តិ៍ឈ្មោះចំពោះវង្សត្រកូល។ ដោយ

អំពើមិនប្រកបដោយធម៌នោះ អាចត្រូវទោសគុកច្រវាក់ ធ្វើឱ្យម៉ែឪខ្មាសគេ កើតទុក្ខក្ដៅក្រហាយយ៉ាងក្រៃលែង។

- កូនស្លូតដឹងគួរសម មេបាថ្កុំថ្កើងកេរ្ដិ៍ឈ្មោះ
- ផ្ទុយទៅវិញបើកូនដែលកើតមកហើយបានទទួលការសិក្សាអប់រំ មានចំណេះវិជ្ជាមុះមុត ដែលទទួលបានពីការខិតខំសង្វាតព្យាយាមសិក្សា មិនខ្ជិលច្រអូស មានការតាំងចិត្តខ្ពស់ មានស្មារតីភ្ញាក់រឭកប្រកបដោយ វិចារណញាណជាប់ជានិច្ចសមស្របតាមសេចក្ដីសង្ឃឹម សេចក្ដីរំពឹងទុករបស់ឪពុកម្ដាយ។ កូននោះនឹងយកចំណេះចេះដឹងរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់ពុកម៉ែ បងប្អូន ញាតិសន្ដាន ព្រមទាំងប្រើប្រាស់នូវចំណេះវិជ្ជារបស់ខ្លួនទៅបម្រើជាតិមាតុភូមិ ឱ្យឆ្ពោះទៅរកវឌ្ឍនភាពថ្កុំថ្កើងរុងរឿងត្រចះត្រចង់ជាលំដាប់។
- មិនត្រឹមតែមានចំណេះវិជ្ជាជ្រៅជ្រះទេ កូនស្លូតនៅមានកិរិយាប្រព្រឹត្តប្រកបដោយធម៌ផងដែរ ពោលគឺសមប្រកបទៅដោយគុណធម៌ សុជីវធម៌ សីលធម៌ ចរិយាធម៌ ស្គាល់បាបបុណ្យគុណទោស ស្គាល់ល្អស្គាល់អាក្រក់ ស្គាល់ចាស់ស្គាល់ទុំ។ ពួកគេជាកូនដែលមានប្រយោជន៍ចំពោះម៉ែឪពូជពង្សវង្សត្រកូល និងចំពោះជាតិមាតុភូមិថែមទៀតផងធ្វើឱ្យចិត្តម្ដាយឪពុកសោមនស្ស សុខសប្បាយ រីករាយ ប្រជាជនទាំងឡាយរាប់អានសរសើរ អាចធ្វើឱ្យគ្រួសារដែលទាបទន់អន់ខ្សោយ បានឡើងថ្កុំថ្កើងរុងរឿង ធ្វើឱ្យគ្រួសារដែលរុងរឿងស្រាប់ ឱ្យកាន់តែរុងរឿង

ឡើង ធ្វើឱ្យប្រទេសជាតិមានតម្លៃ អាស្រ័យពលរដ្ឋជាបញ្ញាវន្ត និងប្រកបដោយធម៌នោះ ប្រៀបបានដូចជាកែវភ្នែកដែលភ្លឺថ្លាត្រចះត្រចង់សម្រាប់មាតាបិតាគ្រប់រូប។

ង. សរុបសេចក្ដី

រួមសេចក្ដីមកកូនកាចតែងតែនាំមកនូវសេចក្ដីទុក្ខព្រួយដល់លោកអ្នកដ៏មានគុណគ្រប់ពេលវេលាឥតស្រាកស្រាន្ត រីឯកូនស្លូតរម៉ែងនាំមកនូវសេចក្ដីរីកចម្រើនរុងរឿងថ្កុំថ្កើងកេរ្តិ៍ឈ្មោះជូនដល់មាតាបិតាជាក់ជាមិនខានឡើយ។ បុត្រធីតាអាចនាំមកនូវភាព ដុនដាបនិងថ្កុំថ្កើងនៃមាតាបិតាមែនហើយ តែមាតាបិតាចាំបាច់ត្រូវតែរក្សានូវការអប់រំទូន្មានប្រៀនប្រដៅណែនាំ លើកទឹកចិត្ត ជួយឧបត្ថម្ភទំនុកបម្រុងកូន ជាពិសេសនោះគឺត្រូវធ្វើជាគម្រូដ៏ល្អសម្រាប់កូនជានិច្ច ប្រសិនបើចង់ឱ្យកូនប្រកបទៅតាមគន្លងធម៌។

## III. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន៖

ឆ្លងតាមរយៈការសរសេរបកស្រាយបំភ្លឺយ៉ាងពិស្ដាររួចមក យើងអាចសន្និដ្ឋានជាចុងក្រោយបានថា កំណាព្យដកស្រង់របស់អ្នកព្រះភិរម្យភាសាអ៊ូ ហៅង៉ុយនេះ ពិតជាតម្លៃយ៉ាងជ្រាលជ្រៅវិសេសវិសាលបំផុតដែលបានលើកយកមកបង្ហាញឱ្យឃើញពីតួនាទីរបស់កុលបុត្រ កុលធីតានៅក្នុងការគ្រួសារ ដោយហេតុថាឱនភាពនិងវឌ្ឍនភាពរបស់គ្រួសារ ជាពិសេសកេរ្តិ៍ឈ្មោះរបស់ឪពុកម្ដាយ អាស្រ័យទៅលើទង្វើ និងសកម្មភាព

របស់កូនៗ។ បើកូនអាក្រក់ពុកម៉ែទុក្ខព្រួយតែបើកូនល្អពួកលោកក៏បាន ខ្ពស់មុខខ្ពស់មាត់ទៅតាមនោះដែរ។

- ទស្សនៈផ្ទាល់ខ្លួន

ដូចនេះក្នុងនាមយើងទាំងអស់គ្នាអនុជនខ្មែរជំនាន់ក្រោយ គប្បីប្រព្រឹត្តខ្លួនជាកូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អ ដើម្បីជួយលើកស្ទួយកិត្តិយសគ្រួសារ ក៏ដូចជាសង្គមជាតិទាំងមូលឱ្យមានការអភិវឌ្ឍន៍ជឿនលឿនលើគ្រប់វិស័យ៕

## សេចក្តីអធិប្បាយ

តាមធម្មជាតិមនុស្សយើង កើតមកតែងតែចង់រស់នៅ ដោយប្រាថ្នាចងមិត្តមួយរយឆ្នាំនៃសុភមង្គលជីវិតរបស់ពួកគេ។ចំពោះ អ្នកមានស្វាមីភរិយា កាលបើគ្មានកូន ក៏ចង់តែបានកូន រហូតដល់បន់ព្រះសំពះទេវតា អារុក្ខអារក្ស អ្នកតា វត្ថុសក្តិសិទ្ធទាំងពួកក្នុងគោលបំណងចង់បានកូនព្រោះដោយហេតុថាកូនជាសម្បត្តិរបស់មនុស្ស សម្រាប់បន្តពូជពង្សវង្ស ត្រកូល។ កូនខ្លះធំឡើងប្រកបទៅដោយគន្លងធម៌ ឯខ្លះទៀតប្រាសចាកគន្លងធម៌ ។ដោយសង្កេតឃើញដូច្នេះហើយទើបបានជាអ្នកព្រះភិរម្យភាសាអ៊ូ បានពោលទុកនៅក្នុងកំណាព្យបណ្តាំក្រមង៉ុយរបស់លោកថា៖ “កូនកាចបំពេញទុក្ខ ម្តាយឪពុកមានបារម្ភ កូនស្លូតដឹងគួរសម មេបាថ្កុំថ្កើងកេរ្តិ៍ឈ្មោះ”។

តើកំណាព្យដកស្រង់ខាងលើមានបង្កប់នូវអត្ថន័យយ៉ាងដូចម្តេចខ្លះ?

មុននឹងឈានដល់ការបកស្រាយអត្ថន័យឃ្លាកំណាព្យខាងលើឲ្យមានន័យស៊ីជម្រៅជាដំបូងយើងគប្បីពន្យល់ពាក្យគន្លឹះមួយចំនួនសិនដូចជាពាក្យ "កូនកាច និង កូនស្លូត"ជាមុនសិន។ ពាក្យថា "កូនកាច" មានន័យថាកូនទាំងឡាយណាដែលមិនស្ដាប់ដំបូន្មានឪពុកម្ដាយ ជាកូនអកត្តញ្ញូ កូនដែលប្រាសចាកគន្លងធម៌ កូនដែលមិនគោរពមាតាបិតា គ្រូបាធ្យាយនិងខ្ជិលច្រអូសបង្ករឿងឥតឈប់ឈរ។ ចំណែកឯពាក្យថា "កូនស្លូត" វិញមានន័យថាសំដៅដល់ កូនទាំងឡាយណាដែលស្ដាប់ដំបូន្មានឪពុកម្ដាយ កូនល្អ កូនដែលមានភាពកត្តញ្ញូហើយនិងជាកូនដែលលើកស្ទួយមុខមាត់ឪពុកម្ដាយ។ ដូចនេះឃ្លាដែលបានលើកឡើងនេះមានន័យថា កូនគ្មានប្រយោជន៍ មានតែបង្កើតសេចក្ដីហិនហោចខ្លោចផ្សា ក្ដៅក្រហាយចំពោះឪពុកម្ដាយ ជាដង្កូវមេរោគនៃប្រទេសជាតិ។ ចំណែកឯកូន មានប្រយោជន៍ឱ្យសេចក្ដីចម្រើន កើតកាលវាលគុម្ពត្រជាក់ត្រជុំ ចម្រុងចម្រើនដល់ក្រុមគ្រួសារ ញាតិមិត្ត រហូតដល់ប្រទេសជាតិទៀតផង។

ជាការពិតណាស់កូនល្ងង់ គឺជាកូនដែលគ្មានចំណេះវិជ្ជា តាំងពីវិជ្ជា អក្សរ ភាសា លេខនព្វន្ត រហូតដល់ល្ងង់ក្នុងការធ្វើកិច្ចការផ្សេងៗ មិនមានគំនិតឈ្លាសវៃអាចដោះស្រាយបញ្ហាបានដោយខ្លួនពួកគេផ្ទាល់នោះឡើយ។កត្តាដែលបណ្ដាលឲ្យពួកគេក្លាយជាមនុស្សដូច្នោះអាចដោយសារ ឪពុកម្ដាយមិនបានបញ្ជូនពួកគេឲ្យទៅសិក្សាអប់រំនូវវិជ្ជានានា ឬដោយកូននោះជាមនុស្សអៀនប្រៀន ខ្ជិលច្រអូស មិនព្រមសិក្សា ក៏ទៅជាកូនល្ងង់ងងឹតឥតវិជ្ជា។ ដូចដែលយើងដឹងហើយថាសេចក្ដី

ល្ងង់នៃកូននោះ មិនមានប្រយោជន៍អ្វីចំពោះកូននោះផង ចំពោះម៉ែឪវង្ស ត្រកូលផង ប្រទេសជាតិផង អាកប្បកិរិយាតាំងពីនិយាយស្តីអ្វីក៏ឆ្គាំឆ្គង ខុសទំនង ធ្វើការងារអ្វីមិនកើត ចូលជំនុំចំណោមមិនចុះ ជាទីពេបជ្រាយ មើលងាយនៃជនទាំងឡាយ មិនអាចកសាងខ្លួនឱ្យមាំមួនស្តុកស្តម្ភដោយ ធនធាន មានកេរ្តិ៍ឈ្មោះ យសសក្តិ មិនអាចជាទីពឹងពាក់នៃម៉ែឪ គ្រួសារ ញាតិមិត្ត មិនអាចជួយឃឹតយោងជ្រោងស្ទួយវង្សត្រកូលឱ្យខ្ពង់ខ្ពស់បាន មានតែធ្វើឱ្យទាបទន់អន់ខ្សោយចុះ។ ជាក់ស្តែងក្នុងឋានៈជាអ្នកគ្រប់គ្រង ចំពោះកូនចៅ លោកទាំងពីរតែងតែ គិតគូរសព្វគ្រប់យ៉ាង ខ្លាចក្រែងកូន មិនបានល្អ មិនបានសុខសាន្ត បារម្ភជានិច្ច ចំពោះជោគវាសនាកូន ខ្លាច កូនមិនបានខ្ពង់ខ្ពស់។ ជាពិសេសទៅទៀតលោកបារម្ភតាំងពីក្មេងរហូត ដល់ធំ ខ្លាចកូនដើលេងល្បែងពាលា ធ្វើជាបងធំ សេពគប់ជាមួយមិត្តភក្តិ មិនល្អ មិនចូលសាលារៀន ដើរលេងខិលខូចផ្តេសផ្តាស មានស្រីញី ។ ម្យ៉ាងវិញទៀតកូនមិនប្រកបដោយធម៌ កូនគ្មានវិជ្ជា គ្មានបញ្ញា គឺកូន ល្ងង់រមែងធ្វើឱ្យម៉ែឪពិបាកមួយផ្នែកហើយ តែបើកូននោះ មិន ប្រកបដោយធម៌ផង ក៏រឹតតែធ្វើឱ្យម៉ែឪក្តៅក្រហាយ តឹងចិត្តឆ្អែតទ្រូង ថែមទៀត។ ដោយហេតុថាកូនដែលមិនប្រកបដោយគន្លងធម៌ ជាកូន ប្រកបដោយកិរិយាការប្រព្រឹត្តខុសក្រមក្រឹត្យ ឥតសុជីវធម៌ សុជីវធម៌ សីលធម៌ ចរិយាធម៌ ជួជាតិ មារយាទព្រហើនកោងកាច ខិលខូច ឃោរឃៅ ពាលា ប៉ោទ្បេអាវ៉ាសៃ ប្រព្រឹត្តិអាក្រក់ថោកទាប មានលួចប្លន់ កាប់ចាប់ ជាប់នឹងអំពើអបាយមុខ បង្ហិនបំផ្លាញទ្រព្យសម្បត្តិ មនុស្ស ទាំងឡាយស្អប់ខ្ពើមឆ្អើមខ្ពាញ់ និងស្អុយខូចកេរ្តិ៍ឈ្មោះចំពោះវង្សត្រកូល។

ទន្ទឹមនឹងនេះហើយដោយអំពើមិនប្រកបដោយធម៌នោះ ពួកគេអាចត្រូវទោសគុកច្រវាក់ ធ្វើឱ្យម៉ែឪខ្មាសគេ កើតទុក្ខក្តៅក្រហាយយ៉ាងក្រៃលែង។ ក្នុងករណីណាដែលកូនមិនបានដោយគន្លងធម៌ មិនខំរៀនសូត្រគេចសាលា ឈ្លោះទាស់ទែងគ្នា ប្រព្រឹត្តល្បែងស៊ីសងគ្រប់ប្រភេទ បៀ ហ្គេម ប៊ីយ៉ា ប្រនាំងម៉ូតូ ដើរលេងខុសបែបខុសបទ សង្សារស្រីញី សេពគប់ជាមួយនិង បាបមិត្ត អាចរហូតដល់ពាក់ព័ន្ធនឹងគ្រឿងញៀន នោះឪពុកម្តាយក៏ដូចជារដ្ឋ អំណាចថ្នាក់ដឹកនាំ តែងតែទទួលបាននូវការអាប់ឱនកិត្តិយស ផលប្រយោជន៍ ការប្រមាថមើលងាយ ការបង់ខាតទ្រព្យធនទាំងបុគ្គលទាំងជាតិ ព្រោះកាលណាប្រទេសមួយដែលពោរពាស ទៅដោយជនអគតិដូចខាងលើនោះ តើមានទេសចរណាមួយដែលគេនឹងហ៊ានចូលមកធ្វើដំណើរកំសាន្តនៅក្នុងប្រទេសយើងនោះ។

ផ្ទុយទៅវិញបើកូនដែលកើតមកហើយបានទទួលការសិក្សាអប់រំមានចំណេះវិជ្ជាមុះមុតដែលទទួលបានពីការខិតខំសង្វាតព្យាយាមសិក្សាមិនខ្ជិលច្រអូស មានការតាំងចិត្តខ្ពស់ មានស្មារតីភ្ញាក់រឭកប្រកបដោយវិចារណញ្ញាណជាប់ជានិច្ច សមស្រប តាមសេចក្តីសង្ឃឹម សេចក្តីរំពឹងទុករបស់ឪពុកម្តាយ។ យើងសង្កេតឃើញថាកូននោះនឹងយកចំណេះចេះដឹងរបស់ខ្លួនដើម្បីជាប្រយោជន៍ដល់ពុកម៉ែបងប្អូន ញាតិសន្តាន ព្រមទាំងប្រើប្រាស់នូវចំណេះវិជ្ជារបស់ខ្លួនទៅបម្រើជាតិមាតុភូមិ ឱ្យឆ្ពោះទៅរកវឌ្ឍនភាពថ្កុំថ្កើងរុងរឿងត្រចះត្រចង់ជាលំដាប់។ក្នុងករណីដែលឪពុកម្តាយ ឬប្រទេសដែលមានកូនចៅមានការយល់ដឹងប្រកបដោយគន្លងធម៌ ស្តាប់និងធ្វើតាមការប្រៀនប្រដៅរបស់ ឪពុកម្តាយ លោកគ្រូអ្នកគ្រូ

ខិតខំធ្វើការ ខំតខំរៀនសូត្រ ធ្វើតែអំពើជាកុសល គោរពចាស់ទុំ ព្រឹទ្ធាចារ្យ ព្រះសង្ឃ លោកអាចារ្យ ដូនជី វៀរចាកនូវអបាយមុខទាំងប្រាំមួយប្រការ នោះនឹងតែងមានមុខមានកិត្តិយស ដោយសារត្រូវបានមជ្ឈដ្ឋាន ខាងក្រៅកោតសរសើរស្ញប់ស្ញែងមានអនាគតល្អ ហើយប្រែក្លាយទៅជាពលរដ្ឋដ៏ល្អ ។ ដរាបណាជាតិមួយដែលសំបូរទៅដោយកូនល្អ សិស្សល្អ និងពលរដ្ឋល្អ ដរាបនោះកេរ្តិ៍ឈ្មោះខ្លួនឯងផ្ទាល់ គ្រួសារផ្ទាល់ លោកឪពុកអ្នកម្តាយ លោកតាលោកយាយ ក៏ដូចជាមាតុភូមិនឹងបានខ្ពង់ខ្ពស់ មានកេរ្តិ៍ឈ្មោះមានកិត្តិសព្ទ បញ្ជាក់នូវភាពថ្លៃថ្នូររុងរឿង ហើយប្រទេសបែបនេះ នឹងក្លាយទៅជាអារ្យប្រទេស ដើរទាន់ជំហានរីកចម្រើននៃអារ្យប្រទេសនានា លើសកលលោក ។មិនត្រឹមតែមានចំណេះវិជ្ជាជ្រៅជ្រះទេ កូនស្លូតនៅមានកិរិយាប្រព្រឹត្តប្រកបដោយធម៌ផងដែរ ពោលគឺសមប្រកបទៅដោយគុណធម៌ សុជីវធម៌ សីលធម៌ ចរិយាធម៌ ស្គាល់បាបបុណ្យ គុណទោស ស្គាល់ល្អស្គាល់អាក្រក់ ស្គាល់ចាស់ស្គាល់ទុំ។ ជាពិសេសពួកគេជាកូនដែលមានប្រយោជន៍ចំពោះម៉ែឪពូជពង្សវង្សត្រកូល និងចំពោះជាតិមាតុភូមិថែមទៀតផងធ្វើឱ្យចិត្តម្តាយឪពុក សោមនស្សសុខសប្បាយ រីករាយ ប្រជាជនទាំងឡាយរាប់អានសរសើរ អាចធ្វើឱ្យគ្រួសារដែលទាបទន់អន់ខ្សោយ បានឡើងថ្កុំថ្កើងរុងរឿង ធ្វើឱ្យគ្រួសារដែលរុងរឿងស្រាប់ ឱ្យកាន់តែរុងរឿងឡើង ធ្វើឱ្យប្រទេសជាតិមានតម្លៃអាស្រ័យពលរដ្ឋជាបញ្ញាវន្ត និងប្រកបដោយធម៌នោះ ប្រៀបបានដូចជាកែវភ្នែកដែលភ្លឺថ្លាត្រចះត្រចង់សម្រាប់មាតាបិតាគ្រប់រូប។

រួមសេចក្ដីមកកូនកាចតែងតែនាំមកនូវសេចក្ដីទុក្ខព្រួយដល់លោកអ្នកដ៏មានគុណគ្រប់ពេលវេលាឥតស្រាកស្រាន្ត រីឯកូនស្លូតវិមែងនាំមកនូវសេចក្ដីរីកចម្រើនរុងរឿងថ្កុំថ្កើងកេរ្តិ៍ឈ្មោះជូនដល់មាតាបិតាជាក់ជាមិនខានឡើយ។ បុត្រធីតាអាចនាំមកនូវភាព ដុនដាបនិងថ្កុំថ្កើងនៃមាតាបិតាមែនហើយ តែមាតាបិតាចាំបាច់ត្រូវតែរក្សានូវការអប់រំទូន្មានប្រៀនប្រដៅណែនាំ លើកទឹកចិត្ត ជួយឧបត្ថម្ភទំនុកបម្រុងកូន ជាពិសេសនោះគឺត្រូវធ្វើជាគម្រូដ៏ល្អសម្រាប់កូនជានិច្ច ប្រសិនបើចង់ឱ្យកូនប្រកបទៅតាមគន្លងធម៌។

ឆ្លងតាមរយៈការសរសេរបកស្រាយបំភ្លឺយ៉ាងពិស្ដាររួចមក យើងអាចសន្និដ្ឋានជាចុងក្រោយបានថា កំណាព្យដកស្រង់របស់អ្នកព្រះភិរម្យភាសាអ៊ូ ហៅង៉ុយនេះ ពិតជាតម្លៃយ៉ាងជ្រាលជ្រៅវិសេសវិសាលបំផុតបានអប់រំយុវជនខ្មែរដើរលើផ្លូវត្រូវ គឺខិត ខំរៀនសូត្រអោយបានចេះដឹងជ្រៅជ្រះ ទាន់ខ្លួននៅក្មេង ដើម្បីលើកតម្កើងខ្លួនឯង គ្រួសារ ឪពុកម្ដាយ និង មាតុភូមិ អោយមានកេរ្តិ៍ឈ្មោះមានកិត្តិយស សក្តិសមជាពលរដ្ឋខ្មែរធ្លាប់មានកិត្យានុភាព តាំងពីយូរណាស់មកហើយ។ បើកូនអាក្រក់ ពុកម៉ែទុក្ខព្រួយ តែបើកូនល្អ ពួកលោកក៏បានខ្ពស់មុខខ្ពស់មាត់ទៅតាមនោះដែរ។ ដូចនេះក្នុងនាមយើងទាំងអស់គ្នាអនុជនខ្មែរជំនាន់ក្រោយ គប្បីប្រព្រឹត្តខ្លួនជាកូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អ ដើម្បីជួយលើកស្ទួយកិត្តយសគ្រួសារ ក៏ដូចជាសង្គមជាតិទាំងមូលឱ្យមានការអភិវឌ្ឍន៍ជឿនលឿនលើគ្រប់វិស័យ៕

# ប្រធានទី១០

មានមតិជាច្រើនបានលើកឡើងថា៖ "ចំណេះវិជ្ជា មានតម្លៃយ៉ាងវិសេសដែលអាចធ្វើឱ្យមនុស្សមានសុភមង្គលយូរអង្វែងបាន"។ ចូរពន្យល់ឱ្យបានក្បោះក្បាយព្រមទាំងលើកឧទាហរណ៍បញ្ជាក់ផង។

## គម្រោងតែង

### I. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ ឆ្លងកាត់នូវបទពិសោធរបស់មនុស្ស យើងឃើញថាដំណើរជីវិតរបស់មនុស្សគ្រប់រូបពោរពេញទៅដោយឧបសគ្គរាប់មិនអស់។ ឧបសគ្គទាំងនោះបានធ្វើអោយមនុស្សចេះប្រើប្រាជ្ញាដើម្បីដោះស្រាយភាពទាល់ច្រករបស់ខ្លួន ហើយទោះបីជាឧបសគ្គធំឬតូចយ៉ាងណាក៏ដោយក៏មនុស្សម្នាក់ៗប្រើប្រាស់ខួរក្បាល បានផ្ទុកទៅដោយចំណេះវិជ្ជាយកមកដោះស្រាយបានប្រកបដោយជោគជ័យ។
- ចំណូលបញ្ហា៖ ហេតុនេះហើយទើបមានមតិជាច្រើនយល់ឃើញថា "ចំណេះវិជ្ជា មានតម្លៃយ៉ាងវិសេសដែលអាចធ្វើឱ្យមនុស្សមានសុភមង្គលយូរអង្វែងបាន"។
- ចំណោទបញ្ហា៖ តើទស្សនៈរបស់ប្រធានដែលបានលើកឡើងខាងលើមានអត្ថន័យដូចម្ដេចដែរ?

### II. តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្តី៖ មុននឹងធ្វើការបកស្រាយទស្សនៈខាងលើនេះយើងគប្បីយល់នៅពាក្យគន្លឹះមួយចំនួនជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ៖ ពាក្យថា "ចំណេះវិជ្ជា"សំដៅដល់ការចេះដឹងនៅផ្នែកជំនាញ ផ្សេងៗ។ ចំណែកឯពាក្យ "សុភមង្គល" មានន័យថាមង្គលល្អឬសេចក្តីសុខទាំងផ្លូវចិត្តនិងផ្លូវ កាយ។
- ពន្យល់ន័យប្រធាន៖ អត្ថន័យរបស់ប្រធាននេះចង់និយាយថាការចេះដឹងនូវជំនាញផ្សេងៗអោយពិតប្រាកដរមែងនាំមកនូវសេចក្តីសុខទាំងផ្លូវកាយនិងផ្លូវចិត្តបានយូរអង្វែង ផ្ទុយទៅវិញបើមនុស្សមិនមានចំណេះវិជ្ជាទេ និងធ្វើការតាមរយៈការប្រើកំលាំងបាយសុទ្ធសាធនោះ ក៏មិនបានទទួលផលល្អប្រសើរដូចអ្នកដែលមានតម្រិះវិជ្ជានោះដែរ។
- បកស្រាយប្រធាន៖ ជាការពិតណាស់ការដែលមានចំណេះវិជ្ជាឬជំនាញណាមួយ ណាមួយឱ្យបានច្បាស់លាស់រមែងអោយយើងមានភាពងាយស្រួល ក្នុងការប្រកបការងារ និងធ្វើ អោយមានសេចក្តីសុខ សុភមង្គល ហើយមានកិត្តិយសថែមទៀតផង
  - សម្រាប់ការសិក្សារបស់សិស្សឬយុវជននោះក៏ជាការអភិវឌ្ឍខ្លួន ក្នុងការពង្រីងសមត្ថភាពនិងគុណភាពតាំងពីចំណេះដឹងទូទៅនិងតាំងពីថ្នាក់តូចឡើងទៅជាបន្តបន្ទាប់រហូតដល់ថ្នាក់ខ្ពស់។

- មានចំណេះវិជ្ជា មិនងាយនិងចាញ់បោក អាចបញ្ចៀសផុតពីការគេងប្រវ័ញ្ចគ្រប់រូបភាពពីជនខិលខូចនៅក្នុងសង្គម
- មានចំណេះវិជ្ជាអាចជួយមនុស្សឱ្យមានគំនិតឆ្នៃប្រឌិតខ្ពស់ មិនធ្វើរឿងដដែល ឬចាំតែគេប្រាប់ និយាយាថាអាចអភិវឌ្ឍខ្លួនឯងឱ្យកាន់តែប្រសើរជាងមុនដោយមិនចាំបាច់គេបង្ហាញប្រាប់រហូត
- មានចំណេះវិជ្ជាធ្វើឱ្យមនុស្សស្វែងរកភាពត្រឹមត្រូវ យុត្តិធម៌ បំបាត់អំពើពុករលួយដែលកើតមានក្នុងសង្គម

- ...........................................................................................................
- ក្នុងសង្គមជាក់ស្តែង៖

សម្តេចព្រះសង្ឃរាជ ជួនណាត ព្រះអង្គជាបុគ្គលដែលមានចំណេះដឹងជ្រៅជ្រះ មានប្រាជ្ញាឈ្លាសវៃ ព្រះអង្គបង្កើតស្នាដៃជាច្រើន ជាពិសេស វចនានុក្រមខ្មែរ...ធ្វើឱ្យកិត្តនាមរបស់ព្រះអង្គល្បីល្បាញ ទទួលសាទរគ្រប់មជ្ឈដ្ឋាន...។

- ខ. ក្នុងប្រវត្តសាស្ត្រ
  - ព្រះបាទអង្គឌួង មិនត្រឹមតែជាក្សត្រដែលគិតគូពីប្រទេសលើការឈ្លានពានពីយួននឹងសៀមទេ ព្រះអង្គជាអ្នកមានចំណេះដឹងជ្រៅជ្រះ និងជាអ្នកនិពន្ធខ្មែរល្បីល្បាញមួយរូបក្នុងសម័យកាលនោះផងដេរ ព្រះអង្គពូកែខាងកំណាព្យកាព្យឃ្លោង។ព្រះអង្គបាននិពន្ធរឿង ចំប៉ាថោង, ច្បាប់ស្រី, កាកី ជាដើម។

គ. ក្នុងអក្សរសិល្ប៍

- រឿងកុលាបប៉ៃលិនៈ ដោយសារតែចំណេះវិជ្ជា ធ្វើឱ្យតួអង្គចៅចិត្ររំដោះខ្លួនចេញពីភាពកម្មករ មកជាអ្នកត្រួតមើលបញ្ជីត្បូងរួចក្លាយជាកូនប្រសារថៅកែត្បូងថែមទៀត។
- រឿងធនញ្ជ័យៈ តួអង្គធនញ្ជ័យត្រូវបានទទួលរងនូវការប្រមាថពីសំណាក់មន្ត្រីខិលខូចមានទាំងសេដ្ឋី និងស្តេចផង តែដោយសារធនញ្ជ័យមានប្រាជ្ញាធនញ្ជ័យអាចការពារខ្លួនបានគ្រប់ពេល។
- រឿង ជីវិតក្មេងកំព្រាៈ ជីវិតកុមារប្អូននៅពេលដែលឪពុកចែកឋានទៅ គេបានរៀនចេះ ចាំស្ទាត់ពីវិជ្ជាដែលឪពុកបានបន្សល់ទុករហូតធ្វើឱ្យជីវិតគេមានសេចក្តីសុខ មានមាសប្រាក់ ក្លាយជាស្តេច...។

- សរុបសេចក្តីៈ សរុបមកចំណេះវិជ្ជានាំឱ្យមនុស្សមានវិន័យ និងសេចក្តីថ្លៃថ្នូរក្នុងជីវិតរស់នៅ។

## III. បញ្ចប់សេចក្តី

- វាយតម្លៃប្រធានៈ ឆ្លងតាមការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថា មតិរបស់ប្រធានពិតជាត្រឹមត្រូវដែលអាចយកជាគតិអប់រំមនុស្សគ្រប់រូបឱ្យខិតខំរៀនសូត្រ។
- មតិផ្ទាល់ខ្លួនៈ ដូចនេះយុវជនទាំងឡាយ មិនត្រូវបណ្តោយឱ្យពេលវេលាដ៏មានតម្លៃក្នុងការសិក្សារៀនសូត្រកន្លងទៅឥតប្រយោជន៍ឡើយ។

# សេចក្តីអធិប្បាយ

ឆ្លងកាត់នូវបទពិសោធរបស់មនុស្ស យើងឃើញថាដំណើរជីវិតរបស់មនុស្សគ្រប់រូបពោរពេញទៅដោយឧបសគ្គរាប់មិនអស់។ ឧបសគ្គទាំងនោះបានធ្វើអោយមនុស្សចេះប្រើប្រាជ្ញាដើម្បីដោះស្រាយភាពទាល់ច្រករបស់ខ្លួន ហើយទោះបីជាឧបសគ្គធំឬតូចយ៉ាងណាក៏ដោយក៏មនុស្សម្នាក់ៗប្រើប្រាស់ខួរក្បាលបានផ្ទុកទៅដោយចំណេះវិជ្ជាយកមកដោស្រាយបានប្រកបដោយជោគជ័យ។ហេតុនេះហើយទើបមានមតិជាច្រើនយល់ឃើញថា៖ "ចំណេះវិជ្ជា មានតម្លៃយ៉ាងវិសេសដែលអាចធ្វើឱ្យមនុស្សមានសុភមង្គលយូរអង្វែងបាន"។

តើទស្សនៈរបស់ប្រធាន ដែលបានលើកឡើងខាងលើមានអត្ថន័យដូចម្តេចដែរ?

មុននឹងធ្វើការបកស្រាយទស្សនៈខាងលើនេះយើងគប្បីយល់នៅពាក្យគន្លឹះមួយចំនួនជាមុនសិន។ពាក្យថា "ចំណេះវិជ្ជា"សំដៅដល់ការចេះដឹងនៅផ្នែកជំនាញផ្សេងៗ។ចំណែកឯពាក្យ "សុភមង្គល"មានន័យថាមង្គលល្អឬសេចក្តីសុខទាំងផ្លូវចិត្តនិងផ្លូវកាយ។ អត្ថន័យរបស់ប្រធាននេះចង់និយាយថា ការចេះដឹងនូវជំនាញផ្សេងៗអោយពិតប្រាកដរមែងនាំមកនូវសេចក្តីសុខទាំងផ្លូវកាយនិងផ្លូវចិត្តបានយូរអង្វែង ផ្ទុយទៅវិញបើមនុស្សមិនមានចំណេះវិជ្ជាទេ និងធ្វើការតាមរយៈការប្រើកំលាំងបាយសុទ្ធសាធនោះ ក៏មិនបានទទួលផលល្អប្រសើរដូចអ្នកដែលមានតម្រិះវិជ្ជានោះដែរ។

ជាការពិតណាស់ការដែលមានចំណេះវិជ្ជា ឬជំនាញណាមួយណាមួយឱ្យបានច្បាស់ លាស់រមែងអោយយើងមានភាពងាយស្រួលក្នុងការប្រកបការងារនិងធ្វើអោយមានសេចក្ដីសុខសុភ-មង្គល ហើយមានកិត្តិយសថែមទៀតផង។ ជាមួយគ្នាផងដែរសម្រាប់ការសិក្សារបស់សិស្ស ឬយុវជននោះក៏ជាការអភិវឌ្ឍខ្លួន ក្នុងការពង្រឹងសម្ថតភាពនិងគុណភាពតាំងពីចំណេះដឹងទូទៅនិងតាំងពីថ្នាក់តូចឡើងទៅជាបន្តបន្ទាប់រហូតដល់ថ្នាក់ខ្ពស់។ មានចំណេះវិជ្ជា មិនងាយនិងចាញ់បោក អាចបញ្ចៀសផុតពីការគេងប្រវ័ញ្ចគ្រប់រូបភាពពីជនខិលខូចនៅក្នុងសង្គម។ វិជ្ជានាំឱ្យយើងមានទ្រព្យសម្បត្តិធូធារ ព្រោះបើកាលណាយើងចេះធ្វើអ្វីមួយពិតប្រាកដ យើងយកវិជ្ជានោះទៅប្រកបរបរទទួលទាន និងផ្គត់ផ្គង់ជីវភាពគ្រួសារបានយ៉ាងងាយស្រួល។ មានចំណេះវិជ្ជាអាចជួយមនុស្សឱ្យមានគំនិតឆ្នៃប្រឌិតខ្ពស់ មិនធ្វើរឿងដដែល ឬចាំតែគេប្រាប់ និយាយាថាអាចអភិវឌ្ឍខ្លួនឯងឱ្យកាន់តែប្រសើរជាងមុនដោយមិនចាំបាច់គេបង្ហាញប្រាប់រហូត។ មានន័យថានៅពេលមានចំណេះដឹង ដូចជាការរៀបចំកន្លែងឱ្យទាក់ទាញ គេអាចធ្វើជាគំរូមុន ដឹងពីរបៀបរបបនៃការតុបតែងធ្វើជាប្លង់ ជាគម្រោងទើបគេយកមកអនុវត្ត ទីបំផុតគេនឹងបាននូវអ្វីដែលគេចង់បានដោយការច្នៃប្រឌិតគំនិតរបស់ខ្លួន។ មានចំណេះវិជ្ជាធ្វើឱ្យមនុស្សស្វែងរកភាពត្រឹមត្រូវ យុត្តិធម៌ បំបាត់អំពើពុករលួយដែលកើតមានក្នុងសង្គម។ មានន័យថា ប្រសិនគេជួបនឹងភាពអយុត្តិធម៌ណាមួយគេនឹងស្វែងរកការពិត ស្វែងរកមេធាវី ស្វែងពីគន្លឹះដែលនាំឱ្យកើតរឿងនេះឡើយ ហើយគេអាចបកស្រាយ តស៊ូ ឬសញ្ចៀសខ្លួនមិនឱ្យរូបភាព

ទាំងនោះកើតមានចំពោះខ្លួន ធ្វើយ៉ាងណាឱ្យជីវិតរស់នៅស្រួល។ បើយើងងាកមកមើលនៅក្នុងសង្គមអតីតកាល ដូចជាសម្ដេចព្រអសង្ឃរាជ ជួន ណាត លោកជាបុគ្គលដែលមានចំណេះវិជ្ជាជ្រៅជ្រះ លោកបានត្រួសត្រាយជីវិតរបស់ព្រះអង្គឱ្យមានកិត្តនាមល្បីល្បាញតាមរយៈស្នាដៃរបស់ព្រះអង្គ។ សម្ដេចខិតខំបង្កើតនូវវចនានុក្រមខ្មែរ បទភ្លេងជាតិ និងស្នាដៃជាច្រើនទៀត។ ចំណុចនោះហើយដែលធ្វើឱ្យជីវិតរបស់ព្រះអង្គមានសេចក្ដីសុខ និងរីករាយជាទីបំផុត។ ប្រវត្តិសាស្ត្រខ្មែរយើងវិញ នាសម័យកណ្ដាល ព្រះបាទអង្គឌួងមិនត្រឹមតែជាក្សត្រដែលគិតគូពីប្រទេសលើការឈ្លានពានពីយួននឹងសៀមទេ ព្រះអង្គជាអ្នកមានចំណេះដឹងជ្រៅជ្រះ និងជាអ្នកនិពន្ធខ្មែរល្បីល្បាញមួយរូបក្នុងសម័យកាលនោះផងដែរ ព្រះអង្គពូកែខាងកំណាព្យកាព្យឃ្លោង។ព្រះអង្គបាននិពន្ធរឿង ចំប៉ាថោង ច្បាប់ស្រី កាកី ជាដើម។ រីឯនៅក្នុងអក្សរសិល្ប៍យើងវិញ យើងឃើញថារឿងកុលាបប៉ៃលិនដោយសារតែចំណេះវិជ្ជា ធ្វើឱ្យតួអង្គចៅចិត្ររំដោះខ្លួនចេញពីភាពកម្មករ មកជាអ្នកត្រួតមើលបញ្ជីត្បូងរួចក្លាយជាកូនប្រសារថៅកែត្បូងថែមទៀត។ ចំណែកក្នុង រឿងធនញ្ជ័ន តួអង្គធនញ្ជ័យត្រូវបានទទួលរងនូវការប្រមាថពីសំណាក់មន្ត្រីខិលខូចមានទាំងសេដ្ឋី និងស្ដេចផង តែដោយសារធនញ្ជ័យមានប្រាជ្ញាធនញ្ជ័យអាចការពារខ្លួនបានគ្រប់ពេល ដូចជាយកកូនមាន់ និងកូនដំរីទៅប្រជល់ជាមួយនឹងមាន់ដំរីរបស់ស្ដេច យកសេះចត្រង្គរត់តាមស្ដេចទៅប្រពាតព្រៃ ធ្វើមាន់ឈ្មោលរងាវនៅក្នុងទឹកជាដើម។ផលប្រយោជន៍នៃចំណេះវិជ្ជាមួយទៀតគឺអាចបង្កើតឬច្នៃប្រឌិតនៅផលលិតផល គ្រប់បែបយ៉ាងដើម្បីរំដោះខ្លួន

ពីគ្រោះអាសន្នផ្សេងៗ។ ពេលទៅដល់ស្រុកចិនធនញ្ជ័យធ្វើនំបញ្ចុកលក់ដើម្បីយកប្រាក់ចិញ្ចឹមខ្លួន។លុះពេលជាប់គុកក្នុងគុកសំរិទ្ធ ធនញ្ជ័យចេះធ្វើខ្លែងឯកចង្ក្រោះបំភ័យស្តេចចិន ធ្វើឱ្យស្តេចចិនភិតភ័យក៏ដោះលែងធនញ្ជ័យ រួចបញ្ជូនត្រឡប់មកស្រុកខ្មែរវិញដោយមានបរិវារ និងមានទ្រព្យសម្បត្តិហែរហមមកជាមួយផង។ ក្រៅពីនេះការរកកម្រៃទាយយកទ្រព្យសម្បត្តិចំណេះវិជ្ជាក៏អាចជួយយើងឱ្យមានសេចក្តីសុខផ្នែកផ្លូវកាយបានយ៉ាងងាយស្រួល ដូចជាការស្វែងយល់ពីសុខភាពអនា-ម័យ បរិស្ថានការយល់ដឹងពីជំងឺផ្សេងៗ ដូចជាវិធីការពារខ្លួនឱ្យរួចផុតពីជំងឺគ្រប់ប្រភេទ។យ៉ាងណាមិញដូចជាចៅចិត្រត្រូវទៅរស់នៅតំបន់ប៉ៃលិនដែលជាស្រុកដែលមានជំងឺគ្រុនចាញ់ តែដោយសារការជួយពន្យល់ពីគ្រូពេទ្យស្អាត គួបផ្សំនឹងចំនេះដឹងដែលបានរៀននៅសាលាផង ចៅចិត្រអាចថែរក្សាសុខភាពបានល្អប្រសើរ។ ម្យ៉ាងវិញទៀតចំណេះវិជ្ជាបានជួយសម្រាលបន្ទុកយើងឱ្យរួចផុតពីការងារដែលប្រើកំលាំងបាយ ដូចជាកម្មករសែងធ្ងន់ៗ ដូចករណីចៅចិត្រអីចឹង។ ពីដំបូងក៏ជាកម្មករដូចគេដែលក៏ប៉ុន្តែដោយសារតែចៅចិត្រមានចំណេះវិជ្ជាក៏បានឡើងឋានៈជាអ្នកមើលការខុសត្រូវវិញម្តង។ រីឯរឿង ក្មេងកំព្រា ក្រោយពីឪពុកទទួលមរណកាលទៅ ក្មេងទាំងពីរខិតខំបន្តការងារពីឪពុក ដែលគេបានរៀនចាំស្ទាត់កាលពីឪពុកនៅរស់។ កុមារទាំងពីរចេះធ្វើជុកដាក់សត្វតូចរហូតដល់សត្វធំ ។ នៅពេលដែលពួកគេប្រើជំនាញរបស់ខ្លួនបានយ៉ាងស្ទាត់ មិនតែប៉ុណ្ណោះ ពួកគេក៏ធ្វើជុកធំសម្រាប់ដាក់យក្ស រហូតសម្រេច។ ទីបំផុត

ចំណេះ និងការខំប្រឹងធ្វើការរបស់ពួកគេ បានធ្វើឱ្យជីវិតរស់នៅយ៉ាងមានសេចក្តីសុខ។

សរុបមកចំណេះវិជ្ជានាំឱ្យមនុស្សមានវិន័យ និងសេចក្ដីថ្លៃថ្នូរក្នុងជីវិតរស់នៅ ព្រោះចំណេះវិជ្ជាអាចតម្រង់មនុស្សឱ្យប្រកបតែរបរណាដែលសុចរិតត្រឹមត្រូវ មិនប៉ះពាល់សិទ្ធិអ្នកដទៃ មិនប្រព្រឹត្តិអំពើដែលខុសច្បាប់។ ហើយវិជ្ជាធ្វើឱ្យមនុស្សមានឯករាជ្យភាព ព្រោះមិនចាំបាច់រស់នៅដោយពឹងពាក់លើអ្នកដទៃ ពោលគឺអាចរស់នៅដោយខ្លួនឯងបាន។ កាលណាមនុស្សមានការងារធ្វើ រកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារបានធូរធារ នោះនឹងមានការកោតសរសើរ ពីគ្រប់មជ្ឈដ្ឋាន ដែលអាចញ៉ាំងជីវិតឱ្យរស់នៅចុះចម្រុងចាមួយអ្នកដទៃប្រកបដោយសុខដុមរមនា។ ដូចនេះយើងឃើញថា វិជ្ជាពិតជាបាននាំមកនូវសុភមង្គលទាំងផ្លូវកាយ នឹងផ្លូវចិត្តដល់មនុស្សលោកពិតប្រាកដមែន។

ឆ្លងតាមការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថាប្រធានពិតជាមានតម្លៃអប់រំដែលអាចយកជាគតិអប់រំមនុស្សគ្រប់រូបឱ្យខិតខំរៀនសូត្រស្វះស្វែងរកចំណេះវិជ្ជាមកទុកក្នុងខ្លួនដើម្បីញ៉ាំងជីវិតឱ្យមានភាពរីករាយ និងមានសុភមង្គលសមដូចពាក្យចាស់មួយពោលថា "បើចេះប្រាកដប្រាក់រត់តាមហៅ"។ ប៉ុន្តែត្រូវចងចាំថាចំណេះវិជ្ជាទាំងនោះត្រូវតែប្រកបដោយក្រមសីលធម៌ផង។ដូចនេះយុវជនទាំងឡាយ មិនត្រូវបណ្តោលឱ្យពេលវេលាដ៏មានតម្លៃក្នុងការសិក្សារៀនសូត្រកន្លងទៅអសារបង់ឡើយ។

# ប្រធានទី១១

មានទស្សនៈមួយលើកឡើងថា៖"សង្គមជាអ្នកកំណត់ជោគវាសនាមនុស្ស"។ តើទស្សនៈនេះត្រឹមត្រូវឬទេ? ចូរពិភាក្សា ដោយលើកយកអក្សរសិល្ប៍ខ្មែរមកបញ្ជាក់ឱ្យបានច្បាស់លាស់។

## គម្រោងតែង

### I. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ មនុស្សម្នាក់ៗរស់នៅក្នុងសង្គមមួយ រមែងទទួលឥទ្ធិពលនៃសង្គមនោះមកលើការរស់នៅរបស់ពួកគេ។
- ចំណូលបញ្ហា៖ ដោយសារតែការទទួលឥទ្ធិពលនេះ ទើបធ្វើឱ្យមានទស្សនៈខ្លះលើកឡើងថា " សង្គមជាអ្នកកំណត់ជោគវាសនាមនុស្ស"។
- ចំណោទបញ្ហា៖ តើទស្សនៈនេះត្រឹមត្រូវឬទេ?

### II. តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី៖ ដើម្បីបកស្រាយប្រធានខាងលើឱ្យបានស៊ីជម្រៅ យើងត្រូវយល់ន័យពាក្យគន្លឹះជាមុនសិន។
- ពន្យល់ពាក្យ៖ "សង្គម" មានន័យថាជាការប្រមូលផ្ដុំនៃមនុស្សការរស់នៅជាក្រុម ឬ ជាសង្កាត់មួយដែលជាទីប្រជុំនៃមនុស្សមួយក្រុម អាចជាស្ថានភាព ឬមនុស្សដែលរស់នៅក្នុងសង្គម។ កន្សោមពាក្យ "កំណត់ជោគវាសនា" មានន័យថា ជាគូសវាសដំណើរជីវិត ជាការកំណត់ជោគជតានៃមនុស្សម្នាក់ៗ។

- ពន្យល់ប្រធាន៖ ទស្សនៈប្រធានដែលលើកឡើងនេះមានន័យថា សង្គមជាអ្នក គូសវាសនូវដំណើរជីវិតនៃមនុស្សម្នាក់ៗដែលរស់នៅក្នុងសង្គម។
- បកស្រាយប្រធាន

+ មតិស្រប៖ មែន! ប្រទេស ឬសង្គមបែបណា ជីវិតមនុស្សដែលរស់នៅទីនោះក៏ប្រែប្រួលទៅតាមនោះដែរ។

ស្ថានភាពសង្គម

- ប្រជាជនរស់នៅក្រោមអាណានិគម ការគៀបសង្កត់ ជិះជាន់ពីសំណាក់បរទេស ដោយក្ដីវេទនា។

ឧទាហរណ៍៖ នៅក្នុងរឿង ភូមិតិរច្ឆាន(ស្ថិតក្រោមអាណានិគមបារាំង ត្រូវបារាំងចាប់ដាក់គុក ទារពន្ធ វាយធ្វើបាប)

ឧទាហរណ៍៖ រឿងគូលីកំណៃាន (ស្ថិតក្រោមអាណានិគមជប៉ុន ត្រូវជាប់កំណៃាន ព្រាត់ប្រាស់ប្ដីប្រពន្ធ កូនចៅ)

ឧទាហរណ៍៖ រឿងមាលាដួងចិត្ត (ស្ថិតក្រោមការគៀបសង្កត់របស់សៀម និងអាមេរិក មានសង្គ្រាម ស្លាប់)។

– ប្រជាជនត្រូវអ្នកមានអំណាច នាយទុន ធ្វើបាប កេងប្រវ័ញ្ច ជិះជាន់។

ឧទាហរណ៍៖ រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ (សមត្រូវអ្នកនយោបាយបោកប្រាស់ នាងសយ ត្រូវថៅកៃហុកចាប់រំលោភ ហើយឆ្លៀតឱកាសចាប់សមដាក់គុក)

ឧទាហរណ៍៖ រឿងចៅកែចិត្តចោរ (ពូឃំត្រូវចៅកែហុក បោកប្រាស់ឱ្យសម្លាប់ចៅកែហុងលី)។

សរុបមកឃើញថា ជីវិតរបស់មនុស្សម្នាក់ៗ ពិតជាត្រូវបានសង្គមជាអ្នកកំណត់កំណត់មែន សង្គមមានលក្ខណៈបែបណា ជីវិតមនុស្សក៏មានលក្ខណៈបែបនោះដែរ។

+ មតិផ្ទុយ៖ តើសង្គមពិតជាអ្នកកំណត់ជោគវាសនារបស់មនុស្សមែនឬ? ទេមិនពិតទេ វាសនារបស់មនុស្សម្នាក់ៗមិនមែនត្រូវបានសង្គមជាអ្នកកំណត់នោះទេ។ វាសនារបស់មនុស្សម្នាក់ៗយ៉ាងណាអាស្រ័យលើ ខ្លួនឯងដែលជាអ្នកកំណត់។ បើទោះជាសង្គមបែបណា ប្រសិនបើខ្លួនយើងចេះបែងចែកខុសត្រូវ ល្អអាក្រក់នោះសង្គមមិនអាចអូសទាញជីវិតយើងបាននោះ។

ឧទាហរណ៍៖ រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ (សមបានតស៊ូ រើរបំរះចេញពីភាពក្រីក្រ លំបាកវេទនា ដោយឈរលើគោលជំហរសុច្ចរិត រហូតបានប្រែក្លាយជីវភាពអោយមានភាពល្អប្រសើរ)។

ឧទាហរណ៍៖ កុលាបប៉ៃលិន (ចៅចិត្របានក្លាយជាកូនប្រសារ និងជាទីទុកចិត្តនៃលោកហ្លួងរតនៈសម្បត្តិ ព្រោះតែភាពស្មោះត្រង់ និងតស៊ូ)។

ឧទាហរណ៍៖ រឿងមាលាដួងចិត្ត (ទីឃាវុធបានក្លាយជាចៅហ្វាយស្រុកក៏ព្រោះតែការតស៊ូ និងមនសិការស្នេហាជាតិមាតុភូមិរបស់គេ)។

ឧទាហរណ៍៖ រឿងផ្កាស្រពោន (នាងវិធាវីត្រូវស្លាប់ ក៏ព្រោះតែការមិនហ៊ានប្រាប់នូវការពិតឱ្យឃាយនួនដឹង អំពីក្តីស្នេហាខ្លួនចំពោះប៊ុនធឿន)។

សរុបមកជីវិតរបស់មនុស្សម្នាក់ៗ មិនត្រូវបានអ្នកណាជាអ្នកកំណត់នោះទេ មានតែខ្លួនឯងតែប៉ុណ្ណោះដែលសម្រេចថាតើត្រូវធ្វើបែបណាសម្រាប់ជីវិតខ្លួនឯង។

\+ សំយោគមតិ៖ ជារួមមកយើងឃើញថា សង្គមគ្រាន់តែជាអ្នកជួយសម្រួលដល់ការរស់នៅរបស់មនុស្ស ឬជាអ្នកកែប្រែស្ថានភាពខ្លះនៃជីវិតមនុស្សតែប៉ុណ្ណោះ ប៉ុន្តែជីវិតរបស់មនុស្សម្នាក់ៗ មាន វាសនាយ៉ាងណានោះត្រូវពឹងផ្អែកលើទៅលើការខិតខំប្រឹងប្រែង តស៊ូព្យាយាមរៀងៗខ្លួន មិនត្រូវអស់សង្ឃឹមនោះទេ បើទោះសង្គមជាតិធ្លាក់ក្នុងសភាពណាក៏ដោយ។

## III. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ មតិខាងលើនេះត្រឹមត្រូវតែមួយជ្រុងប៉ុណ្ណោះ ត្បិតតែពេលខ្លះឥទ្ធិពលនៃសង្គម ឬមនុស្សនៅជុំវិញខ្លួនអាចរុញច្រាន ឆាកជីវិតមនុស្សឱ្យប្រែប្រួលខ្លះនឱ្យមែន ប៉ុន្តែវាសនាមនុស្សម្នាក់ៗយ៉ាងណាអាស្រ័យលើខ្លួនឯង បូកផ្សំជាមួយកត្តាសង្គមផងដែរដែលជាអ្នកកំណត់។
- មតិផ្ទាល់ខ្លួន៖ មនុស្សម្នាក់ៗត្រូវចេះរើរបំរាស់ចេញពីសង្គមជិះជាន់ សង្គមអយុត្តិធម៌ មិនត្រូវបណ្តោយឱ្យសង្គមមាន

ឥទ្ធិពលមកលើខ្លួនរហូតធ្វើឱ្យបាត់បង់ជំនឿចិត្តលើខ្លួនឯង នោះទេ ត្រូវធ្វើជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិ។

**សេចក្តីអត្ថាធិប្បាយ**

មនុស្សម្នាក់ៗរស់នៅក្នុងសង្គមមួយ រមែងទទួលរងនូវឥទ្ធិពលនៃសង្គមនោះមកលើជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ដោយសារឥទ្ធិពលទាំងនេះហើយទើបធ្វើឱ្យមានទស្សនៈលើកឡើងថា " សង្គមជាអ្នកកំណត់ជោគវាសនាមនុស្ស" ។

តើទស្សនៈនេះត្រឹមត្រូវឬទេ?

ដើម្បីបកស្រាយប្រធានខាងលើបានស៊ីជម្រៅ ជាដំបូងយើងត្រូវយល់ន័យពាក្យគន្លឹះជាមុនសិន។ ពាក្យ "សង្គម" មានន័យថាជាការប្រមូលផ្តុំនៃមនុស្ស ការរស់នៅជាក្រុម ឬ ជាសង្កាត់មួយដែលជាទីប្រជុំនៃមនុស្សមួយក្រុម អាចជាស្ថានភាព ឬមនុស្សដែលរស់នៅក្នុងសង្គមនេះឯង។ កន្សោមពាក្យ "កំណត់ជោគវាសនា" មានន័យថា ជាគូសវាសដំណើរជីវិត ជាការកំណត់ជោគជតានៃមនុស្សម្នាក់ៗ។ ដូចនេះទស្សនៈប្រធានដែលលើកឡើងនេះមានន័យថា "ស្ថានភាព ឬមនុស្សដែលរស់នៅជុំវិញខ្លួនយើង ជាអ្នកគូសវាសនូវដំណើរជីវិតនៃមនុស្សម្នាក់ៗដែលរស់នៅក្នុងសង្គម"។

មែន! ប្រទេស ឬសង្គមបែបណា ជីវិតមនុស្សដែលរស់នៅទីនោះក៏ប្រែប្រួលទៅតាមនោះដែរ។ បើសង្គមនោះមានភាពរីកចម្រើន មានស្ថេរភាព មនុស្សដែលរស់នៅក្នុងសង្គមនោះក៏សប្បាយរីករាយ មានសុភមង្គលទៅតាមនោះដែរ។ ផ្ទុយទៅវិញបើសង្គមនោះពោរពេញទៅដោយ

អំពើឆក់ប្លន់ កេងប្រវ័ញ្ច ភាពអយុត្តិធម៌កើតមានស្ទើរគ្រប់កន្លែង មានសង្គ្រាមមិនចេះដាច់ ពិតណាស់ដែលមនុស្សទាំងអស់ទទួលរងនូវសេចក្តីខ្លោចផ្សារ រស់នៅដោយភាពភ័យខ្លាចគ្រប់ពេលវេលា។ ស្ថានភាពសង្គមជាកត្តាមួយដែលចូលរួមកែប្រែវាសនាមនុស្ស។ ជាក់ស្តែងបើយើងក្រលេកទៅមើលរឿង ភូមិតិរច្ឆាន នោះយើងឃើញថា ប្រជាជនខ្មែរស្ថិតនៅក្រោមអាណាព្យាបាលរបស់បារាំង ប្រជាជនរងទុក្ខវេទនាត្រូវបារាំងបង្ខំឱ្យបង់ពន្ធ បើពុំបានបង់ពន្ធតាមការកំណត់នឹងត្រូវបារាំងវាយ ដំច្រំធាក់ ហើយខ្លះត្រូវបារាំងវាយដាក់ខ្នោះ ដូចសំដីនាងនីបានលើកឡើងថា "លោកធ្វើចៅហ្វាយលើខ្មែរ លោកមើលឃើញត្រឹមតែប្រាក់មួយមុខប៉ុណ្ណោះ ចង់ខ្មែរធ្វើស្រែមិនបាន ចង់ខ្មែរដាច់ពោះស្លាប់ លោកឥតឈឺក្បាលអ្វីទេ លោកគិតតែពីសង្វៀញទារពន្ធ....."។ មួយវិញទៀតនៅក្នុងរឿងគូលីកំណៃន ដែលជាស្នាដៃរបស់លោកអ៊ឹម ធុកក៏បានបង្ហាញដែរ ប្រជានជនខ្មែររងទុក្ខវេទនាដោយស្ថិតក្រោមអាណានិគមជប៉ុន ត្រូវជាប់កំណៃន ព្រាត់ប្រាស់ប្តីប្រពន្ធ កូនចៅ ដូចមាននាងហេងជាឧទាហរណ៍ស្រាប់ នាងត្រូវស្លាប់ព្រាត់ពីលឹមដែលជាគូដណ្តឹង ត្រូវព្រាត់ពីឪពុកម្តាយដោយសារការទម្លាក់គ្រាប់បែក ដូចបង្ហាញនៅត្រង់ "គ្រាប់បែកបានលើកនាងហេងគ្រវែងចោលទៅឆ្ងាយ ហើយបានទាំងលើកដុំថ្មមួយដុំទៅសង្កត់ទ្រូងនាងទៀត"។ ក្រៅពីស្ថានភាពសង្គម កត្តា មនុស្សនៅជុំវិញខ្លួនក៏ជាផ្នែកមួយដែលជួយជំរុញឱ្យជីវិតមនុស្សប្រែប្រួលដែរ។ បើយើងងាកទៅមើលអក្សរសិល្ប៍ខ្មែរមួយចំនួនបានបង្ហាញថាប្រជាជនត្រូវអ្នកមានអំណាច នាយទុន ធ្វើបាប កេងប្រវ័ញ្ច ជិះជាន់ ធ្វើឱ្យជីវិតគេក្រឡាប់ចាក់

ជាឧទាហរណ៍រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ សមត្រូវអ្នកនយោបាយបោកប្រាស់ "ខ្ញុំស្ម័គ្រចិត្តធ្វើជាបេក្ខជនតំណាងរាស្ត្រ.....បើខ្ញុំបានធ្វើជាតំណាងរាស្ត្រមែននោះ សូមកុំភ័យឱ្យសោះខ្ញុំនឹងជួយកម្មករឱ្យពេញទំហឹង..."ចំណែកឯនាងសយប្រពន្ធសមត្រូវថៅកែហុកចាប់រំលោភ "នាងឯងធ្លាក់ខ្លួនមកនៅក្នុងក្រញាំដៃខ្ញុំហើយ ឯងគេចទៅណាក៏មិនរួចដែរ ខ្ញុំត្រូវការអូនស្រី..." ។ មួយវិញទៀតនៅក្នុងរឿងថៅកែចិត្តចោរ ពូហំត្រូវថៅកែហុក បោកប្រាស់ឱ្យសម្លាប់ថៅកែហុងលីដោយសន្យាថាឱ្យមួយម៉ឺន តែចុងក្រោយថៅកែមិនទទួលស្គាល់ បែរជាហៅប៉ូលិសឱ្យមកចាប់ពូហំវិញ។

សរុបមកឃើញថា ជីវិតរបស់មនុស្សម្នាក់ៗ ពិតជាត្រូវបានសង្គមជាអ្នកកំណត់មែន សង្គមជាអ្នកទាញមនុស្សឱ្យលុះនៅក្រោមអំណាចរបស់ខ្លួន។ សង្គមមានលក្ខណៈបែបណា ជីវិតមនុស្សក៏មានលក្ខណៈបែបនោះដែរ។

តើសង្គមពិតជាអ្នកកំណត់ជោគវាសនារបស់មនុស្សមែនឬ?

ទេមិនពិតទេ វាសនារបស់មនុស្សម្នាក់ៗមិនមែនត្រូវបានសង្គមជាអ្នកកំណត់នោះទេ។ វាសនារបស់មនុស្សម្នាក់ៗយ៉ាងណាអាស្រ័យលើខ្លួនឯងដែលជាអ្នកកំណត់។ បើទោះជាសង្គមបែបណា ប្រសិនបើខ្លួនយើងចេះបែងចែកខុសត្រូវ ល្អអាក្រក់នោះសង្គមមិនអាចអូសទាញជីវិតយើងបាននោះ។ យ៉ាងណាមិញរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ សមបើទោះជាត្រូវទទួលរងនៅភាពអយុត្តិធម៌ពីសង្គម ត្រូវបាននាយទុនធ្វើបាបយ៉ាងក៏ដោយ តែនៅចុងក្រោយសមបានតស៊ូ រើរបំរះចេញពីភាពក្រី

ក្រ លំបាកវេទនា ដោយឈរលើគោលជំហរសុច្ចរិត រហូតបានប្រែក្លាយជីវភាពអោយមានភាពល្អប្រសើរឡើងវិញ។ សមមិនបានបណ្តោយឱ្យសង្គមអូសទាញខ្លួនឱ្យធ្លាក់ដុនដាប បាត់បង់ភាពជាមនុស្សទេ។ ចំណែកឯរឿងកុលាបប៉ៃលិន របស់លោកញ៉ុក ថែម បានបង្ហាញថាចៅចិត្របានក្លាយជាកូនប្រសារ និងជាទីទុកចិត្តនៃលោកហ្លួងរតនៈសម្បត្តិ ក៏ព្រោះតែភាពស្មោះត្រង់ តស៊ូ ព្យាយាមមិនខ្លាចឧបសគ្គនេះឯង។ ចៅចិត្របានក្លាយជាជនជោគជ័យក៏ព្រោះតែចៅចិត្រអនុវត្តតាមបណ្តាំតាចឹម " អត្តាហិ អត្តនោ នាថោ" មានន័យថាខ្លួនត្រូវទីពឹងខ្លួន មិនត្រូវអស់សង្ឃឹមនោះទេ។ លើសពីនេះទៅទៀត ទីឃាវុធ ក្នុងរឿងមាលាដួងចិត្ត បានក្លាយជាចៅហ្វាយស្រុកក៏ព្រោះតែការតស៊ូ និងមនសិការស្នេហាជាតិមាតុភូមិរបស់គេ។ ទីឃាវុធបើទោះជាធ្លាក់ក្នុងសេចក្តីលំបាកបែបណាក៏ដោយ ក៏គេប្រកាន់គោលជំហាររក្សាភាពសុច្ចរិតមិនទទួលលុយពីចៅកែហុងឈីជាហេតុធ្វើឱ្យគេមានតម្លៃកាន់តែខ្ពស់។

សរុបមកជីវិតរបស់មនុស្សម្នាក់ៗ មិនត្រូវបានអ្នកណាជាអ្នកកំណត់នោះទេ មានតែខ្លួនឯងតែប៉ុណ្ណោះដែលសម្រេចថាតើត្រូវធ្វើបែបណាសម្រាប់ជីវិតខ្លួនឯង។ មានតែខ្លួនឯងប៉ុណ្ណោះដែលជាអ្នកដឹកនាំជីវិតទៅរកផ្លូវដែលខ្លួនពេញចិត្ត។

ជារួមមកយើងឃើញថា សង្គមគ្រាន់តែជាផ្នែកមួយជួយសម្រួលដល់ការរស់នៅរបស់មនុស្ស ឬជាអ្នកកែប្រែស្ថានភាពខ្លះនៃជីវិតមនុស្សតែប៉ុណ្ណោះ ប៉ុន្តែជីវិតរបស់មនុស្សម្នាក់ៗ មាន វាសនាយ៉ាងណានោះ

ត្រូវពឹងផ្អែកលើទៅលើការខិតខំប្រឹងប្រែង តស៊ូព្យាយាមរៀងៗខ្លួនដែលជាកត្តាចម្បង។

ឆ្លងតាមការបកស្រាយពិភាក្សាមតិខាងលើយើងអាចធ្វើការវាយតម្លៃបានថាមតិខាងលើនេះត្រឹមត្រូវតែមួយជ្រុងប៉ុណ្ណោះ ត្បិតតែពេលខ្លះឥទ្ធិពលនៃសង្គម ឬមនុស្សនៅជុំវិញខ្លួនអាចរុញច្រាន ឆាកជីវិតមនុស្សឱ្យប្រែប្រួលខ្លះមែន ប៉ុន្តែវាសនាមនុស្សម្នាក់ៗយ៉ាងណាអាស្រ័យលើខ្លួនឯង បូកផ្សំជាមួយកត្តាសង្គមផងដែរដែលជាអ្នកកំណត់។ មនុស្សម្នាក់ៗត្រូវចេះរើសបំរាស់ចេញពីសង្គមជិះជាន់ សង្គមអយុត្តិធម៌ មិនត្រូវបណ្ដោយឱ្យសង្គមមានឥទ្ធិពលមកលើខ្លួនរហូតធ្វើឱ្យបាត់បង់ជំនឿចិត្តលើខ្លួនឯងនោះទេ ត្រូវធ្វើជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិ។

# ប្រធានទី១២

តាមទស្សនៈព្រះពុទ្ធបានអប់រំថា៖ "កូនដែលដឹង និងតបស្នងគុណមាតាបិតាត្រូវបានអានិសង្ស កតញ្ញូ"។ ចូរពន្យល់ ដោយលើកឧទាហរណ៍ក្នុងសង្គម និងអក្សរសិល្ប៍មកបញ្ជាក់ផង។

## គម្រោងអធិប្បាយ

### I. សេចក្តីផ្តើម

- លំនាំបញ្ហា៖ មាតាបិតាគឺជាអ្នកដែលបង្កើតនូវរូបវិញ្ញាណ និងអាយុជីវិតដល់បុត្រធីតាគ្រប់រូប...
- ចំណូលបញ្ហា៖ ទាក់ទងទៅនឹងបញ្ហាខាងលើនេះហើយតាមទស្សនៈព្រះពុទ្ធអប់រំថា ៖ " កូនដែលដឹង និងតបស្នងគុណមាតាបិតាត្រូវបានអានិសង្ស កតញ្ញូ"។
- ចំណោទបញ្ហា៖ តើគេសំអាងលើហេតុផលអ្វីខ្លះបានជាគេអះអាងបែបនេះ?

### II. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ក្នុងគោលបំណងជួយសម្រួលដល់ការពន្យល់នូវចម្លល់ខាងលើយើងគួរតែស្វែងយល់នូវពាក្យគន្លឹះមួយចំនួនជាមុនសិន។
- ពន្យល់ពាក្យ

- អានិសង្ស៖ គឺជាផលនៃកុសលឬជាផលបុណ្យជាគុណប្រយោជន៍ផ្តល់នូវសេចក្តីសុខចម្រើនចំពោះ បុគ្គលដែលប្រព្រឹត្តអំពើល្អ។
- កត្តញ្ញូ៖ គឺសំដៅលើបុគ្គលដែលដឹងពីឧបការគុណរបស់អ្នកដទៃដែលបានធ្វើមកកាន់ខ្លួន ពោលគឺអ្នកដែលមិនបានភ្លេចគុណ។

- ពន្យល់ន័យប្រធាន៖ តាមន័យប្រធានខាងលើចង់មានន័យថា កូនគ្រប់រូបដែលបានដឹង និងតបស្នងសងគុណឪពុកម្តាយនឹងត្រូវបានទទួលនូវបុណ្យកុសល ឬបានសេចក្តីសុខនិងចម្រើនដែលកើតចេញមកអំពីការមិនភ្លេចគុណលោកទាំងពីរ។
- បកស្រាយ
- ឪពុកម្តាយមានគុណ៖

✓ លោកជាអ្នកផ្តល់កំណើតឱ្យយើងមានជីវិត

✓ លោកជាចិញ្ចឹមបីបាច់ ថែរក្សាយើងតាំងពីបាតជើងក្រហមរហូតដល់ធំ

✓ ផ្គត់ផ្គង់ ទំនុកបម្រុងយើងរាល់ចំណុចខ្វះខាត

✓ ណែនាំយើង អនុគ្រោះយើងគ្រប់ពេល នៅក្បែរ និងផ្តល់កម្លាំងចិត្តដល់យើងគ្រប់ពេល

✓ តាមមើលកូនរហូតទាំងការរស់នៅ ការងារ កេរ្តិ៍ឈ្មោះ...

- កូនត្រូវ

- ✓ ជួយសម្រួលកិច្ចការតិចច្រើន ធ្ងន់ស្រាល
- ✓ ថែទាំលោកវិញនៅពេលលោកចាស់ទៅ
- ✓ បន្សល់ រក្សាវង្សត្រកូល និងទ្រព្យសម្បត្តិរបស់លោកដែលបាន បន្សល់ទុកឱ្យបានល្អ
- ✓ ត្រូវធ្វើបុណ្យ ឧទ្ទិសកុសលជូនលោក ពេលលោកចែកឋានទៅ

កូនដែលដឹង និងតបស្នងគុណមាតាបិតាត្រូវបានអានិសង្ស កតញ្ញូ៖

- ✓ មានកេរ្តិ៍ឈ្មោះល្អក្នុងសង្គម
- ✓ មានសេចក្ដីថ្លៃថ្នូរ មានញាតិមិត្តរាប់រក
- ✓ ទៅណាមកណាមានទេវតា ព្រលឹងជីដូនជីតាតាមថែរក្សា
- ✓ មានឈ្មោះជាកូនកតញ្ញូ...

- បញ្ហាទាក់ទងទៅនឹងសង្គម

១. និយាយបញ្ហាដែលទាក់ទងទៅនឹងពុទ្ធប្រវត្តិ

២. ការអប់រំរបស់ព្រះពុទ្ធ

៣.ការយកទស្សនៈរបស់ព្រះពុទ្ធមកធ្វើការប្រៀប ធៀបជាមួយមាតាបិតា ដោយចាត់ទុកគាត់ជាព្រះ កន្លោងដោយបង្ហាញពីគុណមាតាបិតា និងការតប ស្នងសងគុណរបស់យើង ព្រមទាំងកុសលផលបុណ្យ នៃការប្រព្រឹត្តរបស់យើង។

៤.បញ្ហាដែលមិនបានបំពេញកិច្ចដូចខាងលើគេឱ្យ ឈ្មោះថាកូនអកតញ្ញូជួបតែទុក្ខសោកទាំង បច្ចុប្បន្នកាល ក៏ដូចជាអនាគត ។

- បញ្ហាដែលទាក់ទងទៅនឹងអក្សរសិល្ប៍

  ១.រឿងសុវណ្ណសាម

  ២.រឿងកុលាបប៉ៃលិន

  ៣.រឿងព្រះវេស្សន្តរ

- សរុបសេចក្តី៖ ការតបស្នងសងគុណចំពោះលោកអ្នកដែលមានគុណ ជាពិសេសមាតាបិតា ឬព្រះកន្លោងគឺជាអំពើល្អ ។

## III. សេចក្តីបញ្ចប់

- សន្និដ្ឋាន៖ ប្រធានខាងលើគឺមានខ្លឹមសារអប់រំយ៉ាងជ្រាលជ្រៅដល់អ្នកអានអ្នកសិក្សា ជាពិសេសប្រជាពលរដ្ឋខ្មែរគ្រប់មជ្ឈដ្ឋាន គ្រប់ទីកន្លែង។
- យោបល់ផ្ទាល់ខ្លួន៖ ដូចនេះក្នុងនាមជាសិស្ស គ្រប់រូបត្រូវចេះគោរពដឹងគុណគ្រូ បាធ្យាយមាតាបិតា ចាស់ព្រឹទ្ធាចារ្យ អ្នកដឹកនាំប្រទេសដើម្បីឱ្យក្លាយខ្លួនជាសិស្សល្អ ពលរដ្ឋល្អរួមចំណែកធ្វើឱ្យសង្គមជាតិយើង មានការរីចម្រើនទាន់សន្ទុះ វិវត្តន៍នៃអារ្យប្រទេសនានានៅលើសកលលោក។

## សេចក្តីអធិប្បាយ

មាតាបិតា គឺអ្នកដែលបង្កើតនូវរូបរាងវិញ្ញាណនិងអាយុជីវិតដល់បុត្រាបុត្រីគ្រប់រូប ។ លោកគឺជាអ្នកមានគុណបំផុតចំពោះកូនចៅទាំងការផ្តល់កំណើត ការចិញ្ចឹម ថៃទាំបីបាច់ថែរក្សាឱ្យមានជីវិតរស់រានជាមនុស្សដូចគេឯង។ ដូចនេះហើយតាមទស្សនៈព្រះពុទ្ធសាសនា បានអប់រំថា " កូនដែលដឹងគុណមាតាបិតាត្រូវទទួលអានិសង្ស កតញ្ញូ"។

តើទស្សនៈនេះមានអត្ថន័យដូចម្ដេច? តើគេសំអាងលើអ្វីខ្លះបានជាអះអាងបែបនេះ?

ក្នុងគោលបំណងជួយសំរួលដល់ការពន្យល់បំភ្លឺចំពោះចម្ងល់ប្រធានយើងគប្បីស្វែងយល់ពាក្យ "អានិសង្ស" និង "កតញ្ញូ" ជាមុនសិន។ ពាក្យថាអានិសង្ស សំដៅទៅលើផលនៃកុសល ឬជាផលបុណ្យជាគុណប្រយោជន៍ផ្ដល់នូវសេចក្ដីសុខចម្រើនចំពោះ បុគ្គលដែលប្រព្រឹត្តអំពើល្អ។ កត្តញ្ញូ សំដៅលើបុគ្គលដែលដឹងពីឧបការគុណរបស់អ្នកដទៃដែលបានធ្វើមកកាន់ខ្លួន ពោលគឺអ្នកដែលមិនបានភ្លេចគុណ។ ដូចនេះប្រធានខាងលើមានន័យថា កូនគ្រប់រូបដែលបានដឹង និងតបស្នងសងគុណឪពុកម្ដាយនឹងត្រូវបានទទួលនូវបុណ្យកុសល ឬបានសេចក្ដីសុខនិងចម្រើនដែលកើតចេញមកអំពីការមិនភ្លេចគុណលោកទាំងពីរ។

ជាការពិតណាស់ "កូនដែលដឹង និងតបស្នងគុណមាតាបិតាត្រូវបានអានិសង្ស កតញ្ញូ"។ យើងបានដឹងរួចមកហើយថាឪពុកម្ដាយលោកមានគុណធំធេង ទោះបីមហាសមុទ្រ ឬភ្នំព្រះសុមេរក៏មិនធំដូចគុណលោកផង។ លោកជាអ្នកផ្ដល់កំណើតឱ្យយើងមានជីវិត។ ចាប់តាំងពីយើងមកចាប់កំណើតក្នុងផ្ទៃមាតាមក លោកមើលថែទាំងផ្លូវកាយ ផ្លូវចិត្តមិនឱ្យប៉ះពាល់ដល់ទារកក្នុងផ្ទៃនោះទេ។ ការងារធ្ងន់ ស្រាលឪពុកជាអ្នករ៉ាប់រង ប្រយ័ត្នចំពោះមាតាមិនឱ្យធ្វើការធ្ងន់។ នៅពេលដែលយើងកើតមកហើយ លោកជាចិញ្ចឹមបីបាច់ ថែរក្សាយើងតាំងពីបាតជើងក្រហមរហូតដល់ធំមិនខ្លាចនឿយហត់ក៏ព្រោះតែក្ដីស្រឡាញ់របស់លោកចំពោះបុត្រធីតា។ មួយវិញទៀតលោកផ្គត់ផ្គង់ ទំនុកបម្រុងយើង

វាល់ចំណុចខ្វះខាត បញ្ចុកបាយ នំ ចំណី ផ្តល់ឱ្យកូនបានទៅរៀនសូត្រ មានចំណេះដឹងពេញខ្លួន។លើសពីនេះលោកជាអ្នកណែនាំយើង អនុគ្រោះយើងគ្រប់ពេល នៅក្បែរ និងផ្តល់កម្លាំងចិត្តដល់យើងគ្រប់ពេល។ ពេលកូនធ្វើខុស មានតែម្តាយឪពុកនេះឯងជាអ្នកលើកលែងទោស ឬធ្វើមើលមិនឃើញពីទោសរបស់កូន។ អ្វីដែលសំខាន់លោកមានតែផ្តល់កម្លាំងចិត្ត ជំរុញបន្ថែមចំពោះកិច្ចការកូនធ្វើដែលនាំឱ្យចម្រុងចម្រើនដល់ខ្លួន ដោយគ្មានចង់បានអ្វីពីកូនមកវិញសោះ សំខាន់កូនបានជោគជ័យគឺជាសេចក្តីសុខឪពុកម្តាយទៅហើយ។ មិនថាកូនទៅដល់ទីណាទេ លោកតាមមើលកូនរហូតទាំងការរស់នៅ ការងារ កេរ្តិ៍ឈ្មោះ កូនមានសេដក្តីខុស មានមុខមានមាត់ លោកត្រេកអរ កូនមានបញ្ហា លោកកើតទុក្ខ។ នេះហើយជាទឹកចិត្តឪពុកម្តាយ ជាគុណដល់ធំមិនអាចកាត់ថ្លៃបាន។ បែបនេះហើយក្នុងនាមជាកូនត្រូវ ជួយសម្រួលកិច្ចការតិចច្រើនធូន់ស្រាលចំពោះលោក ប្រសិនបើយើងស្នាក់នៅជាមួយ ឬក៏នៅឆ្ងាយក៏ត្រូវឆ្លៀតពេលមកជួយសម្រួលបន្ទុករបស់លោកផង។ ចំណុចមួយទៀត កុលបុត្រកុលធីតាត្រូវចេះថែទាំលោកវិញនៅពេលលោកចាស់ទៅ បម្រើឆ្វេងស្តាំ លោកចង់ទៅណាត្រូវជូនលោកទៅតាមបំណង ព្រោះពេលចាស់ទៅលោកមិនអាចទៅដោយខ្លួនឯងបានទេ។ ជាពិសេសជាងនេះទៅទៀត ត្រូវចេះការពារ រក្សាវង្សត្រកូល និងទ្រព្យសម្បត្តិរបស់លោកដែលបានបន្សល់ទុកឱ្យបានល្អ កុំយកទៅចាយវាយផ្តេសផ្តាស ឬក៏មិនទុក្ខដាក់បានត្រឹមត្រូវនាំឱ្យវិនាស។ ចំណុចសំខាន់មួយទៀតណៅពេលលោកចែកឋានទៅ ត្រូវធ្វើបុណ្យ ឧទ្ទិសកុសលជូនលោក ពេលលោក

ថែកឋានទៅ ដើម្បីរំឮកគុណ តបគុណលោកដែលបានថ្មិ្ហ ីមបីបាច់ថែរក្សាយើងតាំងពីតូចមក។ កូនដែលដឹង និងតបស្នងគុណមាតាបិតាត្រូវបានអានិសង្ស កតញ្ញូ មានកេរ្តិ៍ឈ្មោះល្អក្នុងសង្គម មានគេនិយាយថាកូនល្អ កូននេះចេះមើលថែទាំឪពុកម្ដាយណាស់ កូនគេអើយអីក៏ល្អម្ល៉េះ។ វាជាវាចាមួយដែលធ្វើឱ្យចិត្តរបស់យើងសប្បាយរីករាយ មានកម្លាំងចិត្តមានទឹកចិត្តប្រពៃថែមទៀតផង។ លើសពីនេះ ពួកគេនឹងមានសេចក្ដីថ្លៃថ្នូរ មានញាតិមិត្តរាប់រក ទៅណាមកណាមានទេវតា ព្រលឹងជីដូនជីតាតាមថែរក្សា បើទោះបីមានគ្រោះថ្នាក់ក៏យើងអាចចៀសផុតបានដែលដោយកុសលផលបុណ្យបំពេញករណីកិច្ចចំពោះមាតបិតារបស់ខ្លួនកាលពីលោកនៅមានជីវិត ក៏ដូចលោកអស់ជីវិត។ មានន័យថាព្រលឹងលោកនៅតាមឃ្លាំមើលយើងជានិច្ច។ មួយវិញទៀតនោះ ការតបគុណចំពោះមាតាបិតាយើងនឹងមានឈ្មោះជាកូនកតញ្ញូ។ បើយើងក្រឡេកមកមើលក្នុងសង្គមជាក់ស្ដែង យើងដឹងហើយថាព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ សាសនានេះមានអាទិភាពមួយចំបងគឺ ព្រះសម្មាសម្ពុទ្ធ ព្រះបរមសាស្ត្រាចារ្យ ហើយទ្រង់បានចំណាយនូវការប្រោសសត្វអស់រយៈពេលសែសិបប្រាំឆ្នាំ ហើយបរិនិព្វានក្នុងព្រះជន្មាយុ ប៉ែតសិបព្រះវស្សា។ ព្រះអង្គបានផ្ដល់នូវគតិអប់រំជាច្រើនដល់មនុស្សទូទៅឱ្យប្រព្រឹត្តតែទង្វើជាកុសល ក្នុងនោះការអប់រំបុត្រាបុត្រីគប្បីមានកតញ្ញូតាធម៌ កតវេទិតាចំពោះមាតាបិតាផងដែរ។ បើគិតតាមជីវភាពជាក់ស្ដែងវិញ មាតាបិតាក្រៅពីបានផ្ដល់អាយុជីវិតដល់កូនប្រុសស្រីពោលគឺជាគ្រឹះជាបង្អែកដ៏រឹងមាំសម្រាប់គ្រួសារ។ ក្នុងន័យនេះគេសង្កេតឃើញថា កូនចៅប្រុស

ស្រីគឺដូចជាកូនបំណុលរបស់មាតាបិតា ហើយត្រូវបានសងនៅក្នុងរូបភាពបួនប្រការរួមមានគ្រឿង ហូបចុក ស្លៀកពាក់ ឧបករណ៍ស្លៀកពាក់ប្រចាំថ្ងៃ និងថ្នាំសង្កូវ កែព្យាបាលរោគផ្សេងៗចំពោះលោកទាំងពីរដោយក្តីស្មោះសនិងគោរព។ សម្រាប់គ្រឿងផ្ទាល់ខ្លួនម្នាក់ៗចាំបាច់ត្រូវខិតខំរៀនសូត្រប្រកបដោយសតិសម្បជញ្ញៈ និងមនសិការ។ លើសពីនេះត្រូវតបស្នងសងគុណាត្រងត្រាប់ស្តាប់ឱវាទនិងដំបូន្មានរបស់ឪពុកម្តាយ ហើយមិនត្រូវពោលពាក្យអសុរស ទ្រគោះបោះបោកគ្មានសីលធម៌ទៅកាន់លោកឡើយ។ ពិសេសមិនត្រូវនាំភ្លើងក្រៅចូលក្នុងផ្ទះឡើយ ព្រោះបង្កភាពក្តៅក្រហាយដល់លោកក៏ដូចជាក្រុមគ្រួសារទាំងមូលផងដែរ។ ករណីបុត្រាបុត្រីគ្រប់រូប បានប្រព្រឹត្តខាងលើពួកគេនឹងទទួលបានមកវិញនូវសេចក្តីពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ ទាំងបច្ចុប្បន្នក៏ដូចជាអនាគតជាតិផងដែរ ហើយត្រូវគ្រួសារទាំងមូលមានកិត្តិយស កេរ្តិ៍ឈ្មោះល្អ និងរីកចម្រើន។ ទាំងនេះហើយដែលចាត់ទុកថាជាអានិសង្សកតញ្ញូ ពោលគឺផលបុណ្យប្រកបដោយគុណធម៌ដែលកើតចេញមកពីការដឹងគុណ និងតបស្នងសងគុណមាតាបិតាវិញ។ ផ្ទុយទៅវិញបុត្រាបុត្រីណាពុំបានបំពេញកាតព្វកិច្ចខាងលើនោះប្រាកដគេឱ្យឈ្មោះថា ជាកូនអកតញ្ញូជួបតែទុក្ខសោកទាំងបច្ចុប្បន្នក៏ដូចជាអនាគតជាតិផងដែរ។ បញ្ហាទាំងនេះគឺស្តែងឡើងចេញពីទស្សនៈខាងលើ គេតែងប្រទះក្នុងសង្គមក៏ដូចជានៅនៅក្នុងអក្សរសិល្ប៍ផងដែរ។ តាមរយៈភាពជាក់ស្តែងនៅក្នុងសង្គម កូនចៅគ្រប់រូបដែលបានគោរពតាមការប្រៀនប្រដៅរបស់ឪពុកម្តាយ ស្គាល់គុណដឹងគុណមាតាបិតា រមែងរស់នៅ

ប្រកបទៅដោយភាពសុខដុមរមនា និងភាពសម្បូរសប្បាយ ជាប្រចាំ ដែលចាស់បានពោលថា ទេវតារក្សា កូនណាដែលដឹងគុណឪពុកម្ដាយ។ បើយើធ្វើការពិនិត្យមើលនៅក្នុអក្សរសិល្បវិញម្ដងយើងសង្កេតឃើញថា តួអង្គចៅសុវណ្ណសាមដែលជារឿងមួយស្ថិតនៅក្នុងចលនាពុទ្ធនិយមក៏ បានបង្ហាញយ៉ាងច្បាស់ផងដែលអំពីការក៏សាងនូវបុណ្យកុសល ការធ្វើ នូវអំពើល្អ ការតបស្នងសងគុណចំពោះមាតាបិតា មានកតញ្ញូមាន កតវេទីចំពោះមាតាបិតា ដោយចៅសុណ្ណសាមមិនបោះបង់ឪពុកម្ដាយ នៅពេលដែលឪពុកម្ដាយពិការភ្នែកទាំងសងខាង មើលអ្វីពុំឃើញគាត់ បានរែកអ្នកមានគុណទាំងទ្វេដោយប្រើកម្លាំងផ្ទាល់ខ្លួនគ្រប់ច្រកល្ហកគឺ ធ្វើយ៉ាងណាឱ្យលោកអ្នកដ៏មានគុណមានក្ដីសុខដើម្បីជាកម្លាំងផ្ដល់នូវ ទឹកចិត្តមកឱ្យកូន។ ដោយសារផលបុណ្យបែបនេះហើយទើប សុវណ្ណសា មគេបានរស់ជីវិតឡើងវិញក៏ព្រោះតែទទួលបានអានិសង្សកត្តញ្ញូនេះដែ រ។ ទន្ទឹមនឹងនេះដែររឿងពុទ្ធនិយមដែររឿងព្រះវេស្សន្តរក៏បានបង្ហាញពីរ ការសាងផលបុណ្យកុសល ចំពោះឪពុកម្ដាយផងដែរ គឺទាំងព្រះវេស្សន្តរ ទាំងជាលី និងក្រស្នា ជារឿយៗតែងតែដឹងគុណចំពោះមាតាបិតាដែរ ដោយសាតែទង្វើបែបនេះហើយនៅទីបំផុតក៏បានមកជួបជុំព្រះញាតិវង្ស វិញរស់នៅប្រកបដោយភាពសុខដុមរមនាលុះមរណា។ ជាចុងក្រោយគឺ ជារឿងដែលស្ថិតនៅក្នុងចលនាខេមរៈនិយមដែលបង្ហាញពីជីវិតរស់នៅ របស់ប្រជាជនពិតៗ ដែលទាក់ទងទៅនឹងជីវភាពរស់នៅ គឺរឿងកុលាប ប៉ៃលិនដែលជាកម្រងវណ្ណកម្មរបស់លោក ញ៉ុក ថែមគឺបានបង្ហាញអំពី ទឹកចិត្តដែលប្រកបទៅដោយកតញ្ញូកតវេទិតាធម៌របស់ចៅចិត្រចំពោះ

ឪពុកដែលបានគោរពស្រលាញ់ ស្តាប់ដំបូន្មានរបស់តាចឹម ប្រតិបត្តិ ថែមទាំងមើលថែជំងឺឪពុកជានិច្ច។ ដោយសាទង្វើដែលប្រកបទៅភាពមនុស្សធម៌បែបនេះធ្វើឱ្យលោកគ្រូពេទ្យស្អាតណែនាំឱ្យទៅធ្វើការងារជាមួយលោកហ្លួងរតនៈសម្បត្តិនៅឯបរប៉ៃលិនហើយរហូតធ្វើឱ្យក្រុមកម្មករលោកហ្លួង និងនាងឃុននារីមានការស្រឡាញ់ពេញចិត្តគ្រប់ៗគ្នា ហើយជាចុងក្រោយបានក្លាយទៅជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភបានឃុននារីជាភរិយាសោយសុខលុះក្ស័យជីពជន្ម។

ជារួមមកយើងឃើញថា ការតបស្នងសងគុណចំពោះលោកអ្នកដែលមានគុណ ជាពិសេសមាតាបិតា ឬព្រះកន្លោងជាអំពើកុសល់ដែលនាំមកនូវសេចក្តីសុខសប្បាយចិត្តគ្រប់ការលៈទេសៈ។ លើសពីនេះទៅទៀតភាពកតញ្ញូក៏ត្រូវបំពេញចំពោះបុគ្គលដែលធ្លាប់មានចំពោះយើងផងដែរ។

ដូចនេះឆ្លងតាមរយៈការបកស្រាយនូវមតិប្រធានខាងលើយើងអាចសន្និដ្ឋានបានថាកូនដែលដឹងគុណចំពោះកូនដែលដឹងគុណចំពោះមាតាបិតាត្រូវទទួលបានអានិសង្សកតញ្ញូគឺមានលក្ខណៈសមស្របប្រកបដោយខ្លឹមសារអប់រំយ៉ាងជ្រាលជ្រៅ ដល់អ្នកអានអ្នកសិក្សាគ្រប់លំដាប់ថ្នាក់ និងគ្រប់ទីកន្លែង។ ដូចនេះក្នុងនាមយើងជាសិស្ស គ្រប់គ្នាត្រូវគោរពដឹងគុណចំពោះគ្រូដូចនេះក្នុងនាមយើងជាសិស្ស គ្រប់គ្នាត្រូវគោរពដឹងគុណចំពោះគ្រូ បាធ្យាយមាតាបិតាចាស់ព្រឹទ្ធាចារ្យអ្នកដឹកនាំប្រទេសដើម្បីធ្វើខ្លួនយើងឱ្យក្លាយទៅជាកូនល្អ ពលរដ្ឋល្អរួមចំណែកធ្វើឱ្យ

សង្គមជាតិរបស់យើងមានការរីកចម្រើនទាន់សន្ទុះវិវត្តន៍នៃអារ្យប្រទេសនៅលើសកលលោក។

## ប្រធានទី១៣

មានមតិជាច្រើនបានលើកឡើងថា៖ "អក្សរសិល្ប៍ខ្មែរបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់វប្បធម៌ជាតិខ្មែរឱ្យបានគង់វង្ស"។ ចូរពន្យល់ដោយលើកក្នុងអក្សរ សិល្ប៍ខ្មែរមកបញ្ជាក់។

### គម្រោងតែង

#### I. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ វប្បធម៌ជាធាតុដ៏សំខាន់មួយសម្រាប់សម្គាល់ជាតិសាសន៍ផ្សេងៗ វប្បធម៌ មួយរុងរឿង ឬមិនសូវរុងរឿងអាស្រ័យទៅលើជាតិសាសន៍នោះ។
- ចំណូលបញ្ហា៖ អាស្រ័យដោយហេតុនេះហើយទើបមានមតិជាច្រើនបានលើកឡើងថា "អក្សរសិល្ប៍ខ្មែរបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់វប្បធម៌ជាតិខ្មែរឱ្យបានគង់វង្ស"។
- ចំណោទបញ្ហា៖ តើមតិដែលបានលើកឡើងខាងលើនេះមានអត្ថន័យយ៉ាងដូចម្ដេច?

#### II. តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី៖ ដើម្បីជាពន្លឺឲ្យច្បាស់ដល់ការបកស្រាយមតិដែលបានលើកឡើងខាងលើ យើងគួរគប្បីត្រូវយល់ពីពាក្យគន្លឹះ...។
- ពន្យល់ពាក្យគន្លឹះ៖

+ អក្សរសិល្ប៍ គឺជាស្នាដៃដែលធ្វើការឆ្លុះបញ្ចាំងអំពីតថភាពជាក់ស្តែងនៅក្នុងសង្គមមកបង្ហាញឱ្យយើងបានឃើញទាំងផ្នែកវិជ្ជមាន និងផ្នែកអវិជ្ជមាន។

+ វប្បធម៌គឺជាការសាបព្រោះឬផ្សាំបណ្តុះនូវចំណេះដឹងនិងប្រាជ្ញាស្មារតីឲ្យបានចម្រើនលូតលាស់ដោយវិទ្យាសាស្ត្រ ឬសិល្បៈផ្សេងៗ។

- ពន្យល់ន័យប្រធានៈ អត្ថបទអក្សរសិល្ប៍ខ្មែរគឺបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់វប្បធម៌ជាតិឲ្យគង់វង្សដោយបានឆ្លុះបញ្ចាំងពីភាពពិតនៅក្នុងសង្គមជាក់ស្តែងដោយបានបញ្ចូលនូវវប្បធម៌ជាតិរបស់ខ្លួន ទៅក្នុងស្នាដៃអក្សរសិល្ប៍ទាំងនោះមានដូចជា៖ ផ្នែកចំណេះដឹង ការផ្សព្វផ្សាយ និងការអនុវត្ត។

- បកស្រាយន័យប្រធានៈ វប្បធម៌ជាផ្នែកសំខាន់មួយនៃអរិយធម៌ហើយវប្បធម៌ត្រូវបានអ្នកនិពន្ធបញ្ជ្រាបទៅរាល់ស្នាដៃអក្សរសិល្ប៍ខ្មែរពិសេសអក្សរសិល្ប៍ទាំងនោះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់វប្បធម៌ជាតិខ្មែរឲ្យគង់វង្សដោយស្នាដៃភាគច្រើនអ្នកនិពន្ធបានឆ្លុះបញ្ចាំងអំពីផ្នែកតូចៗជាច្រើនក្នុងវប្បធម៌ខ្មែរដូចជា៖

+ ផ្នែកចំណេះដឹង៖ ជំនឿ សាសនា សីលធម៌ វិទ្យាសាស្ត្រ។

- ជំនឿ : ជឿទៅលើទេវតា មន្តអាគម អបិយជំនឿ ការបន់ស្រន់ ទស្សនៈ។កម្មផល ពាក្យសម្បថ ព្រេងវាសនា បញ្ញាញាណ ការទស្សន៍ទាយ ធាតុភូតធម្មជាតិជាដើម

ឧទាហរណ៍រឿងទុំទាវ៖ ជឿលើកម្មផល ការទស្សន៍ទាយ។

រឿងផ្កាស្រពោន៖ ជឿលើទេវតាថែរក្សា មន្តអាគមអបិយជំនឿ

រឿងគ្រូបង្រៀនស្រុកស្រែ៖ជឿលើកម្លាំងក្រៅខ្លួនទស្សនៈកម្មផល

- សីលធម៌ : ការមិនរើសអើង ពាក្យសម្តី កាយវាចាចិត្ត ភាពកត្តញ្ញូ។

ឧទាហរណ៍រឿង កុលាបបៃលិន៖ លោក ហ្លួង មិនរើសអើងចំពោះ ចៅ ចិត្រ។

រឿង មហាចោរនៅទល់ដែន៖ ពាក្យសម្តីរបស់តួអង្គនាងទេវី ការប្រព្រឹត្តិអំពើល្អទាំងកាយវាចាចិត្ត។

រឿងផ្កាស្រពោន៖ ប៊ុន ធឿន ជួយធ្វើការឪពុកម្តាយ។

- សាសនា : ការគោរពប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន ការបួសក្នុងសំណាក់សាសនា។

ឧទាហរណ៍ រឿង ទុំទាវ៖ ម្តាយទាវទៅវត្តរៀងរាល់ថ្ងៃសីល ទុំ និងពេជបួសក្នុងសំណាក់ពុទ្ធសាសនា។

រឿងផ្កាស្រពោន៖ការគោរពលើព្រះពុទ្ធរូបការរំឭកដល់គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។

- វិទ្យាសាស្ត្រ : គំនិតទស្សនៈ ឧបករណ៍ប្រើប្រាស់ ឱសថ យានជំនិះ។

ឧទាហរណ៍រឿងផ្កាស្រពោន៖យាយនួនឃើញកូនឈឺស្គមស្គាំង ក៏នាំកូនដើរកម្សាន្តខេត្តសៀមរាប។

រឿងមេឃបាត់ដួងច័ន្ទ៖ បូផាន់មិនយល់ស្របនឹងម្តាយ។

+ ផ្នែកផ្សព្វផ្សាយ៖ ភាសា អក្សរសិល្ប៍ សិល្បៈ ព័ត៌មាន។

- ភាសា : បាលី សំស្ក្រឹត សៀម ចិន វៀតណាម ខ្មែរ។

ឧទាហរណ៍ រឿង គ្រូបង្រៀនស្រុកស្រែ៖ ភាសាបាលី សំស្ក្រឹត ភាសាបារាំង ភាសាសៀម ភាសាចិនភាសាខ្មែរ។

- អក្សរសិល្ប៍ : កំណាព្យ សុភាសិត សំបុត្រ ចម្រៀង ក្រាំង

ឧទាហរណ៍រឿងផ្កាស្រពោន៖យាយនួនបបួលកូនឲ្យមើលក្រាំង សាស្ត្រា ព្រះលក្ខិណវង្ស។

រឿង មហាចោរនៅទល់ដែន៖ សូត្រកំណាព្យ សុភាសិត ការសរសេរសំបុត្រ។

- សិល្បៈ ព័ត៌មានៈ របាំ ល្ខោន ការឃោសនា ខិតប័ណ្ណ។

ឧទាហរណ៍រឿងគ្រូបង្រៀនស្រុកស្រែ៖សារព័ត៌មានប្រើនៅពេលឃោសនារកសន្លឹកឆ្នោត បិទខិតប័ណ្ណ។

រឿងភូមិតិរិច្ឆាន៖បង្ហាញពីរបាំ"ល្ខោនហ្លួង"និងល្បែងប្រជាប្រិយផ្សេងៗតាមរបៀបខ្មែរ។

+ ការអនុវត្ត៖ ទំនៀមទម្លាប់ ប្រពៃណី ការសិក្សា ការអប់រំ (ប្រដៅទូន្មាន) កីឡា ការកម្សាន្ត ច្បាប់ផ្សេងៗ។

- ទំនៀមទម្លាប់ប្រពៃណីៈ ចូលម្លប់ ស្ដីដណ្ដឹង រៀបការ ការបួសរៀន ពិធីបុណ្យសព ការប្រណាំងទូក ការ

រៀបចំទុកដាក់កូនចៅ ការប្រកបរបរចិញ្ចឹមជីវិត មធ្យោបាយធ្វើដំណើរ ការស្លៀកពាក់ ពិធីផ្សេងៗ...។

ឧទាហរណ៍រឿងមហាចោរនៅទល់ដៃនះពិធីបុណ្យសពពិធីបង្កក់កូនឬចេញភ្លើង ការប្រកបរបរ មធ្យោបាយធ្វើដំណើរ ការស្លៀកពាក់។ រឿងទុំទាវះការចូលម្លប់នាងទាវការបួសរៀនរបស់នេនទុំ និងនេនពេជ្រ ស្តីដណ្តឹង រៀបការ។

- ការសិក្សាការអប់រំៈរៀននៅផ្ទះនៅវត្តសាលារៀន ស្វែងរកវិជ្ជាពីសំណាក់គ្រូអាចារ្យតាមអប់រំតាមគំនិតយោបល់ និងអប់រំតាមការទូន្មានពីគ្រួសារ។

ឧទាហរណ៍ រឿងសូផាត៖ រៀននៅតាមសាលារៀនវិទ្យាល័យ។
រឿង គ្រូបង្រៀនស្រុកស្រែ៖ អប់រំតាមគំនិតយោបល់។
រឿងផ្កាស្រពោន៖ទទួលការអប់រំពីម្តាយ។
រឿងទុំទាវ៖កូនប្រុសបួសរៀននៅវត្តកូនស្រីរៀនវិជ្ជាមេផ្ទះ។

- ការកម្សាន្ត កីឡា ច្បាប់ផ្សេងៗៈ ច្បាប់អប់រំកូនចៅ (ច្បាប់ស្រី ប្រុស)។

ឧទាហរណ៍រឿង មហាចោរនៅទល់ដៃនះ ច្បាប់អប់រំព្រឹត្តិតែអំពើល្អ។

រឿង ផ្កាស្រពោន៖ ក្បួនច្បាប់អប់រំចិត្តគំនិត។

- សរុបមតិ៖សរុបសេចក្តីមករអក្សរសិល្ប៍ខ្មែរបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់វប្បធម៌ជាតិខ្មែរឲ្យបានគង់វង្ស ព្រោះបានបង្ហាញឲ្យឃើញថា ជំនឿ សាសនា...។

## III. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធានៈ មានអត្ថន័យល្អជ្រាលជ្រៅបានបង្ហាញពីវប្បធម៌នៅក្នុងអក្សរសិល្ប៍មានទាំង...។
- មតិផ្ទាល់ខ្លួនៈ ដូច្នេះយើងទាំងអស់គ្នាត្រូវចូលរួមចំណែកក្នុងការទ្រទ្រង់វប្បធម៌ជាតិឱ្យបានគង់វង្ស...។

## សេចក្ដីអធិប្បាយ

វប្បធម៌ ជាធាតុដ៏សំខាន់មួយសម្រាប់សម្គាល់ឱ្យជាតិសាសន៍ផ្សេងៗ ហើយគ្រប់ជាតិសាសន៍នីមួយៗតែងតែមាននូវវប្បធម៌ល្អរៀងៗខ្លួន ដែលជាតិសាសន៍ក៏រុងរឿង និងមិនសូវរុងរឿងអាស្រ័យទៅលើជាតិសាសន៍នោះ បូកផ្សំនឹងធាតុសំខាន់ៗជាច្រើនដែលជាមែកធាងនៃវប្បធម៌ជាតិផងដែរ។ អាស្រ័យដោយហេតុនេះហើយ ទើបមានទស្សនៈមួយបានលើកឡើងថា៖ "អក្សរសិល្ប៍ខ្មែរ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់វប្បធម៌ជាតិខ្មែរឱ្យបានគង់វង្ស"។

តើមតិដែលបានលើកឡើងខាងលើនេះមានអត្ថន័យយ៉ាងដូចម្ដេច?

ដើម្បីជាពន្លឺឱ្យច្បាស់ដល់ការបកស្រាយមតិ យើងគួរគប្បីត្រូវយល់ពីពាក្យគន្លឹះ "អក្សរសិល្ប៍" និង "វប្បធម៌" ជាមុនសិន។ ពាក្យ "អក្សរសិល្ប៍" គឺជាស្នាដៃដែលធ្វើការឆ្លុះបញ្ចាំងអំពីតថភាពនៅក្នុងសង្គម មកបង្ហាញឱ្យយើងបានយល់ឃើញទាំងផ្នែកវិជ្ជមាន និងផ្នែកអវិជ្ជមាន។ ឯពាក្យ "វប្បធម៌" គឺជាការសាបព្រោះ ឬផ្សាំបណ្ដុះនូវចំណេះដឹង និងប្រាជ្ញាស្មារតីឱ្យបានចម្រើនលូតលាស់ដោយវិទ្យាសាស្ត្រ ឬសិល្បៈផ្សេ

ងៗ។ ប្រការនេះហើយធ្វើឱ្យយើងអាចនិយាយបានថា អត្ថបទអក្សរសិល្ប៍ខ្មែរគឺបានឆ្លុះបញ្ចាំងពីភាពពិតនៅក្នុងសង្គមជាក់ស្តែងដោយបានបង្ហាញនូវវប្បធម៌ជាតិរបស់ខ្មែរទៅក្នុងស្នាដៃអក្សរសិល្ប៍ទាំងនោះមានដូចជា ផ្នែកចំណេះដឹង ការកំណាត់ផ្សាយ ឬការផ្សព្វផ្សាយ និងការអនុវត្តជាដើម។

យើងដឹងហើយថាវប្បធម៌ជាផ្នែកតូចមួយនៃអរិយធម៌ ហើយវប្បធម៌ត្រូវបានអ្នកនិពន្ធជាច្រើនបានបញ្ជ្រាបទៅរាល់ស្នាដៃអក្សរសិល្ប៍ទាំងឡាយ ពិសេសអក្សរសិល្ប៍ទាំងនោះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់វប្បធម៌ជាតិខ្មែរឱ្យបានគង់វង្ស។ ដោយសារតែស្នាដៃភាគច្រើនអ្នកនិពន្ធបានឆ្លុះបញ្ចាំងអំពីបញ្ហាវប្បធម៌។ ផ្នែកដំបូងគឺចំណេះដឹងដែលមានដូចជា ជំនឿ សាសនា សីលធម៌ វិទ្យាសាស្ត្រ។ ជាបឋមទាក់ទងទៅនឹងជំនឿ គឺមានស្នាដៃជាច្រើនដែលបានបង្ហាញពីទេវតា អបិយជំនឿ មន្តអាគម ការបន់ស្រន់ ទស្សនៈកម្មផល ពាក្យសម្បថ ព្រេងវាសនា ការទស្សន៍ទាយ បាតុភូតផ្សេងៗ កម្លាំងក្រៅខ្លួន និងបញ្ញាញាណជាដើម។ តួយ៉ាងដូចនៅក្នុងរឿង ទុំទាវ ដែលនិពន្ធដោយភិក្ខុ សោម ឆ្នាំ១៩១៥ គឺអ្នកនិពន្ធបានបង្ហាញឱ្យឃើញថា ប្រជាជនខ្មែរយើងនៅសម័យនោះជឿទៅលើកម្មផលក្នុងពុទ្ធសាសនា ជឿទៅលើការទស្សន៍ទាយ។ ជាក់ស្តែងណាស់ការទស្សន៍ទាយរបស់គ្រូអធិការ ដែលជាគ្រូបាអាចារ្យរបស់នេនទុំ។ ម្យ៉ាងវិញទៀតក្នុងរឿងផ្កាស្រពោនក៏បានបង្ហាញពីជំនឿជាច្រើនផងដែរ ដូចជា ជឿលើទេវតា ជឿលើមន្តអាគម អបិយជំនឿ ដូចដែលតួអង្គ ប៊ុន ធឿន ពេលទៅរៀនបន្តនៅឯភ្នំពេញ

វិធាវី បានបន់ស្រន់បួងសួងទេវតា សុំឱ្យទេវតាជួយថែរក្សាឱ្យមានក្ដីសុខសប្បាយជៀសផុតពីសេចក្ដីទុក្ខសោក។ ស្របនឹងនេះនាងថូ បានទៅនិមន្តព្រះសង្ឃដែលចង្រ្កមភាវនានៅក្នុងភ្នំសំពៅឱ្យស្រោចទឹករំដោះគ្រោះជាដើម។ ក្នុងករណីនេះ រឿងគ្រូបង្រៀនស្រុកស្រែ អ្នកនិពន្ធក៏បានបង្ហាញពីជំនឿលើកម្លាំងក្រៅខ្លួន ការបន់ស្រន់ ទស្សនៈកម្មផលផងដែរ។ តួយ៉ាងសុខដែលជាក្មួយពូហាម ដោយខ្លាចរដ្ឋចាប់ពូហាមដាក់គុក ក៏បានអុជធូបបីសរសៃ សូមឱ្យលោកយាយម្ចាស់ស្រុកជួយកុំឱ្យគេចាប់ពូហាម។ មួយវិញទៀតអាចារ្យសម បានជឿទៅលើកម្មផលយ៉ាងខ្លាំង សូម្បីពេលដែលគាត់កំពុងភាវនាធម៌ មូសខាំជិតងាប់ក៏គាត់មិនហ៊ានទះមូសដែរ ព្រោះខ្លាចមានកម្មវេរាទៅជាតិក្រោយ។ ក្នុងផ្នែកចំណេះដឹងនេះដែរទាក់ទងនឹងសីលធម៌វិញ ស្នាដៃភាគច្រើនគឺតែងតែបានបង្ហាញពីបញ្ហាសីលធម៌ ការរើសអើង ការជិះជាន់ទៅលើអ្នកទន់ខ្សោយ ដូចជាតាមរយៈរឿង កុលាបប៉ៃលិន គឺអ្នកនិពន្ធបានបំផុសឱ្យអ្នកអានមានក្រមសីលធម៌មិនត្រូវមានការរើសអើងគ្នាដូចជា លោក ហ្លួង រតនសម្បត្តិ ចំពោះ ចៅចិត្រ ដែលជាកូនកំព្រាគ្មានឪពុកម្ដាយ និងទ្រព្យសម្បត្តិ។ យ៉ាងណាមិញរឿង មហាចោរនៅទល់ដែន អ្នកនិពន្ធក៏បានពន្លេចនូវសីលធម៌តាមរយៈពាក្យសម្ដីរបស់នាងទេវីដោយការប្រព្រឹត្តអំពើល្អទាំងកាយវាចាចិត្តថា "ស្រីស្រស់បានភ្ញាក់ស្មារតី ឪពុកនាងពុំស្រឡាញ់ទ្រព្យ ឬបុណ្យសក្តិ ឬប្រាក់កាសទេ តែស្រឡាញ់កេរ្តិ៍ឈ្មោះ ធ្វើឱ្យនាងយល់ថាឪពុកនាងមានចិត្តខ្ពស់ ស្គាល់តម្លៃពិតរបស់មនុស្ស"។ ទន្ទឹមនឹងនេះរឿង ផ្កាស្រពោន អ្នកនិពន្ធបង្ហាញពីការជួយការងារស្រែចម្ការឪពុកម្ដាយពេលសម្រាកពី

ការសិក្សា ដូចនៅត្រង់ឃ្លាមួយដែលបានលើកឡើងថា "ប៊ុន ធឿន ក្មេងកម្លោះម្នាក់ដែលយើងបានស្គាល់ពីមុនមក ហើយត្រឡប់មកជួយដកស្ទូងនាងង៉ាន់ជាម្ដាយ"។ លើសពីនេះសាសនាក៏បានចូលរួមចំណែកក្នុងអក្សរសិល្ប៍ខ្មែរជាច្រើនផងដែរ ដែលបង្ហាញពីការគោពសាសនាយ៉ាងល្អខ្ជាប់ខ្ជួនដូចជា ព្រះពុទ្ធសាសនា ឬការបួសក្នុងសំណាក់សាសនាជាដើម។ តួយ៉ាងរឿង ទុំទាវ គឺម្ដាយទាវបានទៅវត្តជារៀងរាល់ថ្ងៃសីល ហើយទុំនិងពេជ្របានបួសនៅក្នុងសំណាក់ព្រះពុទ្ធសាសនា។ ស្របនឹងនេះរឿងផ្កាស្រពោន ក៏បានបង្ហាញពីការគោរពលើព្រះពុទ្ធសាសនាដែរ ដូចនៅត្រង់ឃ្លាដែលបានលើកឡើងថា "ថ្ងៃពេញបូណ៌មី យាយនួន និងយាយផៃទៅវត្តដើម្បីប្រគេនចង្ហាន់ដល់ព្រះសង្ឃ" គឺបានសេចក្ដីថា ពុទ្ធសានិកគោរពបូជាចំពោះព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួនណាស់។ ចំណុចចុងក្រោយនៃផ្នែកចំណេះដឹង គឺវិទ្យាសាស្ត្រ។ វិទ្យាសាស្ត្រគឺជាទស្សនៈដែលប្រាសចាកពីជំនឿ ទស្សនៈ ឬគំនិតដែលមនុស្សយល់ឃើញថាជាការប្រសើរ ការយល់ពីសង្គមច្បាស់ ដោយយល់ថាការកើតមានមូលហេតុអ្វីហើយត្រូវយកទៅដោះស្រាយដើម្បីអភិវឌ្ឍន៍ចិត្តគំនិត។ តួយ៉ាងរឿង ផ្កាស្រពោន យាយនួនយល់ឃើញកូនឈឺស្គមស្គាំងមិនមែនដោយសារខ្មោចព្រាយបិសាចធ្វើទុក្ខទេ ប៉ុន្តែគិតថាកូនឈឺក៏នាំកូនដើរកម្សាន្តខេត្តសៀមរាប។ ដូចត្រង់ឃ្លាដែលបានលើកឡើងថា "យាយនួន ឃើញកូនគាត់ទឹកមុខស្រពោនថយកម្លាំងក៏គិតថា គួរនាំកូនទៅលេងរំហើយចិត្ត ដោយយល់ថា ការទស្សនាបុរាណដ្ឋានទាំងឡាយដែលស្ថិតនៅខេត្តសៀមរាប ដើម្បីឱ្យកូនរីករាយសប្បាយ"។ ស្របនឹងនេះនៅក្នុងរឿង

មេឃបាត់ដួងច័ន្ទ ក៏បានបង្ហាញគំនិតរបស់បូផាន់មានភាពមិនយល់ស្របនឹងម្តាយរបស់គាត់ ដែលមានជំនឿទៅលើទេវតា ឥន្ទព្រហ្ម ដែលម្តាយរបស់ខ្លួនបានលើកដៃឡើងទៅលើថ្លៃងអំណរគុណចំពោះទេវតា ដែលបានផ្តល់សេចក្តីសុខ និងថែរក្សាដល់បូផាន់ជាកូន តែគំនិតបូផាន់វិញមិនយល់ស្របនឹងម្តាយគាត់ទេ ព្រោះតាមពិតអ្នកដែលជួយចិញ្ចឹមផ្គត់ផ្គង់បូផាន់ឱ្យមានសេចក្តីសុខនោះ គឺគ្រួសារពូរ៉ឹស មិនមែនឥន្ទព្រហ្មទេវតាឯណាទេ។ នេះសបញ្ជាក់ឲ្យឃើញថាបូផាន់មានគំនិតបែបវិទ្យាសាស្ត្រដែលមិនជឿលើអបិយជំនឿ ឬកម្មផលឡើយ ព្រោះគាត់ជាមនុស្សល្អ សុចរិតត្រឹមត្រូវ។ ទាំងអស់នេះហើយគឺជាចំណុចតូចៗនៅក្នុងផ្នែកចំណេះដឹងនៅក្នុងវប្បធម៌ ដែលមាននៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ។

បន្ទាប់មកទៀតកំណត់ផ្សាយ ឬការផ្សព្វផ្សាយជាផ្នែកផាងសំខាន់ទីពីរនៃផ្នែកផាងវប្បធម៌ខ្មែរ ដែលចូលរួចំណែកយ៉ាងសំខាន់ក្នុងការបកស្រាយពន្យល់ឱ្យវប្បធម៌។ ព្រោះតែការកត់ត្រា វិធីសាស្ត្រនៃការសរសេរ ឬការនិយាយរបស់តួអង្គ ភាសា អក្សរ សុទ្ធតែជាយុទ្ធសាស្ត្រក្នុងការផ្សព្វផ្សាយវប្បធម៌ក្នុងសម័យកាលនីមួយៗរបស់សង្គម។ តួយ៉ាងភាសាគឺសម្តៅទៅលើការប្រើប្រាស់របស់តួអង្គនៅក្នុងរឿង ការប្រើចំពោះតួអង្គដោយមានលាយ ឬក្លាយរបស់ភាសាបរទេសមកលើភាសាខ្មែរ ដែលធ្វើឱ្យខ្មែរមានការកម្ចីភាសាជាច្រើនរួមមាន ភាសាបារាំងសៀម អង់គ្លេស ចិន បាលីសំស្ក្រឹតជាដើម ប៉ុន្តែខ្មែរមានការប្រើភាសាបរទេសដែលកម្ចីទាំងនោះឱ្យមានលក្ខណៈជារបស់ខ្មែរ ទោះបីមានសូរ

បរទេសខ្លះក៏ដោយ។ ជាក់ស្តែងដូចក្នុងរឿង គ្រូបង្រៀនស្រុកស្រែ យើងឃើញថានៅក្នុងសម័យនោះប្រជាពលរដ្ឋខ្មែរមានពាក្យកម្ចីពីភាសាបាលីសំស្ក្រឹត បារាំង ចិន និងវៀតណាមខ្លះដែរ ដូចជាកម្ចីពីបារាំង ពាក្យម៉ាស៊ីន ខោរអាវ ស៊ីវិល ប៉ូលីស អាវសឺមី។ ឯពាក្យកម្ចីពីចិន-វៀតណាមមានដូចជាពាក្យ ហាងឆេង ចាងហ្វាង...និងកម្ចីពីបាលីសំស្ក្រឹតវិញមានដូចជាពាក្យ ស្ម័គ្រចិត្ត បរិច្ចាគ អនុញ្ញាត្តិ រដ្ឋមន្ត្រី យុត្តិធម៌ ឧបត្ថម្ភ ចក្រពត្តិ អព្យាក្រឹត្យ...ជាដើម។ ម្យ៉ាងវិញទៀតសោត អក្សរសិល្ប៍ក៏ជាចំណែកមួយយ៉ាងសំខាន់ក្នុងផ្នែកផ្សព្វផ្សាយផងដែរ ព្រោះអក្សរសិល្ប៍គឺជាកញ្ចក់ឆ្លុះបញ្ចាំងពីតថភាពរបស់សង្គមនៅក្នុងសម័យកាលណាមួយតាមរយៈការលើកយកបញ្ហារបស់មនុស្សនាសម័យនោះមកចោទ ឬធ្វើការដោះស្រាយតាមសិល្បវិធីរបស់អ្នកនិពន្ធ។ អក្សរសិល្ប៍ទាំងនោះរួមមាន កំណាព្យ សុភាសិត ចម្រៀង សាស្ត្រាក្រាំង ជាដើម។ ស្របនឹងនេះរឿង ផ្កាស្រពោន ក៏បានបង្កប់នូវតម្លៃអក្សរសិល្ប៍ត្រង់វគ្គ "នៅយប់នោះយាយនួនគាត់មានកង្វក់ក្នុងចិត្ត ហើយគាត់បានបបួលកូនឱ្យមើលក្រាំងព្រះលក្ស្មណវង្សគ្រាន់កែអផ្សុក"។ ត្រង់ចំណុចនេះបានសេចក្តីថាសម័យនោះប្រជាជនដែលចេះអានអក្សរ ឬមានចំណេះដឹងខ្ពង់ខ្ពស់ គេចូលចិត្តអានក្រាំង សាស្ត្រា ឬអត្ថបទអក្សរសិល្ប៍បុរាណនានា។ ទន្ទឹងនឹងនេះរឿង មហាចោរនៅទល់ដែន បានបង្ហាញពីសកម្មភាពរបស់តួអង្គដែលចេះសូត្រកំណាព្យ សុភាសិត ច្រៀងកំណាព្យ ដែលបង្កប់ដោយសិល្បៈរូបារម្មណ៍។ ដូចសុភាសិតមួយឃ្លាត្រង់វគ្គទី១៦បានលើកឡើងថា "ឃ្លោកលិចអំបែងអណ្តែត កង់ត្រាចកង់ធ្នង់" ហើយក្នុងត្រង់វគ្គទី១៧ "ទឹក

ឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី" និងវគ្គទី២១ "ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ"។ លើសពីនេះទៅទៀត សិល្បៈ និងព័ត៌មានក៏ជាផ្នែកមួយសម្រាប់សម្គាល់វប្បធម៌ខ្មែរផងដែរ សិល្បៈរួមមាន ទាំងរបាំល្ខោន ឯព័ត៌មានវិញបង្ហាញតាមរយៈការឃោសនា ខិតប័ណ្ណ ការផ្ដល់ដំណឹងពីមនុស្សម្នាក់ទៅមនុស្សម្នាក់តាមរយៈការសរសេរសំបុត្រ នាំពាក្យ ឬការសួរផ្ទាល់មាត់។ តួយ៉ាងក្នុងរឿង គ្រូបង្រៀនស្រុកស្រែ បង្ហាញពីបញ្ហាព័ត៌មានដូចជា ការឃោសនារកសន្លឹកឆ្នោត បិតខិតប័ណ្ណផ្សេងៗក្នុងពេលយុទ្ធនាការបោះឆ្នោតប្រជែងគណបក្សនាពេលនោះ។ ក្នុងពេលនោះដែរ គេក៏ប្រើនូវគ្រឿងបំពងសំឡេងមីក្រូក្នុងពេលឃោសនាដល់ប្រជាពលរដ្ឋ។ ទន្ទឹមនឹងនេះតាមរយៈអត្ថបទរឿង ភូមិតិរិច្ឆាន ក៏បានបង្ហាញសិល្បៈមួយគឺ សិល្បៈស្មូនឆ្នាំង ក្អម...។ ប្រការខាងលើនេះហើយ ដែលបានទ្រទ្រង់នូវវប្បធម៌ជាតិយ៉ាងខ្លាំងតាមរយៈអក្សរសិល្ប៍ខ្មែរយើង។

ក្រៅពីនោះផ្នែកទីបីបន្ទាប់ពីការផ្សព្វផ្សាយ គឺការអនុវត្ត ដែលជាធាតុមួយក្នុងចំណោមធាតុទាំងបីរបស់វប្បធម៌។ ក្នុងនោះមានចំណុចសំខាន់ៗដូចជា ទំនៀមទម្លាប់ប្រពៃណី ការសិក្សាការអប់រំ កីឡា ការកម្សាន្ត និងច្បាប់ផ្សេងៗ។ ដំបូងឡើយទាក់ទងនឹង ប្រពៃណី ទំនៀមទម្លាប់ អ្នកនិពន្ធក៏បានបញ្ជ្រៀតចូលក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរដូចជា ពិធីចូលម្លប់ ពិធីស្ដីដណ្ដឹង ពិធីរៀបអាពាហ៍ពិពាហ៍ ការរៀបចំទុកដាក់កូនចៅ ពិធីបុណ្យសព ពិធីប្រណាំងទូក ការបួសរៀន ការស្លៀកពាក់ ការប្រកបរបរចិញ្ចឹមជីវិត មធ្យោបាយធ្វើដំណើរជាដើម។ តួយ៉ាងតាមរយៈរឿង មហា

ចោរនៅទល់ដែន បានបង្ហាញពីពិធីរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីខ្មែរ ដូចប្រយោគមួយបានលើកឡើងថា "ពិធីសែនព្រេនចាប់ផ្ដើមឡើងមួយរំពេចក្នុងវេលានោះ។ នាងភួងត្រូវទៅដាស់លោកមេឃុំជំទប់ឃុំមកដោយឥតបង្អង់។ នាងទេវីធ្វើម្ហូបអាហារសម្រាប់សែនព្រេន។ មានួនត្រូវកាច់ផ្កាស្លា រកទៀនធូបដោយរួសរាន់។ មិនយូរប៉ុន្មានមេឃុំនិងជំទប់ឃុំក៏មកដល់ ទៀនធូបភ្លឺរន្ទាល កូនប្រុស កូនស្រីក៏ក្រាបទាំងគូទន្ទឹមគ្នា"។ ជាងនេះទៅទៀតក៏បានបង្ហាញពីប្រពៃណីបង្កក់កូន ឬចេញភ្លើងរបស់នាងទេវី ដូចត្រង់ឃ្លាមួយបាននិយាយថា "នាងទេវីមើលបុត្រីនាងញញឹមដោយរីករាយ។ ប៉ុន្តែថ្ងៃក្រោយមក នាងទេវីក៏ចេញភ្លើង។ មានបងប្អូនជិតខាងជាច្រើន ខ្លះយកអង្ករមួយកញ្ជើមកចងដៃកូនថ្មី ខ្លះយកសំពត់ថ្មីៗមកជូន ខ្លះទៀតបានត្រីសាច់ជាដើម"។ លើសពីនេះទៅទៀតតាមរយៈអក្សរសិល្ប៍នេះដដែរ យើងក៏បានឃើញពីមធ្យោបាយធ្វើដំណើរជាច្រើន ដែលបានបង្ហាញពីទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជនខ្មែរនាសម័យនោះដូចជា ជិះសេះ ជិះរទេះគោ ជិះដំរី ជិះទូក ដូចនៅក្នុងវគ្គទី៣បានបង្ហាញឃ្លាមួយថា "ក្នុងពេលនោះ ជើងសេះពុកបៗ ផាយពីចម្ងាយមក លុះមកដល់មុខខ្ទមកម្សត់ អ្នកជិះលោតពីខ្នងសេះអាជានេយ្យយ៉ាងរហ័ស"។ ក្នុងករណីនេះរឿង ទុំទាវ ក៏បានបង្ហាញពីទំនៀមទម្លាប់ប្រពៃណីខ្មែរជាច្រើនដែរ ដូចជាពិធីចូលម្លប់របស់ទាវ និងការបួសរៀនកូនប្រុសនៅក្នុងវត្តរបស់ទុំ ពិធីមង្គលការទុំនិងទាវ និងការចូលស្ដីដណ្ដឹងនាងទាវរបស់ស្ដេចរាមាជើងព្រៃជាដើម។ បន្ទាប់មកចំណុចមួយដែលសំខាន់នៅក្នុងការអនុវត្តនោះគឺ ការសិក្សា ការអប់រំ ដែលយើងសង្កេត

ឃើញមានជាច្រើននៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរនានា។ ការសិក្សាទាំងនោះមានច្រើនបែបទៅតាមសម័យកាលនីមួយៗ ដូចជាទទួលការសិក្សានៅក្នុងវត្តអារាម រៀននៅផ្ទះ តាមសាលារៀន ពីសំណាក់គ្រូអាចារ្យ និងទទួលការអប់រំពីគ្រួសារ និងគំនិតយោបល់អ្នកជុំវិញខ្លួន។ ជាការពិតណាស់តាមរយៈរឿង សូផាត បង្ហាញថានាសម័យនោះសូផាតរៀននៅវិទ្យាល័យ អក្សរសាស្ត្របារាំងខ្មែរជាមួយនឹងណារិននៅសាលាកូលេសស៊ីសុវត្ថិ។ តួយ៉ាងនៅក្នុងរឿង គ្រូបង្រៀនស្រុកស្រែ យើងបានឃើញថាតួអង្គចេះអប់រំផ្ដល់គំនិតយោបល់ ក៏ដូចជាការដាស់តឿនគ្នា ដូចត្រង់សម្ដីរបស់ពូហម ដែលបាននិយាយក្រើនរំឭកដាស់តឿនចំពោះអាចារ្យសមដែលមិនបានដឹងរឿងរ៉ាវសង្គម ដែលមិនខ្វល់ខ្វាយនិងបញ្ហាសង្គមថា "យើងត្រូវអប់រំខ្លួនយើង និងអប់រំអ្នកភូមិឱ្យយល់ជឿលើកម្លាំងខ្លួនហើយឱ្យដឹងថាទាល់តែយើងរួមកម្លាំងគ្នា សាមគ្គីគ្នាទើបយើងអាចទប់ទល់នឹងអ្នកដទៃបាន"។ យ៉ាងណាមិញរឿង ផ្កាស្រពោន ការសិក្សាការអប់រំបានស្ដែងឡើងតាមរយៈតួអង្គទាំងពីរគឺ ប៊ុន ធឿន និងនាងវិធាវី។ ដូចត្រង់ឃ្លាមួយបានបង្ហាញថា "នាងវិធាវីស្ដាប់តាមដំបូន្មានម្ដាយនាង កាលពីនាងនៅតូច នាងបានទៅរៀននៅសាលាវត្តពោធិវាល លុះដល់វ័យជំទង់ នាងកាន់កាប់ការងារតែនៅក្នុងផ្ទះ តែពេលទំនេរនាងតែងតែទៅសិក្សាភាសាសៀម និងរៀនដេរប៉ាក់ជាមួយគ្រូម្នាក់នៅជិតផ្ទះរបស់នាង"។ ចំណែកឯ ប៊ុន ធឿនវិញ គេបានបន្តការសិក្សានៅឯភ្នំពេញរហូតដល់ថ្នាក់ឌីប្លូម ដូចសម្ដីរបស់នាង វិធាវីពោលទៅកាន់ម្ដាយខ្លួនថា "បង ប៊ុន ធឿន ធ្លាក់ខ្លួនក្រខាងទ្រព្យធនមែនពិត តែគេនៅមានសម្បត្តិ

មួយយ៉ាងប្រពៃណាស់ គឺចំណេះវិជ្ជា។ បើកាលណាគេប្រឡងជាប់ឌីប្លូមហើយ...”។ ក្នុងនោះដែររឿង ទុំទាវក៏សបញ្ជាក់ឲ្យយើងឃើញថា ការសិក្សា ការអប់រំកូនប្រុស កូនស្រីតាមរយៈ ការបួសរៀននៅក្នុងវត្តសម្រាប់កូនប្រុស គឺនេនទុំ និងនេនពេជ្រ ឯកូនស្រីវិញតាមរយៈការចូលម្លប់ ដើម្បីឱ្យចេះពីជំនាញវិជ្ជាមេផ្ទះជាដើម ជាក់ស្ដែងគឺនាង ទាវ។ ក្រៅពីការសិក្សា ការអប់រំ ក៏ដូចជាទំនៀមទម្លាប់ប្រពៃណី គឺការកម្សាន្ត កីឡា និងច្បាប់ផ្សេងៗក៏ត្រូវបានអនុវត្តនៅក្នុងសង្គមខ្មែរផងដែរ ដូចជា ការទស្សនា ច្បាប់ប្រុស ច្បាប់ស្រី ច្បាប់អប់រំចិត្តគំនិតជាដើម ដែលសុទ្ធសឹងតែជាកត្តាសំខាន់មិនអាចខ្វះបានក្នុងវប្បធម៌ខ្មែរ។ តាមរយៈអក្សរសិល្ប៍រឿង ផ្កាស្រពោនដដែរ ក៏បានបង្ហាញពីការកម្សាន្តនៅពេលវិសមកាលនៃពួកសិស្សវិទ្យាល័យខណៈធ្វើដំណើររត្រឡប់ទៅក្រុងបាត់ដំបងវិញ ដោយ អឹងកង ខ្លះផ្លុំគែន ខ្លះទះដៃ ខ្លះទន្ទ្រាំក្ដារ បន្ទរ ហើយខ្លះទៀតច្រៀងតាមទំនុកបារាំងក៏មាន។ មួយវិញទៀតបានបង្ហាញពីកីឡាប្រណាំងទូកនាពេលឱកាសបុណ្យអុំទូក។ ទន្ទឹមនឹងនេះទាក់ទងទៅច្បាប់អប់រំចិត្តគំនិតកូនប្រុស កូនស្រីក៏យើងសង្កេតឃើញមានជាច្រើនស្ទើរតែគ្រប់អក្សរសិល្ប៍ខ្មែរ។ ដូចនៅក្នុងរឿង មហាចោរនៅទល់ដែន បានបង្ហាញពីច្បាប់អប់រំកូនចៅ ប្រុស ស្រីឱ្យប្រព្រឹត្តតែអំពើល្អ អំពើដែលជាកុសល ដូចត្រង់វគ្គទី១៦មានប្រយោគមួយថា “ក្នុងពេលថ្ងៃ ចិត្តស្រីប្រកាន់ថា មិនស្រឡាញ់នឹងប្រុសណាជាដាច់ខាត។ រួចបើស្រឡាញ់ តោងតែស្រឡាញ់ប្រពៃណីបុរាណ គឺត្រូវឪពុកម្ដាយទុកដាក់ឱ្យត្រូវតាមច្បាប់”។

សរុបសេចក្ដីមកអក្សរសិល្ប៍ខ្មែរពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់វប្បធម៌ជាតិខ្មែរឱ្យបានគង់វង្សពិតប្រាកដមែន។ ព្រោះរាល់ស្នាដៃអក្សរសិល្ប៍ទាំងឡាយពិតជាបានឱ្យយើងប្រមើលឃើញពីបញ្ហាជាច្រើនដូចជា ជំនឿ សាសនា អក្សរសាស្ត្រ អក្សរសិល្ប៍ សិល្បៈ ព័ត៌មាន ទំនៀមទម្លាប់ ប្រពៃណី ការសិក្សា ការអប់រំ ការកម្សាន្ត កីឡា និងច្បាប់ផ្សេងៗជាដើម ដែលជាមែកធាងនៃវប្បធម៌ខ្មែរ ដែលអ្នកនិពន្ធបានបញ្ចូលទៅរាល់ស្នាដៃអក្សរសិល្ប៍ដើម្បីទ្រទ្រង់នូវវប្បធម៌ជាតិឱ្យបានគង់វង្ស ដើម្បីឱ្យកូនខ្មែរបានស្គាល់ ហើយផ្សព្វផ្សាយទៅកាន់សកលលោក និងបានចូលរួមថែរក្សានៃវប្បធម៌របស់ជាតិខ្លួនឱ្យស្ថិតនៅគង់វង្សស្ថិតស្ថេរតទៅមុខទៀត។

ឆ្លងតាមរយៈការពន្យល់បកស្រាយមតិដែលបានលើកឡើងថា "អក្សរសិល្ប៍ខ្មែរបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់វប្បធម៌ជាតិខ្មែរ ឱ្យបានគង់វង្ស" រួចមក គឺយើងឃើញថាពិតជាមានអត្ថន័យយ៉ាងល្អជ្រាលជ្រៅដោយបានបង្ហាញពីវប្បធម៌នៅក្នុងអក្សរសិល្ប៍ខ្មែរ និងបានបំផុសឱ្យយើងបានឃើញអំពីបញ្ហាវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា ការប្រកបរបរចិញ្ចឹមជីវិតជាដើម ដែលបានចូលរួមចំណែកក្នុងការទ្រទ្រង់វប្បធម៌ខ្មែរឱ្យបានស្ថិតស្ថេរ និងគង់វង្ស។ ដូច្នេះក្នុងនាមយើងជាអ្នកសិក្សា ក៏ដូចជាកូនខ្មែរមួយរូប ត្រូវចូលរួមចំណែកក្នុងការទ្រទ្រង់វប្បធម៌ជាតិឱ្យបានគង់វង្ស។ ប៉ុន្តែវាមិនមែនផ្អែកទៅលើផ្នែកអក្សរសិល្ប៍ទាំងស្រុងនោះទេ ព្រោះវប្បធម៌ខ្មែរអាចស្ថិតស្ថេរ

និងគង់វង្សទៅបាន ក៏អាស្រ័យទៅលើកត្តាសំខាន់ៗជាច្រើនផ្សេងទៀត ដែលបានចូលរួមចំណែកជាមួយគ្នាផងដែរ។

# ប្រធានទី១៤

ប្រជាជនខ្មែរបានពោលថា៖ "ជីវិតដែលរស់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺជាជីវិតរស់នៅក្នុងនរកអវិចី"។ តើជីវិតនៅសម័យ នោះមានលក្ខណៈដូចម្តេច? ចូរពន្យល់ និងលើកឧទាហរណ៍មកបញ្ជាក់ផង។

## គម្រោងតែង

### I. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរទាក់ទងនិង ជីវិតខ្មែរនៅសម័យកម្ពុជាប្រជាធិបតេយ្យ ឬ ភាពលំបាកដែលខ្មែរបានជួបនៅសម័យនោះ។
- ចំណូលបញ្ហា៖ អាស្រ័យហេតុហើយបានមានទស្សនៈមួយពោលថា "ជីវិតដែលរស់នៅក្នុងសម័យ កម្ពុជាប្រជាធិបតេយ្យ គឺជាជីវិតរស់នៅក្នុងនរកអវិចី"
- ចំណោទបញ្ហា៖ តើជីវិតនៅសម័យ នោះមានលក្ខណៈដូចម្តេច?

### II. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាជំនួយដល់ការបកស្រាយ...
- ពន្យល់ពាក្យគន្លឹះ៖
  + របបកម្ពុជាប្រជាធិបតេយ្យ គឺជារបបមួយដែលចូលមកកាន់កាប់ប្រទេសកម្ពុជានៅ ថ្ងៃទី១៧មេសាឆ្នាំ១៩៧៥

ហើយបានសម្លាប់ប្រជាជនយ៉ាងព្រៃផ្សៃ ឫជារបបប៉ុលពត។

\+ នរកអវិចី ទីអបាយភូមិ ទីដែលមនុស្សស្លាប់ទាំងរស់ ទីគ្មានពន្លឺសេរីភាព គ្រប់យ៉ាង។

- ពន្យល់ន័យប្រធាន៖ ដូចនេះប្រធានខាងលើមានន័យថា ពលរដ្ឋខ្មែរដែលបានឆ្លងកាត់ របបប៉ុលពត គឺជារបបមួយដែលសម្លាប់ពលរដ្ឋខ្មែរយ៉ាងព្រៃផ្សៃ ហើយក៏ជារបបមួយដែលធ្វើទារុណកម្មខ្មែរឱ្យស្លាប់ទាំងរស់។
- បកស្រាយប្រធាន៖ ជាការពិតណាស់វាជាការឈឺចាប់មួយដែរខ្មែរគ្រប់រូបជួបប្រទះនៅដើមសតវត្សទី២០ វាជាទារុណកម្មដ៏ឈឺខ្លោចផ្សាមួយដែល បានបំផ្លាញនូវធនធានមនុស្ស រួមទាំងវិស័យសង្គមឱ្យវិនាសសាបសូន្យ៖

ក. ជីវិតភាពរស់នៅ នៅសម័យខ្មែរក្រហម ៖

- ធ្វើការងារគ្មានពេលសម្រាក ទំហំការងារ ធ្ងន់ធ្ងរ ដូចជា ធ្វើស្រែ ជីកប្រឡាយ កាប់គាស់គល់ឈើ លើកទំនប់ ។ ( មួយថ្ងៃធ្វើការ ១២ម៉ោង ឧ. ប្រុសស្រីប្រែភេទ ស្លាប់គ្មានដឹងហេតុ....។)
- ការរស់នៅបែកបាក់គ្នា ។ ឧ.កូនបែកម្តាយ ប្រពន្ធព្រាត់ប្តី
- ទទួលបានរបបអាហារមិនគ្រប់គ្រាន់ ។ ឧ. បបររាវក្លូកមានតែទឹក...

- ការសម្លាប់មិនរកមូលហេតុបានត្រឹមត្រូវ រួមទាំងទារុណកម្មសួរ ចម្លើយ យ៉ាងសាហាវព្រៃផ្សៃ ដូចជាឆក់ខ្សែភ្លើង ច្រមុជទឹក ដកក្រចក...

ខ . បំបិទសិទ្ធិសេរីភាព៖

- មនុស្សគ្មានសេរីភាពដើរហើរ និយាយស្តី ជួបជុំបញ្ចេញមតិ។ ឧ. ខ្មែរទាំងប្រុសស្រី អស់សិទ្ធិសេរី...។
- ការរស់នៅស្ថិតក្នុងភាពភ័យខ្លាច ។ឧ. ពួកអ្នកថ្មីត្រូវពួកអ្នកចាស់បំភ័យដូចជា "ទុកមិនចំណេញ ដកចេញមិនខាត"
- សិទ្ធិរស់រានជីវិត ។ ឧ. មានសម្លាប់ជីវិតមនុស្សដូចសត្វធាតុ
- បង្ខំឱ្យរៀបការជាមួយមនុស្សដែលខ្លួនមិនស្រលាញ់ ឧ. រឿងប្តីប្រពន្ធ ធ្ងន់អើយ សែនធ្ងន់ ក្រៀមក្រមឱរា ....។

គ . បំផ្លាញសង្គមជាតិ៖

- ធនធានមនុស្សត្រូវបានសម្លាប់
- ប្រពៃណីទំនៀមទម្លាប់ត្រូវបំផ្លាញ
- សាសនា និងវិស័យអប់រំវិនាសសាបសូន្យ ។ ឧ ផ្សឹកព្រះសង្ឃ ប្រែសាលារៀន កុដិ វិហារ ជាគុក ឬ ទ្រុងជ្រូក មាន់ ទា...
- ហេដ្ឋារចនាសម្ព័ន្ធត្រូវបំផ្លាញ...

- ជីវិតស្រែចំការពោលពេញដោយគ្រាប់បែក និងគ្រាប់មិនទាន់ផ្ទុះ...។

- សរុបមតិ៖ ដូចនេះជីវិតខ្មែរដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពិតជាជីវិតមួយដែលមានជីវភាពរស់នៅ យ៉ាងលំបាកដូចសម្លាប់ទាំងរស់ ថែមទាំងបំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាងទៀតផង។

## III. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ មានអត្ថន័យ និងខ្លឹមសារអប់រំ ឱ្យយើងស្គាល់ពីប្រវត្តិសាស្ត្រដ៏ខ្មៅងងឹត រួមទាំង ទារុណកម្ម ផ្លូវកាយចិត្តរួមទាំងបំផ្លាញ់សង្គមឱ្យវិនាសសាបសូន្យ។
- ទស្សនៈផ្ទាល់ខ្លួន៖ ដូចនេះក្នុងនាមខ្ញុំជាកុលបុត្រខ្មែរមួយរូបត្រូវខំធ្វើអំពើល្អ ចេះជួយអ្នកដទៃរួមទាំងខិតខំសិក្សារៀនសូត្រដើម្បីអភិវឌ្ឍប្រទេសឱ្យរីកចម្រើន និងមានសន្តិភាពប្រកបដោយភាពថ្លៃថ្នូរ។

## សេចក្តីអធិប្បាយ

កាលណាគេនឹកឃើញដល់ព្រឹត្តិការណ៍១៧ មេសា ឆ្នាំ១៩៧៥។ ដែលពួកខ្មែរក្រហមឡើងកាន់អំណាចហើយ បានជម្លៀសប្រជាជនទៅកាន់ទីជនបទ យ៉ាងព្រៃផ្សៃ រួមទាំងទារុណកម្ម នឹងការកាប់សម្លាប់ប្រជាជនគ្មានត្រាប្រណីនៅក្នុងរបបដ៏ព្រៃផ្សៃនេះ។ អាស្រ័យហេតុនេះហើយ បានជាមានមតិមួយបានពោលថា៖ ‶ជីវិតខ្មែរដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាជីវិតដែររស់នៅក្នុងនរករអរវិចី″។

តើនរកអវិចីនៅសម័យនោះមានលក្ខណៈដូចម្ដេច?

ដើម្បីជាប្រទីបដល់ការបកស្រាយប្រធានបទខាងលើឱ្យបានក្បោះក្បាយយើងគួរគប្បីយល់អត្ថន័យនៃពាក្យ "របបកម្ពុជាប្រជាធិបតេយ្យ" មានន័យថាគឺជារបបមួយដែលចូលមកកាន់កាប់ប្រទេសកម្ពុជានៅថ្ងៃទី១៧មេសាឆ្នាំ១៩៧៥ ហើយបានសម្លាប់ប្រជាជនយ៉ាងព្រៃផ្សៃ ឬជារបបប៉ុលពត។ ចំណែកឯពាក្យ"នរកអវិចី" វិញសំដៅ ទីអបាយភូមិ ទីដែលមនុស្សស្លាប់ទាំងរស់ទីគ្មានពន្លឺសេរីភាព គ្រប់បែបយ៉ាង។ ដូចនេះប្រធានខាងលើមានន័យថា ពលរដ្ឋខ្មែរដែលបានឆ្លងកាត់ របបប៉ុលពតគឺជារបបមួយដែលសម្លាប់ពលរដ្ឋខ្មែរយ៉ាងព្រៃផ្សៃ ហើយក៏ជារបបមួយដែលធ្វើទារុណកម្មខ្មែរគ្រប់បែបយ៉ាងឱ្យស្លាប់ទាំងរស់។

ជាការពិតណាស់ វាជាការឈឺចាប់មួយដែលខ្មែរគ្រប់រូបជួបប្រទះនៅដើមសតវត្សទី ២០។ វាជាទារុណកម្មយ៉ាងព្រៃផ្សៃ ដ៏សាហាវ ដ៏ឈឺចាប់ ខ្លោចផ្សា ដែលដក់ជាប់នៅក្នុងចិត្តពលរដ្ឋគ្រប់រូប ដោយវាបានបំផ្លាញជីវិតខ្មែររាប់លាននាក់ បំផ្លាញធនធានមនុស្ស បំបិទសិទ្ធិសេរីភាព រួមទាំងហេដ្ឋារចនាសម្ព័ន្ធសង្គមឱ្យវិនាសសាបសូន្យគ្មានសល់។ ក្រោយពីជម្លៀសប្រជាជនទៅកាន់ទីជនបទហើយ ពួកអង្គការប្រើពលរដ្ឋខ្មែរមិនថា ចាស់ ក្មេង ប្រុសស្រី ឱ្យធ្វើការងារដ៏ធ្ងន់ធរ ការងារដែលពួកខ្មែរក្រហម ចាប់ឱ្យប្រជាពលរដ្ឋនោះ គឺធ្វើស្រែចំការ ជីកប្រឡាយ កាប់គាស់គល់ឈើ លើកទំនប់ វាជាការងារមួយដ៏សែននឿយហត់ ដោយធ្វើការមួយថ្ងៃដប់ពីរម៉ោង ឬច្រើនជាងនេះ ដោយចាប់ពីម៉ោង ប្រាំមួយទៀបភ្លឺដល់ម៉ោងប្រាំមួយល្ងាច ហើយក្រោយពីបញ្ចប់ការងារប្រចាំថ្ងៃហើយ

ទោះបីជាពួកគាត់មានការនឿយហត់ អត់ងងុយ ទន់ប្រាណសឹងទប់មិនរួចយ៉ាងណាក្តី ក៏ពួកគាត់នៅតែអង្គុយបញ្ឈរក្បាលជង្គង់ម្ខាងជាវង់ដើម្បីធ្វើមិទ្ទិញជារៀងរាល់យប់។ ដូចនៅក្នុងឃ្លាមួយរបស់កំណាព្យមើលផែនដីខ្មែរ បានបញ្ជាក់ថា "ស្រណោះភ្លៀងធ្លាក់ បែកញើសសស្រាក់ គេរេមើលងាយ ទឹកញើសជន់ជោរ ដូចអូរប្រឡាយ ខំគាស់កកាយ ក្រោមការបញ្ជា"។ ក្រៅពីទារុណកម្មផ្លូវកាយហើយ ផ្លូវចិត្តក៏ត្រូវទទួលនូវការប៉ះទង្គិតយ៉ាងខ្លាំង ដោយការរស់នៅត្រូវនិរាសព្រាត់ប្រាស់មនុស្សជាទីស្រលាញ់ កូនត្រូវបែកពីម្តាយ ប្រពន្ធព្រាត់ប្តី សាច់ញាតិត្រូវគេសម្លាប់នៅនឹងមុខ ការរស់នៅទទួលរងនូវការភ័យខ្លាចដោយពួកអ្នកចាស់បានបំភ័យពួកអ្នកថ្មីថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត" ថែមទាំងប្រយោល ពិឃាដមួយចំនួនទេ" ដូចជាយកទៅសាលាកាលេស យកទៅកសាងឡើងវិញ" ពាក្យទាំងនេះសុទ្ធតែជាពាក្យមានន័យថា យកទៅសម្លាប់ចោល។ បន្ថែមពីទារុណកម្មខាងលើ របបអាហារដែលទទួលបានគឺត្រឹមតែ បបររាវកក្លូកដូចទឹកហូបមិនឆ្អែត ហើយដើម្បីកុំឱ្យដាច់ពោះស្លាប់ដោយការគ្មានអាហារបរិភាគគ្រប់គ្រាន់ ពួកអ្នកថ្មីបាន ចាប់ផ្តើមប្រជែងគ្នាដេញចាប់សត្វល្អូន ដូចជាពស់ បង្កួយ ចង្រិច កណ្តូប ក្អែប ខ្ទួយ ដែលប្រទះឃើញនៅពេលវេលាកាប់គាស់គល់ឈើ។ ដោយយកសត្វទាំងនោះមកដុត ឬ អាំងដើម្បីបរិភាគជាមួយនឹងបបរយ៉ាងតិចតួចស្តួចស្តើងដែលជាចំណែកក្នុងមួយថ្ងៃ ដែរមានតែពីរដងប៉ុណ្ណោះក្នុងមួយថ្ងៃ។ ដូចនៅក្នុងកំណាព្យមួយលើកឡើងថា "ស្រូវពេញជង្រុក មាន់ទាសត្វស្រុក កើតរាប់រយពាន់ ម្ហូបសាបជូរចត់ ដាក់មាត់សំរន់ ចាំឆ្អែតគ្រប់គ្រាន់ ថ្ងៃរះឆ្នាំ

ក្រោយ" ។ បើនិយាយពីជីវិតនៅសម័យនោះវិញគឺផុយស្រួយ ងាយបាត់បង់ ងាយស្លាប់ ដោយការសម្លាប់មិនបានសួររកមូលហេតុបានត្រឹមត្រូវ ដោយសារមនុស្សធម៌ត្រូវបានបាត់បង់។ ចំណែកឯទារុណកម្មដែលប្រើសម្រាប់សួរចម្លើយ ឬក៏ដាក់ទោសបុគ្គលណាម្នាក់មានដូចជា ការអុចភ្លើងបារី បង្ខំឱ្យស៊ីលាមក ឬ ផឹកទឹកនោម យកម្ជុលចាក់ចូលសាច់ និងព្យួរដៃឡើងលើពេញមួយថ្ងៃ ឬព្យួរជើងឡើងលើដាំក្បាលចុះក្រោម។ អ្នកទោសខ្លះទៀតត្រូវបានឆូតសាច់ និងកាំបិត ឬយកថង់ខ្ទប់ច្រមុះ។ វិធីសាស្ត្រមួយចំនួនទៀតដែលប្រើសម្រាប់ចម្រាញ់យកចម្លើយសារភាព រួមមានដកក្រចកដៃហើយចាក់អាកុល ពីលើ ឬជ្រមុជទឹក បើជាអ្នកទោសស្រីត្រូវបានធ្វើទារុណកម្មដោយកាត់ដោះ ឬបង្ខំឱ្យស្ត្រីនោះដោះ ខោអាវចេញ ហើយអ្នកទោសមួយចំនួនទៀតត្រូវអ្នកសួរចម្លើយចាប់រំលោភ។ ចំពោះសិទ្ធិសេរីភាពយើងឃើញថាត្រូវបានហាមឃាត់គ្រប់ បែបយ៉ាងតាំងពីសិទ្ធិបញ្ចេញមតិ សិទ្ធិទទួលបានព័ត៌មាន និងទំនាក់ទំនង ការនិយាយស្តី ការប្រជុំផ្សេងៗត្រូវបានអង្គការហាមឃាត់ និងដកហូតអស់នូវសិទ្ធិជាមូលដ្ឋានរបស់មនុស្សគ្រប់រូប ហើយប្រជាជនទាំងអស់មិនត្រូវបានអនុញ្ញាត ឱ្យដើរចេញក្រៅសហករណ៍របស់ខ្លួនទេ មិនឱ្យប្រមូលផ្តុំ និងពិភាក្សាគ្នាឡើយ។ បើសិនប្រមូលផ្តុំមនុស្សបីនាក់ហើយនិយាយគ្នាលេង អ្នកទាំងនោះអាចត្រូវចោទប្រកាន់ជាខ្មាំង ហើយអាចត្រូវសម្លាប់ចោល។ បើទោះបីឃើញមានការប្រជុំ (មិទ្ទិញ) នៅពេលបញ្ចប់ការងារក៏ដោយ ប៉ុន្តែវាគ្រាប់តែធ្វើបង្គប់កិច្ចប៉ុណ្ណោះ។ ហើយចំពោះការប្រជុំនោះប្រសិនមាននរណាម្នាក់ហ៊ានមានមតិ យោបល់ចំពោះការគ្រប់គ្រង ឬ

ការមិនពេញចិត្តណាមួយចំពោះការដឹកនាំរបស់អង្គការ ជននោះនឹងត្រូវអង្គការធ្វើទារុណកម្ម ឬសម្លាប់ចោល។ ដូចនៅក្នុងសៀវភៅភាសាខ្មែរថ្នាក់ទីដប់ មេរៀនទីប្រាំមួយ អំណានទីពីរមានចំណងជើងថា "ជីវិតខ្មែរក្នុងនរកអវិចី" បានលើកឡើងថា នៅពេលដែលពលរដ្ឋទាំងអស់បំពេញការងារចប់ ត្រូវចូលរួមអង្គប្រជុំជាមួយអង្គការ។ ការចាប់ផ្ដើមធ្វើមិទ្ទិញ ជាដំបូងប្រធានក្រុមតែងពោលថា សូមគោរពអង្គប្រជុំនិងសមមិត្តទាំងអស់ ដែលបានមកចូលរួមក្នុងអង្គប្រជុំ តើមានយោបល់អ្វី? ដូចជាការមិនពេញចិត្តនិងវិន័យអង្គការ ការមិនពេញចិត្តនិងការងារ ដែលធ្វើក្នុងមួយឆ្នាំមានដល់៣៦៥ ថ្ងៃ ការងារដែលប្រើកម្លាំងបាយនឿយហត់លើសកំរិត។ ទោះបីជាយើងរាល់គ្នាយល់ឃើញដូចពាក្យខាងលើក្ដី តែតាមធម្មតា ពុំដែលមានជនអ្នកថ្មីណាមួយរូបហ៊ានបញ្ចេញយោបល់ឡើយ។ ប៉ុន្តែពេលនោះមានយុវជនមួយដែលជាអ្នកថ្មីគាត់បានបញ្ចេញមតិចំពោះការគ្រប់គ្រង របស់អង្គការ ដែលប្រើប្រជាជនឱ្យធ្វើការយ៉ាងធ្ងន់ហើយទទួលរបបអាហារដ៏តិចតួចបំផុត។ នៅពេល នោះគេគ្រប់គ្នាភ្ញាក់ព្រមទាំងសែនបារម្ភ នឹងអាកប្បកិរិយារបស់គាត់ដែលអាចសន្និដ្ឋានបានយ៉ាងជាក់ថាគាត់អស់សមត្ថភាព ដើម្បីតស៊ូនឹងជីវិតទៅមុខទៀតហើយ។ ដូចដែលការបារម្ភមែន ព្រឹកឡើងថ្ងៃបន្ទាប់ប្រធានក្រុមបានចាប់មិត្តអ្នកថ្មីនោះ ចង់ផ្អោបទៅនឹងគល់ឈើ ដែលពោរពេញទៅ ដោយសំបុកស្រមោចភ្លើង។ ដោយត្រូវហ្វូងស្រមោចភ្លើងខាំ គ្មានត្រាប្រណី គាត់ពត់កាយរើបំរះ ដោយការឈឺពើតផ្សា ហើយបណ្ដោយឱ្យគាត់រាកនោមនៅនឹងកន្លែងតែម្ដង បន្ទាប់មកគេក៏យក គាត់ទៅស្លាប់ចោលទៅ។ រីឯទំនាក់

ទំនងក្នុងគ្រួសារ ប្តីប្រពន្ធ ទទួលរងនូវការរិះគន់យ៉ាងខ្លាំងក្លាដែរ។ ប្រជាជនគ្រប់រូប ត្រូវអង្គការហាមឃាត់មិនឱ្យ សម្តែងចេញនូវការស្រលាញ់ សេចក្តីសប្បាយរីករាយ ឬ សេចក្តីអាណិតអាសូរ សូម្បីតែ បន្តិចបន្តួចក៏ដោយ។ ដោយពួកខ្មែរក្រហមបានបង្គាប់បញ្ជាឱ្យប្រជាជនខ្មែរគ្រប់រូប ជឿធ្វើតាម និងគោរពអង្គការបដិវត្តន៍តែមួយគត់។ លើសពីនេះទៀត នោះអ្វីដែលប្រជាពលរដ្ឋខ្មែរគ្រប់មិន អាចបំភ្លេចបាននោះ គឺការសម្លាប់ប្រជាពលរដ្ឋស្លូតត្រង់យ៉ាងព្រៃផ្សៃ រួមទាំងទារុណកម្មយ៉ាងសាហាវឃោរឃៅ គ្មានធម៌មេត្តា ។រួមទាំងការរស់នៅដូចជាសត្វធាតុ ដូចជាការចាប់សត្វល្អិតស៊ីដូចជាអាប។ រួមទាំងការបង្ខំឱ្យរៀបការជាមួយមនុស្ស ដែលខ្លួនមិនស្រលាញ់ វាជាអារម្មណ៍មួយដ៏ឈឺចាប់ ហើយមិនអាចប្រកែកបាន ។ នៅត្រង់ឃ្លាមួយសរសេរថា "រឿងប្តីប្រពន្ធ ធ្ងន់អើយសែនធ្ងន់ ក្រៀមក្រមឱរា គេរៀបបង្ខំ ឱយផ្គុំគ្រួសារ គ្មានសួរចិន្តា ស្ម័គ្រឬមិនស្ម័គ្រ"។ ក្រៅពីទារុណកម្មដ៏ឈឺចាប់ ការបំផ្លាញ់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសង្គមឱ្យខ្ទីខ្ទេចស្ទើរតែអស់បានធ្វើឱ្យប្រទេសជួបនូវវិបត្តិ រួមទាំងជាបន្ទុកមួយសម្រាប់ពលរដ្ឋគ្រប់រូប ត្រូវកសាងឡើងវិញ។ ស្ពាន ប្រព័ន្ធគមនាគមន៍ វត្តអារាម សាលារៀន មន្ទីរពេទ្យ រោងចក្រ សហគ្រាស ត្រូវបានបិទទ្វារ ឬបំផ្លាញចោល។ ក្នុងនោះវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ក៏ត្រូវបំផ្លាញ់ចោលគ្មានសល់ ដូចជាពិធីរៀបមង្គលការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យខុសគ្នាទាំងស្រុងពីមង្គលការតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ។ កូនកម្លោះក្រមុំទាំងអស់ត្រូវបានរៀបចំក្នុងពិធីរួមតែមួយ ដែលមានចំនួនបីទៅដប់គូក្នុងពិធីតូច ហើយពិធីធំមានពីសាមសិបទៅ

ហាសិបគូ ឬរហូតដល់ទៅមួយរយគូក្នុងពិធីនីមួយៗ។ បុរសនារីភាគច្រើនមិនត្រូវអនុញ្ញាតឱ្យជ្រើសរើសគូស្រករបស់ខ្លួនទេ។ គូនីមួយៗត្រូវបានចាត់តាំងដោយ អង្គការ ដែលអះអាងថាជាឪពុកម្ដាយ របស់មនុស្សគ្រប់រូប។ អ្នកខ្លះមិនទាំងស្គាល់ឈ្មោះ និងមុខមាត់អនាគត គូស្រកររបស់ខ្លួនផងទេ រហូតដល់ពេលប្រារព្ធពិធីតែម្ដង។ សូមបីតែបងប្អូនសាច់ញាតិមិនអនុញ្ញាត ឱ្យចូលរួមក្នុងពិធីមង្គលការ ឬចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្តណាមួយឡើយ។ សម្លៀកបំពាក់ប្រពៃណី ពិធីរាំរែក ចម្រៀងប្រពៃណី និងពិធីតាមបែបសាសនាត្រូវបានហាមឃាត់។ រីឯសាសនាវិញក៏ត្រូវសាបសូន្យ ដោយយើងឃើញថាក្រោយពីពួកខ្មែរក្រហមកាន់អំណាច បានចាប់ព្រះសង្ឃផ្សឹកទាំងអស់ដើម្បីទៅធ្វើស្រែចំការ ហើយបានប្រែក្លាយព្រះវិហារ កុដិ សាលាឆាន់ ឱ្យទៅជា គុក ទ្រុងសត្វចិញ្ចឹម ឃ្លាំងស្រូវ ឃ្លាំងផ្ទុកអាវុធ ជង្រុកជាដើម។ លើសពីនេះទៅទៀតនោះគ្រឹះស្ថានអប់រំរដ្ឋ និងឯកជនត្រូវបានបិទទ្វារ ដោយមិនឱ្យមានការសិក្សារៀនសូត្រអ្វីទាំងអស់ ហើយក៏បានចាប់ បញ្ញាវន្ត សិស្ស និស្សិត លោកគ្រូ អ្នកគ្រូ និងអ្នកចេះដឹងមួយចំនួនទៀត ត្រូវបានពួកខ្មែរក្រហមសម្លាប់ចោលទាំងអស់។ បើនិយាយពីវិស័យសុខាភិបាលវិញគ្មានសកម្មភាពអ្វីទាំងអស់ នៅពេលប្រជាជនមានជំងឺគឺទុកឱ្យរស់ឬ ស្លាប់តាមកម្ម។ ហើយក្រោយពីរបបដ៏ខ្មៅងងឹតនេះដួលរលំទៅបានបន្សល់ទុកនូវ កុមារកំព្រា ចាស់ជរា និងផលប៉ះពាល់ផ្លូវចិត្ត អ្នកដែលរស់រានមានជីវិត ហើយក៏បានប្រែក្លាយដីដ៏មានជីវជាតិឱ្យទៅ ជាស្រែមីន និងចំការគ្រាប់មិនទាន់ផ្ទុះ។ អ្វីទាំងអស់ដែរពួកខ្មែរក្រហមធ្វើមកលើប្រជាជនស្លូតត្រង់នេះ វាជា

ការឈឺចាប់ ជាជីវិតរស់នៅក្នុងស្រមោលអតីតកាល ដ៏ជូរ ចត់ ព្រៃផ្សៃ ហើយប្រៀបដូចជីវិតដូចធ្លាក់នរក ទាំងរស់។ សរុបមតិមកយើងឃើញថា ជីវិតខ្មែរដែររស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពិតជាជីវិតមួយដែល មានជីវភាពរស់នៅយ៉ាងលំបាកគ្រប់បែបយ៉ាងដូចសម្លាប់ទាំងរស់ ថែម ទាំងបំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាងទៀតផង។

ឆ្លងតាមការបកស្រាយខាងលើមកយើងអាចវាយតម្លៃប្រធាន ខាងលើកបានថាប្រធានខាងមានអត្ថន័យ និងខ្លឹមសារអប់រំ ឱ្យយើង ស្គាល់ពីប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរួមទាំង ទារុណកម្មដ៏សែនព្រៃផ្សៃ ហើយ បានបំផ្លាញ់សង្គមឱ្យវិនាសសាបសូន្យ ស្ទើរគ្រប់វិស័យ។ ដូចនេះក្នុងនាម ខ្ញុំជាកុលបុត្រខ្មែរមួយរូបត្រូវខំធ្វើអំពើល្អ ចេះជួយអ្នកដទៃនិងទប់ស្កាត់ របបមួយនេះមិនឱ្យកើតឡើងម្តងទៀត រួមទាំងខិតខំសិក្សារៀនសូត្រ ដើម្បីអភិវឌ្ឍប្រទេសឱ្យរីកចម្រើន និងមានសន្តិភាព ប្រកបដោយភាពថ្លៃ ថ្នូរ។

# ប្រធានទី១៥

អ្នកខ្លះបានថ្កោលទោសថា៖ «នាងទាវបានប្រព្រឹត្តបាបកម្មខ្លាំងណាស់ ព្រោះនាងបានធ្វើឱ្យសាមណោរទុំប្រាសចាកពីភាពជាបុព្វជិត»។ តែអ្នកខ្លះបាននិយាយថា៖ «កំហុសនេះមិនត្រូវឱ្យធ្លាក់ទៅលើនាងទាវទេ គឺសាមណោរទុំទេតើដែលដោះស្បង់ចីវរខ្លួនឯង»។ ចូរអ្នកពិភាក្សានូវមតិខាងលើនេះ។

## គម្រោងតែង

### I សេចក្តីផ្តើម

- លំនាំបញ្ហា ៖ តាមដំណើរសាច់រឿងទុំទាវយើងឃើញថា ក្រោយពីសាមណោរទុំបានវិលត្រឡប់ពីដំណើរលក់តោកឯភូមិពោធិជើងខាលមកដល់វត្តវិញ ហើយបានកើតក្តីអន្ទះអន្ទែងក្នុងចិត្តកាន់តែខ្លាំងឡើងៗ រហូតដល់ទ្រាំរស់នៅក្នុងភេទជាបព្វជិតទៅទៀតមិនបាន ក៏លួចដោះស្បង់ចីវរចោលទៅ។
- ចំណូលបញ្ហា៖ ហេតុនេះហើយទើបមានអ្នកខ្លះបានថ្កោលទោសថា៖ «នាងទាវបានប្រព្រឹត្តបាបកម្មខ្លាំងណាស់ ព្រោះនាងបានធ្វើឱ្យសាមណោរទុំប្រាសចាកពីភាពជាបុព្វជិត»។ តែអ្នកខ្លះបាននិយាយថា៖ «កំហុសនេះមិនត្រូវឱ្យធ្លាក់ទៅលើនាងទាវទេ គឺសាមណោរទុំទេតើដែលដោះស្បង់ចីវរខ្លួនឯង»។
- ចំណោទបញ្ហា៖ តើមតិទាំងពីរខាងលើនេះមួយណាត្រឹមត្រូវជាង?

## II តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី៖ ដើម្បីឈានទៅដល់ការពិភាក្សាប្រធានខាងលើឱ្យកាន់តែច្បាស់ លាស់ យើងគប្បីយល់ន័យនៃពាក្យគន្លឹះជាមុនសិន។
- ពន្យល់ពាក្យ៖

+បាបកម្ម មានន័យថាអំពើអកុសល អំពើអាក្រក់។

+សាមណេរ គឺលោកនេន អ្នកស្ងប់បន្ទាប់ពីភិក្ខុមក ។

+បុព្វជិត ជាអ្នកបួស។

- ពន្យល់ន័យប្រធាន៖ នាងទាវបានប្រព្រឹត្តអំពើអកុសលខ្លាំងណាស់ព្រោះនាងបានធ្វើឱ្យនេនទុំប្រាសចាកអំពីភេទជាអ្នកបួស។ រីឯមតិទីពីរ កំហុសនេះមិនអាចធ្លាក់លើនាងទាវម្នាក់ឯងទេ នេនទុំទេតើដែលដោះស្បង់ចីវរដោយខ្លួនឯងនោះ។
- បកស្រាយប្រធាន៖

❖ មតិទីមួយ “នាងទាវបានប្រព្រឹត្តបាបកម្មខ្លាំងណាស់ ព្រោះនាងបានធ្វើឱ្យសាមណេរទុំប្រាសចាកពីភាពជាបុព្វជិត”

❖ គំនិតសំខាន់

- ស្រឡាញ់ទាំងមិនទាន់ឃើញលោក អារម្មណ៍រវើរវាយ
- ការប្រើភ្នែកគនគន់ សម្លឹងមើលលោកសង្ឃទាំងខ្លួននៅក្រមុំ ឥរិយាបថទាវ
- ការប្រគេនផាហ៊ុម ផ្សងចួបលោករបស់ឱបដៃ
- សម្ដែងអារម្មណ៍ឱ្យទុំដឹងថាខ្លួនពេញចិត្ត

– ជាស្ត្រីក្នុងម្លប់តែអារម្មណ៍គិតដល់ទុំ(គិតពីប្រុស) សុំម្ដាយអញ្ជើញលោកមកសូត្រធម៌

❖ ឧទាហរណ៍

+ពិតមែនហើយបើតាមដំណើរសាច់រឿង នាងទាវជាដើមហេតុដែលធ្វើឱ្យនេនទុំដោះស្បង់ចីវរ។ ដោយគ្រាន់តែឮនាងនៅជាតិល្បៀងរៀបរាប់ពីសម្រស់ និងគុណសម្បត្តិរបស់នេនទុំក៏មានចិត្តស្រឡាញ់ភ្លាម...

+នាងទាវគ្រាន់តែឃើញនេនទុំ ក៏មកគយគន់ពីរូបនេនទុំមិនកោតក្រែង នាងចង់ចេញមកក្រៅណាស់ដូចកំណាព្យបាន បរិយាយថា«អើតអើមដកក...»

+នាងទាវរៀបចំគ្រឿងបរិក្ខារមានបារីស្លាម្លូ និងផាហ៊ុមប្រគេននេនទុំ។ ហើយនាងទាវបានលើកដៃផ្សងចង់ជួបនេនទុំនៅជាតិនេះជាតិមុខ...

- សរុបមតិ៖ ទុំដោះស្បង់ចីវរ គឺដោយសារតែនាងទាវបានប្រព្រឹត្តអំពើអកុសលមែន ដែលបង្ហាញបើកទ្វូងបញ្ចេញមនោសញ្ចេតនាស្នេហាចំពោះនេនទុំ

តើកំហុសគ្រប់យ៉ាងបណ្ដាលមកពីនាងទាវពិតមែនទេ?

❖ មតិទីពីរ “កំហុសនេះមិនត្រូវឱ្យធ្លាក់ទៅលើនាងទាវទេគឺសាមណេរទុំទេតើ ដែលដោះស្បង់ចីវរខ្លួនឯង”

❖ គំនិតសំខាន់

+ផ្ទុយទៅវិញបើយោងតាមមតិទីពីរ កំហុសនេះមិនត្រូវធ្លាក់ទៅលើនាងទាវទេ គឺនេនទុំទេតើដែលដោះស្បង់ចីវរដោយខ្លួនឯង។

– ជាសង្ឃតែមានឥរិយាបថមិនគប្បី
– ជាព្រះសង្ឃត្រូវគោរពវិន័យឱ្យបានល្អិតល្អន់
– ដល់ផ្ទះអ្នកស្រុកមិនត្រូវក្រឡេកមើលផ្ដេសផ្ដាស តែទុំមៀងមើលទាវ
– ជាលោកសង្ឃតែប្រើមន្តអាគម(ដាក់ស្នេហ៍)
– ទុំជាលោកសង្ឃតែចេះកុងហាក...

❖ ឧទាហរណ៍

+នេនទុំជាអ្នកបួសត្រូវមានក្រឹត្យវិន័យរឹងប៉ឹងជាងនាងដែលជាគ្រហស្ថតែទុំវិញមិនបានតាំងចិត្តខ្លួនឯងជា...

+គ្រាន់តែនេនទុំក្រឡេកឃើញនាងទាវ ក៏គយគន់ពីសម្រស់នាងទាវតាំងពីមាត់ដល់សាច់ដល់រាងរៅដូចកំណាព្យមួយឃ្លាថា«...ក្នុងពោះ...ឱរូបហ្នឹងហើយទាវពុំងារ...»

+នេនទុំប្រើមន្តអាគមគាថាសារិកាលិនថោងដាក់នាងទាវ អាងខ្លួនចេះសូត្រសារិកា...ក៏តាំងសូត្រដូចកមណាព្យ»...»

+នេនទុំមុខក្រៀមក្រំ ចេះភូតភរគ្រូ ភូតភរម្ដាយថាឈឺបួសមិនកើត...

+នេនទុំលួចសឹកដោះស្បង់ចីវរនៅមុខដំបូកដោយខ្លួនឯង...

-សរុបមតិ៖សរុបមកបើតាមការបកស្រាយមតិទីពីរខាងលើ យើងឃើញថានេនទុំពិតជាបានដោះស្បង់ចីវរដោយខ្លួនឯងពិតប្រាកដមែន។

❖ សំយោគមតិ៖ សរុបមកតាមការបកស្រាយខាងលើមានមតិពីរខ្វែងគំនិតគ្នាហើយមានមានអំណះអំណាងរៀងៗខ្លួន។ មតិទីមួយគេថា«នាងទាវបានប្រព្រឹត្តបាបកម្មខ្លាំងណាស់ ព្រោះនាងបានធ្វើឱ្យសាមណេរទុំប្រាសចាកពីភាពជាបុព្វជិត» ដោយសារសកម្មភាពមិនសមរម្យមួយចំនួនរបស់ទាវបានធ្វើឱ្យទុំសឹក។ រីឯមតិទីពីរ«កំហុសនេះមិនត្រូវឱ្យធ្លាក់ទៅលើនាងទាវទេ គឺសាមណេរទុំទេតើដែលដោះស្បង់ចីវរខ្លួនឯង» ដែលទុំខ្លួនឯងបានប្រព្រឹត្តខុសប្រាសចាកវិន័យសង្ឃ...។

ប៉ុន្តែបើពិនិត្យឱ្យបានដិតដល់ គឺមតិទីពីរមានលក្ខណៈទទួលខុសត្រូវធំជាងមតិទីមួយ ដោយសារមតិទីមួយកំហុសស្រាលជាងមតិទីពីរដែលជាអ្នកបួស។ ម្យ៉ាងជាលោកសង្ឃ ជាគំរូសាសនាក៏ដូចជាគំរូខាងផ្លូវសីលធម៌ស្គាល់បុណ្យបាបជាងគ្រហស្ថ ប្រសិនបើការប្រកាន់វិន័យមិនបានល្អ មានការធ្វេសប្រហែសនោះនឹងនាំកំហុសដល់ធ្ងន់មួយ...។

## III សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថាមតិទីពីរត្រឹមត្រូវជាង។ ប្រធានពិតជាមានអត្ថន័យជ្រាលជ្រៅណាស់។

- ទស្សនៈផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកចេះដឹងជ្រៅជ្រះ ត្រូវតែចេះទទួលខុសត្រូវរាល់ទង្វើដែលខ្លួនបានប្រព្រឹត្ត

## សេចក្ដីអត្ថាធិប្បាយ

តាមដំណើរសាច់រឿងទុំទាវយើងឃើញថា ក្រោយពីសាមណេរទុំបានវិលត្រឡប់ពីដំណើរលក់តោកឯភូមិពោធិជើងខាលមកដល់វត្តវិញ ហើយបានកើតក្ដីអន្ទះអន្ទែងក្នុងចិត្តកាន់តែខ្លាំងឡើងៗរហូតដល់ទ្រាំរស់នៅក្នុងភេទជាបព្វជិតទៅទៀតមិនបាន ក៏លួចដោះស្បង់ចីវរចោលទៅ។ ហេតុនេះហើយទើបមានអ្នកខ្លះបានថ្កោលទោសថា៖ "នាងទាវបានប្រព្រឹត្តបាបកម្មខ្លាំងណាស់ ព្រោះនាងបានធ្វើឱ្យសាមណេរទុំប្រាសចាកពីភាពជាបព្វជិត"។ ហើយទន្ទឹមនឹងនេះក៏មានអ្នកខ្លះបាននិយាយថា៖ "កំហុសនេះមិនត្រូវឱ្យធ្លាក់ទៅលើនាងទាវទេ គឺសាមណេរទុំទេតើដែលដោះស្បង់ចីវរខ្លួនឯង"។

តើមតិទាំងពីរខាងលើនេះមួយណាត្រឹមត្រូវជាង?

ដើម្បីឈានទៅដល់ការពិភាក្សាប្រធានខាងលើឱ្យកាន់តែច្បាស់លាស់ យើងគប្បីយល់ន័យនៃពាក្យគន្លឹះជាមុនសិន។ បាបកម្ម មានន័យថាអំពើអកុសល អំពើអាក្រក់។ សាមណេរ គឺលោកនេន អ្នកស្ងប់បន្ទាប់ពីភិក្ខុមក។ បព្វជិត ជាអ្នកបួស។ ដូចនេះប្រធានបទខាងលើចង់និយាយថានាងទាវបានប្រព្រឹត្តអំពើអកុសលខ្លាំងណាស់ ព្រោះនាងបានធ្វើឱ្យនេនទុំប្រាសចាកអំពីភេទជាអ្នកបួស។ រីឯមតិទីពីរ កំហុសនេះមិនអាចធ្លាក់លើនាងទាវម្នាក់ឯងទេ នេនទុំទេតើដែលដោះស្បង់ចីវរដោយខ្លួនឯងនោះ។

ពិតមែនហើយបើតាមដំណើរខ្លឹមសារនៃសាច់រឿង នាងទាវចាប់តាំងពីបានព្នាងនោជាភិល្បេងនិយាយរៀបរាប់រ៉ាយរ៉ាប់ពីនេនទុំថា "ទាវអើយទាវស្រីសេចក្តីនេះ លោកនេនេនោះចេះមើលសាស្ត្រា សំលេងស្រួចស្រាប់ស្តាប់ភាសា ដូចសត្វសារិកាពិសារចេក នាងបានព្រឺព្រួចក្បួចចាប់ចិត្ត ចង់ស្នេហ៍ស្និទ្ធរួមមេត្រីជាមួយនេនទុំ។ នាងទាវទ្រាំនៅតទៅទៀតពុំបាន ក៏ទទូចអង្វរម្តាយនាងឱ្យនិមន្តលោកទុំមកដូចដែលអ្នកនិពន្ធបញ្ជាក់ថា "ទាវទៅនៅយូរគួរពិភាល់ មិនយល់គេប្រាប់ជាក់ហើយត្រង់ណោះកុំឆ្ងល់បានដឹងពេក បំណាងចង់ស្តាប់ហ៊ានប្រាប់ម្តាយ"។ ក្រោយមកម្តាយទាវបាននិមន្តលោកនេនមកផ្ទះមែន។ រួចគ្រាន់តែក្រឡេកឃើញនេនទុំភ្លាមក៏លបគយគន់រូបនេនទុំមិនកោតក្រែង ព្រឺព្រួចស្អប់ស្អែងក្នុងកាយាថែមទៀត នាងទាវក៏បានទាំងអើតមុខមកនៅមាត់ទ្វារឱ្យនេនទុំគយគន់ឃើញរូបនាងទៀត។ ដូចដែលអ្នកនិពន្ធបញ្ជាក់ថា "អើតអឺមងកកច្រហមាត់ ចង់ចេញប្រាដកគ្មានគេហៅ ស្ទុះស្ទើតម្នាក់ឯងដោយក្មេងស្ទាវ ស្ទុះចូលយកអាវមកពានា" ដោយឥតលាក់លៀមទៀតផង។ មិនតែប៉ុណ្ណោះដាងនេះទៅទៀត គឺនាងទាវទ្រាំពុំបានក៏រៀបចំ ក្រមួនមាត់មានបារីស្លា កន្សែងគ្រីបប៉ាក់ដាក់បង្ការ មានសព្វបរិក្ខារគ្មានខ្វះមុខ។ នាងទាវថែមទាំងដោះផាហ៊ុមចេញពីស្មាហើយលើកដៃផ្សងសច្ចាប្រាថ្នាទុកថា ខ្លួនស្រីជាតិនោះទៅជាតិមុខសូមបានរួមសុខទុក្ខកុំឱ្យឃ្លាតឡើយ។ ពាក្យសម្តីទាំងអស់នេះព្រមទាំងអាកប្បកិរិយារបស់នាងទាវ ហើយនឹងព្រមទាំងន័យនៃបណ្ណាការទាំងឡាយដែលនាងបានដាក់ប្រគេននេនទុំនោះបញ្ជាក់ឱ្យឃើញថា របស់ទាំងនោះជាភស្តុតាងបង្ហាញយ៉ាងច្បាស់

នៃទំហំនៃសេចក្ដីស្នេហា ដែលកំពុងតែឆេះឆាបបេះដូងនាងចំពោះនេន ទុំ។ ចំពោះនេនទុំវិញបើទុកជាមានសេចក្ដីស្នេហាពុះពារចំពោះនាងទាវ យ៉ាងណាក្ដី នេនក៏មិនហ៊ានគេចទៅសឹក ដោយឆក់កណ្ដៀតដូចនេះដែរ ប្រសិនបើនេនមិនបានយល់ពីចិត្តទោរទន់របស់នាងទាវ ដែលបានបើក ទ្រូងបង្ហាញសញ្ចេតនារបស់នាងដែលស្មោះស្ម័គ្រហើយសុខចិត្តពឹងផ្អែក លើនេននោះដែរ។ ប្រសិនបើសាមណេរទុំពុំមានសង្ឃឹមក្នុងជោគជ័យនៃ សេចក្ដីស្នេហាលោកនោះទេ លោកក៏មិនហ៊ានសឹកដែរ។ ប៉ុន្តែទុំហ៊ាន សឹកដោយសាររំលោភវិន័យមកពីលោកមានការធានារ៉ាប់រងយ៉ាង ច្បាស់ ថានឹងបានសម្រេចជោកជ័យក្នុងចំណុចស្នេហានោះវិញយ៉ាងពិត ប្រាកដ។

សរុបសេចក្ដីមក ទុំដោះស្បង់ចីវរគឺដោយសារតែនាងទាវបាន ប្រព្រឹត្តនូវទង្វើ និងអាកប្បកិរិយាខុសដែលបង្ហាញបើកទ្រូងបញ្ចេញ មនោសញ្ចេតនាស្នេហាចំពោះនេនទុំយ៉ាងពិតប្រាកដមែន។

តើនាងនាងទាវមានកំហុសទាំងស្រុងឬ?

ផ្ទុយទៅវិញបើយោងតាមមតិទីពីរយើងឃើញថា កំហុសនេះមិន ត្រូវឱ្យធ្លាក់តែលើ នាងទាវទេ គឺនេនទុំទេតើដោះស្បង់ចីវរដោយខ្លួនឯង។ ដូចនេះតើនាងទាវជាអ្នកទទួលកំហុសតែម្នាក់ឯងឬ? បើយល់ឃើញ បែបនេះ គឺប្រាសចាកពីវិចារណញ្ញាណឆ្ងាយណាស់ ព្រោះថានាង អាស្រ័យសភាពក្រមុំចូលម្លប់របស់នាងក្ដី នាងបានបង្កហេតុប៉ុណ្ណឹង ហើយក៏ដោយក៏អ្នកចាំមើលពុទ្ធវិន័យដែលប្រកបដោយគតិបណ្ឌិត រឹងប៉ឹងមែនទែន មិនអាចនឹងលុះទៅតាមការស្រើបស្រាល ហើយដួល

តាំងជំហរដូចនេនទុំនោះបានឡើយ។ នេះជាកត្តាមួយពន្យល់ឱ្យឃើញថា នេនទុំក៏បានចូលរួមក្នុងការទទួលខុសត្រូវនេះដែរ អាស្រ័យលើការឆាបឆេះផុសផុលរបស់នេនទុំនេះដែរ។ ដូចការដែលយើងបានដឹងបានឮស្រាប់ហើយថាស្ថិតនៅក្នុងភាពជាសង្ឃនេនទុំក៏ដូចជានាងទាវដែរ ក្រោយពីបានទទួលការនិមន្តរបស់ម្ដាយទាវឱ្យទៅស្មូតនៅផ្ទះខ្លួននេនទុំយល់ព្រមភ្លាម។ ពេលនោះហើយដែលនាំឱ្យនេនទុំបានយល់រូបនាងទាវ។ សេចក្ដីស្នេហាបានដុតរោលដល់រូបរាងកាយនេនភ្លាមមួយរំពេច។ គ្រាន់តែទុំក្រឡេកឃើញរូបនាងទាវភ្លាមទុំនឹកក្នុងចិត្តថា នេះពេញល្អពិតឥមានស្រីណាផ្ទឹមបាន។ ដូចពាក្យអ្នកនិពន្ធបង្ហាញថា "នេនយល់ដូចនោះក្នុងពោះព្រួច កាន់ក្ដួចកើតទុក្ខចុកឱរ៉ា ឱរូបហ្នឹងហើយទាវពុំងា មិនងាកបំពាបំពេនរ"។ ចំពោះការស្មូតវិញទុំក៏ខិតខំជ្រើសរើសអន្លើមួយពោរពេញដោយភាពកម្សត់ឥតឧបមា ហើយចលនារឿងដែលកម្សត់ស្រាប់ទៅហើយនោះផ្សំនឹងការប្រៀបធៀបដូចជា ខ្លួននៃនេនទុំមកដល់ត្បូងឃ្មុំដែនដីអាយផ្សំនឹងសំឡេងពីរោះរបស់នេនទុំទៀតនោះ បានធ្វើឱ្យចិត្តរបស់ទាវអណ្ដែតអណ្ដូងឡើងក្នុងបរិយាកាសមួយដ៏ស្រងេះស្រងោចអាណិតអាសូរចំពោះនាងទាវដែលបានឮ ហើយក៏កើតមានសេចក្ដីស្នេហាចំពោះអ្នកស្មូត ដែលបានជ្រួតជ្រាបខ្លាំងជាងគេ។ ម្យ៉ាងទៀតនៅពេលសម្រាកឆាន់ស្លា ទុំក៏បានចោលកន្ទុយភ្នែកគយគន់នាងទាវសព្វគ្រប់តាំងពីមាត់ដល់សាច់ដល់រាងរៅ ហើយក៏តាំងសែកមន្តអាគមគាថាសារិកាលិនថោងដាក់នាងថែមទៀត។ ដូចជាក្នុងវគ្គមួយបានពោលថា "កន្ទុយភ្នាសោតដេញរកភ្នា ចោលឬចោលពាឱ្យដឹងដាន" ដែលសុទ្ធសឹង

ជាសក្ខីភាពបញ្ជាក់នូវការស្រើប ស្រាលរបស់នេនទុំទាំងអស់។ មិនតែប៉ុណ្ណោះនេនទុំក្រោយពីបានត្រឡប់មកពីលក់តោកឯភូមិជើងខាលមកដល់វត្តវិញ ទុំកើតទុក្ខមុខក្រៀមក្រំស្រងូតស្រងាត់ខុសធម្មតា ហើយក៏កើតមានគំនិតភូតភរគ្រូ ភូតភរម្ដាយថាឈឺបួសពុំបាន ហើយគ្រូមិនឱ្យសឹកក៏រត់ទៅលួចដោះស្បង់ចីវរនៅមុខដំបូកដោយខ្លួនឯង។ ដូចនេះបើតាមការបកស្រាយខាងលើយើងឃើញថានេនទុំពិតជាបានដោះស្បង់ចីវរដោយខ្លួនឯងពិតប្រាកដមែន។ មិនមែនជាកំហុសរបស់នាងទាវតែម្នាក់ឯងនោះទេ។

សរុបរួមមកតាមការបកស្រាយខាងលើ បង្ហាញឱ្យឃើញថាមតិទាំងពីរមាន លក្ខណៈត្រឹមត្រូវដូចគ្នា។ ប៉ុន្តែបើយើងពិនិត្យហើយនឹងពិចារណាឱ្យបានដិតដល់ យើងនឹងសង្កេតឃើញថា នាងទាវជាអ្នកបង្កបង្កើតសេចក្ដីស្នេហានេះ ដែលជាហេតុនៃការដោះស្បង់មែនហើយ។ ប៉ុន្តែដោយឋិតនៅក្នុងភាពជាគ្រហស្ថដែលគ្មានវិន័យអ្វីតឹងរឹងដូចនេនទុំជាសង្ឃឡើយ។ នេនទុំជាសង្ឃជាអ្នកប្រតិបត្តិក្រិតវិន័យស្គាល់បុណ្យស្គាល់បាប ស្គាល់រាក់ស្គាល់ជ្រៅនោះជាអ្នកខុសដោយខ្លួនឯង។ កំហុសរបស់នាងទាវក៏ស្រាលជាងកំហុសរបស់នេនទុំ ដែលជាអ្នកទទួលខុសត្រូវមួយភាគធំជាងនាងទាវដែរ។

ឆ្លងតាមការបកស្រាយខាងលើ ឃើញថាមតិទីពីរត្រឹមត្រូវជាង។ មតិប្រធានខាងលើពិតជាមានតម្លៃយ៉ាងជ្រលជ្រៅណាស់ចំពោះមនុស្សជាពិសេសព្រះសង្ឃក្នុងការគោរពវិន័យ។ យើងអាចសន្និដ្ឋានបានថាការដោះស្បង់ចីវររបស់នេនទុំពិតជាបង្ហាញឱ្យឃើញ ថានាងទាវក្តីនេនទុំក្តី

សុទ្ធតែមានកំហុសដូចគ្នាគ្រាន់តែថា កំហុសរបស់នាងទាវមានមែនក៏ស្រាលជាងកំហុសរបស់នេនទុំដែរ ព្រោះនេនទុំជាព្រះសង្ឃដែលមានវិន័យត្រឹមត្រូវ។ ដូចនេះក្នុងនាមយើងជាអ្នកចេះដឹងជ្រៅជ្រះត្រូវតែចេះទទួលខុសត្រូវរាល់ទង្វើដែលខ្លួនបានប្រព្រឹត្តកន្លងមក៕

## ប្រធានទី១៦

មានទស្សនៈលើកឡើងថា៖ «ប្រជាពលរដ្ឋខ្មែរទាំងប្រុសស្រី មានមោទនភាពជាតិណាស់ ដែលបានកើតជាកូនខ្មែរ»។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងសង្គម និងអក្សរសិល្ប៍មកបញ្ជាក់។

### គម្រោងតែង

**I. សេចក្តីផ្តើម**

- លំនាំបញ្ហា៖ មនុស្សរស់នៅលើផែនដីនេះ តែងតែមានទឹកចិត្តស្រឡាញ់ ពេញចិត្ត កោតសរសើរចំពោះអ្វីៗដែលយើងមាន មិនថាជាមនុស្ស ទឹកដី ប្រាសាទបុរាណ លើកតម្កើងជាតិសាសន៍ ប្រទេសជាតិ របស់មនុស្សទូទៅ។
- ចំណូលបញ្ហា៖ ស្របតាមន័យនេះ ទើបមានទស្សនៈលើកឡើងថា៖ «ប្រជាពលរដ្ឋខ្មែរទាំងប្រុសស្រី មានមោទនភាពជាតិណាស់ ដែលបានកើតជាកូនខ្មែរ»។
- ចំណោទបញ្ហា៖ តើទស្សនៈដែលបានលើកឡើងខាងលើនេះមានអត្ថន័យដូចម្តេច?

**II. តួសេចក្តី**

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាជំនួយក្នុងការ បកស្រាយ......។
- ពន្យល់ពាក្យគន្លឹះ
  - ប្រជាពលរដ្ឋខ្មែរ៖ ប្រជាជនដែលកើត មានសញ្ជាតិខ្មែរ រស់នៅទឹកដីក្នុងប្រទេសកម្ពុជា។

- មោទនភាពជាតិ៖ ដែលបង្ហាញពីការស្រឡាញ់ ពេញចិត្ត សេចក្តីស្រឡាញ់ កោតសរសើរ ការលើកតម្កើង ប្រវត្តិ កំណើតជាតិសាសន៍ ការឱ្យតម្លៃខ្ពស់ចំពោះជាតិរបស់ខ្លួន។
- កូនខ្មែរ៖ មនុស្សកើតលើទឹកដី សុវណ្ណភូមិ ជាពិសេស ប្រទេសកម្ពុជាយើង។

- ពន្យល់ន័យប្រធាន៖ តាមការលាតត្រដាងបង្ហាញខាងលើ យើងឃើញថាកុលបុត្រ កុលធីតាខ្មែរមានភាពសប្បាយ រីករាយ រំភើបដែលបានកើតលើទឹកដី ដ៏សម្បូរបែប ទាំង ធនធានសម្បត្តិធម្មជាតិ ធនធានសម្បត្តិវប្បធម៌ ទីតាំង ភូមិសាស្ត្រ និងជីវភាពរស់នៅ ជាដើម។
- បកស្រាយប្រធាន៖ ប្រជាពលរដ្ឋខ្មែរទាំងប្រុសស្រី មាន មោទនភាពជាតិ ដែលបានកើតជាកូនខ្មែរព្រោះប្រទេសខ្មែរ មានទឹកដី មានធម្មជាតិ ប្រពៃណី វប្បធម៌ អក្សរសាស្ត្រ អក្សរ សិល្ប៍ និងប្រវត្តិសាស្ត្ររបស់ខ្លួនពិតប្រាកដ ដែលមានដូច តទៅ៖

1. សម្បត្តិធម្មជាតិ ប្រទេសកម្ពុជាយើងមានទឹកដី មានជី ជាតិ ផ្តល់អំណោយផលដល់ដំណាំគ្រប់ប្រភេទ ពិសេស ព្រៃឈើ ទឹកទន្លេ ដី...។

ឧ. រឿងទុំទាវ បានរៀបរាប់ព្រៃព្រឹក្សា ពេល... ។

- លើកឡើងក្នុងសង្គម ធម្មជាតិ តំបន់ ...។

2. សម្បត្តិវប្បធម៌ មានការអប់រំ សិល្បៈ សាសនា ទំនៀមទម្លាប់ ប្រពៃណីពិសេសប្រាសាទបុរាណទូទាំងប្រទេសស្ទើរគ្រប់តំបន់។

ឧ. រឿងទុំទាវ បានលើកបង្ហាញពីអក្សរសាស្ត្រ សិល្បៈ សាសនា ទំនៀមទម្លាប់ ប្រពៃណី ជាអាទិ៍តួអង្គទុំ ពេជ្រ.

ឧ. រឿងផ្កាស្រពោន តួអង្គប៊ុន ធឿនបានខិតខំរៀនសូត្រ.

- លើកក្នុងសង្គម ពិធីបុណ្យពិសាខបូជា មាឃបូជា...។

3. ទីតាំងភូមិសាស្ត្រ ប្រវត្តិសាស្ត្រ ឈ្មោះភូមិ ឃុំ ស្រុក ខេត្ត

ឧ រឿងព្រះថោង នាងនាគ ពីដំបូងឡើយផ្ទៃប្រទេសជាទឹក

ឧ. រឿងទុំទាវ ស្រុកបាភ្នំ ត្បូងឃ្មុំ ... ។

ឧ. រឿងផ្កាស្រពោន ទន្លេសាប ភ្នំពេញ អង្គរវត្ត... ។

4. ជីវភាពរស់នៅ ប្រជាពលរដ្ឋ មានមុខរបរ វិជ្ជាជីវៈ របស់មនុស្សរស់នៅក្នុងសង្គម ..

ឧ. រឿងទុំទាវ បង្ហាញពីការលក់ដូររបស់ប្រជាជន ទុំពេជ្រដើរលក់តោក... ។

ឧ. រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ បង្ហាញពីមុខរបរកសិករ កម្មករធាក់ស៊ីក្លូ... ។

- សរុបសេចក្តី

សរុបសេចក្តីមក ពំនោលខាងលើបានបង្ហាញឱ្យឃើញពីសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ ទីតាំងភូមិសាស្ត្រប្រវត្តិសាស្ត្រ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ នេះជាភស្តុតាងថា

ប្រជាពលរដ្ឋមានការរំភើប ត្រេកអរ កោតសរសើរ ដល់បុព្វបុរស ដែលបានបន្សល់ទុកឱ្យ កូនខ្មែរជំនាន់ក្រោយថែរក្សាការពារ។

### III. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ មានអត្ថន័យល្អ ជ្រាលជ្រៅដោយបានឆ្លុះបញ្ចាំងពីកំណើតជាតិសាសន៍របស់ខ្លួន សេចក្តីស្រឡាញ់ពេញចិត្ត ការលើកតម្កើង និងការឱ្យតម្លៃជាតិរបស់ខ្លួន។
- មតិផ្ទាល់ខ្លួន៖ ដូចនេះយើងទាំងអស់គ្នា ត្រូវប្រឹងប្រែងរៀនសូត្រ ឱ្យបានខ្ពង់ខ្ពស់ដើម្បីចូលរួមចំណែកកសាងការពារ ថែរក្សាកេរដំណែលដូនតា ឱ្យបានគង់វង្ស និងរីកចម្រើនជានិរន្តរ៍។

## សេចក្តីអត្ថាធិប្បាយ

មនុស្សរស់នៅលើផែនដីនេះ តែងតែមានទឹកចិត្តស្រឡាញ់ពេញចិត្តកោតសរសើរចំពោះអ្វីៗដែលយើងមាន មិនថាជាមនុស្ស ទឹកដី ប្រាសាទបុរាណ លើកតម្កើងជាតិសាសន៍ប្រទេសជាតិរបស់មនុស្សទូទៅ។ ស្របតាមន័យនេះ ទើបមាន តើទស្សនៈដែលបានលើកឡើងថា៖ « ប្រជាពលរដ្ឋខ្មែរទាំងប្រុសស្រី មានមោទនភាពជាតិណាស់ ដែលបានកើតជាកូនខ្មែរ»។

តើទស្សនៈដែលបានលើកឡើងខាងលើនេះមានអត្ថន័យដូចម្តេច?

ដើម្បីជាជំនួយដល់ការបកស្រាយប្រធាន ខាងលើឱ្យបានក្បោះក្បាយ យើងត្រូវដឹងពីអត្ថន័យនៃពាក្យ "ប្រជាពលរដ្ឋខ្មែរ" "មោទនភាពជាតិ" និង"កូនខ្មែរ"ជាមុនសិន។ "ប្រជាពលរដ្ឋ" ប្រជាជនដែលកើតមានសញ្ជាតិខ្មែរ រស់នៅទឹកដីក្នុងប្រទេសកម្ពុជាយើងទាំងមូល។ "មោទនភាពជាតិ" គឺបង្ហាញពីការ ស្រឡាញ់ ពេញចិត្ត សេចក្តីស្រឡាញ់ ការកោត សរសើរ ការលើកតម្កើង ប្រវត្តិកំណើតជាតិសាសន៍ ការឱ្យតម្លៃខ្ពស់ចំពោះជាតិយើង។ ចំណែក "កូនខ្មែរ" សំដៅលើកូន ឬមនុស្សកើតលើទឹកដី សុវណ្ណភូមិ ជាពិសេសប្រទេសកម្ពុជាយើង ។ តាមការលាតត្រដាងបង្ហាញខាងលើយើងឃើញថា កុលបុត្រកុលធីតាខ្មែរ មានភាពសប្បាយរីករាយ រំភើបដែលកើតលើទឹកដី ដ៏សម្បូរបែប ទាំងសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ ទីតាំងភូមិសាស្ត្រប្រវត្តិសាស្ត្រ និងជីវភាពរស់នៅរបស់ប្រជាជនជាដើម។ យោងតាមអត្ថន័យរបស់ពាក្យគន្លឹះខាងលើអំណះអំណាងដែលជាភស្តុតាង ប្រជាពលរដ្ឋខ្មែរទាំងប្រុសស្រី មានមោទនភាពជាតិដែលបានកើតជាកូនខ្មែរ មានដូចតទៅ សម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ ទីតាំងភូមិសាស្ត្រ និងជីវភាពរស់នៅរបស់ប្រជាជនជាដើម។

យើងឃើញថា ប្រទេសកម្ពុជាជាប្រទេសមានវ័យចំណាស់ជាងគេ ហើយប្រជាពលរដ្ឋខ្មែរទាំងប្រុសស្រី មានមោទនភាពជាតិ ដែលបានកើតជាកូនខ្មែរព្រោះប្រទេសខ្មែរមានទឹកដីរបស់ខ្លួនដែលកើតតាំងពីយូរយារណាស់មកហើយ។ លើសពីនេះក៏មានសម្បត្តិធម្មជាតិជាច្រើនដូចជាដើមត្នោតជាដើម។ មិនតែប៉ុណ្ណោះខ្មែរយើងមាន ប្រពៃណីទំនៀម

ទម្លាប់ មានពិធីបុណ្យ មានរបៀបរបបទម្លាប់នៃការធ្វើជារៀងរាល់ឆ្នាំ។ បើនិយាយផ្នែកវប្បធម៌ អក្សរសាស្ត្រ អក្សរសិល្ប៍ និងប្រវត្តិសាស្ត្ររបស់ខ្លួនពិត ហើយក៏មានវ័យចំណាស់ផងដែរ។ ជាក់ស្តែងបានពីបង្ហាញក្នុងរឿងទុំទាវ ត្រង់ទុំពេជ្រធ្វើដំណើរពីត្បូងឃ្មុំទៅបាភ្នំ ហើយពីបាភ្នំ ទៅលង្វែកដើម្បីទៅបម្រើចម្រៀងថ្វាយស្តេចរាមាជើងព្រៃ បានរៀបរាប់ថាទុំច្រៀងរៀបរាប់ធម្មជាតិ ព្រៃ ព្រឹក្សាលតាវល្លិ បក្សាបក្សីក្នុងព្រៃ "មើលមានជ្រៃជ្រៃសង្កែថ្វាន់ ត្រៀលត្រស់ក្រវាន់គុយស្រគំ ស្រឡីស្រឡៅក្របៅក្ដម្ព ទន្រំអាររូដ្ឋចង្អូរត្នោត" ជាដើម។ រីឯក្នុងសង្គមជាក់ស្តែង ប្រទេសយើងមានតំបន់វាលទំនាប តំបន់ខ្ពង់រាប ដែលមានព្រៃឈើ ជួរភ្នំ ភ្នំហ៊ុំព័ទ្ធស្ទើរជុំ ផ្ទៃប្រទេសទាំងមូល ដែលជួយការពារមិនមានគ្រោះធម្មជាតិ ធំដុំកើតឡើងទេ។ ហើយព្រៃឈើផ្តល់ជាជម្រក សត្វ គ្រប់ប្រភេទទាំងសត្វដើរលើដី សត្វហើរលើអាកាស វាផ្តល់ផលដល់សត្វ និងមនុស្សយ៉ាងច្រើនរាប់មិនអស់ តាំងពីជម្រក ដើមមែក ស្លឹក ផ្លែផ្កា ត្រួយ ឬសធ្វើថ្នាំ ជាអាហារជាដើម។ ជាក់ស្តែងទឹកទន្លេ បឹងបួរ សមុទ្រ សាបប្រៃវិញមាន ត្រី ក្តាម ខ្យង ត្រីមានស្រកា ត្រីមិនមានស្រកា ជាអាហារសម្រាប់មនុស្ស សត្វគ្រប់បែបយ៉ាង។ ចំណែកដីវិញក៏មានជីជាតិសម្រាប់ផ្តល់ ឱ្យមនុស្ស បង្កបង្កើនផលដំណាំគ្រប់ប្រភេទ សម្រាប់ហូបធ្វើអាជីវកម្មផ្គត់ផ្គង់គ្រួសារទាំងមើម ស្លឹក ដើម ផ្លែផ្កា ត្រួយជាដើម តាមតម្រូវការរបស់មនុស្សឬសត្វ។ តួយ៉ាងនៅក្នុងរឿងទុំទាវ បានលើកបង្ហាញពីអក្សរសាស្ត្រ សិល្បៈសាសនា ទំនៀមទម្លាប់ ប្រពៃណី ជាអាទិ៍តួអង្គទុំ ពេជ្របានបួសរៀនជាសាមណេរ ចេះស្មូត លក់តោក តាំងពីបាភ្នំរហូតត្បូងឃ្មុំ អប់រំមនុស្សឱ្យ

ស្រឡាញ់ គោរពសាសនាព្រះពុទ្ធ ព្រោះព្រះអង្គបានផ្តល់ឱ្យមនុស្សមាន សេចក្តីសុខស្ងប់ក្នុងជីវិត។ រីឯតួរអង្គទាវវិញជាកូនស្រី ត្រូវរៀននៅផ្ទះគឺ ពិធីចូលម្លប់ ដោយរៀបចំដាំស្ល រៀបចំផ្ទះសម្អែងដេរប៉ាក់ចាក់ជាយ អក្សរសាស្ត្រ ជាដើម។ យ៉ាងណាមិញដូចក្នុងរឿងផ្កាស្រពោនវិញតួរអង្គ ប៊ុន ធឿនខិតខំរៀនសូត្របានបន្តការសិក្សា ខេត្តបាត់ដំបងដល់ភ្នំពេញ នាងវិធាវីចូលម្លប់ខិតខំរៀននៅផ្ទះជាមួយម្តាយ និងយាយផៃ។ ទន្ទឹមនឹង នេះក្នុង សង្គម ជាក់ស្តែងមាន ពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យទាន មានពិធីបុណ្យបំបួសនាគ ពិសាខបូជា មាឃបូជា ភ្ជុំ បិណ្ឌ ចូលឆ្នាំថ្មីជាដើ ម។ ហើយពិសេសជាងនេះទៀតប្រទេសខ្មែរយើងមានប្រាសាទបុរាណ យ៉ាងច្រើន សន្និកសន្ធាប់ដែលជាកេរដំណែលរបស់បុព្វបុរសដូនតាយើង បានកសាងទុកឱ្យ កូនចៅជំនាន់ក្រោយថែរក្សា ការពារសម្បត្តិវប្បធម៌ដ៏ ល្អអស្ចារ្យទាំងនេះ ដែលប្រទេសដទៃគ្មាន។ ដោយលោកបង្ហាញ ពីការរីក ចម្រើនយ៉ាងខ្លាំង រហូតដល់សង់ប្រាសាទស្ទើរគ្រប់ទិសទី លើទឹកដីយើង នេះ។តាំងពីការសាសង់លើផ្ទៃរាប ក្នុងទឹក រហូតសង់លើកំពូលភ្នំ មាន ប្រាសាទមេបុណ្យ ស្ថិតក្នុងទឹកស្រះបារាយណ៍ ប្រាសាទអង្គរវត្ត ប្រាសាទ បាយ័ន តាព្រហ្ម នាគព័ន្ធ ភ្នំបាខែង ភ្នំគូលែន ជាដើម នេះជាភាពរីកលូត លាស់ថ្កើនថ្កាន របស់ប្រទេសយើង។ លើសពីនេះទៅទៀត វាបានក្លាយ ជាតំបន់ទេសចរណ៍យ៉ាងច្រើនអនេក មានកន្លែងតំបន់ទេសចរណ៍ធម្ម ជាតិ កន្លែងតំបន់ទេសចរណ៍ការកែច្នៃ និងធម្មជាតិ ជាកន្លែងតំបន់ ទេសចរណ៍សិប្បនិម្មិត តំបន់ទេសចរណ៍វប្បធម៌ ស្ទើរគ្រប់តំបន់ និងទី កន្លែងនៅតាមបណ្តាខេត្ត ទូទាំងប្រទេសកម្ពុជាយើង។ នៅប្រទេសយើង

មានឈ្មោះប្រវត្តិសាស្ត្រដែលកកើតទឹកដី តួយ៉ាងដូចស្តែងក្នុងរឿង ព្រះថោងនាងនាគ ពីដំបូងឡើយផ្ទៃប្រទេសកម្ពុជាយើង មានផ្ទៃជាទឹកទាំងអស់ តែដល់ពេលមាននាងនាគ និងព្រះថោងរៀបអភិសេក ទើបក្លាយពីផ្ទៃទឹកមកជាដីគោកជាប្រទេស ជានគរ ហើយមានកំណរកំណើតមនុស្សចាប់តាំងពីពេលនោះមក រហូតដល់សម័យបច្ចុប្បន្ននេះ។ យ៉ាងណាមិញស្តែងដូចក្នុងរឿងទុំទាវ បានកកើតឡើងនៅឈ្មោះភូមិ ឃុំ ស្រុក ខេត្ត វត្តវិហារធំ ស្រុកបាភ្នំ ខេត្តព្រៃវែង និងឃុំពោធិ៍ជើងខាល ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ សព្វថ្ងៃ និងរាជធានីលង្វែក នៅកំពង់ឆ្នាំងបច្ចុប្បន្ន។ រឿងផ្កាស្រពោនស្ថិតនៅខេត្តបាត់ដំបង វត្តដំរីស ទន្លេសាប និងអង្គរវត្ត ខេត្តសៀមរាបភ្នំពេញជាដើម។ រីឯក្នុងរឿងទុំទាវ បានបង្ហាញពីមុខរបរលក់ដូរនៅផ្សាររបស់ប្រជាជនតាមជនបទ នេនទុំ ពេជ្របរទេសគោដើរលក់គោកតាំងពីស្រុកបាភ្នំ រហូតដល់ស្រុកត្បូងឃ្មុំ មានមន្ត្រីសេនាគ្រប់គ្រងស្រុក ខេត្ត តាមឋានានុក្រម។ ចំណែកឯនៅក្នុងរឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់ តួអង្គសមជាកសិករធ្វើស្រែចម្ការ តែដោយសារមានបញ្ហាក្នុងគ្រួសារធ្វើឱ្យសម ឃ្លាតឆ្ងាយពីភូមិស្រុក មករស់នៅក្រុងភ្នំពេញប្រកបមុខរបរ ជាកម្មករធាក់ស៊ីក្លូ ដោយប្រើកម្លាំងបាយសុទ្ធសាត ដើម្បីចិញ្ចឹមជីវិតប្តីប្រពន្ធ។

សរុបសេចក្តីមកភស្តុតាងទាំងអស់ខាងលើ ជាតឹកតាងយ៉ាងច្បាស់ដែលបានបញ្ជាក់ និងរៀបរាប់ពីធនធានសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ ទីតាំងភូមិសាស្ត្រប្រវត្តិសាស្ត្រ និងបង្ហាញពីជំនឿសាសនា ទំនៀមទម្លាប់ប្រពៃណី ដែលប្រជាជនកម្ពុជាបច្ចុប្បន្នកោតស្ញប់ស្ញែង

លើកតម្កើង ឱ្យតម្លៃមិនអាចកាត់ថ្លៃបាន គោរពប្រតិបត្តិ ថែរក្សាបាន រហូតមកដល់សព្វថ្ងៃនេះ ធ្វើឱ្យពួកគាត់មានទឹកចិត្តសប្បាយរីករាយ រំភើប ដែលទទួលយកកេរដំណែលដ៏ល្អ ដែលប្រទេសយើងមាន។

ឆ្លងតាមការបកស្រាយខាងលើ បានផ្តល់នូវតម្លៃអប់រំ មានខ្លឹមសារ មានអត្ថន័យជ្រាល ជ្រៅបំផុតដែលបានឆ្លុះបញ្ចាំង ពីកូនខ្មែរទាំងប្រុសស្រី មានមោទនភាពជាតិ។ ដែលដូនតាបានបន្សល់ទុកឱ្យ នូវអរិយធម៌ វប្បធម៌ ដ៏រុងរឿងលើទឹកដីដ៏បវរនេះ ពិសេសកូនចៅយកមកប្រើប្រាស់ជាប្រយោជន៍ របស់សង្គមមនុស្សជាអនេក ភាពអស្ចារ្យនៃវត្ថុអច្ឆរិយៈ ទាំងសម្បត្តិវប្បធម៌ សម្បត្តិធម្មជាតិ។ ដូចនេះក្នុងនាមកូនខ្មែរគ្រប់រូប ត្រូវតែប្រឹងប្រែងរៀនសូត្រ ឱ្យបានខ្ពង់ខ្ពស់ដើម្បីចូលរួមចំណែកកសាង ការពារ ថែរក្សាកេរដំណែលបុព្វបុរសដូនតា ឱ្យបានគង់វង្ស និងរីកចម្រើន ជានិច្ចនិរន្តរ៍។

# ប្រធានទី១៧

តម្លៃអប់រំក្នុងរឿងកុលាបប៉ៃលិន គឺជឿលើសមត្ថភាពផ្ទាល់ខ្លួន។ ចូរពន្យល់គំនិតខាងលើដោយលើកហេតុផលក្នុងរឿងកុលាបប៉ៃលិនមកបញ្ជាក់។

## គម្រោងតែង

### I. សេចក្តីផ្តើម

- ✓ លំនាំបញ្ហា៖ រៀបរាប់គំនិតដែលទាក់ទងទៅនឹងសមត្ថភាពផ្ទាល់ខ្លួន។
- ✓ ចំណូលបញ្ហា៖ តម្លៃអប់រំក្នុងរឿងកុលាបប៉ៃលិន គឺជឿលើសមត្ថភាពផ្ទាល់ខ្លួន។
- ✓ ចំណោទបញ្ហា៖ តើនៅក្នុងរឿងកុលាបប៉ៃលិនបានបង្ហាញពីសមត្ថភាពផ្ទាល់ខ្លួនដូចម្តេចខ្លះ?

### II. តួសេចក្តី

- ✓ ឃ្លាភ្ជាប់សេចក្តី៖ មុននឹងធ្វើការបកស្រាយប្រធាន...។
- ✓ ពន្យល់ពាក្យ៖ សមត្ថភាព ភាពជាបុគ្គលម្នាក់ៗធ្វើបានដោយខ្លួនឯង។
- ✓ ពន្យល់ន័យប្រធាន៖ ដាស់តឿនឱ្យយុវជនទាំងឡាយចេះកសាងសមត្ថភាពខ្លួនឯងឱ្យបានច្រើនទាំងផ្លូវកាយ ទាំងផ្លូវចិត្ត និងបញ្ញា។

✓ បកស្រាយប្រធានះ ជំនឿជាក់គឺការមានសមត្ថភាពក្នុងការធ្វើកិច្ចការអ្វីមួយមិនថាការប្រើកម្លាំងកាយ និងចិត្តប្រាជ្ញាទេ។ រាល់ការងារដែលយើងអាចធ្វើបានតាមកម្លាំងកាយ ប្រមាណ ឬស្មានកម្លាំងដឹងថាទៅរួច ឬមិនរួច។ ការដោះស្រាយបញ្ហាដោយប្រើបញ្ញាបានទាន់ចិត្ត វាកើតមានចំពោះបុគ្គលដែលមានជំនឿជាក់លើខ្លួនឯង។ តួយ៉ាងក្នុងរឿងកុលាបប៉ៃលិនសម្រាប់តួអង្គចៅចិត្រគេជាបុគ្គលដែលមានភាពជឿជាក់ព្រោះ៖

+ សមត្ថភាពផ្លូវកាយ៖ កម្មករត្បូង បើកឡាន មានកម្លាំងប្រយុទ្ធនឹងចោរ
+ សមត្ថភាពផ្លូវចិត្ត៖ ស្មោះត្រង់ ក្លាហាន តស៊ូ អត់ធ្មត់
+ សមត្ថភាពបញ្ញា៖ ចេះជួសជុលឡាន ចេះច្រៀង ចេះរកទឹកដាំបាយ ចេះដឹកនាំគ្រប់គ្រង។

លើកអំណះអំណាងមកបញ្ជាក់

✓ សរុបសេចក្តី៖ ចៅចិត្រជាយុវជនកំព្រា អាចក្លាយជាកូនប្រសាលោកហ្លួងរតនសម្បត្តិ បានដោយពឹងលើសមត្ថភាពខ្លួនឯងទាំងស្រុង។

## III. បញ្ចប់សេចក្តី

✓ វាយតម្លៃប្រធានះ ឆ្លងតាមការបកស្រាយរួចមកឃើញថារឿងកុលាបប៉ៃលិន បានផ្តល់តម្លៃអប់រំដល់យុវវ័យគ្រប់សម័យកាលឱ្យជឿលើសមត្ថភាពផ្ទាល់ខ្លួននិងមិនរើសរើងការងារ។

✓ មតិផ្ទាល់ខ្លួន៖ ដូច្នេះក្នុងនាមយើងជាយុវជនត្រូវពឹងលើសមត្ថភាពផ្ទាល់ខ្លួនជាចម្បងទើបអាចទទួលបានជោគជ័យ កុំផ្ដេកផ្ដួលលើព្រេងវាសនា។

## សេចក្ដីអធិប្បាយ

រាល់បណ្ដាស្នាដៃអក្សរសិល្ប៍ទាំងអស់ ទាំងអក្សរសិល្ប៍បុរាណក្ដី អក្សរសិល្ប៍ប្រជាប្រិយក្ដី និងទាំងអក្សរសិល្ប៍ទំនើបក្ដី គឺសុទ្ធតែបានបង្កប់នូវតម្លៃអប់រំតាមសិល្បវិធីរបស់អ្នកនិពន្ធរៀងៗខ្លួន។ យ៉ាងណាមិញក្នុងរឿងកុលាបប៉ៃលិនបានអប់រំយើងឱ្យជឿលើសមត្ថភាពផ្ទាល់ខ្លួន។

តើការជឿលើសមត្ថភាពផ្ទាល់ខ្លួនក្នុងរឿងនេះបានបង្ហាញយ៉ាងដូចម្ដេចខ្លះ?

មុននឹងធ្វើការបកស្រាយប្រធានបទខាងលើ យើងគប្បីយល់ពាក្យគន្លឹះរបស់ប្រធានជាមុនសិន។ សមត្ថភាពគឺជាភាពដែលអាចធ្វើអ្វីៗបានដោយខ្លួនឯង។ ដូចនេះប្រធានដែលបានលើកឡើងនេះមានន័យថាមនុស្សយើងម្នាក់ៗត្រូវមានទំនុកចិត្ត ជឿលើអ្វីៗដែលយើងមានទាំងសមត្ថភាពផ្លូវកាយ ផ្លូវចិត្ត និងបញ្ញា។

ជាការពិតណាស់យើងអាចទទួលបានភាពជោគជ័យ គឺអាស្រ័យដោយមានសមត្ថភាពផ្លូវកាយ ផ្លូវចិត្ត បញ្ញា ទាំងបីនេះរួមបញ្ចូលគ្នា។ សមត្ថភាពផ្លូវកាយគឺសំដៅលើរាងកាយមាំមួន មានសុខភាពល្អ គឺត្រូវចេះថែរក្សាសុខភាព ដោយមានការទទួលទានអាហារ បានគ្រប់គ្រាន់ និងលំហាត់ប្រាណជាប្រចាំ។ ជំនឿជាក់គឺការមានសមត្ថភាពក្នុងការធ្វើកិច្ចការអ្វីមួយមិនថាការប្រើកម្លាំងកាយ និងចិត្តប្រាជ្ញាទេ។

វាល់ការងារដែលយើងអាចធ្វើបានតាមកម្លាំងកាយ ប្រមាណ ឬស្មាន កម្លាំងដឹងថាទៅរួច ឬមិនរួច។ ការដោះស្រាយបញ្ហាដោយប្រើបញ្ញាបាន ទាន់ចិត្ត វាកើតមានចំពោះបុគ្គលដែលមានជំនឿជាក់លើខ្លួនឯង។ ជាក់ ស្តែងដូចជាចៅចិត្រ ក្នុងរឿងកុលាបប៉ៃលិន ត្បិតតែមានរាងកាយស្គម បន្តិចមែន តែចៅចិត្រមានសុខភាពល្អ ចេះបើកឡានដោយមិនពុល ។ ហើយពេលមានចោរប្លន់ ចៅចិត្រមានកម្លាំងប្រយុទ្ធជាមួយចោរបាន យ៉ាងខ្លាំងក្លា។ ឯសមត្ថភាពផ្លូវចិត្តគឺសំដៅលើកម្លាំងចិត្តរឹងមាំ ចេះអត់ ធ្មត់តស៊ូ ពុះពាររាល់ឧបសគ្គ ដែលកើតមានឡើងចំពោះមុខមិនរាថយ ដូចជាពេលចោរប្លន់ លោកហ្លួងរតនសម្បត្តិនៅកណ្តាលព្រៃ ចៅចិត្រ មានសេចក្តីក្លាហាន ទោះដឹងថា ពួកចោរមានគ្នាច្រើន មានកម្លាំងខ្លាំងក្លា ក៏ដោយ ក៏ចៅចិត្រមានកម្លាំងចិត្តជាធំតតាំងជាមួយពួកចោរ រហូតនៅ សល់តែគ្រាប់កាំភ្លើងមួយគ្រាប់ ក៏ចៅចិត្រមិនតក់ស្លុតដែរ។ ជាមួយ ការងារវិញ ចៅចិត្រមានភាពស្មោះត្រង់ មិនកឹបកេងពីចៅហ្វាយនាយ ឡើយ។ ចំណែកសមត្ថភាពខាងបញ្ញាវិញ គឺអ្នកនិពន្ធចង់អប់រំយុវជន ទាំងអស់ឱ្យចេះខិតខំរៀនសូត្រ ក្រេបជញ្ជក់យកចំណេះវិជ្ជាដាក់ខ្លួន ព្រោះចំណេះវិជ្ជាជាសម្បត្តិមួយដែលចោរលួចមិនបាន ពេលទៅណាមក ណាវាប្រើប្របានជាអាវុធ នៅជាប់នឹងខ្លួនអញ្ចឹង។ ហើយវាអាចដោះ ស្រាយបញ្ហាបានគ្រប់កាលទេសៈ។ ជាក់ស្តែងចៅចិត្របានចូលរៀននៅ សាលារហូតបានប្រកាសនីយបត្រ ធ្វើឱ្យចៅចិត្រមានសមត្ថភាព អាច កាន់បញ្ជីត្បូងជំនួសលោកហ្លួងរតនសម្បត្តិបាន។ មិនត្រឹមតែចេះកាន់ បញ្ជីត្បូង ចៅចិត្រចេះជួសជុលរថយន្ត និងចេះបើករថយន្ត ជូនចៅហ្វាយ

នាយទាន់ពេលវេលាទៀតផង។ សូម្បីការងារផ្ទះ ក៏ចៅចិត្រចេះដែរដូចជា ដាំបាយ រែកទឹក ។ពេលទំនេរចៅចិត្រ ចេះច្រៀងបំពេរអារម្មណ៍ ដែល អាចទាក់ទាញដល់នាងឃុន នារី។ ទាំងនេះមានន័យថា ចៅចិត្រមាន បញ្ញា បានរៀនសូត្រ បើមិនអញ្ចឹងទេចៅចិត្រមិនអាចដោះស្រាយបញ្ហា ដូចខាងលើបានឡើយ។

សរុបមកយើងឃើញថាចៅចិត្រជាយុវជនកំព្រា អាចក្លាយជា កូនប្រសារលោកហ្លួងរតនសម្បត្តិបានគឺពឹងផ្អែកទាំងស្រុង លើសមត្ថ ភាពខ្លួនឯងផ្ទាល់ ឥតមានកម្លាំងឬ ឥទ្ធិពលអ្វីមកជួយគេនោះឡើយ។

ឆ្លងតាមការបកស្រាយប្រធានរួចមក យើងឃើញថារឿងកុលាប ប៉ៃលិន ពិតជាមានតម្លៃអប់រំ។ ពិសេសដល់យុវវ័យគ្រប់សម័យកាល ឱ្យ ពឹងលើសមត្ថភាពខ្លួនឯង ត្រូវចេះតស៊ូ ត្រូវចេះអត់ធ្មត់ព្យាយាម មិន រើសអើងការងារ ។ ដូចនេះក្នុងនាមយើងជាយុវជន ដែលជាសរសរទ្រូងនៃ ប្រទេសជាតិ ត្រូវខិតខំបណ្តុះសមត្ថភាពផ្ទាល់ខ្លួនឱ្យបានច្រើន ហើយត្រូវ មានទំនុកចិត្តលើខ្លួនឯង មិនត្រូវផ្តេកផ្តួលលើព្រេងវាសនាឡើយ។

## ប្រធានទី១៨

មានទស្សនៈអប់រំមួយបានពោលថា៖ "កុសលកម្មតែងផ្ដល់នូវសេចក្ដីសុខក្សេមក្សាន្ត"។ ចូរបកស្រាយ ដោយលើកឧទាហរណ៍ក្នុងសង្គម និងអក្សរសិល្ប៍មកបញ្ជាក់។

### គម្រោងតែង

**I. សេចក្ដីផ្ដើម**

-លំនាំបញ្ហា៖ នៅក្នុងសង្គមកម្ពុជាប្រជាជនភាគច្រើន ជឿនិងគោរពទៅលើព្រះពុទ្ធ សាសនា ព្រោះព្រះពុទ្ធប្រាថ្នាចង់ឱ្យមនុស្សគ្រប់រូប ប្រព្រឹត្តិតែអំពើល្អ អំពើជាកុសល ដែលនាំឱ្យមនុស្សរស់នៅប្រកបដោយសេចក្ដីសុខសុភមង្គល។

-ចំណូលបញ្ហា៖ អាស្រ័យហេតុនេះហើយ ទើបមានទស្សនៈអប់រំមួយបានពោលថា "កុសលកម្មតែងផ្ដល់នូវសេចក្ដីសុខក្សេមក្សាន្ត" ។

-ចំណោទបញ្ហា៖ តើទស្សនៈដែលពោលមកហើយមានអត្ថន័យដូចម្ដេច?

**II. តួសេចក្ដី**

-ឃ្លាភ្ជាប់សេចក្ដី៖ ដើម្បីជាប្រទីបបំភ្លឺផ្លូវក្នុងការបកស្រាយប្រធានបទ ឱ្យកាន់តែស៊ីជម្រៅ គប្បីយល់ន័យនៃពាក្យ

-ពន្យល់ពាក្យ៖

+កុសលកម្ម មានន័យថា ការប្រព្រឹត្តិធ្វើតែអំពើល្អ ការកសាងអំពើដ៏ត្រឹមត្រូវ ជាអំពើ ប្រកបដោយសីលធម៌ និងគុណធម៌។

+សេចក្តីសុខ គឺសំដៅដល់ភាពសុខស្រួល ភាពគ្មានគ្រោះថ្នាក់ ភាពគ្មានទុក្ខព្រួយ។

-ពន្យល់ន័យប្រធាន៖ មានន័យថា មានតែអំពើល្អជាកុសលទេ ទើបធ្វើឱ្យមនុស្សយើង មានសេចក្តីសុខសុភមង្គលក្នុងការរស់នៅ។

-បកស្រាយប្រធាន៖ ការរស់នៅរបស់មនុស្ស ការប្រព្រឹត្តិធ្វើតែអំពើល្អ អំពើដែលត្រឹមត្រូវ មិនបៀតបៀនអ្នកដទៃជាអំពើសុចរិត...

- រូបភាពនៃកុសលកម្ម៖
  - ✓ ការប្រព្រឹត្តិអំពើល្អ
  - ✓ អំពើដែល ត្រឹមត្រូវ មិនបៀតបៀនអ្នកដទៃ
  - ✓ មិនសម្លាប់ជីវិតមនុស្ស សត្វ
  - ✓ កុំពោលពាក្យមុសា ពោលពាក្យទៀងត្រង់
  - ✓ មិនកេងចំណេញផលប្រយោជន៍ពីអ្នកដទៃ...
- លទ្ធផល៖
  - ✓ ធ្វើឱ្យជីវិតរបស់ពួកគេបានរស់នៅ ប្រកបដោយសេចក្តីសុខសប្បាយសុភមង្គល ហើយទទួលបាននូវការគោរពស្រលាញ់អំពីអ្នកដទៃ។...

+ឧ. ដូចជាមនុស្សក្នុងសង្គមដែលធ្វើអំពើល្អ ស្របច្បាប់តែងរួចផុត ពីការស្អប់ខ្ពើមពីអ្នក ដទៃ និងមិនត្រូវច្បាប់សង្គមផ្តន្ទាទោស។

+ឧ. រឿងកុលាបប៉ៃលិន តួអង្គចៅចិត្តប្រព្រឹត្តិអំពើល្អប្រកបដោយសីលធម៌ មិនបៀត បៀនអ្នកដទៃ ទីបំផុតគេរស់នៅប្រកបដោយសេចក្តីសុខចម្រើន ព្រមទាំងទទួលបាន នូវការកោតសរសើរពីអ្នកដទៃ និងធ្វើឱ្យថៅកែពេញចិត្ត ប្រគល់អ្វីៗទាំងអស់ព្រមទាំងនាងឃុននារី ដែលជាកូនស្រីតែមួយរបស់លោកហ្លួងរតនសម្បត្តិមកធ្វើជាភរិយា។

+ឧ. កូនប្រុសស្រី ដែលដឹងនូវគុណូបការៈ របស់ឪពុកម្តាយ លោកគ្រូ អ្នកគ្រូ ចាស់ ព្រឹទ្ធាចារ្យ ដែនដីមាតុភូមិ ជាមនុស្សដែលមិនចេះបំភ្លេចគុណ ជាអ្នកមានកតញ្ញូជានិច្ច ប្រាកដជាទទួលបានជោគជ័យ និងរីកចម្រើនរុងរឿង។

+ឧ. រឿងសុវណ្ណសាម តួអង្គសុវណ្ណសាមជាតួអង្គ ដែលចេះតបគុណម្តាយឪពុក ទីបំផុត ខ្លួនរស់ដោយភាពសុខស្រួល សុភមង្គល។

+ឧ. នៅក្នុងសង្គមមួយ មានមនុស្សដែលមានសីលធម៌ គុណធម៌ សប្បុរសធម៌ ព្រហ្ម វិហារធម៌ ចេះអត់ឱនអធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក ចេះជួយសង្គ្រោះគ្នាពេលមាន អាសន្ន ហើយជាមនុស្សដែលមានចិត្តមេត្តា អាណិត ស្រលាញ់នោះ នឹងធ្វើឱ្យ ការ

រស់ នៅប្រកបដោយសេចក្តីសុខ គ្មានសង្គ្រាម គ្មានអំពើហឹង្សា មានការអភិវឌ្ឍ។

+ឧ. រឿងមាយើង តួអង្គមាយើង ចេះជួយយកអាសារគេ ដូចជា ជួយសង្គ្រោះព្រះរាជា ឱ្យរួចផុតពីគ្រោះថ្នាក់។

-សរុបសេចក្តី៖ ទស្សនៈដែលលើកឡើងខាងលើ គឺចង់អប់រំឱ្យ មនុស្សគ្រប់រូប ប្រព្រឹត្តិ អំពើល្អ អំពើជាកុសល សាងនូវអំពើ សុចរិត មានសីលធម៌ គុណធម៌ មិនបៀតបៀនអ្នក ដទៃ នឹង ទទួលបានសេចក្តីសុខចម្រើនសុភមង្គល។

## III. សេចក្តីបញ្ចប់

-វាយតម្លៃប្រធាន៖ ឆ្លងតាមរយៈការបកស្រាយខាងលើ យើង អាចវាយតម្លៃបានថា អត្ថន័យ របស់ប្រធានចង់អប់រំមនុស្ស ទូទៅ ឱ្យប្រព្រឹត្តិអំពើល្អ អំពើកុសល សុចរិតទៀងត្រង់ និង ជួយឱ្យ មនុស្សរស់នៅប្រកបដោយសេចក្តីសុខសន្តិភាព។

-មតិផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សា និងជាពលរដ្ឋមួយរូប ដែលរស់នៅក្នុងសង្គម គឺត្រូវធ្វើអ្វីដែលមានប្រយោជន៍ ដល់ មនុស្ស និងសង្គមជាតិឱ្យមានការអភិវឌ្ឍ។

# សេចក្ដីអធិប្បាយ

នៅក្នុងសង្គម ក៏ដូចជានៅក្នុងស្នាដៃអក្សរសិល្ប៍ សុទ្ធតែបានឆ្លុះបញ្ចាំងអំពីការរស់នៅ របស់មនុស្សគ្រប់ស្រទាប់វណ្ណៈ ដែលបានបង្ហាញអំពីសកម្មភាពរបស់មនុស្ស ប្រព្រឹត្តិអំពើល្អ ដែលមនុស្សភាគច្រើនជឿ និងគោរពតាមព្រះពុទ្ធសាសនា ព្រោះព្រះពុទ្ធប្រាថ្នាចង់អប់រំ មនុស្សគ្រប់រូបឱ្យប្រព្រឹត្តិអំពើល្អ អំពើជាកុសល ដែលនាំឱ្យមនុស្សរស់នៅប្រកបដោយសេចក្ដីសុខសុភមង្គល។ អាស្រ័យហេតុនេះហើយ ទើបមានទស្សនៈអប់រំមួយបានពោលថា "កុសលកម្មតែងផ្ដល់នូវសេចក្ដីសុខក្សេមក្សាន្ត"។

តើទស្សនៈដែលពោលមកខាងលើនេះមានអត្ថន័យដូចម្ដេច?

ដើម្បីជាប្រទីបបំភ្លឺផ្លូវក្នុងការបកស្រាយប្រធានបទ ឱ្យកាន់តែស៊ីជម្រៅ យើងគប្បីយល់ន័យនៃពាក្យពាក្យថា "កុសលកម្ម និង សេចក្ដីសុខ" ជាមុនសិន។ ពាក្យថា កុសលកម្ម មានន័យ ថា ការប្រព្រឹត្តិធ្វើតែអំពើល្អ អំពើសុចរិតទៀងត្រង់ ការកសាងអពើដ៏ត្រឹមត្រូវ ជាអំពើប្រកប ដោយសីលធម៌ និងគុណធម៌។ រីឯពាក្យថា សេចក្ដីសុខ គឺសំដៅដល់ភាពសុខស្រួល សុខ សប្បាយ ភាពគ្មានគ្រោះថ្នាក់ ភាពគ្មានទុក្ខព្រួយ។ ដូច្នេះប្រធានមានន័យថា មានតែអំពើល្អជា កុសលទេ ទើបធ្វើឱ្យមនុស្សយើងមានសេចក្ដីសុខសុភមង្គលក្នុងការរស់នៅ។

ជាការពិតណាស់ ការប្រព្រឹត្តិធ្វើតែអំពើល្អ អំពើដែលត្រឹមត្រូវមិនបៀតបៀនអ្នកដទៃ អំពើសុចរិតទៀងត្រង់ការប្រព្រឹត្តិអំពើល្អ មិន

សម្លាប់ជីវិតមនុស្ស សត្វ កុំពោលពាក្យមុសា ពោលពាក្យទៀងត្រង់ មិនកេងចំណេញផលប្រយោជន៍ពីអ្នកដទៃនោះគេនឹងធ្វើឱ្យជីវិតរបស់ពួកគេបានរស់នៅ ប្រកបដោយ សេចក្ដីសុខសប្បាយសុភមង្គល ហើយទទួលបាននូវការគោរពស្រលាញ់អំពីអ្នកដទៃ។ ដែលធ្វើឱ្យជីវិតរបស់ពួកគេ រស់នៅប្រកបដោយសេចក្ដីសុខសប្បាយ សុភមង្គល ហើយទទួលបាននូវការគោរពស្រលាញ់ពីអ្នកដទៃ។ មិនមែនជាអំពើទុច្ចរិតនោះ ទេ ដែលជាអំពើដែលគេស្អប់ខ្ពើម ដូចជាការ លួចឆក់ប្លន់ ភូតភរកុហកបោកប្រាស់ ដែលនាំឱ្យ ជីវិតពួកគេជួបតែសេចក្ដីវិនាសអន្តរាយ និងត្រូវសង្គមផ្ដន្ទាទោស។ តួយ៉ាងដូចជានៅក្នុង សង្គមមនុស្សដែលធ្វើតែអំពើល្អ ស្របច្បាប់ រមែងរួចផុតអំពីការស្អប់ខ្ពើមពីអ្នកដទៃ ហើយ ពោរពេញទៅដោយការស្រលាញ់រាប់រកពីសំណាក់មុស្សទូទៅ និងមិនត្រូវបានច្បាប់សង្គម ផ្ដន្ទាទោសនោះទេ។ យ៉ាងណាមិញដូចជានៅក្នុងរឿងកុលាបប៉ៃលិន តួអង្គចៅចិត្រ ជាតួអង្គ ដែលប្រព្រឹត្តិតែអំពើល្អប្រកបដោយសីលធម៌ មិនបៀតបៀនអ្នកដទៃ ទីបំផុតគេរស់នៅប្រកបដោយសេចក្ដីសុខចម្រើន ព្រមទាំងទទួលបាន នូវការកោតសរសើរពីអ្នកដទៃ និងធ្វើឱ្យថៅកែពេញចិត្ត ប្រគល់អ្វីៗទាំងអស់ព្រមទាំងនាងឃុននារីដែលជាកូនស្រីតែមួយរបស់លោកហ្លួងរតនសម្បត្តិមកធ្វើជាភរិយា របស់ចៅចិត្តទៀតផង។ ម្យ៉ាងទៀតនៅក្នុងសង្គមខ្មែរ ជឿនិង ប្រកាន់ខ្ជាប់នូវកតញ្ញូ ការដឹងគុណចំពោះអ្នកមានគុណ។ ដូចជាកូនប្រុសស្រីតែងគោរព ដឹងគុណចំពោះឪពុកម្ដាយ លោកគ្រូ អ្នកគ្រូ ចាស់ព្រឹទ្ធាចារ្យ ដែនដីមាតុភូមិ អំពើ ទាំងនោះហើយ ទើបផ្ដល់ផលមកវិញនូវភាពសុខ

សប្បាយ សុភមង្គល និងរស់នៅប្រកប ដោយសេចក្ដីសុខសន្តិភាពរុងរឿង។យ៉ាងណាមិញដូចជា រឿងសុវណ្ណសាម តួអង្គសុវណ្ណសាម ជាតួអង្គដែលចេះដឹងតបគុណចំពោះមាតាបិតា ដោយខិតខំមើលថែ ចិញ្ចឹមលោកទាំងទ្វេ ឥតមានត្អូញត្អែរឡើយ ទោះបីខ្លួនស្ថិតនៅក្នុងភាពគ្រោះថ្នាក់ក៏ដោយ ក៏ខិតខំតស៊ូពុះពារ ជំនះគ្រប់ឧបសគ្គទាំងអស់ ទីបំផុតតួអង្គសុវណ្ណសាមរស់ដោយភាពសុខស្រួលសុភមង្គល។ មិនតែ ប៉ុណ្ណោះនៅក្នុងសង្គមមុស្ស ដែលប្រកបដោយសីលធម៌ គុណធម៌ ព្រហ្មវិហារធម៌ចេះអត់ឱន អធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក ចេះជួយសង្គ្រោះគ្នា ចេះជួយទុក្ខធុរៈគ្នាពេលមានអាសន្ន ហើយជាមនុស្សដែលមានចិត្តមេត្តា ករុណាចេះអាណិត ស្រលាញ់នោះ នឹងធ្វើឱ្យជីវិតពួកគេ រស់នៅប្រកបដោយសេចក្ដីសុខសន្តិភាព គ្មានសង្គ្រាម គ្មានអំពើហឹង្សា និងមានការអភិវឌ្ឍ។ បើយើងក្រឡេកទៅមើល ស្នាដៃអក្សរសិល្ប៍ រឿងមាយើង សបញ្ជាក់ឱ្យឃើញថា តួអង្គមា យើង ដែលជាតួអង្គ ចេះជួយសង្គ្រោះអ្នកដទៃ ក៏ដូចជាជួយព្រះរាជា និងអគ្គមហេសីឱ្យរួចផុត ពីសេចក្ដីស្លាប់។

សរុបមកទស្សនៈដែលពោលមកខាងលើនេះ គឺចង់អប់រំឱ្យមនុស្សគ្រប់រូប ប្រព្រឹត្តិអំពើល្អ អំពើជាកុសល សាងនូវអំពើសុចរិតទៀងត្រង់ ត្រឹមត្រូវ មានសីលធម៌ គុណធម៌ មិនបៀត បៀនអ្នកដទៃ ទើបនាំឱ្យជីវិតរបស់ពួកគេ រស់នៅប្រកបដោយសេចក្ដីសុខចម្រើនសុភមង្គល រីកចម្រើនរុងរឿង។

ឆ្លងតាមរយៈការបកស្រាយខាងលើ យើងអាចវាយតម្លៃបានថាទស្សនៈនេះពិតជាមាន អត្ថន័យទូលំទូលាយ វិសេសវិសាល ដែលចង់

អប់រំមនុស្សទូទៅ ឱ្យប្រព្រឹត្តិតែអំពើល្អ អំពើជា កុសល សុចរិតទៀងត្រង់ ត្រឹមត្រូវ និងជួយឱ្យមនុស្សរស់នៅមានន័យ មានសេចក្តីសុខសន្តិភាព ចាកផុតសេចក្តីទុក្ខសោកទាំងឡាយ។ ក្នុងនាមយើងជាអ្នកសិក្សា និងជាពលរដ្ឋមួយរូប ដែលរស់នៅក្នុងសង្គម គឺចង់ធ្វើអ្វីៗដែលមានប្រយោជន៍ដល់មនុស្សទូទៅ និងសង្គមជាតិឱ្យមានការអភិវឌ្ឍទៅមុខជានិច្ច។

# ឯកសារយោង


1. សៀវភៅវិធីសាស្ត្រនៃការសរសេរតែងសេចក្ដីថ្នាក់ទី១០ ១១ ១២ ក្រសួងអប់រំយុវជន និងកីឡា ឆ្នាំ២០១៧។
2. សៀវភៅរបាយការណ៍បូកសរុបលទ្ធផលនៃការស្រាវជ្រាវតែងសេចក្ដីអត្ថាធិប្បាយ របស់សមាគមវញ្ញានពុទ្ធិបពោធនមិត្ត ឆ្នាំ២០០៣។
3. គន្លឹះរៀន និងសរសេរតែងសេចក្ដី របស់គង់ សុខហេង ឆ្នាំ២០១៣។
4. សម្ហូហកម្មអក្សរសាស្ត្រខ្មែរ សាស្ត្រាចារ្យ កេង វ៉ាន់សាក់ ឆ្នាំ២០០៦។



ដើមត្នោត ជារុក្ខជាតិដែលតំណាងឱ្យព្រះរាជាណាចក្រកម្ពុជា ។ វាជារុក្ខជាតិដែលស្ថិតក្នុងតាលព្រឹក្សខ្ពស់ មានដើមទាល គល់ធំ ដុះត្រង់ឡើងទៅលើកម្ពស់ចន្លោះពី ១០ ទៅ ២៥ ម៉ែត្រ។ ដើមត្នោតជារុក្ខជាតិដែលមានឫសយោងហើយគ្មានឫសកែវទេ ។ ដើមត្នោតក៏ជារុក្ខជាតិមួយប្រភេទដែលបានផ្តល់សារៈប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋកម្ពុជាផងដែរ។

និពន្ធនិងរៀបរៀងដោយ អ្នកគ្រូ វណ្ណា ឆាវ៉ា